ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



## ខួបលើកទី១០នៃទស្សនាវដ្តីស្វែងរកការពិត

# ១០

២០០០-២០១០

- ដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកយុត្តិធម៌ ៖ កិច្ចការរយៈពេល១៣ឆ្នាំដើម្បីធានាថាតុលាការខ្មែរក្រហមជារបស់ប្រជាជនកម្ពុជា
- ឌុច មិនអាចបំផ្លាញមនុស្សជាតិបានទេ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២១ ខែមករា ឆ្នាំ២០១០

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២១ ខែមករា ឆ្នាំ២០១០

## មាតិកា

◆ដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកយុត្តិធម៌ : ........ ១
◆ខួបលើកទី១០ នៃទស្សនាវដ្តីស្វែងរកការពិត ........ ៣

**ផ្នែកឯកសារ**

◆បដិវត្តិន៍និងសកម្មភាពក្បត់របស់ កៅលី ថុងហួត ហៅ ធឿន ........ ៥
◆អ្នកគ្រូ មុំ ម៉េត : បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ........ ១៤
◆អ្នកគ្រូ បែន នាង : បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ........ ២១

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆អ៊ឹម ម៉ង់ អតីតគ្រូបង្រៀនរបស់អ្នកនិពន្ធសៀវភៅ ........ ២៤
◆ញ៉ុក ពុយ : រកឃើញប្អូនប្រុសនៅមន្ទីរស-២១ ........ ២៦
◆ការរកឃើញសន្តិភាពនៅមណ្ឌលក្មេងកំព្រា វត្តអូរពោត ........ ២៩
◆ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះ ........ ៣២

**ផ្នែកច្បាប់**

◆ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិ ........ ៣៤

**វេទិកាពិភាក្សាសាធារណៈ**

◆ខុច មិនអាចបំផ្លាញមនុស្សជាតិបានទេ ........ ៤១
◆កំហុសរបស់មេធាវីការពារក្តី ........ ៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ជីវិតឪពុកម្តាយខ្ញុំក្នុងរបប ប៉ុល ពត ........ ៥៩



អ្នកភូមិធ្វើដំណើរត្រឡប់មកលំនៅឋាន ឆ្នាំ១៩៧៩



អ្នកភូមិធ្វើដំណើរត្រឡប់មកលំនៅឋាន ឆ្នាំ១៩៧៩

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរទេក្រឹដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ស សេងគា, ស៊ីរ៉ា សាវីណា, អាឡឺន សៅ, វ៉ាន់ថាន់ ពោដារ៉ា, ម៉ារីឌីត ឌីន និង ណាតាហ្សា បាច, ដេវីដ សេហ្ស៊ូរ, អាដាម ខូឌី, ឌួង ចំរើន **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, **អ្នកបកប្រែ:** ជា ដល្លា, ទេស ម៉ារ៉ែម **និពន្ធនាយកទូទៅ:** ឆាំង យុ **ជំនួយការនិពន្ធនាយក:** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ:** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ:** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ដំណើរដ៏វែងឆ្ងាយទៅរកយុត្តិធម៌:

## កិច្ចការរយៈពេល១៣ឆ្នាំដើម្បីធានាថាតុលាការខ្មែរក្រហមជារបស់ប្រជាជនកម្ពុជា

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាបានធ្វើដំណើរដោយថ្មើរជើងឥតឈប់ឈរ ។ ប្រជាជនកម្ពុជាធ្វើដំណើរចេញពីទីក្រុងទៅកាន់ទីជនបទ ចេញពីភូមិកំណើតទៅកាន់ខេត្តផ្សេងៗ និងចេញពីស្រែចម្ការទៅកាន់សមរភូមិ ។ ប៉ុន្តែបន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនដែលរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមបាននាំគ្នាធ្វើដំណើរម្តងទៀត ពោលគឺធ្វើដំណើរត្រឡប់ទៅរកទីលំនៅឋានរបស់គាត់វិញ ។

មកដល់ឆ្នាំ១៩៩៧ ប្រជាជនកម្ពុជាបានចាប់ផ្តើមធ្វើដំណើរមួយផ្សេងទៀត ប៉ុន្តែដំណើរលើកនេះគឺជាដំណើរស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ថ្ងៃនេះគឺគម្រប់ខួប៣១ឆ្នាំគត់ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្រជាជនកម្ពុជាបានធ្វើដំណើរដោយបោះជំហានយ៉ាងធំនៅលើវិថីយុត្តិធម៌នេះ ។

នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានស្គាល់ជាទូទៅថា តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមបានចាប់ផ្តើមបង្កើតការិយាល័យ



ប្រជាជនត្រឡប់មកលំនៅឋានវិញ ឆ្នាំ១៩៧៩

ឡើងជាផ្លូវការនៅក្នុងបរិវេណនៃបញ្ជាយកងយោធពលខេមរៈភូមិន្ទនៅជាយទីក្រុងភ្នំពេញ ។ សំណុំរឿងទីមួយ ឬសំណុំរឿងលេខ ០០១ បានចាប់ផ្តើមជំនុំជម្រះនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ពោលគឺពីរឆ្នាំយឺតជាងគម្រោងដែលបានគ្រោងទុក ។ ការជំនុំជម្រះនេះត្រូវបានចាប់ផ្តើមឡើងដោយមានការសុំខមាទោសចំពោះជនរងគ្រោះ និងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងពីសំណាក់ចុងចោទដែលជាអតីតប្រធានមន្ទីរស-២១ ឈ្មោះ ឌុច (ឈ្មោះដើម កាំង ហ្គេកអ៊ាវ) ។ ប៉ុន្តែអ្វីដែលគួរឲ្យនឹកស្មានមិនដល់នោះគឺនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឌុច បានបដិសេធការទទួលខុសត្រូវរបស់ខ្លួន ដោយសម្អាងលើហេតុផលយុត្តាធិការតុលាការថាខ្លួនមិនមែនជាមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ដូចដែលមានចែងក្នុងច្បាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហមទេ ។ សាលក្រមកាត់សេចក្តីលើករណីរឿង ឌុច អាចនឹងចេញនៅក្នុងអំឡុងខែមីនា ឆ្នាំ២០១០ ខាងមុខនេះ ។

នៅចុងឆ្នាំ២០១០ ឬដើមឆ្នាំ២០១១ សវនាការកាត់ទោសសំខាន់បំផុតនឹងត្រូវចាប់ផ្តើម ។ ករណីសំណុំរឿងលេខ ០០២ នឹងធ្វើការជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិតសព្វថ្ងៃ រួមមាន៖ នួន ជា, ខៀវ សំផន, អៀង សារី និងអៀង ធីរិទ្ធ ។ ការជំនុំជម្រះនេះគឺជាជំហានយ៉ាងសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជានៅលើវិថីឆ្ពោះទៅរកយុត្តិធម៌ ដោយហេតុថា ភ័ស្តុតាងនិងការវិភាគផ្សេងៗចេញពីដំណើរការជំនុំជម្រះនេះនឹងផ្តល់នូវចម្លើយទៅនឹងចម្ងល់ជាច្រើនទាក់ទងនឹងរបបខ្មែរក្រហម ដែលប្រជាជនកម្ពុជាមានមន្ទិលសង្ស័យអស់ជិតបីទសវត្សរ៍កន្លងមកហើយ ។

ប្រទេសកម្ពុជា អង្គការសហប្រជាជាតិ និងប្រទេសដទៃទៀតបានធ្វើការជាមួយគ្នាអស់រយៈពេលជាច្រើនឆ្នាំដើម្បីជួយ

ស្វែងរកយុត្តិធម៌ដល់ប្រជាជនកម្ពុជា ។ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលប្រទេសផ្សេងៗគឺជាអ្នកចូលរួមចំណែកភាគច្រើននៃថវិកាដប់ងចំនួន៥៦លានដុល្លារអាមេរិក សម្រាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងបានចូលធ្វើអន្តរាគមន៍នៅពេលមានការខ្វះខាតថវិកា នៅចុងឆ្នាំ២០០៨ ។ រដ្ឋាភិបាលប្រទេសទាំងនេះក៏បានផ្តល់នូវជំនួយហិរញ្ញវត្ថុដល់អង្គការសិទ្ធិមនុស្សនិងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិជាច្រើនដែលជួយគាំទ្រ និងឃ្លាំមើលតាមរយៈជួយជនរងគ្រោះដាក់ពាក្យបណ្តឹងអំពីឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហមទៅកាន់តុលាការ ឃ្លាំមើល និងរាយការណ៍អំពីសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិផ្តល់ប្រឹក្សាដល់អ្នកមានបញ្ហាសុខភាពផ្លូវចិត្តនិងសកម្មភាពផ្សេងៗទៀត ។ វិធីសំខាន់បំផុតដែលអង្គការក្រៅរដ្ឋាភិបាលអាចជួយបាននោះ គឺធ្វើការជាមួយតុលាការ និងជាមួយអង្គការដៃគូដើម្បីធានាឲ្យប្រាកដថា ប្រជាជនកម្ពុជានឹងបានទទួលដំណឹង និងបានចូលរួមក្នុងដំណើរការរបស់តុលាការ ។

ការជំនុំជម្រះក្តីនេះត្រូវបានធ្វើឡើងដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះក្រោមរបបខ្មែរក្រហម ។ តុលាការនេះជាតុលាការរបស់ប្រជាជនទាំងអស់គ្នា ដូច្នេះប្រសិនបើគ្មានការចូលរួមរបស់ប្រជាជនកម្ពុជា យើងនឹងមិនអាចវិនិច្ឆ័យបានថាតើការកាត់ក្តីនោះមានភាពត្រឹមត្រូវស្របតាមបទដ្ឋានជាន់ខ្ពស់ និងទទួលបានព័ត៌មានគ្រប់ៗគ្នាទេ ។

អ្វីដែលត្រូវចោទសួរនោះគឺថាតើប្រជាជនកម្ពុជាអាចចូលរួមជាមួយដំណើរការកាត់ក្តីដោយរបៀបណា? ប្រជាជនភាគច្រើនរស់នៅតំបន់ឆ្ងាយៗ ហើយការចំណាយសម្រាប់ការធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញមានតម្លៃថ្លៃ ។ អង្គការក្រៅរដ្ឋាភិបាលកំពុងធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋបានតាមដានតុលាការតាមរយៈទស្សនាវដ្តី និងឯកសារផ្សេងៗដែលអង្គការទាំងនោះបានចែកចាយទៅតាមការិយាល័យឃុំនិងស្រុកទូទាំងប្រទេស ។ ស្ថាប័នមួយចំនួនផ្សេងទៀតព្យាយាមចាក់ផ្សាយព័ត៌មានតាមរយៈវិទ្យុ និងទូរទស្សន៍ ចំណែកមជ្ឈមណ្ឌលឯកសារកម្ពុជាវិញ យើងកំពុងតែធ្វើការជាមួយស្ថានីយទូរទស្សន៍ជាតិ និងស្ថានីយទូរទស្សន៍ដទៃទៀតដើម្បីផលិតកម្មវិធីដែលអាចជួយអប់រំប្រជាពលរដ្ឋឲ្យបានយល់ដឹងអំពីតុលាការ ។

កាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តជំហានទីមួយនៃគម្រោងឯកសាររស់ ដោយបានអញ្ជើញអ្នកភូមិពីទូទាំងប្រទេសប្រមាណពី៤០០ ទៅ៥០០នាក់ជារៀងរាល់ខែ ឲ្យធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញដើម្បីទៅទស្សនាទីតាំងបូជនីយដ្ឋានប្រល័យពូជសាសន៍ និងជួបជាមួយមន្ត្រីតុលាការនៅក្នុងសាលសវនាការ ។ ជំហានទីពីររបស់គម្រោងនេះដែលត្រូវបានចាប់ផ្តើមកាលពីដើមឆ្នាំ២០០៩ ជួយឲ្យជនរងគ្រោះបានចូលមើលដោយផ្ទាល់នៅក្នុងសវនាការកាត់ទោស ឌុច និងបានចូលរួមក្នុងកិច្ចពិភាក្សាអប់រំទាក់ទងនឹងតុលាការកាត់ទោសខ្មែរក្រហម ព្រមទាំងបានទស្សនានូវភាពយន្តឯកសារផ្សេងៗស្តីអំពីរបបខ្មែរក្រហម ។ បន្ទាប់ពីនោះ ប្រជាជនវិលត្រឡប់ទៅកាន់ទីលំនៅវិញ ចែករំលែកជាមួយអ្នកជិតខាងរបស់គាត់នូវអ្វីដែលបានឃើញនិងយល់ដឹងតាមរយៈវេទិកាពិភាក្សាក្នុងភូមិ ។ តាមរយៈការធ្វើដូច្នេះ ប្រជាពលរដ្ឋកម្ពុជាអាចមានឱកាសស្វែងយល់ពីតុលាការតាមរយៈអ្នកភូមិរបស់គាត់ បន្ថែមទៅលើការយល់ដឹងតាមរយៈមន្ត្រីតុលាការ និងបុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាល ។ សកម្មភាពទាំងអស់ខាងលើនេះអាចជួយឲ្យប្រជាពលរដ្ឋឲ្យយល់ដឹងពីដំណើរប្រព្រឹត្តទៅរបស់តុលាការ និងជួយឲ្យប្រជាជនកាន់តែជិតស្និទ្ធជាមួយដំណើរការតុលាការថែមទៀត ។ ចំពោះករណីសំណុំរឿងលេខ០០២ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបន្តពង្រីកនូវសកម្មភាពផ្សព្វផ្សាយរបស់ខ្លួនឲ្យកាន់តែទូលំទូលាយជាងនេះទៅទៀត ដោយសារតែសារសំខាន់នៃសំណុំរឿងនេះ ។

យើងទាំងអស់គ្នាចង់មើលឃើញតុលាការនេះប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ព្រមទាំងអាចចូលរួមជាមួយដំណើរការរបស់តុលាការដោយមិនមានការគំរាមកំហែង ឬភាពមិនប្រាកដក្នុងចិត្ត ។ ជាពិសេសទៅទៀត ការស្វែងយល់ពីតុលាការតាមរយៈឯកសារ វិទ្យុ ទូរទស្សន៍ ក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង អាចជួយឲ្យពួកប្រជាជនកម្ពុជាមើលឃើញពីដំណើរការស្វែងរកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាដែលអាចធ្វើទៅបាន ហើយថែមទាំងអាចជួយធ្វើឲ្យអនាគតរបស់ក្មេងជំនាន់ក្រោយបានកាន់តែប្រសើរជាងនេះនិងក្លាយទៅជាការពិត ។ **ឆាំង យុ**

# ខួបលើកទី១០ នៃទស្សនាវដ្ដីស្វែងរកការពិត

ឆ្នាំ២០១០នេះ គឺជាខួបគម្រប់លើកទីដប់នៃទស្សនាវដ្ដីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អស់រយៈពេល១០ឆ្នាំកន្លងទៅនេះ ទស្សនាវដ្ដីស្វែងរកការពិតបានបោះពុម្ពផ្សាយសំបុត្រ អត្ថបទ ចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរស-២១និងនៅមន្ទីរឃុំឃាំងផ្សេងទៀតជាច្រើន រឿងរ៉ាវបទពិសោធន៍របស់ជនរងគ្រោះនិងកម្មាភិបាលខ្មែរក្រហម កិច្ចពិភាក្សានានាដែលទាក់ទងទៅនឹងបញ្ហាខ្មែរក្រហម សំណើស្រាវជ្រាវរកគ្រួសារនិងឯកសារដទៃទៀតរាប់រយពាន់ទំព័រ ។ លេខដំបូងរបស់ទស្សនាវដ្ដីស្វែងរកការពិតបានបោះពុម្ពផ្សាយមិនដល់មួយឆ្នាំផងក្រោយពេលដែលមេដឹកនាំដ៏ស៊ិតស្មាញពីរនាក់របស់ចលនាខ្មែរក្រហមគឺតាម៉ុក និង កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានចាប់ខ្លួន ។ តាម៉ុក ហើយនិង ឌុច បានបង្កឲ្យមានមនុស្សស្លាប់រាប់ម៉ឺននាក់នៅភូមិភាគនិរតីនិងមន្ទីរស-២១កាលពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ការចាប់ខ្លួននេះគឺជាសញ្ញានៃការដួលរលំចុងក្រោយនៃរចនាសម្ព័ន្ធ រដ្ឋបាល និងនយោបាយរបស់ចលនាខ្មែរក្រហម ហើយក៏ជាសញ្ញាមួយដែលនឹងនាំទៅរកភាពយុត្តិធម៌សម្រាប់សង្គម




**ក្រុមបុគ្គលិកទស្សនាវដ្ដីស្វែងរកការពិត ឆ្នាំ២០១០**
**ជួរក្រោយពីឆ្វេងទៅស្ដាំ ៖ សោម ប៊ុនថន, ញាណ សុជាតិ, ស៊ឹម សុភ័ក្រ្ត**
**ជួរមុខពីឆ្វេងទៅស្ដាំ ៖ គាត លក្ខិណា, ទេស ម៉ារ៉ែម, ជា ផល្លា, ស៊ិន សុធីតា**

កម្ពុជាដែរ ។ ទស្សនាវដ្តីនេះបានបោះពុម្ពផ្សាយមុននឹងផ្នែកខ្លះនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានលុបចេញពីកម្មវិធីសិក្សានៅតាមសាលារដ្ឋ ។

កម្មវត្ថុ និងគោលបំណងនៃការទស្សនាវដ្តីស្វែងរកការពិត គឺជួយដល់តុលាការក្នុងការវិនិច្ឆ័យបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម ដើម្បីអប់រំនិងរួមចំណែកអនុវត្តនីតិរដ្ឋនៅកម្ពុជា ជួយលើកកម្ពស់ការយល់ដឹងឲ្យកាន់តែប្រសើរឡើងចំពោះនីតិវិធីច្បាប់របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បង្កើតជាវេទិកាពិភាក្សាមួយទាក់ទងនឹងការអនុវត្តរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្តល់ជាប្រភពព័ត៌មានសម្រាប់ប្រជាជនកម្ពុជាដើម្បីសិក្សា និងពិភាក្សាអំពីអ្វីដែលបានកើតឡើងនៅប្រទេសផ្សេងទៀតទាក់ទងនឹងការរំលោភបំពានផ្នែកសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ។ លើសពីនេះទៅទៀត ទស្សនាវដ្តីស្វែងរកការពិត ក៏មានបានជួយផ្សះផ្សាការឈឺចាប់របស់អ្នកនៅរស់រានមានជីវិត ដោយផ្តល់នូវវេទិកាមួយដើម្បីចែករំលែកគ្នាទៅវិញទៅមកនូវបទពិសោធន៍ដ៏ឈឺចាប់របស់គាត់ជាមួយអ្នករស់រានមានជីវិតដទៃទៀតដើម្បីលើកទឹកចិត្តឲ្យមានការផ្សះផ្សាជាតិ និងយោគយល់រវាងជនរងគ្រោះ និងកម្មាភិបាលខ្មែរក្រហម ហើយអ្វីដែលសំខាន់ជាងនេះទៅទៀតគឺដើម្បីអប់រំដល់សាធារណជនអំពីហេតុការណ៍ពីអតីតកាលនៅប្រទេសកម្ពុជានិងការពារមិនឲ្យរបបស្រដៀងគ្នានេះកើតឡើងសាជាថ្មីទៀត ។

រយៈពេលដប់ឆ្នាំកន្លងមកនេះ ទស្សនាវដ្តីស្វែងរកការពិត បានបោះពុម្ពផ្សាយប្រហែលមួយលានប្រាំសែនច្បាប់ ហើយបានចែកចាយទៅដល់សាធារណជនតាមរយៈបណ្ណាល័យ ស្ថានទូត ការិយាល័យរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា និងបរទេស និងជាពិសេសដល់ប្រជាជនកម្ពុជាទូទាំងប្រទេស ។ ទស្សនាវដ្តីស្វែងរកការពិតគឺសម្រាប់មនុស្សគ្រប់គ្នាដូចជាសិស្ស អ្នកស្រាវជ្រាវ មន្ត្រីរាជរដ្ឋាភិបាល សាធារណជនទូទៅ ក៏ដូចជាជនរងគ្រោះ និងអតីតកម្មាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានចែកចាយទៅគ្រប់ទីកន្លែងចាប់ពីការិយាល័យរាជរដ្ឋាភិបាលថ្នាក់ខ្ពស់ រហូតដល់ទីលំនៅរបស់ប្រជាជននៅតាមភូមិដាច់ស្រយាល ។ ទស្សនាវដ្តីស្វែងរកការពិតបានដើរតួនាទីក្នុងការផ្តល់ព័ត៌មានជាមូលដ្ឋាននៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាន់សាធារណជនទូទៅ ។ ឪពុកម្តាយបានចែករំលែកទៅកូនចៅរបស់ខ្លួនអំពីបទពិសោធន៍ដែលគាត់បានជួបប្រទះ ។ ដូច្នេះ ទស្សនាវដ្តីស្វែងរកការពិតបានរួមចំណែកជួយឪពុកម្តាយទាំងនោះក្នុងការចែកបញ្ជូននូវរឿងរ៉ាវពិតប្រាកដដល់ក្មេងជំនាន់ក្រោយដែលមិនធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។

ថ្មីៗនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្កើតឡើង ហើយបានដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបនោះ ។ ទស្សនាវដ្តីស្វែងរកការពិតបានក្លាយទៅជាឧបករណ៍ដ៏សំខាន់មួយដើម្បីចែកចាយព័ត៌មានទាន់ហេតុការណ៍អំពីអង្គបុរេជំនុំជម្រះនិងដំណើរការរបស់តុលាការចំពោះប្រជាជនកម្ពុជាទាំងក្នុងនិងនៅក្រៅប្រទេស ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ការស្វែងរកយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍នៅកម្ពុជាតាមរយៈតុលាការឯករាជ្យមួយទាមទារឲ្យមានការចូលរួមនិងតាមដានពីសំណាក់ជនរងគ្រោះគ្រប់ៗគ្នានៅក្នុងសង្គម ។

ទស្សនាវដ្តីស្វែងរកការពិត សូមថ្លែងអំណរគុណដល់អ្នកស្រាវជ្រាវ សិស្សានុសិស្ស មន្ត្រីរាជរដ្ឋាភិបាល និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមដែលបានជួយគាំទ្រអស់រយៈពេលដប់ឆ្នាំកន្លងមក ។ ក្នុងរយៈពេលទៅមុខទៀតនេះ ក្រុមទស្សនាវដ្តីនឹងបន្តចែកចាយព័ត៌មានទាក់ទងទៅនឹងរបបខ្មែរក្រហម និងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបន្តទៀតដើម្បីលើកម្ពស់ការចងចាំ យុត្តិធម៌និងការបង្រួបបង្រួមជាតិ ។ តាមរយៈការងារនេះ ក្រុមទស្សនាវដ្តីយើងសង្ឃឹមថានឹងបង្កើននូវការចូលរួមពីសំណាក់ប្រជាជនកម្ពុជានៅក្នុងដំណើរការស្វែងរកយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មនៅក្នុងសម័យនោះកាន់តែច្រើនឡើងថែមទៀត ។ អ្នករួចរស់រានមានជីវិតនិងកូនចៅរបស់គាត់គឺជាគោលដៅដ៏សំខាន់របស់ទស្សនាវដ្តីស្វែងរកការពិតនេះ ។

**ញាណ សុជាតិ**

# ប្រវត្តិ និងសកម្មភាពក្បត់របស់ កៅលី ថុងហួត ហៅ ធឿន (ប្អូនថ្លៃរបស់ ឌុច) : សមាជិកក្រុមគូរផែនទី ចាប់ខ្លួននៅមន្ទីរស-២១

*កៅលី ថុងហួត ហៅ ធឿន អាយុ៣០ឆ្នាំ ត្រូវបានចាប់ខ្លួន និងសួរចម្លើយនៅក្នុងមន្ទីរស-២១ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់បងថ្លៃខ្លួនឈ្មោះ ឌុច ។ នៅក្នុងសវនាការសាលាដំបូង ឌុច បានអះអាងថា "ប្អូនថ្លៃឈ្មោះ ធឿន ដែលជាសមាជិកក្រុមគូរផែនទីនៅមន្ទីរស-២១ ត្រូវបានចាប់ខ្លួន ដោយសារតែរឿងខូចខិលជាមួយស្រីញី" ។*

*យោងតាមឯកសារចម្លើយសារភាពរបស់ កៅលី ថុងហួត ដែលធ្វើចំនួនពីរលើក ១) នៅក្នុងឯកសារលេខ J០០០៣៦ ចុះកាលបរិច្ឆេទថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៧ (ដែលប្រហែលជាសរសេរដោយសាមីខ្លួនផ្ទាល់ កៅលី ថុងហួត) ដាក់ថា ប្រវត្តិរូបសង្ខេបនិងធ្វើនៅកំពង់ធំ និង២) នៅក្នុងឯកសារលេខ D០០០៣៦ ចុះកាលបរិច្ឆេទថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៨ ដែលសរសេរថា ប្រវត្តិនិងសកម្មភាពក្បត់របស់ខ្ញុំ ដោយមានសមមិត្ត ណាន ជាអ្នកសួរចម្លើយនៅមន្ទីរស-២១ ។*

**ចម្លើយសារភាពលើកទីមួយៈ ឯកសារ J០០០៣៦ ធ្វើនៅកំពង់ធំ**

*ខ្ញុំឈ្មោះ លី ថុង កើតនៅភូមិអង់ឃ្មាំ សង្កាត់ (ឃុំ) ប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ។ ខ្ញុំមានឪពុកឈ្មោះ ហុក លី និងម្តាយឈ្មោះ រឿន ប្រកបមុខរបរធ្វើស្រែ និងលក់នំបញ្ចុក ។ នៅពេលខ្ញុំអាយុបាន៥ឆ្នាំ ម្តាយខ្ញុំបានស្លាប់ ។ ខ្ញុំរស់នៅជាមួយឪពុក និងប្អូនស្រីបង្កើតពីរនាក់ ឈ្មោះ គីម (ឈ្មោះបដិវត្តន៍ ស៊ីម) និងម្នាក់ទៀតឈ្មោះ សៀម ។*

*នៅឆ្នាំ១៩៥៦ នៅពេលខ្ញុំអាយុ៧ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាក្នុងភូមិ ដោយមានប្អូនស្រី១និងឪពុករែកនំបញ្ចុកលក់ដើម្បីសន្សំប្រាក់មកឲ្យខ្ញុំរៀន ។*

*នៅឆ្នាំ១៩៦២-៦៦ ខ្ញុំរៀនថ្នាក់ទី៣ នៅអនុវិទ្យាល័យស្ទោង ដែលមានចម្ងាយផ្លូវប្រមាណ១២គីឡូម៉ែត្រពីផ្ទះ ។ រហូតដល់ឆ្នាំ១៩៦៧ ខ្ញុំចូលរៀនបន្តនៅថ្នាក់ទី២ នៅខេត្តកំពង់ធំ ដោយស្នាក់នៅចម្ការរបស់តំណាងរាស្ត្រឈ្មោះ ណោអុង ឃុំ និងជួយស្រោចទឹកដើមដូង និងដើមស្វាយ ។ នៅពេលនោះ គ្រួសារខ្ញុំបានខ្ចីប្រាក់ថៅកែម៉ាស៊ីនកិនស្រូវឈ្មោះ ទន់ នៅក្បែរផ្ទះចំនួនជិតបីម៉ឺនរៀល ដើម្បីបង់ថ្លៃសាលា និងទិញសម្ភារៈសិក្សា ។*

*នៅឆ្នាំ១៩៦៧ ខ្ញុំសម្រេចចិត្តប្រឡងចូលធ្វើគ្រូនៅសាលាកំពង់កន្ទួត ព្រោះរដ្ឋផ្តល់ប្រាក់ខែនិងបាយឲ្យហូប ។ នៅទីនោះ អ្នកគ្រូ ណូរី ដែលជាកូនអ្នកមាននៅខេត្តកំពង់ចាមបានជួយផ្គត់ផ្គង់សម្លៀកបំពាក់ និងប្រាក់រហូតធ្វើឲ្យខ្ញុំបាក់ចិត្តស្រឡាញ់គាត់ ។*



*នៅឆ្នាំ១៩៦៨ ខ្ញុំបានប្រឡងបញ្ចប់ រួចក៏ចេញទៅបង្រៀន នៅស្រុកកំណើត ដើម្បីសន្សំប្រាក់សងបំណុលគេ ។ ចាប់តាំងពីពេលនោះមក ខ្ញុំក៏បានបែកពី ណូរី រួចសម្រេចចិត្តតាមចាស់ៗរៀបការជាមួយប្រពន្ធឈ្មោះ គីម ហ៊ាន ឈ្មោះបដិវត្ត (លីម) ប្អូនស្រីរបស់ ឌុច ។ បន្ទាប់ពីរៀបការរួច ខ្ញុំបានសន្សំប្រាក់ទិញបានម៉ូតូហុងដាសេអិល៩០មួយគ្រឿង ។*

*នៅខែមីនា ឆ្នាំ១៩៧១ ដោយឃើញមាគ៌ាបក្សដឹកនាំត្រឹមត្រូវ ខ្ញុំនិងប្រពន្ធបានសម្រេចចិត្តចូលជួរបដិវត្តន៍ ។ ដោយសារប្រពន្ធរបស់ខ្ញុំមានទម្ងន់ ខ្ញុំក៏ចូលធ្វើបដិវត្តន៍មុនដោយមានឈ្មោះ ឡើង ជាអ្នកទទួលស្គាល់នៅសង្កាត់សាគ្រាមក្នុងស្រុកស្ទោង ។*

*នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧១ ខ្ញុំបានចូលសម្ព័ន្ធយុវកកនៅសង្កាត់ក្រយា ដោយមានឈ្មោះ ជឹម ហៅ ឈឿន តំណាងអង្គការ និងឈ្មោះ យិន ជាអ្នកខទ្មេសនាម ។*

*នៅថ្ងៃ៣០ ខែមិថុនា ឆ្នាំ១៩៧២ ខ្ញុំបានចូលជាបក្សជនពេញសិទ្ធិនៅភូមិហប់ ដោយមានឈ្មោះ សែន លេខាស្រុក និងគណៈកម្មាធិការស្រុកឈ្មោះ ហ៊ិន, ឡើង និង ហន ហើយបន្ទាប់មក ខ្ញុំក៏បានលះបង់ម៉ូតូមួយគ្រឿងជូនបក្ស ។*

*បន្ទាប់ពីចូលបដិវត្តន៍មកខ្ញុំមានតួនាទីដូចខាងក្រោមៈ*

- *ឆ្នាំ១៩៧១ ជាកម្មាភិបាលសង្កាត់សាគ្រាម*
- *ឆ្នាំ១៩៧២ កម្មាភិបាលសង្កាត់សាគ្រាម និងទទួលឈើយសឹកពីកំពង់ធំ ។*
- *នៅដើមឆ្នាំ១៩៧៣ ខ្ញុំជាប្រធានកងផលិតស្រុកស្ទោង (ទទួលខាងស្រែប្រាំង) និងជាកម្មាភិបាលទទួលបន្ទុកអាណិកជនចិនវៀតណាម ហើយក្រោយមកធ្វើជាកម្មាភិបាលទទួលសហជីពកម្មករក្នុងស្រុកនិងជាប្រធានសន្តិសុខស្រុកស្ទោង ។*
- *ពីឆ្នាំ១៩៧៣-៧៥ ខ្ញុំធ្វើជាប្រធានគណៈអប់រំសាលាយោធារបស់ស្រុកនិងជាកម្មាភិបាលគ្រប់គ្រងយុទ្ធជនពិការ ។*
- *នៅខែឧសភា ឆ្នាំ១៩៧៥ ជាអនុសន្តិសុខតំបន់ ។*
- *នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៦ ជាយុទ្ធជននៅក្រសួងឧស្សាហកម្មតំបន់៤៣ ។*
- *នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៧ ទើបជាប់ជាសមាជិកគណៈក្រសួងឧស្សាហកម្ម ទទួលខាងរោងជាង ស្ពដែក និងដីដែក ។*

***សកម្មភាពៈ***

*ក្រោយពីអង្គការចាប់លេខាស្រុកស្ទោងឈ្មោះ សុន និង ប៊ិន រួច ឈ្មោះ ឡើង បានឡើងជាអនុលេខាថ្មី ។ បន្ទាប់ពីសួរចម្លើយរួចមក ប៊ិន បានឆ្លើយថា នៅស្រុកស្ទោងមានកម្មាភិបាលក្បត់ចំនួន២៤នាក់ទៀត ក្នុងចំណោមនោះក៏មានឈ្មោះខ្ញុំដែរ ដែលបានចូលរួមបើកវគ្គរៀនសូត្រផែនការក្បត់នៅខាងក្រោយផ្ទះ សុន កាលពីខែកញ្ញា ឆ្នាំ១៩៧៦ ។*

***ការអប់រំពីគ្រួសារបដិវត្តន៍ គឺគ្រួសាររបស់ (ឌុច)ៈ***

*នៅប្រហែលខែ៥-៦ ឆ្នាំ១៩៧៦ ពេលខ្ញុំធ្វើការនៅឧស្សាហកម្មតំបន់៤៣ ម្តាយក្មេករបស់ខ្ញុំបានទៅលេងកូនប្រុសរបស់គាត់ (ឌុច) នៅភ្នំពេញ ។ បង ឌុច បានផ្តាំផ្ញើពាក្យមកអប់រំខ្ញុំថា «ត្រូវផ្តោតមនោសញ្ចេតនាឲ្យជ្រៅ គឺស្រឡាញ់ខ្មៅខ្លងគ្រឿងម៉ាស៊ីន ព្រោះជាភារកិច្ចថ្លៃថ្លារបស់ខ្លួនហើយ» ។*

*ក្រោយមក ម្តាយខ្ញុំទៅលេងគាត់ម្តងទៀត នៅពេលសភាពការណ៍នៅភូមិភាគឧត្តរកំពុងស្មុគស្មាញ ។ នៅពេលទំនេរពីការងារម្តាយក្មេករបស់ខ្ញុំបាននិយាយលេងនឹងបង (ឌុច) ថា «តើឲ្យធឿន (ខ្ញុំ) ទៅទាក់ទងនឹងអ្នកណាបើស្មុគស្មាញយ៉ាងនេះ ។ គាត់ថា «ទាក់ទងតាមទង់ (ទស្សនាវដ្តី) ទៅបានហើយ» ។ ម្តាយក្មេកខ្ញុំឆ្លើយតបវិញថា «ទង់» ឯណា បើគេមិនដែលចែកឯកសារអីឲ្យគ្នាផង» បង (ឌុច) បន្តថា «អើឥឡូវកុំស្មុគស្មាញ មានការអីទាក់ទងតែនឹង តាចន និង តាពក ទៅ» ។*

*នៅខែឧសភា ឆ្នាំ១៩៧៦ ដោយមានការការអនុញ្ញាតពីលេខាស្រុកថ្មីគឺ បងឈុំ និងលេខាក្រសួង វ៉ែន ម្តាយក្មេកខ្ញុំ និងគ្រួសារខ្ញុំទៅសម្រាកពេទ្យភ្នំពេញ ហើយម្តាយក្មេកខ្ញុំក៏ទៅមើលបង ឌុច ព្រោះឮតាមរយៈកម្មាភិបាលរបស់ក្រសួងសន្តិបាលដែលចុះមកធ្វើការថា គាត់មិនសូវស្រួលខ្លួន ។ ខណៈនោះ ដោយភាពស្មុគស្មាញនៅតែបន្តនៅក្នុងតំបន់៤៣ ពេលទំនេរម្តាយក្មេកខ្ញុំក៏សួរបង (ឌុច) ពីរឿងខ្ញុំ បង (ឌុច) ក៏បានឆ្លើយតបមកវិញថា «កុំឲ្យវាដើរដឹកស៊ីទាក់ទងគេផ្តេសផ្តាស» ។ ម្តាយក្មេកខ្ញុំក៏សួរបន្ត ចុះតាចន? បង(ឌុច) ឆ្លើយយ៉ាងខ្លីនិងកំបុតថា «អ្នកណាក៏កុំ» ហើយគាត់ក៏បន្ថែមពាក្យថា «ខំតែធ្វើការងារទៅ បើគេបបួលវាយបក្ស យើងកុំទៅគឺចប់ហើយ» ។*

## ចម្លើយសារភាពលើកទីពីរៈ ឯកសារ D០០០៣៦ ធ្វើនៅមន្ទីរ ស-២១

ខ្ញុំមានឪពុកឈ្មោះ កៅ លី អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិអង់ឃ្វាំង ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ និង ម្តាយឈ្មោះ ហ៊ុន វឿន (ស្លាប់) ។

ខ្ញុំមានបងប្អូនស្រីបង្កើតពីរនាក់ គឺឈ្មោះ គីម ប្តីឈ្មោះ មាស ត្រូវអង្គការចាប់ខ្លួននៅ (ឆ្នាំ១៩៧៧) និងឈ្មោះ ស៊ីម មានប្តីឈ្មោះ ពុំ ។

ខ្ញុំរៀននៅសាលា គីម ហួន ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ហើយនៅឆ្នាំ១៩៦២ ខ្ញុំបន្តរៀនពីថ្នាក់ ទី៦ ដល់ទី៣ នៅអនុវិទ្យាល័យស្ទោង ។

នៅឆ្នាំ១៩៦៧ ខ្ញុំចូលរៀននៅថ្នាក់ទី២ នៅវិទ្យាល័យកំពង់ធំ ហើយនៅចុងឆ្នាំដដែលនោះខ្ញុំបានប្រឡងជាប់ចូលសាលាច្បាប់កំពង់កន្ទួត រហូតដល់ពាក់កណ្តាលឆ្នាំ១៩៦៨ ខ្ញុំបានស្រឡាញ់អ្នកគ្រូម្នាក់ឈ្មោះ ណូរី និងបានខូចសីលធម៌លួចលាក់ចំនួន៥ដង ។

នៅដើមខែ៥ ឆ្នាំ១៩៦៨ ឈ្មោះ ទៀង ណៃជៀក រៀននៅសាលាជាមួយគ្នាបានអប់រំខ្ញុំឲ្យស្រឡាញ់លោកសេរី ដោយលើកឡើងថា លោកសេរីមនុស្សអាចធ្វើអ្វីតាមចិត្ត តាំងពីការហូបចុក ចំណែករបបកុម្មុយនីស្តឃើញតែលំបាកយូរៗទៅស៊ីតែអង្ករកំប៉ុង ។

មួយថ្ងៃក្រោយមក ពេលអគ្គុយលេងជុំគ្នា ទី សុគន្ធ (ចុងឆ្នាំ ១៩៦៨ ចេញទៅខេត្តតាកែវ) ប្រកាសថា ថ្ងៃនេះជាថ្ងៃចាត់តាំងគ្រូ ចុងហ៊ួត ជាសមាជិកសេអ៊ីអា ដូច្នេះខ្ញុំខ្ទេសនាមគ្រូ ចុងហ៊ួត ជូន ទៀង ណៃជៀក ដើម្បីប្រកាសចាត់តាំងនិងទទួលស្គាល់ជាផ្លូវការ ។ ពេលនោះ ទៀង ណៃជៀក បានប្រគល់ភារកិច្ចឲ្យខ្ញុំស៊ើបពិនិត្យរកមុខអ្នកបាចគ្រាក់ក្នុងសាលាក្នុងថ្នាក់រៀន និងបានខ្ទេសនាមខ្សែសេអ៊ីអានៅក្នុងថ្នាក់របស់គាត់មានឈ្មោះ ហ៊ាន ឆយ, កែវ សូសាក់, ផូវ ទាលី, អ៊ី ម៉េងហ៊ុយ, លី ឡៅអ៊ុន និង កូយ វ៉ើណូរី ឲ្យខ្ញុំស្គាល់ទៀតផង ។

នៅដើមខែកញ្ញា ឆ្នាំ១៩៦៨ មុនពេលប្រឡងបញ្ចប់វគ្គនៅសាលាមួយថ្ងៃ ខ្ញុំបានឃើញឈ្មោះខ្ញុំត្រូវទៅធ្វើការនៅខេត្តកំពង់ធំ ។ នៅព្រឹកថ្ងៃបន្ទាប់ ទី សុគន្ធ បានហៅខ្ញុំឲ្យទៅជួប ណៃជៀក រួចណែនាំថា ខ្ញុំ និង កូយ វ៉ើណូរី ទៅដល់កន្លែងធ្វើការត្រូវទាក់ទងជាមួយគ្រូឈ្មោះ ចាន់បូរ នៅភូមិបឹង ឃុំបឹង ស្រុកបារាយ(បច្ចុប្បន្នខេត្តកំពង់ធំ) ខេត្តកំពង់ចាម ដើម្បីតាមដាន និងកម្ទេចផែនការរបស់ខ្មែរក្រហមនៅក្នុងសាលា ។

នៅចុងឆ្នាំ១៩៦៨ ខ្ញុំបង្រៀននៅសាលា គីម ហួន រហូតដល់ខែមករា ឆ្នាំ១៩៦៩ ខ្ញុំបានជួបគ្រូ ចាន់ នៅភូមិបឹង ហើយនៅពេលនោះគាត់សួរខ្ញុំថាមានប៉ុន្មាននាក់? ខ្ញុំប្រាប់គាត់ថា មានតែម្នាក់ឯង ព្រោះគ្រូ វ៉ើណូរី ទៅបង្រៀននៅស្រុកក្រូចឆ្មារ ហើយឥឡូវទៅនៅកែប ខេត្តកំពតវិញ ។ បន្ទាប់មក គ្រូ ចាន់ បូរ ក៏ខ្ទេសនាមខ្ញុំឲ្យស្គាល់គ្រូពីនាក់ទៀតគឺ ផុន និង យ៉ិន ម៉េងហឿង រួចណែនាំថា បើសភាពការណ៍នៅស្ទោងមិនតឹងតែងទេ លោកគ្រូត្រូវកសាងកម្លាំងសេអ៊ីអាបន្ថែមទៀត ។

បន្ទាប់មក ខ្ញុំបានកសាងកម្លាំងសិស្ស និងគ្រូបង្រៀនបានចំនួន៦នាក់គឺ ស៊ីង ស៊ាមហ៊ត, ហុង ម៉េងចុង, វៃ វឿន, ប៉ិល ហ៊ីក, ឡាយ ហ៊ត និង ធឿង ហាន ។ ក្រៅពីនោះខ្ញុំកសាងកម្លាំងសេអ៊ីអាបង្កប់នៅក្នុងចំណោមប្រជាជនបានចំនួន៤នាក់ទៀតគឺ មឿន, នឹង, ដេង និង ខាន់ ។

នៅពាក់កណ្តាលឆ្នាំ១៩៦៩ គ្រូ ចាន់បូរ បានជួបខ្ញុំនៅផ្ទះបងប្អូនជីដូនមួយរបស់គាត់ឈ្មោះ តង នៅភូមិជីយោក ឃុំកំពង់ចិនខាងត្បូង ស្រុកស្ទោង ។ បន្ទាប់មក គាត់អប់រំខ្ញុំថា ឥឡូវសកម្មភាពខ្មែរក្រហមនៅស្ទោងស្វាត់ហើយ ភ្នាក់ងារសេអ៊ីអារបស់យើងក៏ក្តាប់អ្វីមិនបាន ដូច្នេះដើម្បីក្តាប់សភាពការណ៍ឲ្យបាន លោកគ្រូត្រូវទៅបង្កប់ខ្លួននៅក្នុងគ្រួសារបដិវត្តន៍មួយ (គ្រួសារ ឌុច) ព្រោះគ្រួសារនេះទាំងក្មេងទាំងចាស់ សុម្បីតែរាជការមកហ៊ុមព័ទ្ធផ្ទះពីរ-បីដង ក៏មិនដែលយកឯកសារអ្វីបានដែរ ។ ខ្ញុំបានសួរថាតើចូលទៅបង្កប់យ៉ាំងម៉េច? គ្រូ ចាន់ បូរ ថាងាយស្រួលទេ ឲ្យតែលោកគ្រូយល់ព្រម ព្រោះតាមបង តង ប្រាប់ខ្ញុំថា គ្រួសារបដិវត្តន៍នេះមាននៅសល់កូនក្រមុំម្នាក់ទៀត ហើយយើងឲ្យបង តង ចូលទៅទាក់ទងគេសិនឯបញ្ហាលុយកាក់ ចាំខ្ញុំឲ្យបង តង ជួយចេញ ពេលនោះខ្ញុំក៏យល់ព្រម ។

ចាប់ពីពេលខ្ញុំរៀបការ រស់នៅក្នុងគ្រួសារបដិវត្តន៍ ខ្ញុំមិនអាចក្តាប់សភាពការណ៍បានទេ ។ ខ្ញុំចាប់ផ្តើមអុកឡុកដោយយក

ប្រាក់គាត់ទៅចាយវាយខ្ជះខ្ជាយក្នុងគោលបំណងឲ្យគ្រួសារនេះរស់នៅលំបាកគោកយ៉ាក ។ ចំពោះប្រពន្ធ ខ្ញុំរករឿងស្តីបន្ទោសរាល់ថ្ងៃដោយប្រើពាក្យសម្តីនិងអាកប្បកិរិយាមើលងាយមើលថោកឪពុកម្តាយក្មេក និងបងប្អូនជាប្រចាំដោយអាងខ្លួនមានប្រាក់ខែចាយ ។

នៅខែមិថុនា ឆ្នាំ១៩៧០ ចាន់ បូរ បានមកជួបខ្ញុំ ហើយប្រាប់ថាកម្លាំងសេអ៊ីអារបាត់របាយ ហើយ ម៉េង ហឿង និង ផុន គេចខ្លួនទៅភ្នំពេញអស់ហើយ ។ រហូតដល់ខែ១០ ចាន់ បូរ ក៏គេចខ្លួនទៅភ្នំពេញទៀត ។

នៅខែមករា ឆ្នាំ១៩៧១ ខ្ញុំបានទៅកន្លែងបង ស្រ៊ុន លេខាស្រុកស្ទោង សុំចូលបដិវត្តន៍ដើម្បី បង្កប់ខ្លួន។ បង ស្រ៊ុន បានសួរខ្ញុំថាលោកគ្រូចង់បានប្រាក់ខែទៀតទេ? ប៉ុន្តែខ្ញុំមិនបានឆ្លើយតបវិញទេ ព្រោះស្មានគាត់និយាយលេង ។ រហូតដល់ចុងខែ១ បង ស្រ៊ុន បានសួរម្តងទៀត ខ្ញុំក៏ឆ្លើយថាចង់ ហើយគាត់ក៏អប់រំថា លោកគ្រូត្រូវជ្រះស្រឡះពីគ្រួសារមកធ្វើការជាមួយខ្ញុំព្រោះភារកិច្ចសំខាន់របស់ខ្ញុំ គឺសេអ៊ីអាបង្កប់និងមានខ្សែរយៈចាប់ពីភូមិភាគគឺបង យួន រហូតដល់តំបន់គឺបង ឡឿន ។ ក្រោយមក ស្រ៊ុន បានចាត់តាំងខ្ញុំឲ្យទៅគ្រប់គ្រងនៅឃុំសាគ្រាមនិងខ្មៃសនាមកម្លាំងសេអ៊ីអាទាំងអស់នៅក្នុងស្រុកស្ទោងមានឈ្មោះ ឡើង អនុលេខាស្រុកស្ទោង និងកម្មាភិបាលគ្រប់គ្រងឃុំចំនួន២៥នាក់ទៀត ។

នៅខែកុម្ភៈ ឆ្នាំ១៩៧១ ខ្ញុំបានចូលរួមប្រជុំនៅមន្ទីររបស់បង ស្រ៊ុន ដែលស្ថិតនៅភូមិកំពង់ក្តី ឃុំកំពង់ចិនត្បូង ដោយមានអ្នកចូលរួមទាំងអស់ចំនួន១៥នាក់ ហើយបង ស្រ៊ុន បានលើកផែនការថា កម្លាំងសេអ៊ីអាត្រូវដើរនិយាយបំផុសប្រាប់ប្រជាជនថាបន្តិចទៀតអ្នកមានទ្រព្យសម្បត្តិអង្គការប្រមូលយកទៅដាក់រួម ហើយអ្នករាជការត្រូវចាប់កម្ទេច ។ មួយអាទិត្យក្រោយ ខ្ញុំបំផុសគ្រូបង្រៀនបួននាក់ និងជាងមាសមួយគ្រួសារឲ្យរត់ចូលភ្នំពេញ ។

នៅខែមីនា ឆ្នាំ១៩៧១ បងស្រ៊ុន បានសួរថាឪពុកម្តាយក្មេកបងប្អូននិងគ្រួសាររបស់ (លោកគ្រូខ្ញុំ) យល់យ៉ាងម៉េចដែរ ពេលលោកគ្រូចូលបដិវត្តន៍? ខ្ញុំបានប្រាប់គាត់ថា គ្រួសារជិតាស់ដែរព្រោះឃើញការអនុវត្តរបស់យើងជួនកាលធូររលុងហួស ជួនកាលខ្លាំងហួស ហើយគាត់សង្ស័យជាប់ ។ បន្ទាប់មក ស្រ៊ុន បានណែនាំថា បញ្ហាគ្រួសារចាំយើងសង្កត់គាត់ឲ្យជាប់ កុំឲ្យធ្វើសកម្មភាព ហើយគាត់ក៏ផ្តាំឲ្យបន្តចលនាប្រជាជនឲ្យរត់ទៅភ្នំពេញបន្តទៀត ចំណែកគាត់ និងបង ឡឿន ត្រូវទៅកំពង់ស្វាយវិញ ដូច្នេះការងារសម្ងាត់ត្រូវទាក់ទងជាមួយគ្នាឡើងវិញ ។

នៅខែមេសា ឆ្នាំ១៩៧១ បង ឡើង បានមកប្រជុំសម្ងាត់នៅមន្ទីរសាគ្រាម ដែលមានសមាជិកទាំងអស់៨នាក់ចូលរួម ។ ក្រោយពីខ្មៃសនាម ខ្ញុំទទួលគ្រប់គ្រងការងារចំហតាមរូបភាពបដិវត្តន៍ និងកម្លាំងសេអ៊ីអានៅក្នុងឃុំរួចមក បង ឡើង បានដាក់ផែនការថា



ផាំង យុ និយាយជាមួយប្អូនស្រី ឌុច

ត្រូវដឹកនាំប្រជាជាជនធ្វើការងារទាំងយប់ទាំងថ្ងៃធ្វើយ៉ាងណាឲ្យប្រជាជនលំបាកនិងអស់ជំនឿលើអង្គការ ។ នៅរដូវដកស្ទូង ខ្ញុំបានកសាងកម្លាំងយុវជនចូលសេអ៊ីអាបានចំនួន៧នាក់ថែមទៀត ដោយមានបង ឡើង ជាអ្នកខ្មៃសនាម ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧១ បង ឡើង បានឲ្យខ្ញុំហៅភ្នាក់ងារសេអ៊ីអាទាំងអស់រួមមាន ហ៊ាក, ស៊ីក, នរ, មិន, ស្គុន, ឈន, ធរ, រីក, រុំ, ធីង, ធួន, ធិ និង ហ៊ាន មកប្រជុំ ។ នៅខណៈនោះ បង ឡើង

បានលើកពីផែនការលួចដុតស្រូវស្រែ ស្រូវជង្រុក និងដកកម្មាភិបាលដែលមានទំនាស់ជាមួយប្រជាជន រួចបញ្ចូលកម្លាំងសេរីអាវិញ ។ បន្ទាប់មក ខ្ញុំអប់រំនិងកសាងកម្លាំងសេរីអាបង្កប់ក្នុងរដ្ឋអំណាចប្រជាជនបាន៧នាក់ទៀត ។ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧២ បង ឡើង បានដកខ្ញុំពីឃុំ សាគ្រាម ឲ្យទៅគ្រប់គ្រងនៅភូមិពពកវិញ និងបានខ្ទេសនាមកម្លាំងសេរីអានៅក្នុងឃុំដូចជា ជន, ណន, ភ្លៀវ, ឌិន, ធីង និង ស៊ីប ឲ្យខ្ញុំទាក់ទង និងបានណែនាំឲ្យបន្តអនុវត្តផែនការដើម្បីវាយ រំលំបដិវត្តន៍ ។



នៅខែកុម្ភៈ ឆ្នាំ១៩៧២ ខ្ញុំបានប្រមូលកម្លាំងសេរីអា៦នាក់ ទៅប្រជុំលើផ្ទះបង ស៊ីប នៅភូមិសំបួរ បន្ទាប់មក ខ្ញុំចាត់តាំង ជន ណន និងភ្លៀវទៅលួចដុតជង្រុកស្រូវនៅភូមិអន្លង់ក្រាញ់ និងភូមិពពក ចំណែកបង ស៊ីប និងបង ធីង ទទួលពិនិត្យសមាគមលក់ដូរ ។

នៅខែឧសភា ឆ្នាំ១៩៧២ ខ្ញុំបានកសាងកម្លាំងបង្កប់ក្នុងជួរបដិវត្តន៍បានចំនួន៣នាក់ទៀតគឺ ឡាយ កម្មាភិបាលឃុំដូង រុង យោធាតំបន់៤៣ និង ភី ជាប្រធានឃុំពពក ។ ខ្ញុំចាត់តាំងឲ្យមិត្ត ភី ដឹកនាំធ្វើសកម្មភាពទប់ទល់ជាមួយចលនាសមាគមភូមិ ។ មិត្ត ឡាយ ដុតស្រូវនៅភូមិពពក និងអន្លង់ក្រាញ់ ហើយ មិត្ត រ៉ុង ធ្វើសកម្មភាពបំផ្លាញផលដំណាំនៅភូមិកន្ទាន ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧២ បង ឡើង បានចាត់តាំងខ្ញុំឲ្យទៅគ្រប់គ្រងកងផលិតស្រែប្រាំង រួចបានណែនាំថា មិត្តទៅទីនោះមួយរយៈខ្លីទេ ប៉ុន្តែសំខាន់មិត្តត្រូវមកធ្វើការនៅស្ទោង ដើម្បីបញ្ចេញស្បៀងទៅភ្នំពេញ ។ នៅខែ១០ ឆ្នាំដដែល បង ឡើង បានដកខ្ញុំមកគ្រប់គ្រងអាណិកជននៅស្ទោងវិញ និងបានហៅខ្ញុំទៅប្រជុំនៅមន្ទីរភូមិត្នោតដែលមានសមាជិកចូលរួមមានឈ្មោះ យិន, ហ៊ិន, ហន, ឈាន, សយ, មល, សង និង ពារ ។ ប្រជុំចប់ បង ឡើង បានដាក់ផែនការរំដោះស្បៀងពីតំបន់រំដោះចូលភ្នំពេញ ពោធិ៍សាត់ កំពង់ឆ្នាំង និងបានប្រគល់ភារកិច្ចឲ្យខ្ញុំដើររកឈ្មួញដើម្បីដឹកស្បៀងទាំងនេះចេញ ។ រំលងបានមួយអាទិត្យ ខ្ញុំរកបានឈ្មួញបាន៥នាក់ គឺ យង់, ហាន, ឡុង, ចក់ និង លាត ហើយខ្ញុំបានអប់រំថា ត្រូវយកអង្ករ ត្រី សាច់ទៅខ្លះ ចំណែក អំបិល ថ្នាំពេទ្យ និងក្រណាត់ កុំយកទៅច្រើនពេក រួចខ្ញុំក៏យកសំបុត្រធ្វើដំណើរទៅឲ្យឈ្មួញទាំងនោះ ។

នៅដើមឆ្នាំ១៩៧៣ បង ឡើង បានដកខ្ញុំមកធ្វើជាអនុសន្តិសុខស្រុកស្ទោង ដែលមានបង យិន ប្រធាន និង មិត្ត ហឿន ជាសមាជិក ។ បន្ទាប់មក បង ឡើង បានប្រជុំសម្ងាត់មួយដោយមានសមាជិកចូលរួមដូចជា យិន, ហ៊ិន, ហន, ពិន, ស៊ីប, ជា (នារី), ធន, មល, សង, ឈាន, ហឿន និងខ្ញុំ ។ នៅពេលនោះ បង ឡើងបានដាក់ផែនការនៅខែខាងមុខ យើងបើកផ្លូវឲ្យផ្នែកទាហានកំពង់ធំចេញមកដឹកជញ្ជូនស្បៀង និងនាំប្រជាជនចូលភ្នំពេញ ដូច្នេះកម្លាំងយោធាស្រុកត្រូវដកទៅត្រៀមនៅមាត់ទន្លេពាមបាងទាំងអស់ដើម្បីជៀសវាងការប៉ះទង្គិច ចំណែកខាងសន្តិសុខត្រូវចូលរួមក្នុងការជម្លៀសដែរ ។ នៅពេលទាហានចូលមកយកស្បៀង និងនាំប្រជាជនចេញអស់ហើយ យើងធ្វើជានាំកម្លាំងស្រុកដេញពីក្រោយដើម្បីបិទបាំងផែនការយើងក្នុងការជម្លៀសប្រជាជនចេញ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៣ នៅពេលទាហានចូលជិតដល់ស្ទោង ខ្ញុំបានទាក់ទងមិត្ត សង, មល, ហ៊ិន, ស៊ីប និងសង ឲ្យជម្លៀសប្រជាជនចេញ ដោយមិនបាច់ឲ្យយកស្រូវអង្ករទៅជាមួយទេ ចំណែកខ្ញុំធ្វើជាចាត់តាំងយុទ្ធជនសន្តិសុខនិងឈ្លបឲ្យទៅត្រៀមនៅវត្តព្រះនាងវិញ ។ នៅរយៈពេលមួយយប់មួយថ្ងៃ ទាហានបានប្រមូលយកស្រូវអង្ករ និងដឹកនាំប្រជាជនចំនួន៥០០គ្រួសារចូលទៅក្នុងខេត្តកំពង់ធំ ។ ក្រោយសភាពការណ៍នេះ បង ឡើង បានចាត់តាំងខ្ញុំឲ្យទៅគ្រប់គ្រងខ្សែត្រៀមការពារស្រុកដែលហ៊ុមព័ទ្ធឃុំចំណារលិច សំព្រោច កំពង់ចិនត្បូង និងម្សាក្រង ដើម្បីកុំឲ្យប្រជាជនរត់ចេញទៅតាមបងប្អូនម៉ែឪ និងកុំឲ្យទាហានឡើងឆ្មក់យកប្រជាជនទៀត ។ ប៉ុន្តែនៅខ្សែត្រៀមនេះ ខ្ញុំបណ្តោយឲ្យទាហានឆ្មក់ចូលមកយកប្រជាជនអស់ប្រហែល២៥គ្រួសារថែមទៀត និងបានខូចសីលធម៌ជាមួយនារីចំនួន៧នាក់ដែលឈ្លបចាប់យកមកប្រគល់ឲ្យខ្ញុំរួចហើយខ្ញុំលួចដោះលែងឲ្យរត់ទៅកំពង់ធំ

ជាមួយឪពុកម្តាយវិញ ។

នៅខែមិថុនា ឆ្នាំ១៩៧៣ ខ្ញុំបានអប់រំកម្លាំងសេអ៊ីអាជាយុទ្ធជននៅមន្ទីរសន្តិសុខបានចំនួន៧នាក់ ទៀត មាន គឹង, ពន, ជាន, ជេក, ផៃ, ឆាន់ និងនីរ ដែលដើរចល័តនៅខ្សែត្រៀម ។ រហូតដល់ចុងឆ្នាំ១៩៧៣ បង ឡើង បានប្រជុំដាក់ផែនការបំផ្លាញសមូហភាពនៅសាលាភូមិសំរោង ឃុំដូង ដោយមានសមាជិកទាំងអស់២៣នាក់ចូលរួម ហើយក្រោយពីប្រជុំចប់ បងឡើង ឲ្យខ្ញុំដកខ្សែត្រៀមចេញ រួចទៅរៀបចំភូមិសម្រាប់ដាក់ប្រជាជនជម្លៀសមកនៅឃុំដូង ឃុំក្រយា ឃុំបន្ទាយស្ទោង និងឃុំពពកវិញ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៤ ដោយទាហានបេះតែឆ្នក់ចូលក្នុងស្រុក បង ឡើង បានដកកម្លាំងខ្ញុំទាំងអស់មករៀបចំកម្លាំងត្រៀមដូចមុន ហើយខ្ញុំក៏បើកខ្សែត្រៀមឲ្យទាហានចូលមកយកប្រជាជនបានពីរគ្រួសារទៀត ដោយគ្រាន់តែនាំឈ្លបបាញ់បង្អើលប៉ុណ្ណោះ ។ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៤ បង ឡើង បានហៅខ្ញុំទៅសួរពីរឿងគ្រួសារទៀត ហើយខ្ញុំបានប្រាប់ថា គ្រួសារខ្ញុំ ប្អូនស្រី បងស្រី ឪពុក-ម្តាយក្មេក មិនយល់ស្របនឹងមាគ៌ាដឹកនាំរបស់យើងសព្វថ្ងៃទេ ហើយពួកគាត់នៅតែសង្ស័យជាប់ថា យើងមិនមែនជាអ្នកបដិវត្តន៍ត្រឹមត្រូវទេ ព្រោះគាត់តែងតែនិយាយថា បើបដិវត្តន៍ត្រឹមត្រូវ មិនដែលធ្វើការខ្លាំង កាន់តែអត់បាយខ្លាំងយ៉ាងនេះទេ ។ ខ្ញុំនិយាយចប់ បង ឡើង លើកឡើងពីវិធានការបំបែកកូនចៅឪពុកម្តាយក្មេកខ្ញុំឲ្យនៅឆ្ងាយពីគ្នា ដើម្បីកុំឲ្យក្តាប់សភាពការណ៍យើងបាន ។ យើងយកគាត់ទៅដាក់នៅកន្លែងលំបាកខ្លាំង និងឲ្យគាត់បាត់ឥទ្ធិពលមួយកម្រិតក្នុងចំណោមប្រជាជន យូរៗទៅឈានទៅរកភាពឯកោ ហើយមហាជនក្នុងជួរបដិវត្តន៍វាយតម្លៃថា គ្រួសារនេះខ្មែរក្រហមតែសំបកទេ ដល់ពេលធ្វើបដិវត្តន៍រកតែកូនម្នាក់មកបម្រើការងារបដិវត្តន៍ឲ្យសមរម្យមិនបាន ។ ខណៈនោះ បង ឡើង ណែនាំឲ្យមូលដ្ឋានចាត់តាំងនិងគាបសង្កត់កុំឲ្យគាត់និយាយផ្តេសផ្តាសបាន ហើយចាត់តាំងឲ្យទៅធ្វើការនៅកន្លែងផ្សេងៗ ហើយកម្លាំងក្មេងៗទើបផ្តល់របបឲ្យហូប បើមិនទៅធ្វើការមួយពេលត្រូវកាត់របបមួយពេល ។

រយៈពេលកន្លះខែក្រោយមក បង ឡើង បានដកគ្រួសារខ្ញុំទៅនៅកន្លែងលត់ដំមួយនៅតាក្រៀល ដែលត្រូវធ្វើការងារទាំងយប់ទាំងថ្ងៃ ហើយទទួលបានរបបអាហារមួយថ្ងៃតែមួយកំប៉ុងប៉ុណ្ណោះសម្រាប់មនុស្ស៥នាក់ ។ ប្អូនតូចរបស់ខ្ញុំម្នាក់ត្រូវចាត់តាំងឲ្យទៅកាប់ចម្ការក្នុងព្រៃដែលជាកន្លែងគ្រុនចាញ់ក្នុងឃុំពពក ប្អូនស្រីម្នាក់ទៀតដកចេញពីស្រុក ចំណែកឪពុកម្តាយក្មេករបស់ខ្ញុំតែងតែរអ៊ូរពីរឿងធ្វើការធន់ទ្រាំមិនបាន ហើយថែមទាំងមានឈ្លបចូលយកការណ៍រាល់យប់ទៀត ។

នៅខែមិថុនា ឆ្នាំ១៩៧៤ ដោយសភាពការណ៍ទាហានឈ្លបស្ងប់ស្ងាត់ ខ្ញុំបានដកកម្លាំងចេញពីខ្សែត្រៀម រួចចាត់តាំងឲ្យចុះធ្វើការតាមភូមិជម្លៀសវិញ ហើយខ្ញុំក៏ចុះទៅភូមិដូងដើម្បីដឹកនាំកម្លាំងប្រជាជនដាំដំឡូងមី ដំឡូងជ្វារួមគ្នា ប៉ុន្តែនៅពេលដំឡូងដុះល្អហើយ ខ្ញុំបានលួយលែងគោឲ្យស៊ីអស់មួយហិកតា និងកាប់ជើងគោអស់ពីរនឹម ។ នៅក្នុងចំណោមប្រជាជនជម្លៀសទាំងនេះ ខ្ញុំបានកសាងកម្លាំងចូលជាសេអ៊ីអា៥នាក់គឺ ធុន, ធូ, រីន, ទ្រី និងគាន បន្ទាប់មកខ្ញុំចាត់តាំងឲ្យដើរនិយាយបំផុសទំនាស់ជាមួយមាគ៌ាបដិវត្តន៍ ដែលធ្វើបាបប្រជាជនមកដាក់ក្នុងព្រៃ អត់ឲ្យបាយស៊ី និងគ្រុនចាញ់ ស្លាប់ជាបន្តបន្ទាប់ ។

នៅចុងឆ្នាំ១៩៧៤ បង ស្រ៊ុន ត្រឡប់មកទទួលស្រុកស្ទោង ក្នុងនាទីជាលេខាស្រុក បន្ទាប់មកខ្ញុំក៏បានចូលរួមប្រជុំនៅមន្ទីរភូមិកោះដែលមានសមាជិកទាំងអស់១២នាក់ ។ នៅពេលប្រជុំ គាត់ដាក់ផែនការចែករបបអង្ករមួយកំប៉ុងសម្រាប់មនុស្សពី១៥-២១ ហើយត្រូវធ្វើការងារទាំងយប់ទាំងថ្ងៃទៀត និងត្រូវបញ្ចេញស្រូវអង្ករទៅខាងក្រៅ ។ បន្ទាប់មក បងស្រ៊ុន បានណែនាំថា ខាងសន្តិសុខត្រូវប្រមូលកម្លាំងមកដើរចល័តពិនិត្យសភាពការណ៍តាមឃុំ ហើយទប់ទល់កុំឲ្យមានបាតុកម្ម ព្រោះទំនាស់ប្រជាជនជាមួយនឹងការដឹកនាំរបស់យើងកាន់តែខ្លាំងឡើងហើយ ។

រហូតដល់ចុងខែ១២ ឆ្នាំ១៩៧៤ បង ស្រ៊ុន បានហៅខ្ញុំ បងឡើង និងបង ស៊ីប ទៅផ្ទះរបស់គាត់នៅភូមិកោះ ហើយគាត់ដាក់ផែនការថា មិត្តទាំងបីត្រូវរួមកម្លាំងគ្នាទៅទម្លាយទំនប់ បង្ហូរទឹកចោលដើម្បីកុំប្រជាជនយកទឹកធ្វើស្រែបាន និងធ្វើឲ្យប្រជាជនអស់ជំនឿលើការដឹកប្រឡាយតទៅទៀត ។ នៅយប់មួយក្នុងពាក់កណ្តាលខែ១ ឆ្នាំ១៩៧៥ យើងបានប្រមូលកម្លាំងបានចំនួន២១នាក់ទៅជួបជុំនៅលើខ្នងទំនប់ ជីកទម្លាយ រួចហើយត្រឡប់មកកន្លែង

រៀងៗខ្លួនវិញ ។

ក្រោយថ្ងៃរំដោះនៅទូទាំងប្រទេស នៅចុងខែមេសា ឆ្នាំ១៩៧៥ បង ស្រ៊ុន បានប្រជុំពិសេសមួយក្នុងគណៈកម្មាធិការស្រុកនៅលើផ្ទះរបស់គាត់មាន ខ្ញុំ, ឡើង, ខេង, ហន, ហ៊ិន និងពិន ចូលរួម ។ បង ស្រ៊ុន បានណែនាំថា នេះជាសភាពការណ៍ថ្មីដែលបក្សកុម្មុយនីស្តកាន់កាប់អំណាចទាំងស្រុង ដូច្នេះកម្មាភិបាលយុទ្ធជនដែលមានប្រវត្តិរូបល្អ ហើយប្រជាជនស្រឡាញ់អាចនៅបន្តប់ក្នុងជួរបដិវត្តន៍ ចំណែកអ្នកដែលប៉ះពាល់ដល់ប្រជាជនត្រូវដកឲ្យទៅធ្វើការបន្តប់នៅសហករណ៍វិញ ។ និយាយចប់ បង ស្រ៊ុន ណែនាំខ្ញុំឲ្យដកកម្លាំងប្រជាជនជម្លៀសនៅឃុំដូង ឃុំក្រយា ឃុំបន្ទាយស្ទោង និងឃុំពពក ឲ្យមករស់នៅក្នុងភូមិឃុំរបស់គេវិញ ។

នៅខែមិថុនា ឆ្នាំ១៩៧៥ បង ស្រ៊ុន បានហៅខ្ញុំទៅសួរពីសកម្មភាពឪពុកម្ដាយក្មេករបស់ខ្ញុំម្ដងទៀត ។ ខ្ញុំបានប្រាប់គាត់ថា មុនរំដោះក៏ដូចជាក្រោយរំដោះដែរ គាត់មិនឯកភាពលើការដឹកនាំរបស់យើងទេ ព្រោះគាត់តែងនិយាយថា ដឹកនាំឃើញតែអន្តរាយប្រជាជនឃើញតែលំបាកឡើងៗ ។ នៅពេលនោះ បងស្រ៊ុន ណែនាំថា ឥឡូវបណ្ដោយឲ្យគាត់និយាយទៀតមិនបានទេ ចាំខ្ញុំទាក់ទងនិងចាត់ចែងឲ្យបង វ៉ុន បច្ចុប្បន្នប្រធានឃុំក្រយា រៀបចំឈ្លបធ្វើការអុកឡុកគាត់ ហើយខ្ញុំក៏យល់ស្របតាមផែនការគាត់ ។ ឈ្លបបានតាមដាននៅក្រោមផ្ទះឪពុកម្ដាយក្មេករបស់ខ្ញុំ ចូលឆែកឆេរលើផ្ទះ ដកខោអាវ ថ្នាំពេទ្យបន្តិចបន្តួចដែលគាត់ទុកព្យាបាលខ្លួនដោយលើកឡើងថា ទុកជូនសម្ពហភាព និងបានចាប់ ខ្លួនម្ដាយក្មេកយកមកអប់រំពីរឿងគាត់យកអង្ករកន្ទះកំប៉ុងដាក់ក្នុងហោប៉ៅអាវប្រុងបបរហូបនៅការដ្ឋាន ដោយយកលេសថា សេរីចង់ហូបឯកជន ហើយបានចាត់តាំងគាត់ឲ្យធ្វើការងារដូចកម្លាំងក្មេងៗ ។ នៅពេលនោះ ខ្ញុំក៏បានសរសេរសំបុត្រតិះដៀលគាត់ជាច្រើនពីបញ្ហាដែលគាត់មិនសូវគិតគូររូបខ្ញុំ ចំណែកគ្រួសារខ្ញុំជួបពេលណាក៏ខ្ញុំរករឿងស្តីបន្ទោសដែរ ។

ដើមខែកក្កដា ឆ្នាំ១៩៧៥ បង ស្រ៊ុន ដកខ្ញុំឲ្យទៅធ្វើការនៅមន្ទីរសន្តិសុខកំពង់ធំ ហើយគាត់បានណែនាំខ្ញុំថា កម្លាំងសល់ក្នុងស្រុកសល់ប៉ុន្មាន គាត់បានដកនិងបំបែក ដោយមួយចំនួនឲ្យទៅនៅភ្នំពេញ ហើយមួយចំនួនត្រូវដកឲ្យមកគ្រប់គ្រងនៅក្នុងក្រសួងមន្ទីរ តំបន់៤៣ ដើម្បីម្ចាស់ការ ។ ដូច្នេះ គាត់ឲ្យខ្ញុំដកយកភ្នាក់ងារសេអ៊ីអាចំនួន៤នាក់គឺ មិត្តកឹង, ពន, ជេត និងផាន និងយុទ្ធជន ២នាក់គឺ មិត្តវិន និងមិត្តស៊ាង យកទៅធ្វើការនៅមន្ទីរសន្តិសុខតំបន់៤៣ ដោយទុកតែមិត្ត ហឿន និងមិត្ត នីរ នៅទទួលសន្តិសុខស្រុកបន្តទៀត ។ ទៅដល់កំពង់ធំ ខ្ញុំបានប្រមូលកម្លាំងមកពីស្រុកស្ទោងស្នាក់នៅផ្ទះមួយជាប់របងគុក ចំណែកមិត្ត ហ៊ូរ ប្រធានគុកបានស្នាក់នៅផ្ទះមួយជាមួយនារី ស្ថិតនៅចម្ងាយ ១០០ម៉ែត្រពីផ្ទះរបស់ខ្ញុំ ។

នៅឆ្នាំ១៩៧៥ ពេលក្រុមខ្ញុំយាម ខ្ញុំបានលួចដោះលែងអ្នកទោសជម្លៀសពីភ្នំពេញ ដែលប្រុងរត់ទៅប្រទេសសៀមអស់ចំនួន៥នាក់ ។ បញ្ហាដោះលែងអ្នកទោសនេះ ក្រុមរបស់ខ្ញុំត្រូវប្រធានឈ្មោះ ហ៊ូរ និងប្រធាននារីឈ្មោះ មួន ស្តីបន្ទោស និងរករឿងរកហេតុជាបន្តបន្ទាប់ ។ នៅពេលនោះ ដោយឃើញខ្ញុំប្រជុំស្ងាត់ៗតែជាមួយកម្លាំងសេអ៊ីអា មិត្ត ស៊ាង ដែលខ្ញុំយកមកជាមួយក៏ប្ដូរទៅរស់នៅផ្ទះជាមួយ ហ៊ូរ វិញ ។

នៅខែធ្នូ ឆ្នាំ១៩៧៥ បង ស្រ៊ុន បានទៅដេកផ្ទះខ្ញុំស្នាក់នៅមួយយប់ ហើយគាត់ក៏បានសួរខ្ញុំពីសភាពការណ៍នៅក្នុងមន្ទីរសន្តិសុខតំបន់ ។ ខ្ញុំបានប្រាប់គាត់ថា ឥឡូវទំនាស់ខាងក្រុមមិត្ត ហ៊ូរ និងក្រុមខ្ញុំកាន់តែខ្លាំងឡើង ហើយមិត្ត ហ៊ូរ បានកៀបខ្ញុំជាប់ស្ទើរតែមិនហ៊ានធ្វើសកម្មភាពអ្វីទាំងអស់ ព្រោះគេតាមដានខ្លាំង ។ ទោះជាយ៉ាងនេះក្ដី ខ្ញុំបានឲ្យអ្នកទោសរត់រួច៥នាក់ទៀតនិងខូចសីលធម៌ជាមួយនារីជម្លៀសមកពីភ្នំពេញចំនួន៦នាក់ ។

នៅដើមឆ្នាំ១៩៧៦ បង ស្រ៊ុន បានចាត់តាំងបង ឡើង ឲ្យមកគ្រប់គ្រងខ្សែសេអ៊ីអាដែលយកពីស្រុកស្ទោងបន្តបន្ទាប់និងទទួលនាទីជាអនុប្រធានមន្ទីរតំបន់ ។ រហូតដល់ពាក់កណ្ដាលខែ៣ ឆ្នាំដដែល ខ្ញុំក៏ទទួលបាននាទីជាអនុប្រធានក្រសួងសន្តិសុខតំបន់៤៣ ហើយនៅខណៈនោះ បង ឡើង បានហៅខ្ញុំទៅជួបនៅផ្ទះរបស់គាត់ទល់មុខមន្ទីរតំបន់៤៣ រួចណែនាំថា បើតាមគាត់ក្ដាប់បាន ប្រធានមន្ទីរ តំបន់ ប្រធានសន្តិសុខតំបន់ និងប្រធានពាណិជ្ជកម្មតំបន់កំពុងរកល្បិចដកមិត្ត(ខ្ញុំ) ចេញពីសន្តិសុខដោយគេចោទថា មិត្ត ស្រ៊ុន ប្រុងដកពួកគេចេញ ដោយសារតែខ្ញុំចាក់ដោត ។

នៅខែ៤ ឆ្នាំ១៩៧៦ ខ្ញុំត្រូវដកទៅជាយុទ្ធជនក្រសួងខស្សរាហកម្មតំបន់៤៣ ។ នៅយប់មួយក្នុងដើមខែ៥ បង ឡើង បានទៅផ្ទះខ្ញុំនៅទល់មុខរោងចក្រតម្បាញ រួចហើយប្រាប់ថា មិត្ត ស្រ៊ុន មិនទាន់ដឹងរឿងនេះទេ ដូច្នេះចេះតែធ្វើការធម្មតាទៅ ចំណែកខ្សែសេអ៊ីអាគាត់ខទ្ទេសនាមខ្ញុំឲ្យទាក់ទងជាមួយ មិត្ត ពៃ ។

រំលងបាន៥ថ្ងៃ ក្រសួងចាត់តាំងឲ្យខ្ញុំទៅដឹកជញ្ជូនកីតម្បាញពីរោងចក្រតម្បាញកំពង់ចាម ។ នៅពេលនោះ ខ្ញុំក៏បានជួបមិត្ត ពៃ ហើយគាត់ក៏បានអប់រំខ្ញុំថា នៅពេលដឹកជញ្ជូនត្រូវធ្វើឲ្យបាក់បែក និងដោះចោលខ្លះខ្លះ ធ្វើយ៉ាងណាឲ្យដំណើរការរោងចក្រស្ទះ ។ បន្ទាប់មក មិត្ត ពៃ បានខទ្ទេសនាមកម្លាំងសេអ៊ីអានៅក្នុងរោងចក្រមួយចំនួនដូចជាមិត្ត ពាត់, ណាត់, ជាន, និត, យី, រ៉ាត, លីម, ខាន់, សែន, ហែល និងពារ ឲ្យខ្ញុំទាក់ទង ។ នៅក្នុងរយៈពេល៣ខែ ខ្ញុំបានលើកទម្លាក់ម៉ាស៊ីនកីតម្បាញបាក់ជើងអស់៣គ្រឿង ម៉ាស៊ីនអំបោះឆ្មារបាក់ជើងអស់២គ្រឿង ។

នៅខែកក្កដា ឆ្នាំ១៩៧៦ ក្រសួងបានចាត់តាំងខ្ញុំឲ្យទៅកាប់ដើមឈើទាលនៅប្រាសាទសំបូរព្រៃគប់ ដើម្បីយកមកធ្វើរោងចក្រ នៅពេលនោះ មិត្ត ពៃ បានអប់រំថា មិនបាច់កាប់ឈើល្អៗទេ គឺកាប់ដើមឈើខ្ទិៗបានហើយ ។ បន្ទាប់ពីខ្ញុំកាប់ដើមឈើបានចំនួន៦០ដើមមក នៅខែ១០ ក្រសួងក៏ចាត់តាំងខ្ញុំឲ្យទៅរៀបរោងអារឈើនៅស្មោងទៀត ។ នៅទីនោះរយៈពេល៣ថ្ងៃ ខ្ញុំបានជួបជាមួយបង ស្រ៊ុន នៅផ្ទះរបស់គាត់ ហើយខ្ញុំក៏បានសួរពីផែនការមួយចំនួនទៅថ្ងៃមុខ ។ បង ស្រ៊ុន បានអប់រំថា ឥឡូវមិត្តកុំគិតវែងឆ្ងាយពេក ខំតែរៀបម៉ាស៊ីនអារឈើឲ្យដំណើរការសិនទៅដើម្បីឲ្យប្រជាជនមានជំនឿលើយើង ចំណែកអង្គរត្រីសាច់ចាំខ្ញុំជួយដោះស្រាយ ។ គាត់បានបន្តថា ឥឡូវនៅក្រសួងពាណិជ្ជកម្មគាត់ដាក់មិត្ត ហ៊ិន ជាប្រធាន និងមិត្ត ពិន អនុប្រធាន ។

នៅខែឧសភា ឆ្នាំ១៩៧៧ ក្រសួងដកខ្ញុំមកគ្រប់គ្រងរោងជាងដែក ផ្នែកខាងរោងចក្រតម្បាញ តំបន់៤៣ ។ នៅពេលនោះ ខ្ញុំបានជួបមិត្ត ហ៊ិន និងបានសួរពីសភាពការណ៍សេអ៊ីអានៅកំពង់ធំ ។ បង ហ៊ិន បានប្រាប់ខ្ញុំថា ឥឡូវបង ស្រ៊ុន អង្គការចាប់ខ្លួនហើយ ចំណែកបង ឡើង អង្គការដកទៅនៅកសិកម្មស្រុកសន្ទុក ដូច្នេះមិត្តចាំជួបជាមួយមិត្ត ពៃ ព្រោះគាត់អាចទាក់ទងរហូតដល់ភូមិភាគ ។

នៅចុងខែឧសភា ឆ្នាំ១៩៧៧ មិត្ត ពៃ បានហៅខ្ញុំទៅប្រជុំនៅផ្ទះគ្រួសាររបស់គាត់ដែលមានសមាជិកចូលរួមដូចជា លីម និងពាត់ ។ នៅពេលនោះមិត្ត ពៃ បានណែនាំឲ្យខំកសាងកម្លាំងបន្ថែម និងធ្វើសកម្មភាពឲ្យស្ទះការងារក្នុងរោងចក្រ ។ នៅរយៈ២ខែក្រោយមក ខ្ញុំបានកសាងកម្លាំងសេអ៊ីអា នៅក្នុងរោងជាងដែកបានចំនួន៤នាក់គឺ ខែម, ណាង, ស៊ាន និង យឿន ។ កម្លាំងទាំងនោះ ខ្ញុំបានដឹកនាំធ្វើសកម្មភាពដូចជាធ្វើឲ្យស្ទះរន្ធបង្ហូរទឹកបណ្តាលឲ្យឆេះស្លែលែងកើត ។ នៅពេលនោះ ខ្ញុំបានប្រាប់មិត្ត ពាត់ ពីភាពរអាក់រអួលដោយសារដាច់ភ្លើង ភ្លើងមិនគ្រប់ និងឌីណាម៉ូឆេះ ។ ស្របពេលនោះ ខ្ញុំបានអប់រំកម្លាំងបច្ចេកទេសពីសង្គមចាស់ចូលមកជាកម្លាំងសេអ៊ីអាបានចំនួន៤នាក់បន្ថែមទៀតរួមមានមិត្ត ថៃ, ហ៊ា, ទុន និងស៊ូ ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ក្រសួងបានចាត់តាំងឲ្យទៅដកស្នូងស្រែរបស់តំបន់ និងកម្លាំងសេអ៊ីអា ៤នាក់គឺ ថៃ, ហ៊ូ, ទុន, សែន នៅក្នុងរោងចក្រតម្បាញទៅជាមួយដែរដើម្បីរៀបចំផែនការបំផ្លាញសំណាប និងសន្ទូង ។

នៅខែសីហា ឆ្នាំ១៩៧៧ ខ្ញុំបានជួបមិត្ត ពៃ នៅលើផ្ទះគ្រួសារគាត់ ហើយខ្ញុំបានសួរគាត់ថាតើផែនការសេអ៊ីអាយ៉ាងម៉េច? បើបងស្រ៊ុន មិត្ត ហ៊ិន អង្គការចាប់ ចំណែកមិត្ត ពិន ត្រូវដកទៅសហករណ៍ ហើយបង ឡើង បាត់ដំណឹងទៀត ។ នៅពេលនោះ ពៃ បានអប់រំខ្ញុំថា មិត្តកុំអស់សង្ឃឹម អស់ម្នាក់ ឬពីរនាក់ក៏នៅមានសេអ៊ីអាពាសពេញអាចធ្វើការបានដែរ ឥឡូវមិត្តត្រូវធ្វើការបន្តទៅមុខទៀតកុំព្រួញបារម្ភ ។

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៧៧ ពេលត្រឡប់មកពីស្រែនៅពេលយប់ ខ្ញុំក៏ត្រូវអង្គការចាប់ខ្លួន ។ នៅពេលនោះ ប្រធានសន្តិសុខឈ្មោះ ឆាយ ហៅខ្ញុំមកសួរ ខ្ញុំក៏បានរាយការណ៍ពីភាពខុះខាតរបស់ខ្លួនក្នុងចំណោមពួកក្បត់ ហើយធ្វើសំណូមពរដើម្បីរាយការណ៍ពីលេខាតំបន់ឈ្មោះ ចន ដែលបម្រើសកម្មភាពសេអ៊ីអា ជូនបង ពក លេខាភូមិភាគជីង ។ នៅកន្លែងឃុំឃាំង ខ្ញុំចង់តែជួបមុខគ្រួសារនិងកូនៗប៉ុណ្ណោះ ដោយលែងគិតពីរឿងអ្វីទាំងអស់ ។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការអនុគ្រោះទាំងគ្រួសារឲ្យមកនៅមន្ទីរស-២១ ហើយបង ឌុច បានឲ្យខ្ញុំនៅកន្លែងឈូសឈើ ធ្វើជ្រុំងដែនទីនិងក្តារខៀន ដោយមិនអនុញ្ញាតឲ្យដើរទៅណាទេ។ នៅទីនោះខ្ញុំទទួលបានការអប់រំស្មើរតែរាល់យប់ពីមិត្ត ថន ដែលនិយាយពីការសប្បាយ និងស្រីញី។

រយៈពេលកន្លះខែក្រោយមក បង ឌុច បានឲ្យខ្ញុំរាយការណ៍អំពីសកម្មភាពរបស់ខ្ញុំផ្ទាល់ដោយស្មោះត្រង់ដែលទាក់ទងជាមួយនឹងពួកក្បត់ជូនអង្គការ ពេលនោះដោយខ្លាចបងចាប់ខ្លួនម្តងទៀតខ្ញុំក៏សរសេររាយការណ៍លាក់លៀម បិទបាំង និងមិនស្មោះត្រង់។ រំលងបានមួយខែក្រោយមក បង ឌុច បានហៅខ្ញុំទៅសួរដោយពាក្យធ្ងន់ៗថា «មើលអាអ្ហែង មានធ្វើឲ្យរួចគិញនៅកំពង់ធំយ៉ាងម៉េចខ្លះ?» ខ្ញុំកុំក៏ឆ្លើយបិទបាំងកុហកគាត់ទៀត។ នៅកន្លែងស្នាក់នៅ បង ឌុច មិនឲ្យដើរចេញទៅណាទេ សូម្បីតែផ្ទះគាត់ធ្វើការក៏មិនឲ្យខ្ញុំទៅជិតដែរ។ នៅដើមឆ្នាំ១៩៧៨ បង ឌុច ចាត់តាំងខ្ញុំឲ្យនៅគូរផែនទីក្នុងមន្ទីរស-២១។ នៅក្នុងខែ៧ ឆ្នាំដដែល វេលាយប់ មួយពេលបង ឌុច ឈឺខ្លាំង គ្រួសារខ្ញុំ និងប្អូនភី ឲ្យខ្ញុំជូនប្អូន ហុង ទៅកន្លែងធ្វើការវិញ។ ប៉ុន្តែដោយយប់នោះ បង ឌុច មិនទាន់សម្រាន្ត ហើយកំពុងជាប់ធ្វើការទាក់ទងតាមទូរស័ព្ទជាមួយមិត្តយើងផ្សេង ខ្ញុំមិនទាន់ហ៊ានដកខ្លួនជូនប្អូន ហុង ទៅទេ ព្រោះខ្លាច បង ឌុច រកខ្ញុំហុចនេះហុចនោះ។ ម៉ោងប្រហែល២យប់ ពេលបង ឌុច ឈប់ធ្វើការ ហើយសម្ងំស្ងៀម ខ្ញុំក៏ចុះមកផ្ទះគ្រួសារខ្ញុំ ដោយចង់រកពេលដើម្បីរំលោភ ហុង។ ពេលនោះ ខ្ញុំបង្ខំ ហុង ទៅកន្លែងធ្វើការ (ពេទ្យ៧០៣) ទាំងយប់ រួចហើយខ្ញុំឡើងជិះកង់ជូន ហុង ក្នុងគោលបំណងទៅកន្លែងស្ងាត់ដើម្បីរំលោភ ប៉ុន្តែមិនបានសម្រេច ដោយសារតាមផ្លូវមានភ្លើងភ្លឺខ្លាំងពេកនិងមានកងទ័ពដើរចល័ត។ ឃើញដូច្នេះ ខ្ញុំក៏ជូន ហុង ទៅដល់កន្លែងធ្វើការ រួចហើយក៏ត្រឡប់មកវិញ។

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៧៨ វេលាម៉ោង១០កន្លះយប់ ខ្ញុំបានជូនប្អូន ហុង ពីផ្ទះកុមារទៅ កន្លែងធ្វើការនៅពេទ្យ៧០៣ម្តងទៀត។ នៅខណៈនោះ ខ្ញុំមានបំណងប្រុងរំលោភ ហុង ម្តងទៀត ដោយខ្ញុំបានឲ្យបង្ខំ ហុង ទៅផ្ទះខ្ញុំកន្លែងគូរផែនទី ដោយយកលេសថា ទៅប្រាប់មិត្តយើងក្រែងបង ឌុច រក។ ទៅដល់ផ្ទះ ខ្ញុំបានទាញដៃ ហុង ឡើងទៅលើផ្ទះចូលបន្ទប់ខ្ញុំដេក រួចបើកទ្វារម្ខាងដើម្បីស្រែកប្រាប់ទៅមិត្ត ឡុង និងមិត្ត លក ថា បើបង ឌុច ឲ្យមិត្តយើងមករកខ្ញុំ ប្រាប់ថា ខ្ញុំជូន ហុង ទៅមន្ទីរ៧០៣មួយភ្លែត។ ខ្ញុំស្រែកប្រាប់ ឡុង និង លក នេះដើម្បីជាលេសកុំឲ្យមិត្តយើងសង្ស័យ ហើយឲ្យ ហុង អស់ចិត្ត។ នៅមុនពេលចូលបន្ទប់វិញ ខ្ញុំទាញទ្វារបន្ទួចបិទ ហើយខ្ទាស់ជាប់។ ខ្ញុំចូលទៅបន្ទប់ ឃើញ ហុង កំពុងអង្គុយលើគ្រែក៏ស្ទុះទៅអង្គុយជិតចាប់ស្មាជាប់ឱនថើបញីញក់ ខាំកដោយប្រុងបង្ខំរំលោភ ប៉ុន្តែ ហុង បានរើបម្រះប្រានដៃខ្ញុំចេញ ហើយបើកទ្វាររត់ចុះមកក្រោមជិះកង់ចេញទៅ។ ពេលនោះខ្ញុំក៏រត់មកក្រោមផ្ទះ រួចជិះកង់ជូនដំណើរគាត់ទៅមន្ទីរពេទ្យ៧០៣វិញ។ នៅតាមផ្លូវ ហុង មិនសូវរាក់ទាក់ជាមួយខ្ញុំទេ។ ដោយឃើញអាកប្បកិរិយា ហុង ខឹងនឹងខ្ញុំខ្លាំង ខ្ញុំក៏ចាប់ផ្តើមភ័យខ្លួនដោយខ្លាចគាត់រាយការណ៍ទៅបង (ឌុច)។ ទៅដល់មុខមន្ទីរពេទ្យ ខ្ញុំទាញដៃ ហុង ឲ្យឈប់កង់មួយភ្លែត ប៉ុន្តែគាត់មិនព្រមឈប់ ខ្ញុំក៏ទាញរហូត ហុង ឈប់កង់។ នៅពេលនោះ ខ្ញុំនិយាយថា «បងស្រឡាញ់ ហុង ខ្លាំងណាស់ ចង់តែលេបទុក បើសិនលេបកើត»។ ប្រសិនបើ ហុង ទៅសមរភូមិ កុំភ្លេចបងណា ខ្ញុំនិយាយលួងលោមយ៉ាងនេះដោយចង់បំភាន់ ហុង ថាខ្ញុំស្រឡាញ់គាត់ដោយស្មោះ ហើយឲ្យគាត់អាណិតដើម្បីកុំឲ្យយកអំពើឃោរឃៅរបស់ខ្ញុំទៅរាយការណ៍ឲ្យបង ឌុច ដឹង។ ប៉ុន្តែពេលនោះ ហុង អត់មាននិយាយតបមកខ្ញុំវិញទេ ហុង ឡើងជិះកង់ ហើយនិយាយរកខ្ញុំតែមួយម៉ាត់ថា គាត់ចូលកន្លែងវិញហើយ។

នៅល្ងាចថ្ងៃ២១ ខែកក្កដា ឆ្នាំ១៩៧៨ ខ្ញុំជួប ហុង មួយភ្លែតនៅផ្ទះគ្រួសារខ្ញុំ ពេលនោះ ហុង ធ្វើគោះតើយ ហើយមិននិយាយរកខ្ញុំទេ។ ខ្ញុំបានសួរ ហុង ថា បែបមានរឿងអី ឬខឹងអ្នកណាទើបមិនសូវនិយាយ? គាត់ទាញកង់ជិះបណ្តើរ និយាយបណ្តើរថា ខ្ញុំប្រញាប់ទៅវិញព្រោះមិត្តយើងគេចាំ ដោយសារខ្ញុំមកផ្ទះបងយូរហើយ។ បន្ទាប់មក ខ្ញុំក៏វិលត្រឡប់ទៅផ្ទះខ្ញុំវិញ ដោយអត់ហ៊ានឡើងលេងផ្ទះបង ឌុច ដូចមុនៗទៀតទេ។ នៅយប់ថ្ងៃដដែល ខ្ញុំត្រូវអង្គការចាប់ខ្លួននៅមន្ទីរស-២១ តែម្តង។

**សោម ប៊ុនថន**

# អ្នកគ្រូ មុំ ម៉េត : បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ



មុំ ម៉េត ក្នុងឆ្នាំ២០០៩

មុំ ម៉េត គឺជាគ្រូបង្រៀនថ្នាក់ជាតិផ្នែកប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ ។ មុំ ម៉េត ធ្វើជាគ្រូបង្រៀនចាប់តាំងពីឆ្នាំ១៩៦៩មក ។ ប្តីរបស់គាត់និងប្អូនស្រីត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ដោយគ្មានទោសកំហុស ។ ម៉េត រស់នៅជាស្ត្រីមេម៉ាយ និងមានកូន៥នាក់ បានរៀបរាប់ទាំងទឹកភ្នែកថាៈ ខ្ញុំមានអាយុ៦៨ ឆ្នាំ មានស្រុកកំណើតនៅភូមិគោកត្រប់ ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ខ្ញុំមានបងប្អូន៤នាក់និងមានឪពុកឈ្មោះ មុំ ម៉ែន ជាកសិករ ម្តាយឈ្មោះ អ៊ួង មិ ជាកសិករ និងត្បាញសារុងសូត្រនៅរដូវប្រាំង ។ ទោះបីឪពុកម្តាយរបស់ខ្ញុំរកប្រាក់កម្រៃបានបន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃក៏ដោយ ក៏គាត់ជំរុញកូនឲ្យបានទៅរៀនសូត្រដែរ ។ នៅអាយុ៦ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាកោកកាក ហើយជារៀងរាល់ខែ ខ្ញុំតែងតែទទួលបានចំណាត់ថ្នាក់ល្អជានិច្ច និងជាសិស្សពូកែខាងគណិតវិទ្យា ។ នៅពេលមានពិធីបុណ្យទានផ្សេងៗនៅក្នុងវត្តម្តងៗ ក្មេងស្រីដែលមានវ័យស្របាលខ្ញុំនៅក្នុងភូមិមិនសូវរាក់ទាក់ជាមួយខ្ញុំទេ ហើយតែងតែដើរចេញពេលឃើញខ្ញុំទៅអង្គុយជិតម្តងៗ ព្រោះក្មេងទាំងនោះគិតថាខ្ញុំជាអ្នករៀនសូត្រ ។ ប៉ុន្តែ ទោះជាមានការរើសអើងយ៉ាងនេះក្តី ក៏ខ្ញុំខិតខំរៀនបានដល់ថ្នាក់ទី៧ ពេលប្រឡងជាប់ចូលថ្នាក់ទី៦ ខ្ញុំមករៀនបន្តនៅវិទ្យាល័យសង្គមរាស្ត្រនិយម (បច្ចុប្បន្នសាលាគរុកោសល្យខេត្តកណ្តាល) ។ ដោយសារសាលានេះមានចម្ងាយឆ្ងាយពីផ្ទះឪពុកម្តាយដែលស្ថិតនៅស្រុកកណ្តាលស្ទឹង ខ្ញុំក៏បានមកស្នាក់នៅជាមួយបងស្រីធ្វើជាគិលានុប្បដ្ឋាយិកា ដែលមានផ្ទះស្ថិតនៅខាងត្បូងវត្តលង្កា ។ នៅពេលព្រឹក ខ្ញុំត្រូវជិះកង់ចម្ងាយប្រមាណជាងដប់គីឡូម៉ែត្រ ពីភ្នំពេញទៅរៀនសាលានៅតាខ្មៅ និងត្រឡប់មកវិញនៅពេលល្ងាច ។ ប៉ុន្តែទោះបីជាមានការនឿយហត់ក៏ដោយក៏ខ្ញុំនៅតែខិតខំរៀនសូត្ររហូតក្លាយជាសិស្សពូកែប្រចាំថ្នាក់ផ្នែកគណិតវិទ្យាមួយរូបដែរ ។

នៅឆ្នាំ១៩៦៥ ខ្ញុំបានប្រឡងជាប់សញ្ញាប័ត្រឌីប្លូម បន្ទាប់មកខ្ញុំក៏ប្តូរមករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិក្នុងទីក្រុងភ្នំពេញវិញ ។ រហូតមកដល់ឆ្នាំ១៩៦៧ បន្ទាប់ពីខ្ញុំបានប្រឡងជាប់សញ្ញាប័ត្របាក់អង (មធ្យមសិក្សាប័ត្រភាគទី១សង្គមចាស់) ខ្ញុំមិនបានជ្រើសរើសយកមុខវិជ្ជាគណិតវិទ្យាទេ ព្រោះខ្លាចប្រឡងធ្លាក់ត្រូវរៀនត្រួតថ្នាក់ ម្យ៉ាងទៀតឪពុកម្តាយត្រូវចំណាយលុយទិញសម្ភារៈសិក្សាបន្ថែមទៀត ។ ដូច្នេះ ខ្ញុំក៏សម្រេចចិត្តយកផ្នែកវិទ្យាសាស្ត្រពិសោធន៍វិញ ដែលរួមមានគីមីវិទ្យា រូបវិទ្យា ជីវវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា ទស្សនវិជ្ជា និងភាសាបរទេសដើម្បីបន្តយកមធ្យមសិក្សាប័ត្រភាគទី២នៅឆ្នាំ១៩៦៨ ។ ក្រោយពេលប្រឡងជាប់ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំដែលជាសាស្ត្រាមធ្យមសិក្សាបឋមភូមិ បង្រៀននៅវិទ្យាល័យក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ នៅពេលនោះ ដោយសារខ្ញុំចង់ធ្វើជាគ្រូបង្រៀនដែរ ខ្ញុំក៏បានដាក់ពាក្យប្រឡងចូលរៀននៅសាលាគរុកោសល្យជាគរុនិស្សិត ប៉ុន្តែលទ្ធផលធ្លាក់ ។ បន្ទាប់មក ខ្ញុំបានប្រឡងជាប់ជាគរុសិស្ស(នៅសាលាគរុកោសល្យទន្លេបាទី) ។

នៅពេលរៀនចប់គ្រូបឋមសិក្សាក្នុងឆ្នាំ១៩៦៩ ខ្ញុំបានទៅបង្រៀននៅសាលាបឋមសិក្សាសួងជាមួយប្តីដែលទើបតែផ្លាស់មកពីវិទ្យាល័យក្រូចឆ្មារមកបង្រៀននៅវិទ្យាល័យសួងដែរ ដោយសារផ្លូវឆ្ងាយនិងពិបាកធ្វើដំណើរ ។ នៅទីនោះ ខ្ញុំជាមួយ

នឹងប្តីបានជួលផ្ទះមួយស្ថិតនៅជិតសាលាបឋមសិក្សាដើម្បីស្នាក់នៅ ។ ការបង្រៀននៅទីនោះមិនបានទៀងទាត់ទេ ក្រោយពេលលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ព្រោះសភាពការណ៍នៅតំបន់ស្ទួងទាំងមូលមានភាពច្របូកច្របល់ គ្រប់បន្ទប់រៀនទាំងអស់ រដ្ឋាភិបាល លន់ នល់ តម្រូវឲ្យដោះព្រះឆាយាល័ក្ខណ៍សម្តេចព្រះនរោត្តម សីហនុ ចេញពីបន្ទប់ ដែលមានរួមទាំងបន្ទប់ខ្ញុំបង្រៀនផង ។ ភ្លាមៗនោះ ក៏មានចលនាឃោសនាក្នុងចំណោមប្រជាជនដើម្បីប្រមូលកម្លាំងដែលស្រឡាញ់និងគាំទ្រសម្តេចព្រះ សីហនុ ឲ្យដើរហែរក្បួនបាតុកម្មដែលប្រដាប់ដោយកាំបិតនិងពូថៅសំដៅមកទីរួមខេត្តកំពង់ចាម ដើម្បីទាមទារឲ្យសម្តេចព្រះ សីហនុ យាងមកកាន់អំណាចវិញ ។ ប៉ុន្តែបាតុករទាំងនោះត្រូវកងទ័ព លន់ នល់ ដេញបាញ់ឲ្យរត់ខ្ចាត់ខ្ចាយទៅវិញអស់ ។ ទោះបីជាមានការបង្ក្រាបយ៉ាងនេះក៏ដោយ ក៏ហ្វូងបាតុករបានដើរពិនិត្យតាមផ្ទះប្រជាជន និងសាលារៀន បន្ទប់ណាដែលមិនមានរូបសម្តេចព្រះ សីហនុ នឹងត្រូវថ្កោលទោស ។

ក្រោយមក ដោយសារតំបន់ស្ទួងមានអសន្តិសុខកាន់តែខ្លាំង ហើយមានកងទ័ពវៀតកុង និងកងទ័ពខ្មែរក្រហមជាច្រើនចូលក្នុងភូមិ ខ្ញុំក៏ឈប់ទៅបង្រៀន ហើយយកកូនរបស់ខ្ញុំម្នាក់ទៅផ្ញើម្តាយនៅកណ្តាលស្ទឹងឲ្យជួយចិញ្ចឹម ។ ចំណែកប្តីខ្ញុំត្រូវសាលាចាត់តាំងឲ្យទៅយាមការពារនៅសាលាស្រុកត្បូងឃ្មុំរៀងរាល់យប់ ។ នៅខែឧសភា ឆ្នាំ១៩៧០ កងទ័ពខ្មែរក្រហមនិងវៀតកុងបានចូលមកវាយបំផ្ទុះឃ្លាំងគ្រាប់របស់កងទ័ព លន់ នល់ និងចូលវាយយកបានសាលាស្រុកត្បូងឃ្មុំដែលមានទីតាំងនៅក្នុងឃុំស្ទួង ។ ឃើញដូច្នេះខ្ញុំដែលកំពុងមានផ្ទៃពោះកូនទីពីរនោះក៏បានរត់គេចខ្លួនទៅនៅជាមួយគ្រួសារម្ចាស់ផ្ទះដែលខ្ញុំជួលស្នាក់នៅ ។ នៅយប់ថ្ងៃនោះកងទ័ព លន់ នល់ បានបាក់ទ័ពរត់ខ្ចាត់ខ្ចាយ ។ ស្របពេលនោះខ្ញុំក៏បានទទួលដំណឹងពីអ្នកភូមិថា ប្តីខ្ញុំបានស្លាប់នៅក្នុងហេតុការណ៍វាយប្រយុទ្ធគ្នានេះដែរ ។ បន្ទាប់ពីដឹងដំណឹងនេះភ្លាម ខ្ញុំរន្ធត់ចិត្តខ្លាំងណាស់ រួចក៏យកម៉ូតូម៉ូប៊ីឡែតមួយគ្រឿងជិះទៅរកប្តីនៅសាលាស្រុក ។ ដោយមានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្ញុំ ម្ចាស់ផ្ទះបានឲ្យកូនប្រសាគាត់ជិះម៉ូតូជូនដំណើរតាមពីក្រោយ ។ ខ្ញុំជិះជិតដល់ផ្សារស្ទួង ស្រាប់តែមានយុវជនម្នាក់ស្លៀកពាក់ខោអាវខ្មៅនិងបង់កក្រមាស្រែកហៅថា «អ្នកគ្រូៗ» ទើបខ្ញុំឈប់ម៉ូតូ ហើយខ្ញុំក៏ប្រាប់ថា ទៅរកប្តីនៅសាលាស្រុក ។ យុវជននោះបានប្រាប់ថា អ្នកគ្រូកុំទៅ អ្នកដែលស្លាប់នោះមិនមែនលោកគ្រូទេ (ប្តីរបស់ខ្ញុំ) គឺអ្នកភូមិច្រឡំទេ បន្ទាប់មកខ្ញុំក៏ទៅយកខោអាវមួយចំនួនពីផ្ទះជួលរួចក៏ជិះត្រឡប់ទៅជប់វិញ ។ ចំណែកកូនប្រសាម្ចាស់ផ្ទះនៅប្រមូលរបស់របរនៅក្នុងផ្ទះ ខណៈនោះគាត់ក៏ឃើញវៀតកុងម្នាក់កំពុងអង្គុយធ្វើកង់នៅមុខផ្ទះ ហើយក៏ទៅសួរសុខទុក្ខ ស្រាប់តែវៀតកុងចាប់ខ្លួនគាត់ហើយចោទថាគិញ ។ ក្រោយមក ដោយមានការធានាពីអ្នកភូមិនិងអ្នកធ្លាប់ស្គាល់គាត់ទើបវៀតកុងបានដោះលែង ប៉ុន្តែបានគំរាមឲ្យនាំគ្រួសារទាំងអស់មកស្នាក់នៅផ្ទះនេះវិញ ព្រោះខ្មែរក្រហមវាយកាន់កាប់ជប់ ជីហែ និងផ្នែកខាងកើតទន្លេបានហើយ ។

ខ្ញុំនិងម្ចាស់ផ្ទះក៏បានត្រឡប់មកនៅផ្ទះក្នុងឃុំស្ទួងវិញ ។ ប៉ុន្តែដោយសារខ្ញុំមិនឃើញប្តីរបស់ខ្ញុំត្រឡប់មកផ្ទះយូរថ្ងៃ ខ្ញុំក៏បានសុំអនុញ្ញាតពីកងទ័ពវៀតកុងចូលទៅរកមើលនៅកន្លែងឃុំឃាំងរបស់គេនៅសាលាបឋមសិក្សាទួលទ្រា ក្នុងស្រុកត្បូងឃ្មុំ ដែលឃើញសុទ្ធតែទាហាន លន់ នល់ ។ ប៉ុន្តែដោយរកមិនឃើញប្តីរបស់ខ្ញុំ ខ្ញុំក៏ទៅរកនៅកន្លែងឃុំឃាំងឈ្មោះគីឡូ៦២ ស្ថិតនៅក្នុងចម្ការកៅស៊ូជប់និងកន្លែងឃុំឃាំងមួយទៀតនៅមង់រៀវ ទើបកងទ័ពវៀតកុងប្រាប់ថា គ្រូបង្រៀនបានដោះលែងអស់ហើយ ។ ពីរថ្ងៃក្រោយមក មិត្តភក្តិរបស់ប្តីខ្ញុំបានទៅដល់ផ្ទះជួលរបស់ខ្ញុំ ហើយប្រាប់ថា គាត់បានជួបនឹងប្តីរបស់ខ្ញុំនៅភូមិដូនម៉ៅជិតទន្លេបិទ ហើយថែមទាំងបានខ្ចីលុយប្តីរបស់ខ្ញុំមួយចំនួនសម្រាប់ទិញម្ហូបអាហារបរិភោគទៀតផង ។ បន្ទាប់បានឮដំណឹងនេះ ខ្ញុំត្រេកអរ ហើយបានទៅពឹងប្រជាជនដែលរស់នៅទល់មុខនឹងផ្ទះរបស់ខ្ញុំស្នាក់នៅឲ្យជូនទៅរកប្តី ។ ខ្ញុំត្រូវធ្វើដំណើរឆ្លងកាត់ខ្សែត្រៀមរបស់វៀតកុងជាច្រើនកន្លែងនៅតាមបណ្តោយមាត់ទន្លេរហូតដល់ភូមិដូនម៉ៅក្រោមដំណក់ភ្លៀងនិងគ្រាប់ផ្លោងពីទីរួមខេត្តកំពង់ចាម ។ ប៉ុន្តែខ្ញុំមិនបានឃើញគាត់ទេ ព្រោះប្តីខ្ញុំបានកាប់ដើមចេកបណ្តែតខ្លួនកាត់ទន្លេមេគង្គមកដល់ព្រែកដើមចាន់ក៏ត្រូវទាហាន លន់ នល់ ចាប់ខ្លួនដោយចោទថាជាខ្មែរក្រហម ។ ពេលនោះមានមនុស្សម្នាក់ស្គាល់ប្តីខ្ញុំ គាត់ក៏ប្រាប់ទៅម្តាយក្មេកខ្ញុំដែលរស់នៅភូមិវាល

ស្បូវ ស្រុកកំពង់សៀម ។ បន្ទាប់ពីទទួលដំណឹងនេះភ្លាម បងថ្លៃនិង ម្តាយខ្ញុំ ព្រមទាំងមន្ត្រីគ្រប់គ្រងគ្រូបង្រៀននៅខេត្តកំពង់ចាមក៏ទៅ ធានាយកប្តីរបស់ខ្ញុំមករស់នៅក្នុងភូមិវាលស្បូវវិញ ។ ខ្ញុំបានត្រឡប់ មកផ្ទះវិញទាំងយប់កាត់តាមចម្ការកៅស៊ូពាមជាំងដែលមានភ្លៀង ធ្លាក់ពេញមួយថ្ងៃ ។ ខ្ញុំឮសំឡេងគ្រាប់កាំភ្លើងបាញ់ជាច្រើនគ្រាប់ ដែលធ្វើឲ្យខ្ញុំរន្ធត់យ៉ាងខ្លាំងនិងភ័យញ័រ ។ លុះព្រឹកឡើង ខ្ញុំបបួល មិត្តភក្តិរបស់ប្តីខ្ញុំចំនួនពីរនាក់ដើម្បីរត់មកតំបន់ លន់ នល់ ក្នុងស្រុក ព្រៃឈរ ព្រោះប្រពន្ធគាត់រស់នៅព្រៃទទឹង ។ បន្ទាប់ពីព្រមព្រៀង គ្នាហើយ យើងបានរៀបចំខោអាវបន្តិចបន្តួចចេញដំណើរនៅ ពេលព្រឹក ដោយខ្ញុំជិះជាមួយមិត្តប្តីខ្ញុំ ចំណែកមិត្តភក្តិម្នាក់ទៀត ដែលធ្វើជានាយករងវិទ្យាល័យសួងបានជិះម៉ូតូម្នាក់ឯងនិងមាន ដឹកអីវ៉ាន់បន្តិចបន្តួចពីខាងក្រោយ ។ យើងមិនសូវស្គាល់ផ្លូវច្បាស់ លាស់ទេ ដូច្នេះយើងត្រូវធ្វើដំណើរកាត់ចម្ការកៅស៊ូពាមជាំង ។ ពេលនោះ នៅក្នុងទីរួមខេត្តកំពង់ចាម កងទ័ពវៀតកុងនិងកងទ័ព ខ្មែរក្រហមបានចូលទៅបោះទីតាំងនៅសាកលវិទ្យាល័យកំពង់ចាម នាពេលយប់ (បច្ចុប្បន្នសាលាគរុកោសល្យខេត្តនិងភូមិភាគកំពង់ ចាម) រួចធ្វើការវាយប្រហារទៅលើបន្ទាយស៊ីប (បន្ទាយទាហាន របស់ លន់ នល់) ស្ថិតនៅខាងជើងវិទ្យាល័យព្រះសីហនុ ប៉ុន្តែក៏ មានការបាញ់ផ្ទៀងពីសំណាក់កងទ័ព លន់ នល់ វិញដែរ ។ ចំណែក គ្រូបង្រៀននិងនិស្សិតមួយចំនួនកើតការភ័យខ្លាចរហូតរត់ចោល កង់ ម៉ូតូ ទៅជ្រកនៅក្នុងវិទ្យាល័យព្រះសីហនុ ។ នៅពេលព្រឹក កងទ័ពវៀតកុងនិងខ្មែរក្រហមបានដកចេញពីសាកលវិទ្យាល័យ នេះអស់ ខណៈនោះចៅហ្វាយខេត្តកំពង់ចាម (លោក អ៊ុន តាំ) ក៏បានទូរស័ព្ទហៅកងទ័ពរដ្ឋការ (វៀតណាមខាងត្បូង) មកជួយ ។ រហូតដល់ពេលថ្ងៃត្រង់ ដោយសភាពការណ៍ស្ងប់ស្ងាត់ និស្សិតក៏ ចូលទៅយកកង់ ម៉ូតូនិងសម្ភារៈមួយចំនួនត្រឡប់ទៅផ្ទះវិញ ។ ពេលនោះ ស្រាប់តែខ្ញុំមើលឃើញពីចម្ងាយនូវយន្តហោះនិងសន្ទឹក ទម្លាក់គ្រាប់បែកពីយ៉ូនរដ្ឋការមកលើសាកលវិទ្យាល័យកំពង់ចាម នេះ (បច្ចុប្បន្នសាលាគរុកោសល្យខេត្ត និងភូមិភាគកំពង់ចាម) បណ្តាលឲ្យមនុស្សស្លាប់ជាច្រើន ។

បន្ទាប់ពីឈរមើលការទម្លាក់គ្រាប់បែកនៅកំពង់ចាម បន្តិច យើងបន្តដំណើរមកដល់ដីហែបានជួបបុរសពីរនាក់ ហើយ យើងក៏បន្តដំណើរចុះទៅក្រោមទាំងអស់គ្នា (សំដៅទៅទន្លេ) ។ មួយរយៈក្រោយមក យើងក៏ជួបនឹងកងទ័ពវៀតកុងចំនួន៥នាក់ ទៀតដែលមានតួនាទីមើលផ្លូវ ដោយមានកាន់តេអូ កាំភ្លើងខ្លី កាំភ្លើងវែង និងម៉ូតូចំនួន៣គ្រឿង ។ ដោយសារអ្នករួមដំណើរ ជាមួយខ្ញុំចេះនិយាយភាសាវៀតណាម កងទ័ពទាំងនោះបានឲ្យ យើងនាំផ្លូវគេសំដៅទៅឃុំព្រែកពោធិ ។ ពេលឆ្លងទន្លេតូចត្រង់ វត្តអំបែងចេះ កងទ័ពវៀតកុងមិនអនុញ្ញាតឲ្យយើងជិះម៉ូតូដាច់


ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យទៅដល់គ្រូបង្គោលថ្នាក់ខេត្ត នៅ

ឆ្ងាយពីគេទេ ។ ដោយសារខ្ញុំមានផ្ទៃពោះ៨ខែហើយ ហើយម្យ៉ាង ទៀត ខ្លាចមានការវាយប្រយុទ្ធគ្នានៅតាមផ្លូវ ខ្ញុំក៏ដាច់ចិត្តសុំ អនុញ្ញាតពីកងទ័ពវៀតកុងដើម្បីធ្វើដំណើរចូលក្នុងភូមិរកផ្ទះ ប្រជាជន ។ ខ្ញុំបានឆ្លងទន្លេមេគង្គមកស្នាក់នៅផ្ទះប្រពន្ធលោកគ្រូ (មិត្តភក្តិរបស់ប្តីខ្ញុំ) ដែលស្ថិតនៅព្រៃទទឹងមួយយប់ រួចក៏ទៅរកប្តី នៅភូមិវាលស្បូវ ខេត្តកំពង់ចាមវិញ ។ ប៉ុន្តែទាហាននៅប៉ុស្តិ៍ខាង ខាងមុខភ្នំប្រុសហាមឃាត់អ្នកដែលមិនរស់នៅក្នុងទីរួមខេត្តកំពង់ចាម

មិនឲ្យចូលខេត្តទេ ទើបខ្ញុំត្រឡប់ទៅភ្នំពេញដើម្បីបង្ហាញខ្លួននៅទីចាត់ការមធ្យមសិក្សា ក្រសួងអប់រំជាតិ ហើយនៅខណៈនោះ ខ្ញុំបានជួបលោកគ្រូម្នាក់ដែលបង្រៀននៅវិទ្យាល័យសួងជាមួយប្តីខ្ញុំ រយៈពេលពីរថ្ងៃក្រោយមកគាត់ក៏ត្រឡប់ទៅបង្ហាញខ្លួននៅទីចាត់ការមធ្យមសិក្សាខេត្តកំពង់ចាម ហើយក៏បានផ្តល់ដំណឹងអំពីខ្ញុំទៅប្តីខ្ញុំ ។

នៅរយៈពេល១០ថ្ងៃក្រោយមក ទើបខ្ញុំឃើញប្តីរបស់




ខ្ញុំបានរត់ពីភូមិដែលជាខ្សែត្រៀមប្រយុទ្ធរវាង លន់ នល់ និងខ្មែរក្រហមមកដល់ភ្នំពេញដែរ ។ ខ្ញុំបានស្នាក់នៅជាមួយបងស្រីនៅភ្នំពេញរយៈពេលពីរខែ រហូតដល់សង្គ្រាមស្ងប់ស្ងាត់បន្តិចទើបខ្ញុំនិងប្តីត្រឡប់មកធ្វើការនៅខេត្តកំពង់ចាមវិញ ដោយខ្ញុំបង្រៀននៅសាលាបឋមសិក្សាដីដុះ ។ ចំណែកប្តីខ្ញុំបានបង្រៀននៅវិទ្យាល័យពិសេសជាវិទ្យាល័យដែលទទួលសិស្សភៀសខ្លួនមកពីស្រុកក្រូចឆ្មារ ស្ទឹងត្រង់ និងដីហែ ដែលកាន់កាប់ដោយខ្មែរក្រហម ។ ខ្ញុំបង្រៀនបានមួយឆ្នាំក៏ប្តូរមកបង្រៀននៅសាលាជាមួយប្តីដែរ ។ ខ្ញុំធ្វើការនៅវិទ្យាល័យពិសេសបានរយៈពេល២ឆ្នាំ នៅឆ្នាំ១៩៧៣ ទើបផ្លាស់ទៅភ្នំពេញដោយសារនៅកំពង់ចាមមានអសន្តិសុខរាល់ថ្ងៃ ។ ខ្ញុំបានចូលធ្វើជាអនុរក្សនៅវិទ្យាល័យនារី (បច្ចុប្បន្នសាលានរោត្តម) ចំណែកប្តីខ្ញុំបានបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។

មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានស្នាក់នៅសង្កាត់លេខ៦ ស្ថិតនៅខាងត្បូងវត្តលង្កា ក្រុងភ្នំពេញជាមួយប្តី កូន៤នាក់ ឪពុកម្តាយ បងស្រី១នាក់ ប្អូនស្រី២នាក់ ប្អូនប្រុសម្នាក់ និងជីដូនចាស់ជរាម្នាក់ ។ នៅពេលកងទ័ពខ្មែរក្រហមចូលមកដល់ភ្នំពេញវេលាម៉ោង៩ព្រឹក ខ្ញុំនិងក្រុមគ្រួសារទាំងអស់បានយកក្រណាត់សមួយផ្ទាំងចងនៅមុខផ្ទះដូចប្រជាជនដទៃទៀតដែរ ។ ខ្ញុំឮសូរស្នូរគ្រាប់កាំភ្លើងនៅខាងកើតវិមានឯករាជ្យមួយសន្ទុះក៏បាត់ទៅវិញ ។ ខ្ញុំនិងអ្នកនៅផ្ទះជិតខាងរីករាយយ៉ាងខ្លាំងដោយគិតថា សង្គ្រាមបានបញ្ចប់ហើយ ដោយខ្ញុំបានឈរមើលទាហានខ្មែរក្រហមដែលដើរនៅលើផ្លូវមុខផ្ទះ រួចលើកដៃអបអរសាទរ ។

ម៉ោង១១ថ្ងៃត្រង់ សំឡេងគ្រាប់កាំភ្លើងបានផ្ទុះនៅផ្ទះលោក តាន់ គីមហួន (ប្រធានរដ្ឋសភា) ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្ទះរបស់ខ្ញុំ ចំណែកនៅមុខផ្ទះរបស់ខ្ញុំក៏មានទ័ពខ្មែរក្រហមម្នាក់បានភ្ជង់កាំភ្លើងតម្រង់មកចំផ្ទះរបស់ខ្ញុំ រួចស្រែកបញ្ជាឲ្យចេញជាបន្ទាន់ ។

ដោយប្រញាប់ប្រញាល់ពេក បងស្រី និងប្អូនស្រីរបស់ខ្ញុំបានលើកជីដូនដាក់លើម៉ូតូរួចបរចេញទៅតាមបណ្តោយផ្លូវនរោត្តម ដើម្បីទៅជួបជុំឪពុកមារបស់ខ្ញុំនៅផ្សារដើមថ្កូវ ។ ចំណែកខ្ញុំនិងក្រុមគ្រួសារបានប្រមូលសម្លៀកបំពាក់ ដ្អក ប្រហុក អំបិល អង្ករ ចានឆ្នាំង ដែលខ្ញុំបានត្រៀមចាប់តាំងពីពេលអាមេរិកបានដកទូតចេញពីភ្នំពេញ យកទៅដាក់នៅលើរទេះម៉ូតូតូចៗ និងលើកកូនតូចទាំង៤នាក់របស់ខ្ញុំដាក់ពីលើថែមទៀត ដែលប្អូនប្រុសខ្ញុំជាអ្នកអូស ។ ពេលខ្ញុំចាកចេញពីផ្ទះដោយធ្វើដំណើរតាមផ្លូវត្រសក់ផ្អែម ផ្សារបឹងកេងកង មកដល់មុខបន្ទាយ អ៊ិត សួង (បច្ចុប្បន្នស្ថានទូតវៀតណាម) ខ្មែរក្រហមម្នាក់បានស្នើសុំម៉ូតូពីប្តីរបស់ខ្ញុំ ដោយហុចគ្រាប់បែកគំរាមខ្ញុំក៏ឲ្យយកម៉ូតូទៅទាហាននោះ ដោយ

និយាយបន្ថែមថាខ្ទីជិះមួយរយៈ ។ ខ្ញុំនិងក្រុមគ្រួសារបានបន្តដំណើរទាំងកណ្តាលថ្ងៃត្រង់មកដល់ផ្ទះមារបស់ខ្ញុំនៅផ្សារដើមថ្កូវ ចំណែកបងស្រីរបស់ខ្ញុំដែលដឹកជីដូនមិនទាន់មកដល់ទេ ។

នៅព្រឹកថ្ងៃបន្ទាប់ គ្រួសារខ្ញុំនិងគ្រួសារឳពុកមាខ្ញុំបានសម្រេចចិត្តចាកចេញពីផ្ទះដោយមិនអាចរង់ចាំជីដូនទៀតបានទេ ព្រោះខ្មែរក្រហមបានបង្ខំឲ្យចេញពីផ្ទះជាបន្ទាន់ ។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរតាមផ្លូវរោងចក្រកែវនិងសម្រាកនៅតាមផ្លូវអស់ជាច្រើនយប់ទើបទៅដល់ព្រំប្រទល់ខេត្តកណ្តាល និងខេត្តតាកែវ ។ នៅតាមផ្លូវមានសាកសពខ្លះគ្របស្លឹកឈើពីលើ ចំណែកសាកសពទាហានដែលត្រូវគ្រាប់ស្លាប់មានសភាពស្អុយរលួយនិងនារីដែលមានផ្ទៃពោះមួយចំនួនបានសម្រាលកូននៅតាមផ្លូវ ។ ចំណែកគ្រួសារខ្ញុំមានសមាជិកច្រើន មានកង់និងរទេះម៉ូតូមួយសម្រាប់ដឹកអីវ៉ាន់ និងកូនតូចៗ ។ កូនខ្ញុំដែលទើបនឹងកើតនៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានយកមកចងនឹងក្រមារស្ពាយ ។ នៅពេលមកដល់វត្តភ្នំចចក គ្រួសារខ្ញុំបានសម្រាកនៅទីនោះ១សប្តាហ៍ ព្រោះយើងចង់ត្រឡប់មករស់នៅក្នុងស្រុកកំណើតគឺភូមិគោកត្របវិញ ។ ព្រះសង្ឃក្នុងវត្តត្រូវខ្មែរក្រហមចាប់បង្ខំឲ្យសឹកទាំងអស់ ។ មួយរយៈក្រោយមក ខ្មែរក្រហមបានអនុញ្ញាតខ្ញុំចូលមករស់នៅក្នុងភូមិវិញ ។ ពេលមកដល់ ខ្ញុំបានឃើញប្រជាជនមួយចំនួនបានស្លាប់ដោយសារជាន់មីន ព្រោះភូមិខ្ញុំស្ថិតនៅត្រង់ចំណុចខ្សែត្រៀមទីក្រុងភ្នំពេញ ។ គ្រួសារខ្ញុំបានរស់នៅក្នុងសាលាសំណាក់តូចមួយរង់ចាំគណៈភូមិសង់ខ្ទមរួច ។ កន្លះខែក្រោយមក ខ្ទមធ្វើពីឈើដែលបានមកពីការរុះរើផ្ទះចាស់ៗ (ផ្ទះកំណើតរបស់ខ្ញុំ) បានសង់រួចរាល់ ខ្មែរក្រហមក៏បានបែងចែកទៅឲ្យគ្រួសារនីមួយៗរស់នៅ ។ ក្រោយពេលយើងចាកចេញពីសាលាសំណាក់ ទើបយើងឃើញសុទ្ធតែគ្រាប់សីវ៉ែនធីណាយ (៧៩) នៅពីក្រោមកន្លែងយើងដេក ។ ផ្ទះដែលអង្គការចែកឲ្យគ្រួសារខ្ញុំស្ថិតនៅលើដីភូមិមួយដែលម្ចាស់ដីប្រុសៗបានស្លាប់ទាំងអស់ នៅសល់តែប្រពន្ធនិងកូនស្រីៗប៉ុណ្ណោះ ។ ទោះបីខ្ញុំដឹងប្រវត្តិទីនេះហើយក៏ដោយ ក៏ខ្ញុំមិនដែលមានការភ័យខ្លាចដែរ ។ ប៉ុន្តែ៣-៤ថ្ងៃក្រោយមក កូនខ្ញុំដែលមានអាយុទើបតែ៣ឆ្នាំហើយតែងតែលោតលេងចុះឡើងលើរានកន្លែងដេកមកដី ស្រាប់តែឈឺជើងនិងឈឺខ្លួនកម្រើកលែងរួច ដោយនឹកដល់ប្រវត្តិដីភូមិនេះ ទើបខ្ញុំសុំប្រធានភូមិមករស់នៅដីកំណើតរបស់ខ្ញុំវិញ ។ គណៈភូមិអនុញ្ញាត ប៉ុន្តែគេមិនបានជួយសង់លំនៅដ្ឋានឲ្យយើងទេ គឺយើងត្រូវដើររកកាប់ដើមសង្កែ ដើមឫស្សីមកធ្វើសសរនិងស្លឹកត្នោតទុំមកបាំងជញ្ជាំងនិងប្រក់ធ្វើដំបូល ។ ខ្ញុំបានរកគ្រូនៅក្នុងភូមិមកព្យាបាលកូនខ្ញុំអស់រយៈពេលមួយខែក៏ឈប់ ព្រោះគាត់ថា "គាត់អស់សមត្ថភាពព្យាបាលហើយ" ។ រយៈពេលមួយខែក្រោយមក មានកូនឈ្លបម្នាក់មានជំងឺដូចកូនខ្ញុំដែរ គេអាចទៅអញ្ជើញលោកគ្រូនៅទន្លេបាទីមកព្យាបាលកូនគេបាន ពេលនោះខ្ញុំក៏ទៅអញ្ជើញលោកគ្រូនោះមកព្យាបាលកូនខ្ញុំតាមវិធីស្តោះ ផ្លុំនិងស្រោចទឹក ។ ពីមួយសប្តាហ៍ទៅមួយសប្តាហ៍កូនរបស់ខ្ញុំចាប់ផ្តើមធូរស្បើយបន្តិចម្តងៗ ហើយបីខែបន្ទាប់ពីព្យាបាលកូនខ្ញុំរួចលោកគ្រូនោះបាត់ខ្លួនរហូត ។

នៅក្នុងភូមិ ខ្ញុំនិងបងស្រីខ្ញុំជាអ្នកដេរខោអាវនឹងម្ជុលដៃឲ្យកម្មាភិបាលភូមិ ចំណែកឳពុកខ្ញុំជាអ្នកវេញខ្សែគោ ។ រដូវភ្លៀងមកដល់ ប្រជាជននៅក្នុងភូមិទាំងអស់បានសម្រុកធ្វើស្រែចាប់តាំងពីព្រលឹម រហូតដល់ពេលព្រលប់ទើបត្រឡប់មកផ្ទះវិញ ។ ខ្ញុំមានការលំបាកយ៉ាងខ្លាំងដោយសារមានកូនតូចៗចំនួនពីរនាក់ ហើយត្រូវចេញទៅស្ទូងឲ្យទាន់ពេលវេលាទៀត ។ នៅពេលខ្ញុំទៅឃឹតម្តងម្កាល គេបានវាស់ដីទុកឲ្យខ្ញុំស្ទូងឲ្យហើយ ដោយមិនអនុញ្ញាតឲ្យនរណាជួយឡើយ ។ ខ្ញុំត្រូវមេក្រុមស្តីបន្ទោសរាល់ថ្ងៃថាធ្វើការយឺត ប៉ុន្តែខ្ញុំខិតខំយ៉ាងខ្លាំង ។ ចំណែករបបអាហារជួនកាលខ្ញុំទទួលបានតែអង្ករមួយកំប៉ុងក្នុងមួយថ្ងៃសម្រាប់មនុស្សមួយនាក់ ហើយពេលខ្លះក៏ទទួលបានពោតជំនួសវិញ ។ ប៉ុន្តែដោយសារប្តីរបស់ខ្ញុំជាកូនកសិករ ពេលសម្រាកពីការងារថ្ងៃត្រង់ គាត់បានចូលព្រៃដីកបានដំឡូងជ្រូក ចាប់ក្តាម ឬបេះស្លឹកឈើមកធ្វើម្ហូប ។

នៅខែកញ្ញា ឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំ និងក្រុមគ្រួសារបងប្អូនជីដូនមួយមួយគ្រួសារទៀតនិងគ្រួសារដែលមិនមានស្រុកកំណើតនៅក្នុងភូមិនេះខ្លះត្រូវខ្មែរក្រហមជម្លៀសចេញពីភូមិ ដោយឲ្យមកចាំជិះឡាននៅផ្សារសៀមរាប ឃុំសៀមរាប (ស្រុកកណ្តាលស្ទឹង) ។ នៅពេលខ្ញុំមកដល់ រថយន្តដែលត្រូវដឹកប្រជាជនបានផ្ទុកមនុស្សពេញអស់ ។ គ្រួសារទាំងអស់ដែលចេញពីភូមិខ្ញុំត្រូវរង់ចាំនៅតាមដងផ្លូវជាតិលេខ២រយៈពេល៤ថ្ងៃ ។ នៅថ្ងៃ

មួយពេលវេងចាំ ខ្ញុំបានជួបមិត្តភក្តិម្នាក់(ជាប្រធាននិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ) គាត់បានស្នើសុំគណៈស្រុកឲ្យគ្រួសារខ្ញុំ និងគ្រួសារបងប្អូនរបស់ខ្ញុំចូលភូមិវិញ រួចហើយបាននាំបងជីដូនមួយរបស់ខ្ញុំឈ្មោះ គុយ ត្រូ មកភ្នំពេញជាមួយ ក្រោយមកបានបាត់ខ្លួនរហូត ។

គ្រួសាររបស់ខ្ញុំបានចូលមករស់នៅក្នុងភូមិវិញ ។ ប្រធានភូមិបានដើរហាមប្រជាជនក្នុងភូមិមិនឲ្យនិយាយរកគ្រួសារខ្ញុំ និងគ្រួសារបងប្អូនជីដូនមួយខ្ញុំទេ ។ ស្អែកឡើង គ្រួសារខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការទៅតាមមុខសញ្ញារៀងៗខ្លួនជាមួយប្រជាជនថ្មីនៅក្នុងភូមិ ។ បងប្អូនទាំងនោះគ្រាន់តែមើលមុខខ្ញុំដោយមិននិយាយអ្វីទាំងអស់ ។

រដូវធ្វើស្រែបានបញ្ចប់ ខ្ញុំត្រូវបានចាត់តាំងឲ្យជាន់អង្ករចាប់តាំងពីព្រឹករហូតដល់ម៉ោង១២ ទើបសម្រាកដាំបាយហូប រួចក៏បន្តធ្វើការរហូតដល់ម៉ោង១០យប់ទៀត ។ ចំណែកប្តីរបស់ខ្ញុំធ្វើការក្នុងក្រុមដាំបន្លែក៏ត្រូវរែកទឹកស្រោចបន្លែមិនដែលមានពេលសម្រាកដែរ ចំណែកកូនតូចៗរបស់ខ្ញុំត្រូវដើរប្រមូលអាចម៍គោ និងកាប់ទន្ទ្រានខែត្រធ្វើជី ។ ពេលសហករណ៍ភូមិបានផលដំឡូងក៏បែងចែកទៅតាមចំនួនមនុស្សក្នុងគ្រួសារនីមួយៗ ចំណែកគ្រួសាររបស់ខ្ញុំទទួលបានត្រឹមតែដំឡូងវល្លិប៉ុណ្ណោះ ដោយដំឡូងមើមធំៗមេៗយកអស់ ។ រហូតមកដល់រដូវស្រូវទុំ យើងសម្រុកប្រូតកាត់ប្រមូលផលពេលថ្ងៃ ហើយពេលយប់ជញ្ជូនកណ្តាប់រហូតដល់ម៉ោង១០ទើបបានត្រឡប់មកផ្ទះវិញ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ នៅក្នុងភូមិចាប់ផ្តើមហូបរួម ដោយខ្មែរក្រហមបានដើរប្រមូលយកចានឆ្នាំងទាំងអស់ ។ នៅពេលនោះ ខ្ញុំត្រូវចាត់តាំងឲ្យទៅស្ទូក (ជួស) ស្រូវដែលមានចម្ងាយប្រមាណ៤-៥គីឡូម៉ែត្រពីភូមិ ដោយត្រូវទូលសំណាបយកទៅដោយខ្លួនឯង ហើយនៅពេលយប់ត្រូវជាន់អង្ករថែមទៀត ។ ចំណែកកូនស្រីខ្ញុំពីរនាក់ដែលមានអាយុទើបតែ៥-៧ឆ្នាំត្រូវប្រមូលយកទៅនៅជិតផ្ទះប្រធានភូមិ ហើយត្រូវធ្វើការងារទប់ភ្លឺស្រែដោយគ្មានពេលសម្រាក ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៦ ប្រុសៗដែលត្រូវចាត់តាំងទៅធ្វើការងារឆ្ងាយៗពីភូមិមិនដែលឃើញវិលត្រឡប់មកវិញទេ ។ ប្អូនស្រី ប្រុស និងក្មួយត្រូវចាត់ចូលកងចល័តយុវជនដែលត្រូវធ្វើប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ លើកទំនប់ ដែលស្ថិតនៅចម្ងាយប្រមាណ៥-៦គីឡូម៉ែត្រពីភូមិ ។

នៅខែ៤ ឆ្នាំ១៩៧៧ ខ្ញុំមានផ្ទៃពោះកូនទី៥ ខ្ញុំមិនអាចហូបសម្លូរត្រកួនបានទេ ខ្ញុំឃ្លានមាន់និងសាច់យ៉ាងខ្លាំង តែមិនហ៊ានលួចឡើយ ព្រោះជារបស់អង្គការ ។ យប់មួយខ្ញុំបានធំក្លិនបបរឈ្ងុយខ្ទឹមលីងចេញពីរោងបាយ ខ្ញុំចង់ទៅសុំគេហូប ប៉ុន្តែប្តីខ្ញុំបានអង្វរកុំឲ្យខ្ញុំទៅសុំគេ ព្រោះខ្លាចគេយកទៅសម្លាប់ ។

នៅខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំបានទទួលដំណឹងថា ប្អូនស្រីខ្ញុំត្រូវអង្គការនាំយកទៅដាក់គុកនៅមន្ទីរសន្តិសុខទន្លេបាទី ដោយសារមូលហេតុប្អូនស្រីខ្ញុំបានសុំផាងត្នោតសម្រាប់វេញខ្សែបគ្គីពីប្រជាជនក្នុងភូមិ ។ ខ្មែរក្រហមបានចោទប្អូនស្រីខ្ញុំថា មកលួចរបស់របរប្រជាជន ។ នៅខែតុលា ឆ្នាំ១៩៧៧ ការដកស្ទូងក្នុងភូមិបានរួចរាល់ហើយ មេភូមិ គណៈឃុំ បានប្រមូលបុរសដែលមានកម្លាំងមាំ ដែលអាចរែកដីបាន និងលីនង្គ័លរួចចំនួនប្រហែល៥០នាក់ ដោយប្រាប់ថាទៅជួយធ្វើស្រែប្រជាជននៅទន្លេបាទី ព្រោះនៅតំបន់នោះប្រជាជនធ្វើស្រែមិនទាន់ហើយ ។ ប្តីរបស់ខ្ញុំមានឈ្មោះទៅដែរ ខ្ញុំបានទាមទារទៅជាមួយប្តី ព្រោះខ្ញុំគិតថាបើស្លាប់ៗទាំងអស់គ្នា ដោយខ្ញុំមិនមានសង្ឃឹមថាប្តីខ្ញុំអាចត្រឡប់មកវិញទេ ។ ប៉ុន្តែប្តីរបស់ខ្ញុំបានពន្យល់ខ្ញុំថា មិនត្រូវទៅជាមួយគាត់ទេ ដោយសារខ្ញុំមានផ្ទៃពោះ ហើយបើស្លាប់មួយប្រសើរជាងស្លាប់ទាំងអស់គ្នា ។ គាត់បាននិយាយទៀតថា របបនេះមិនមានស្ថិរភាពយូរទេ ថ្ងៃណាមួយនឹងមានគេមករំដោះ ហើយបើម្តាយនៅរស់ កូននឹងមានអនាគតទៅថ្ងៃមុខ ។ ខ្ញុំស្តាប់តាមសម្តីរបស់ប្តីខ្ញុំ ខ្ញុំលួចយំនៅក្នុងផ្ទះ ខ្ញុំមិនបានជូនដំណើរប្តីទេ ខ្ញុំឲ្យប្តីខ្ញុំ ពាក់ខោ-អាវពីរជាន់ និងក្រមាដើម្បីការពារខ្យល់រងា ។ នៅពេលប្តីខ្ញុំចេញទៅបាត់ គ្រួសារខ្ញុំបានយំទាំងអស់គ្នាដោយមិនហ៊ានឲ្យគេឃើញឡើយ ។ ប៉ុន្តែនៅពេលមេក្រុមឃើញភ្នែកខ្ញុំក្រហម ក៏ស្តីបន្ទោសថា គិតអីគ្រាន់តែប្តីទៅជួយធ្វើការអ្នកនៅទន្លេបាទី ។ ថ្ងៃមួយកូនប្រធានភូមិបានប្រាប់កូនខ្ញុំថា ឪពុកឯងត្រូវគេយកទៅសម្លាប់បាត់ហើយ ។ បន្ទាប់ពីឮដំណឹងនេះ ខ្ញុំមានអារម្មណ៍ឈឺចាប់ និងអាណិតប្តីខ្លាំងណាស់ ។ ខ្ញុំយំនិងនឹកឃើញប្តីរហូត ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៨ មុនពេលសម្រាលកូន ខ្ញុំត្រូវបញ្ជូនឲ្យទៅនៅក្នុងមន្ទីរពេទ្យវង់ចាំឆ្លងទន្លេ ខ្ញុំទទួលបានរបបបបរតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ខ្ញុំបានសម្រាលកូននៅមន្ទីរពេទ្យ ប៉ុន្តែគ្មានគ្រូពេទ្យជួយទេ ហើយត្រូវបង្កាត់ភ្លើងឆ្អើរខ្លួនដោយខ្លួនឯង ។ បន្ទាប់ពីសម្រាលកូនរួច អង្គការបានបួរឲ្យខ្ញុំហូបបាយវិញ ។

ព្រឹកឡើង ខ្ញុំបានផ្តាំទៅម្តាយរបស់ខ្ញុំ ម្តាយខ្ញុំក៏បានសុំច្បាប់មកមើលខ្ញុំ ប៉ុន្តែត្រូវប្រធានគណៈឃុំបដិសេធ ប៉ុន្តែម្តាយខ្ញុំមិនបានស្តាប់ទេ ថែមទាំងនាំកូនស្រីទីពីររបស់ខ្ញុំមកជាមួយផង ។ ខ្ញុំបានប្រាប់ឲ្យម្តាយខ្ញុំត្រឡប់ទៅវិញព្រោះខ្លាចអង្គការដាក់ទោសគាត់ ដោយសូមឲ្យគាត់ទុកតែកូនស្រីឲ្យនៅជាមួយមើលខ្ញុំប៉ុណ្ណោះ ។ កូនខ្ញុំបានជួយបង្កាត់ភ្លើងនិងបោកគក់កន្ទបប្អូន ។ ថ្ងៃមួយ ខ្ញុំបានប្រាប់ពេទ្យថា បាយ៣វែកខ្ញុំហូបមិនឆ្អែតទេ ពេទ្យក៏បានបន្ថែមបាយមួយចំនួនទៀត ។ រយៈពេល៥ថ្ងៃក្រោយមក ខ្ញុំបានសុំពេទ្យត្រឡប់មកផ្ទះវិញ ដោយដើរចម្ងាយផ្លូវ៥គីឡូម៉ែត្រ ។ បន្ទាប់ពីខ្ញុំមកដល់ផ្ទះបានមួយសប្តាហ៍ កូនរបស់ខ្ញុំកើតបូសមួយយ៉ាងធំនៅត្រង់ចង្កេះ ហើយកាន់តែមានសភាពឈឺខ្លាំង និងគ្មានថ្នាំព្យាបាល ខ្ញុំក៏សម្រេចចិត្តទៅមន្ទីរពេទ្យម្តងទៀត ។ នៅទីនោះ ដោយសារពេទ្យមិនមានមធ្យោបាយព្យាបាលដែរនោះក៏ទុកឲ្យបូសធ្លាយខ្លួនឯង ខ្ញុំក៏យកស្លឹកពង្រទុំទំពាឲ្យម៉ត់ រួចបិទពីលើបូសរបស់កូនខ្ញុំ ហើយក៏ត្រឡប់មកភូមិវិញ ។

រយៈពេល៣សប្តាហ៍ក្រោយមក មេភូមិបានចាត់តាំងឲ្យខ្ញុំមើលទារកនិងដេរស្លឹកត្នោតចំនួន៤០កណ្តុបក្នុងមួយថ្ងៃរហូតធ្លាក់ខ្លួនឈឺ ។ បន្ទាប់មក ខ្ញុំក៏ត្រូវចាត់តាំងឲ្យគាស់ដើមចេញ ៤០ដើមក្នុងមួយថ្ងៃយកទៅដាំ ។ ខ្ញុំធ្វើការនេះបានរយៈពេល ២ថ្ងៃក៏ចាប់ផ្តើមរាក និងក្អួត ប្រធានភូមិបានរកថ្នាំបុសឈើឲ្យផឹក និងអនុញ្ញាតឲ្យសម្រាកមួយរយៈ ។ ក្រោយពីបានធូស្បើយពីជំងឺ ខ្ញុំត្រូវប្រធានភូមិចាត់តាំងឲ្យដេរស្លឹកនិងត្បាញកន្ទេលស្លឹកត្នោត ព្រោះគាត់យល់ថាជាការងារស្រាល ។

នៅខែមេសា ឆ្នាំ១៩៧៨ គណៈឃុំបានប្រកាសលើកលែងទោសចំពោះប្រជាជនទាំងអស់ ប៉ុន្តែការងារនៅតែបន្តធ្វើដដែល ហើយមិនឲ្យត្រឡប់មកផ្ទះនៅពេលថ្ងៃត្រង់ទេ ។ នៅពេលយប់ អង្គការបានកេណ្ឌប្រជាជនទាំងអស់នៅក្នុងភូមិឲ្យជីកស្រះធំមួយថែមទៀត ។

នៅពេលល្ងាចថ្ងៃមួយ ពេលខ្ញុំកំពុងវាស់ចំនួនផ្ទៃដីដែលបានច្រូតកាត់ដើម្បីរាយការណ៍ទៅថ្នាក់លើ ស្រាប់តែខ្ញុំឃើញមនុស្សរត់លើខ្នងប្រឡាយទៅទិសខាងលិច ហើយគណៈឃុំនិងមេភូមិទាំងអស់ក៏បាត់ពីភូមិដែរ ។ មកដល់ផ្ទះ ម្តាយខ្ញុំបានប្រមូលកូនទាំងអស់របស់ខ្ញុំមកជុំគ្នា ហើយពេលនោះ បងស្រី ប្អូនប្រុស និងក្មួយរបស់ខ្ញុំទាំងអស់ក៏មកជុំគ្នាដែរ ម្តាយខ្ញុំបានទៅយកឆ្នាំងមួយសម្រាប់ទុកដាំបាយហូប ប៉ុន្តែយើងមិនបានចេញពីភូមិទេ ។

នៅចុងខែមករា ឆ្នាំ១៩៧៩ គណៈឃុំ មេភូមិបានត្រឡប់មកវិញដោយមានកាន់កាំបិតផ្កាក់មកដេញប្រជាជនចេញពីភូមិ ។ គ្រួសារខ្ញុំបានធ្វើដំណើរមកទិសអាគ្នេយ៍ក៏ជួបនឹងយោធាខ្មែរក្រហមដែលរត់ចេញពីតាខ្មៅ ។ យោធាទាំងនោះបានកៀរប្រជាជនមួយចំនួន ប៉ុន្តែគ្រួសារខ្ញុំមិនបានទៅជាមួយទេ ព្រោះឪពុកមាខ្ញុំនិងកូនស្រីខ្ញុំគ្រុនក្តៅ ដូច្នេះយើងបានដេកនៅវាលបឹងមួយយប់ ។ ព្រឹកឡើង ខ្ញុំនិងគ្រួសារបានដើរសំដៅមកផ្លូវជាតិលេខ២ រួចធ្វើដំណើរចូលមកតាខ្មៅ ។ នៅខែឧសភា ឆ្នាំ ១៩៧៩ ខ្ញុំបានមករស់នៅក្នុងសាលាបឋមសិក្សាផ្សារដើមថ្កូវ និងធ្វើជាគ្រូបង្រៀននៅទីនោះ ដោយទទួលបានរបបអង្ករពីរដ្ឋបន្តិចបន្តួចសម្រាប់ចិញ្ចឹមកូន ។ ក្រោយមក ដោយមានការខិតខំប្រឹងប្រែងធ្វើការងារ និងរៀនបន្ត ខ្ញុំបានប្រឡងជាប់គ្រូកម្រិតមធ្យមសិក្សា និងនៅឆ្នាំ១៩៩៧ខ្ញុំប្រឡងជាប់ជាអធិការមធ្យមសិក្សា និងគ្រូបង្គោលថ្នាក់ជាតិនៅពេលបច្ចុប្បន្ននេះ ។

អស់រយៈពេលជាង៤០ឆ្នាំមកហើយដែលខ្ញុំធ្វើជាគ្រូបង្រៀន ធ្វើឲ្យខ្ញុំកាន់តែមិនអាចបំភ្លេចរឿងរ៉ាវរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហមបាន ។ ខ្ញុំយំនៅពេលខ្ញុំរំឭករឿងនេះឡើង ប៉ុន្តែខ្ញុំបានខិតខំពុះពារការលំបាក និងកែប្រែកំហឹងនិងការឈឺចាប់ចំពោះការស្លាប់ប្តីរបស់ខ្ញុំនិងប្អូនស្រីទៅជាការខិតខំប្រឹងប្រែងធ្វើការងាររហូតចិញ្ចឹមកូនទាំង៥នាក់របស់ខ្ញុំឲ្យបានរៀនចប់បរិញ្ញាប័ត្រគ្រប់គ្នា ។ ខ្ញុំបានបង្រៀនក្មេងជំនាន់ក្រោយជាច្រើនជំនាន់ឲ្យយល់ដឹងពីប្រវត្តិខ្មែរក្រហម ប៉ុន្តែខ្ញុំបានអប់រំគេមិនឲ្យមានការសងសឹកនិងចេះសាមគ្គីគ្នា ។ **សោម ប៊ុនថន**

# អ្នកគ្រូ បែន នាង : បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

បែន នាង គឺជាគ្រូបង្គោលថ្នាក់ជាតិដែលបានចូលរួមនៅក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ឪពុករបស់ បែន នាង ជាមន្ត្រីរាជការម្នាក់ដែលធ្វើការនៅសាលាខេត្តបាត់ដំបង នៅក្នុងរបបលន់ នល់ ។ នៅក្នុងរបបខ្មែរក្រហម ឪពុករបស់ បែន នាង ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ដែលបានប្រាប់ការពិតទៅអង្គការ រហូតធ្វើឲ្យឈ្មោះរបស់គាត់ស្ថិតនៅក្នុងបញ្ជីខ្មៅក្នុងការតាមដានរបស់អង្គការថែមទៀត ។ ដូច្នេះ រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ គ្រួសាររបស់ បែន នាង ស្ថិតនៅក្នុងសភាពភ័យខ្លាចរហូត ដោយសារតែខ្មែរក្រហមមានការតឹងតែងចំពោះគ្រួសារគាត់ជាងគ្រួសារដទៃទៀត ។ តើខ្មែរក្រហមធ្វើបែបណាចំពោះគ្រួសារ បែន នាង?

ចាប់តាំងពីគ្រួសាររបស់ បែន នាង ដែលមានសមាជិកចំនួន៨នាក់ (ឪពុកម្តាយ គាត់ និងបងប្រុសម្នាក់) ផ្លាស់មករស់នៅភូមិចម្ការសំរោង២ ឃុំចម្ការសំរោង ស្រុកបាត់ដំបង (ទីរួមខេត្ត) ខេត្តបាត់ដំបងវិញ ឪពុករបស់គាត់គឺជាមន្ត្រីម្នាក់ធ្វើការនៅសាលាខេត្តបាត់ដំបង ចំណែកម្តាយជាអ្នកលក់ដូរម្នាក់ ។ បែន នាង នៅចាំបានថា មុនឆ្នាំ១៩៧៥ ប៉ុន្មានថ្ងៃដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ភូមិចម្ការសំរោង២មានសភាពច្របូកច្របល់ជាខ្លាំង ដោយមានឮតែសំឡេងគ្រាប់កាំភ្លើងផ្ទុះឡើងជាច្រើនគ្រាប់ ។ រំលងបានពីរ-បីថ្ងៃ ឪពុកម្តាយរបស់ បែន នាង ក៏ប្រាប់ថា ខ្មែរក្រហមឲ្យគ្រួសាររបស់គាត់ចាកចេញពីផ្ទះក្នុងរយៈពេលបីថ្ងៃ ។ បន្ទាប់មក គ្រួសាររបស់ បែន នាង ព្រមទាំងប្រជាជននៅក្នុងភូមិទាំងអស់គ្នាក៏ចាប់ផ្តើមរៀបចំអីវ៉ាន់ដើម្បីធ្វើដំណើរទៅតាមទិសដៅរបស់អង្គការដែលកំណត់ឲ្យ ។ ស្នាក់នៅភូមិអណ្តូងចេញប្រហែលជាពីរយប់ គ្រួសាររបស់ បែន នាង ក៏បានមកដល់ភូមិក្រួសនៅវេលាល្ងាច (តំបន់៣) ដែលនៅទីនេះប្រជាជនរាប់រយគ្រួសារត្រូវកាប់ឆ្ការព្រៃទាំងយប់ ដើម្បីយកកន្លែងស្នាក់នៅមួយយប់សិន ។ ព្រលឹមឡើង ទើបប្រជាជនទាំងអស់ចាប់ផ្តើមដើររកឈើដើម្បីសង់ខ្ទម ហើយខ្ទមនីមួយៗតម្រូវឲ្យមានចម្ងាយឆ្ងាយពីគ្នាប្រហែលមួយម៉ែត្រ ។ បន្ទាប់មកខ្មែរក្រហមបានប្រកាសឲ្យប្រជាជនយករបស់របរដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនទៅដាក់រួមនិងតម្រូវឲ្យហូបរួមទាំងអស់គ្នានៅសហករណ៍ ដែលស្ថិតនៅចម្ងាយប្រហែល៤-៥ម៉ែត្រពីផ្ទះរបស់គាត់ ។ ប៉ុន្មានខែក្រោយមក ខ្មែរក្រហមក៏ចាប់ផ្តើមបំបែកសមាជិកគ្រួសាររបស់ បែន នាង ឲ្យរស់នៅដាច់ឆ្ងាយពីគ្នាទៀត ដោយគាត់ចូលកងកុមារ បងប្រុសចូលក្នុងអង្គភាពកងចល័ត ចំណែកឪពុកនៅសមរភូមិមុខ និងម្តាយនៅសមរភូមិក្រោយ ។ ដោយសារតែពេលនោះ បែន នាង នៅក្មេងពេក ធ្វើការបានតែមួយថ្ងៃប៉ុណ្ណោះ អង្គការក៏ឲ្យគាត់នៅជាមួយកងយាយៗវិញ ។ បន្ទាប់មកគ្រួសាររបស់ បែន នាង ស្ថិតនៅក្នុងការតាមដានរបស់អង្គការទៀត ដោយសារតែឪពុករបស់គាត់ប្រាប់ការពិតទៅអង្គការថា គាត់ជាមន្ត្រីធ្វើការនៅសាលាខេត្តបាត់ដំបង ។


អ្នកគ្រូ បែន នាង

មិនយូរប៉ុន្មាន អង្គការក៏ផ្លាស់ម្តាយរបស់ បែន នាង ឲ្យនៅសមរភូមិមុខ ចំណែកឪពុកនៅសមរភូមិក្រោយវិញ ។ ពេលនោះអ្នកជិតខាងដែលធ្វើការជាមួយគាត់បានខ្សឹបប្រាប់ឪពុកម្តាយរបស់គាត់ថា

កាលណាផ្លាស់ចុះផ្លាស់ឡើង ដោយយកកម្លាំងទីមួយ (មនុស្សប្រុស) ដូរយកកម្លាំងទីពីរ (មនុស្សស្រី) ប្រហែលជាថ្ងៃណាមួយអង្គការនឹងយកទៅសម្លាប់ហើយ ។ បែន នាង និយាយទាំងស្រក់ទឹកភ្នែកថា «អ៊ីចឹងហើយបានជាឪពុករបស់ខ្ញុំ តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច និងមិនដែលធ្វើអ្វីដែលអាចឲ្យអង្គការចាប់កំហុសឡើយ» ។ ការងារនៅសមរភូមិត្រូវធ្វើការសម្រុកខ្លាំង និងហូបមិនបានគ្រប់គ្រាន់ទេ ដូច្នេះម្ដាយរបស់ បែន នាង ក៏ធ្លាក់ខ្លួនឈឺ ។ ឃើញដូច្នេះ បែន នាង បានទៅរោងម៉ាស៊ីនកិនស្រូវដើម្បីលួចអង្ករហើយទៅដាំបបរឲ្យគាត់ហូប ។

ក្រោយពីជាសះស្បើយពីជំងឺ ដល់ពេលដែលអង្គការបានធ្វើបុណ្យមួយ ហើយអនុញ្ញាតឲ្យប្រជាជនទាំងអស់អាចធ្វើដំណើរឆ្លងពីភូមិមួយទៅភូមិមួយទៀតបាន ។ ឆ្លៀតឱកាសនោះម្ដាយរបស់ បែន នាង បានសម្រេចចិត្តនាំគាត់ទៅរកឪពុករបស់គាត់នៅកន្លែងធ្វើការ ដោយយកពោតលីងដែលបុកជាមួយចេកទៅញាត់ចូលក្នុងកំប៉ុងហ្គីហ្គោផ្ញើគាត់ផងដែរ ។ ពេលទៅដល់ បែន នាង និងម្ដាយរបស់ខ្លួនអាណិតឪពុកជាខ្លាំង ព្រោះខ្មែរក្រហមបានបង្ខំឲ្យគាត់ធ្វើការទាំងជើងរបស់គាត់មានដំបៅផងស្ទើរតែដើរមិនរួច ។ «ទោះបីជាមានមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺ ប៉ុន្តែខ្មែរក្រហមមិនបានអនុញ្ញាតឲ្យឪពុករបស់ខ្ញុំឈប់សម្រាកនិងបញ្ជូនគាត់ទៅព្យាបាលឡើយ» ។

ក្រោយពីបានសួរសុខទុក្ខរួច និងត្រឡប់មកដល់កងវិញ ខ្មែរក្រហមបានបញ្ជូនឪពុកម្ដាយរបស់ បែន នាង ទៅសមរភូមិមុខជាមួយគ្នាវិញ ចំណែកបងប្រុសឲ្យមកធ្វើការនៅភូមិ ដោយមានភារកិច្ចចិញ្ចឹមទា ។ ចូលដល់បុណ្យ១៧ មេសា ខ្មែរក្រហមក៏អនុញ្ញាតឲ្យម្ដាយរបស់ បែន នាង ត្រឡប់មកលំនៅឋានដើម្បីជួបបងប្រុសវិញ ។ ប៉ុន្តែពេលមកដល់ ឪម្ដាយរបស់ បែន នាង ទើបដឹងថាបងប្រុសរបសគាត់កើតដំបៅជើងដើរមិនរួចរហូតត្រូវអង្គការបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ។ ដោយសារមិនសូវរឹតបន្តឹងខ្លាំង អង្គការក៏អនុញ្ញាតឲ្យម្ដាយរបស់ បែន នាង និងគាត់ទៅសួរសុខទុក្ខដល់មន្ទីរពេទ្យ ។ នៅទីនោះ បែន នាង ឃើញបងប្រុសរបស់គាត់ដើរមិនបានទេ បានត្រឹមតែរំកិលគូថទៅមុខប៉ុណ្ណោះ ។ ចំណែកថ្នាំសម្រាប់ព្យាបាលជំងឺគាត់មានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ។ ឥឡូវនេះដំបៅនោះបានបន្សល់ស្លាកស្នាមនៅលើជើងរបស់គាត់រហូតមកដល់សព្វថ្ងៃនេះ ។

ថ្ងៃមួយ ឪពុករបស់ បែន នាង ត្រូវបានបញ្ជូនឲ្យទៅកាប់ព្រៃនៅអូរពងមាន់ ។ ឪពុករបស់ បែន នាង បានរៀបរាប់ពីព្រឹត្តិការណ៍ថ្ងៃនោះថា គាត់សំណាងណាស់ដែលមិនបានប្រឆាំងនឹងបញ្ជារបស់អង្គការ ព្រោះទោះបីជាគាត់ឈឺស្ទើរតែងើបមិនរួចក៏ដោយ ក៏គាត់នៅតែទៅកាប់ព្រៃដែរ ។ ចំណែកអ្នកដែលអវត្តមាននៅយប់នោះ ខ្មែរក្រហមបានយកអ្នកទាំងនោះបណ្ដើរកាត់មុខរបស់ បែន នាង ទៅសម្លាប់ចោលទាំងអស់ ។ ហេតុការណ៍នេះបានធ្វើឲ្យគ្រួសាររបស់ បែន នាង ភ័យខ្លាចជាខ្លាំង ព្រោះមិនដឹងថាថ្ងៃណាខ្មែរក្រហមយកគាត់ទៅសម្លាប់បែបនេះដែរទេ ។

នៅទីនេះ ការហូបចុកមិនដែលគ្រប់គ្រាន់ទេ ។ ដូច្នេះ បែន នាង បានចូលទៅលួចល្ពៅជាមួយក្មេងដទៃទៀតក្នុងភូមិ ។ ខណៈពេលនោះ បែន នាង ហាក់ដូចដូចជាបាត់ស្មារតីអស់រលីង ព្រោះពេលដែលគាត់លួចបានល្ពៅមួយលាក់នៅក្នុងថ្នក់សំពត់ស្រាប់តែកងទ័ពខ្មែរក្រហមមកទាន់ ។ ប៉ុន្តែសំណាងណាស់ដែលខ្មែរក្រហមមើលមិនឃើញ ។ ពេលមកដល់ផ្ទះ បែន នាង បានយករឿងលួចនេះទៅប្រាប់ឪពុកម្ដាយរបស់គាត់ ។ ប៉ុន្តែ ឪពុករបស់ បែន នាង ជាមនុស្សស្មោះត្រង់ គាត់ក៏ចាប់ បែន នាង ទៅសារភាពពីទោសកំហុសរបស់ខ្លួននៅចំពោះមុខអង្គការ ។ ដោយសារតែ បែន នាង យកដៃទាំងពីរឱបសសរជាប់បដិសេធមិនទៅ គាត់បានបញ្ជាឲ្យយកល្ពៅនោះទៅឲ្យក្មេងដែលលួចជាមួយគ្នាវិញ ។ «ខ្ញុំស្ដាយល្ពៅនោះជាខ្លាំង ព្រោះបានត្រឹមតែលួច មិនបានហូប» ។ ប៉ុន្មានខែក្រោយមក ពេលផ្លាស់មកធ្វើការនៅភូមិមួយទៀត បែន នាង ក៏បានលួចបេះផ្លែញ្ញោហូបទៀត ។ លើកនេះ អង្គការមិនបានដឹងនោះទេ ប៉ុន្តែ បែន នាង បែរជាធ្វើឲ្យម្ដាយរបស់ខ្លួនព្រួយបារម្ភចំពោះគាត់ទៅវិញ ព្រោះគាត់បាត់ដំណឹងរហូតដល់ពេលរសៀលទើបត្រឡប់មកវិញ ។ ពេលមកដល់ផ្ទះ ម្ដាយរបស់ បែន នាង បានវាយគាត់ជាច្រើនរំពាត់ ។

នៅឆ្នាំ១៩៧៨ បែន នាង បានឃើញហេតុការណ៍មួយដែលធ្វើឲ្យគាត់មិនអាចបំភ្លេចបានរហូតដល់សព្វថ្ងៃ ។ បែន នាង នៅចាំបានថា ខ្មែរក្រហមចាប់បានស្ត្រីពីរនាក់និងបុរសម្នាក់ដែល

លួចរត់មករស់នៅតំបន់៣នេះដោយចោទថាខុសសីលធម៌ ។ នៅថ្ងៃបន្ទាប់ ខ្មែរក្រហមបានហៅប្រជាជនទាំងអស់នៅក្នុងភូមិទៅប្រជុំនៅសហករណ៍រួម ដើម្បីកុំឲ្យប្រជាជនឯទៀតយកគំរូតាម ។ ពេលនោះ ម្តាយរបស់ បែន នាង បានរៀបរាប់ថា អ្នកទាំងបីត្រូវខ្មែរក្រហមចងស្លាបសេកដោយខ្សែពណ៌ខៀវនៅឡើយ ដែលបញ្ជាក់ថាខ្មែរក្រហមមិនសម្លាប់អ្នកបីនាក់ចោលទេ ។ ប៉ុន្តែក្រោយពីប្រជុំចប់ អ្នកទាំងបីត្រូវបានចងស្លាបសេកដោយខ្សែពណ៌ក្រហមវិញ(ត្រូវយកទៅសម្លាប់) ។ ក្រោយមក ពូទូច ដែលជាអ្នកបណ្តើរមនុស្សយកទៅសម្លាប់(ធ្លាប់វះពោះមនុស្សយកថ្លើម) និងដែលរាប់អានជាមួយម្តាយរបស់គាត់បានប្រាប់ថា អ្នកទាំងបីត្រូវយកទៅសម្លាប់ហើយ ដោយឲ្យជីករណ្តៅខ្លួនឯង ។ ពូទូច ក៏បានរៀបរាប់បន្ថែមថា នៅពេលដែលយកមនុស្សទៅសម្លាប់ គេតែងតែកាច់មែក-គឲ្យគាត់កាន់ទៅផ្ទះវិញ ដែលមានន័យថា ពេលត្រឡប់មកផ្ទះវិញឲ្យធ្វើគ ធ្វើថ្លង់ ។

ប្រហែលនៅដើមឆ្នាំ១៩៧៩ មុនពេលវៀតណាមចូលមករំដោះ បែន នាង បានឃើញយន្តហោះ និងកងទ័ពអាវខ្មៅជិះសេះចូលភូមិ ។ បន្ទាប់មក បែន នាង បានឮមេកងជដែកគ្នាថា មានខ្មាំងចូលបង្កប់ ប្រសិនបើបានឃើញឲ្យជួបប្រាប់ផង បើមិនអ៊ីចឹងទេខ្មាំងនឹងសម្លាប់យើងមិនខាន ។ ព្រឹត្តិការណ៍នៅពេលនោះ បែន នាង បានឮឪពុកម្តាយរបស់គាត់ពិភាក្សាគ្នាថា «បើយើងមិនគេចខ្លួនទេ ខ្មែរក្រហមនឹងកៀរយើងយកទៅសម្លាប់ហើយ» ។ មិនយូរប៉ុន្មាន កងទ័ពខ្មែរក្រហមក៏បាក់ទ័ពរត់ចូលព្រៃអស់ ។ បន្ទាប់មកប្រជាជនទាំងអស់បាននាំគ្នាឈប់ធ្វើការ រួចធ្វើដំណើរត្រឡប់មកលំនៅឋានរៀងៗខ្លួនវិញ ។ ធ្វើដំណើរមកដល់ថ្មគោល គ្រួសាររបស់ បែន នាង ក៏ឈប់សម្រាកនៅទីនោះមួយយប់ ។ ដូចដែលឪពុកម្តាយបានគិតមែន គ្រួសាររបស់ បែន នាង ក៏បានទទួលដំណឹងថា អ្នកដែលស្នាក់នៅភូមិអន្លង់វុនមិនបានបន្តដំណើរទៅមុខគឺត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់ ។ នៅតាមផ្លូវជាតិលេខ៥ ទៅកាន់ភូមិចម្ការសំរោង គ្រួសាររបស់ បែន នាង បានឃើញសាកសពស្អុយរលួយជាច្រើននៅតាមដងផ្លូវ ។

ពេលមកដល់ភូមិ ផ្ទះរបស់ បែន នាង មានប្រជាជនផ្សេងទៀតចូលមករស់នៅចំនួនបួនគ្រួសារ ។ ប៉ុន្តែមួយរយៈក្រោយមក ផ្ទះនេះនៅតែគ្រួសាររបស់ បែន នាង ប៉ុណ្ណោះ ព្រោះបីគ្រួសារទៀតបានបន្តដំណើរទៅប្រទេសទីបីអស់ហើយ ។ ក្រោយពីប្រទេសរៀបចំបានត្រឹមត្រូវហើយ ឪពុករបស់ បែន នាង ត្រូវបានជ្រើសរើសឲ្យធ្វើជាអនុប្រធានសង្កាត់នៅភូមិចម្ការសំរោង២ ឃុំចម្ការសំរោង ស្រុកបាត់ដំបង (ទីរួមខេត្ត) ខេត្តបាត់ដំបង ។

នៅឆ្នាំ១៩៩០ បែន នាង បានប្រឡងបាក់ឌុបជាប់នៅវិទ្យាល័យមុនីវង្ស រួចបន្តការសិក្សាផ្នែកអក្សរសាស្ត្រខ្មែរនៅសកលវិទ្យាល័យភ្នំពេញ ។ បែន នាង ចូលចិត្តមុខវិជ្ជានេះជាខ្លាំងពីព្រោះគាត់ចូលចិត្តអានច្រើន ។ ក្រោយពីរៀនចប់នៅសាកលវិទ្យាល័យភ្នំពេញ បែន នាង បានចេញទៅបង្រៀននៅវិទ្យាល័យនេតយ៉ង់ ខេត្តបាត់ដំបងវិញ ។ មួយឆ្នាំក្រោយមក បែន នាង បានផ្លាស់មកធ្វើការនៅវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ (សព្វថ្ងៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា) ដោយកាន់ផ្នែកបណ្ណាល័យ ។ មួយរយៈក្រោយមក បែន នាង ក៏ប្តូរមកធ្វើការផ្នែកការិយាល័យស្រាវជ្រាវ និងវាយតម្លៃ ។ ការងារទាំងនេះមានការលំបាកជាងការងារមុនបន្តិច ព្រោះត្រូវលើកគម្រោងចុះធ្វើតេសតាមសាសាដោយសរសេរជាអត្ថបទ ឬកម្រងសំណួរដើម្បីសរសេររបាយការណ៍អំពីចំណុចខ្លាំង និងចំណុចខ្សោយ (ទាក់ទងគ្រូនិងសិស្សអំពីកម្មវិធីសិក្សារបស់សាលា) ។ លើសពីនេះទៅទៀត បែន នាង ត្រូវនិពន្ធសៀវភៅសម្រាប់បង្រៀនសិស្សរាល់ថ្ងៃទៀត ។

ពេលក្លាយជាគ្រូបង្គោលថ្នាក់ជាតិ បែន នាង សប្បាយចិត្តជាខ្លាំងដែលបានចូលរួមផ្សព្វផ្សាយឲ្យក្មេងជំនាន់ក្រោយបានដឹងថារបបខ្មែរក្រហមពិតជាកើតមានឡើងមែន ។ បែន នាង យល់ថា ការដាក់បញ្ចូលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីសិក្សារបស់សិស្សនៅតាមសាលាគឺពិតជាមានលក្ខណៈល្អប្រសើរ ព្រោះវាជាការញ្ញាក់ស្មារតីក្មេងឲ្យដឹងថារបបខ្មែរក្រហមបានសម្លាប់ជីវិតប្រពលរដ្ឋខ្មែរអស់ប្រហែលជិតពីរលាននាក់ ។ បែន នាង ជឿជាក់ថា កម្មវិធីនេះមានសារសំខាន់ជាខ្លាំង ព្រោះវាពាក់ពាក់ព័ន្ធនឹងអនាគតរបស់ប្រទេស ។ «កាលណាក្មេងយល់ដឹងច្រើនអំពីរបបនេះ របបខ្មែរក្រហមពិតជាមិនអាចកើតឡើងជាលើកទីពីរបានទេ ហើយភាពព្រាត់ប្រាសនិងទុក្ខវេទនាមិនអាចកើតមានបានដែរ» ។ **គាត លក្ខិណា**

# អឹម ម៉ង់ អតីតគ្រូបង្រៀនរបស់អ្នកនិពន្ធសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ


អឹម ម៉ង់ ក្នុងឆ្នាំ២០០៩

ម៉ង់ ជាកូនទីមួយក្នុងចំណោមបងប្អូន៥នាក់នៅក្នុងត្រកូលកសិករដែលមានដើមកំណើតនៅភូមិត្រើយទន្លាប់ ឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង់ ខេត្តតាកែវ ។ ម៉ង់ បានធ្វើជាគ្រូបង្រៀនអស់រយៈពេល១២ឆ្នាំនៅវិទ្យាល័យព្រះមហាក្សត្រិយានីកុសុមៈក្នុងខេត្តក្រចេះ ហើយបានរៀបការប្រពន្ធ និង មានកូន២នាក់នៅទីនោះ ។

នៅពេលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញទាំងស្រុង ខ្មែរក្រហមបានជម្លៀស ម៉ង់ និង ក្រុមគ្រួសារចេញពីភូមិកំណើតទៅកាន់ភូមិពេជសារ ឃុំពេជសា ស្រុកកោះអណ្តែត ខេត្តតាកែវ ឲ្យទៅរស់នៅក្នុងសហករណ៍មួយ ។

ឆ្នាំ១៩៧៦ ម៉ង់ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅនៅក្នុងកងកុមារធ្វើការរែកដីជំបូក កាប់ទន្រ្ទានខែត្រនិងរែកអាចម៍គោយកទៅដាក់ស្រែជារៀងរាល់ព្រឹក ។ នៅក្នុងកងកុមារដែលមានគ្នាប្រហែល៣០នាក់ ម៉ង់ ត្រូវរស់នៅទីវាលដាច់ឆ្ងាយពីភូមិ និងគ្មានកន្លែងជ្រកកោនឡើយ ។ នៅពេលភ្លៀងម្តងៗ ម៉ង់ ក៏ដូចជាកុមារផ្សេងទៀតដែរ គឺត្រូវរត់ទៅជ្រកនៅក្រោមដើមឈើឬ ជ្រកនៅក្នុងពំនូកចំបើង រហូតដល់ភ្លៀងរាំងទើបចេញមកខាងក្រៅវិញ ។ ចំណែកសម្លៀកបំពាក់របស់ ម៉ង់ ទទឹកជោកហើយគ្មានសម្លៀកបំពាក់ថ្មីផ្លាស់ប្តូរទេ ។ ដោយសាររងាខ្លាំងពេក ម៉ង់ បានទៅរកប្រមូលកម្ទេចឧសនិងចំបើងបង្កាត់ភ្លើងអាំងសម្ងួតខោអាវ ។ ម៉ង់ មិនដែលបានហូបគ្រប់គ្រាន់ទេ ដោយខ្មែរក្រហមចែករបបបបរក្នុងមួយថ្ងៃតែ២ពេលប៉ុណ្ណោះគឺពេលថ្ងៃ និងពេលល្ងាច ។

ឆ្នាំ១៩៧៧ ម៉ង់ ត្រូវបានខ្មែរក្រហមដកពីកងកុមាររែកដីឲ្យមកកងកុមារឃ្វាលគោវិញ ។ នៅក្នុងកងនោះមានកុមារចំនួន៥នាក់ដែលមានឈ្មោះ ថៃ, ខ្វី, ឆុន, ណិច, និងម៉ង់ ព្រមទាំងមានចាស់ៗ២នាក់ទៀតគឺ តាភៅ និង អឹម អ៊ើត ដែលជាឪពុកបង្កើតរបស់ម៉ង់ ។ ក្នុងចំណោមកុមារទាំង៥នាក់នោះមានកុមារ៣នាក់គឺ ខ្វី, ថៃ, និងម៉ង់ ផ្ទាល់ត្រូវខ្មែរក្រហមចាត់ឲ្យទៅរកត្រីដើម្បីផ្គត់ផ្គង់ក្នុងកងទាំងមូល ។ ថ្ងៃមួយក្រុម ម៉ង់ ទៅរកត្រីនៅក្នុងបឹងពេជសា ម៉ង់ ក្រឡេកទៅឃើញត្រីមួយក្បាលធំ រួចក៏ស្ទុះទៅចាប់ ស្រាប់តែមិត្ត ខ្វី យកកាំបិតទៅកាប់ធ្វើឲ្យ ម៉ង់ របួសចំដៃខាងឆ្វេងជាទម្ងន់ ។ ក្រោយមក ឪពុក ម៉ង់ បានយក ម៉ង់ ទៅព្យាបាលនៅមន្ទីរពេទ្យដែលមានត្រឹមតែថ្នាំក្រហមលាបលើមុខរបួសប៉ុណ្ណោះ ។

ក្រោយមក ឪពុក ម៉ង់ បានទៅរកត្រួយចេកយកបុកលាយជាមួយទឹកកំបោរមកបិទនៅលើមុខរបួសរបស់ ម៉ង់ ដែលមិនទាន់ជាសះស្បើយ ។ ប៉ុន្តែការព្យាបាលបែបនេះ រយៈពេលពីរទៅបីថ្ងៃដំបូង ធ្វើឲ្យស្នាមរបួស ម៉ង់ កាន់រីកធំ ប៉ុន្តែរយៈពេលប្រហែលតែ១ខែ ស្រាប់តែរបួសរបស់ ម៉ង់ បានសះជា ។ ប៉ុន្តែស្នាមរបួសរបស់ ម៉ង់ បានបន្សល់ទុកស្លាកស្នាមនៅលើដៃខាងឆ្វេងរហូតមកដល់សព្វថ្ងៃ ។ ម៉ង់ នៅតែនឹកឃើញនិងចងចាំមិនភ្លេចនូវរឿងរ៉ាវជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមនៅពេលឃើញស្លាកស្នាមនេះ ។

នៅពេលដែលកងទ័ពវៀតណាមចូលមកវាយរំដោះប្រទេសកម្ពុជា និងនៅក្នុងកងនីមួយៗក្នុងភូមិចាប់ផ្តើមមានភាព

ចលាចល ម៉ង់ និងប្អូនប្រុសឈ្មោះ ម៉េន មានការភិតភ័យយ៉ាងខ្លាំង ដោយសាររត់វង្វេងឪពុកម្តាយ និងគ្មានអាហារហូប ។ រយៈពេលដប់ថ្ងៃក្រោយមកទើបបានជួបឪពុកម្តាយនៅថ្នល់ក្នុងឃុំគុស ខេត្តតាកែវ រួច ម៉ង់ និងក្រុមគ្រួសារបានត្រឡប់មកស្រុកកំណើតវិញ ។

នៅឆ្នាំ១៩៨០ ឪពុកម្តាយរបស់ ម៉ង់ បានឲ្យ ម៉ង់ ចូលរៀនថ្នាក់ទី១ រហូតបានប្រឡងជាប់ជាគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកសីលធម៌-ពលរដ្ឋវិទ្យា ។ រហូតដល់ឆ្នាំ១៩៩៣ ម៉ង់ បានបញ្ចប់ការសិក្សា ហើយត្រូវទៅបង្រៀននៅសាលាវិទ្យាល័យព្រះមហាក្សត្រិយានីកុសុមៈ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងព្រីង ឃុំក្រចេះ ស្រុកចិត្តបុរី ខេត្តក្រចេះ ដែលជាអតីតសាលារបស់សិស្សឈ្មោះ ឌី ខាំបូលី (អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ) បានរៀនសូត្រ ។

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០០៩ ម៉ង់ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាសហការពីក្រសួងអប់រំអញ្ជើញឲ្យមកចូលរួមវគ្គបណ្តុះបណ្តាលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងភ្នំពេញ ។ នៅពេលដែល ម៉ង់ បានឃើញសិស្ស ឌី ខាំបូលី កំពុងតែអង្គុយនៅលើវេទិកា គាត់មានអារម្មណ៍មន្ទិលសង្ស័យថា បូលី ដូចជាសិស្សរបស់គាត់ ប៉ុន្តែ ម៉ង់ មិនហ៊ានសាកសួរទេ ព្រោះគាត់ខ្លាចមិនមែនជាសិស្សរបស់គាត់ ។ នៅពេលចប់កម្មវិធី បូលី បានដើរមកតម្រង់មក ម៉ង់ ហើយនិយាយថា ខ្ញុំជាសិស្សរបស់លោកគ្រូកាលនៅវិទ្យាល័យ (ខេត្តក្រចេះ) ។ ពេលនោះទើប ម៉ង់ ដឹងច្បាស់ថា បូលី ជាសិស្សរបស់គាត់ពិតប្រាកដមែន ។ ម៉ង់ មានសេចក្តីរំភើបនិយាយស្ទើរតែមិនរួចព្រោះមិននឹកស្មានថា អតីតសិស្សម្នាក់ទទួលបានជោគជ័យក្នុងការសរសេរសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដំបូងគេនៅក្នុងប្រទេសកម្ពុជានេះ ។ ម៉ង់ បានបន្ថែមទៀតថា កាលដែល បូលី រៀននៅវិទ្យាល័យ បូលី ជាសិស្សម្នាក់មានចរិតលក្ខណៈស្លូតបូត សុភាពរាបសារ ខិតខំប្រឹងប្រែងព្យាយាមក្នុងការរៀនសូត្រ និងគោរពវិន័យសាលាបានល្អណាស់ ។ កត្តាទាំងនេះហើយដែលជំរុញឲ្យ បូលី ទទួលបានលទ្ធផលល្អប្រសើរដូចពេលនេះ ។ លើសពីនេះទៅទៀត ម៉ង់ បានបន្ថែមថា ក្រោយពេលដែលបញ្ចប់វគ្គបណ្តុះបណ្តាលនេះហើយ គាត់នឹងយកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះទៅតម្កល់នៅបណ្ណាល័យសាលា ហើយប្រកាសឲ្យគ្រូៗនៅទីនោះទាំងអស់យកទៅស្រាវជ្រាវ ជាពិសេសនឹងប្រឹងប្រែងអប់រំទូន្មានប្រៀនប្រដៅដល់សិស្សជំនាន់ក្រោយៗ យកតម្រាប់តាម បូលី ។ ម៉ង់ មានមោទនភាពជាខ្លាំងចំពោះ បូលី ទោះបីជាឥឡូវគាត់ក្លាយជាកូនសិស្សរបស់អតីតសិស្សរបស់គាត់ក៏ដោយ ព្រោះនេះជាការផ្ទេរចំណេះដឹងឲ្យគ្នាទៅវិញទៅមកនូវអ្វីដែលខ្លួនមិនទាន់ចេះ ។ **ស សេងគា**



ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅដល់គ្រូបង្គោលថ្នាក់ខេត្ត នៅខេត្តកំពង់ចាម

# ញ៉ុក ពុយៈ រកឃើញប្អូនប្រុសនៅមន្ទីរស-២១

បន្ទាប់ពីការព្យាយាមសាជាថ្មីដើម្បីស្វែងរកព័ត៌មានពីប្អូនប្រុសរបស់គាត់ដែលមានឈ្មោះ ញ៉ុក ពុយ ទីបំផុត តា ដាង បានរកឃើញជីវប្រវត្តិនិងរូបថតប្អូនប្រុសរបស់គាត់នៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានិងនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ ដាង បានរកឃើញជីវប្រវត្តិ និងរូបថតទាំងនេះបន្ទាប់ពីគាត់បានចូលរួមមើលដំណើរការជំនុំជម្រះក្តីក្នុងសំណុំរឿងប្រធានមន្ទីរឃុំឃាំងស-២១ ឌុច ដែលសំណុំរឿងនេះមានទាក់ទងនឹងសំណុំរឿងមន្ទីរឃុំឃាំងស-២៤ (ឬហៅថាមន្ទីរឃុំឃាំងព្រៃស) ហើយសំណុំរឿងមន្ទីរឃុំឃាំងស-២១ នេះក៏ត្រូវបានលាតត្រដាងជាសាធារណៈដែរនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ឥឡូវនេះ ដាង មានអាយុ៦៥ឆ្នាំ រស់នៅក្រុងតាខ្មៅ ហើយគាត់កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ពីដំណើរការជំនុំជម្រះក្តីឌុច ដើម្បីស្វែងរកព័ត៌មានបន្ថែមដែលទាក់ទងនឹងការបាត់ខ្លួនប្អូនប្រុសរបស់គាត់ ។ ដាង ធ្លាប់បានដឹងអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងបានស្វែងយល់ពីដំណើរការជំនុំជម្រះសំណុំរឿងរបស់ ឌុច បន្ទាប់ពីសវនាការបានចាប់ផ្តើម ។ ចាប់តាំងពីបានដឹងអំពីដំណើរការជំនុំជម្រះក្តីនេះមក គាត់តែងតែតាមដានយ៉ាងយកចិត្តទុកដាក់តាមរយៈការចូលរួមមើលសវនាការដោយផ្ទាល់ ។ នៅឯសវនាការតាមរយៈភ័ស្តុតាងនិងចម្លើយកសិណសាក្សីបានបង្ហាញពីមុខងាររបស់ដើងឯកនិងព្រៃសហើយនិងទំនាក់ទំនងជាមួយមន្ទីរស-២១ ។ បន្ទាប់ពីបានដឹងពីការទំនាក់ទំនងទាំងនេះ ដាង មានអារម្មណ៍អន្ទះសាយ៉ាងខ្លាំង ហើយចាប់ផ្តើមស្រាវជ្រាវរកព័ត៌មានទាក់ទងនឹងប្អូនប្រុសរបស់គាត់ដែលបានជាប់ឃុំឃាំងក្នុងគុកព្រៃស កាលពីអំឡុងរបបខ្មែរក្រហម ។

បដិវត្តន៍របស់ខ្មែរក្រហមបានអំពាវនាវឲ្យយុវជននៅក្នុងភូមិរបស់ ដាង ដែលស្ថិតនៅភូមិសំប៉ាន ស្រុកកោះធំក្រោកឈរនិងតស៊ូដើម្បីទាមទារសេរីភាពពីការកាន់កាប់របស់លោកខាងលិចក្នុងគោលបំណងបង្កើតសង្គមល្អបរិសុទ្ធ មានសន្តិភាពនិងគ្មានអំពើពុករលួយ ។ ខ្មែរក្រហមបានបំផុសឲ្យកសិករនិងកម្មករទូទាំងប្រទេស



អ្នកភូមិកំពុងមើលរូបថតនៅគុកទួលស្លែង

និងឲ្យគាំទ្រខ្មែរក្រហមក្នុងការស្វែងរកសង្គមបរិសុទ្ធមួយដែលហៅថា សង្គមល្អឥតខ្ចោះ ។ ការគាំទ្រពីប្រជាជនចេញពីវណ្ណៈកសិករនិងកម្មករបានជួយឲ្យខ្មែរក្រហមដណ្តើមទីក្រុងភ្នំពេញហើយគ្រប់គ្រងប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

មានយុវជនជាច្រើននៅក្នុងស្រុកកោះធំត្រូវបានហៅហើយចូលរួមក្នុងបដិវត្តន៍របស់ខ្មែរក្រហមនេះ រួមទាំងប្អូនប្រុសរបស់ ដាង ដែលទើបតែមានអាយុ១៣ឆ្នាំផងដែរ ។ គោលបំណងនៃការចូលរួមក្នុងបដិវត្តន៍របស់យុវជនទាំងនេះ គឺដើម្បីស្តារប្រទេសកម្ពុជាឲ្យមានសន្តិភាព និងភាពរុងរឿងតាមរយៈបដិវត្តន៍ ។ យុវជនទាំងនោះរំពឹងថានឹងមកជួបជុំក្រុមគ្រួសារនិងមិត្តភក្តិរបស់ខ្លួនវិញ បន្ទាប់ពីបដិវត្តន៍នេះត្រូវបានបញ្ចប់ ។ ទស្សនៈរបស់យុវជនកម្ពុជាគឺដើម្បីប្រឆាំងនឹងជម្លោះនិងភាពភ័យខ្លាចនៅក្នុងប្រទេសដែលខ្មែរក្រហមនឹងត្រូវបង្កើតឡើង ។ សូម្បីតែក្លាយខ្លួនជាអ្នកបដិវត្តន៍ដែលគ្មានទំនាក់ទំនងជាមួយនឹងអតីតរបប លន់ នល់ ក៏ដោយ ក៏អ្នកបដិវត្តន៍ទាំងនោះរស់នៅដោយភាពភ័យខ្លាចនិងព្រួយបារម្ភថាអាចនឹងត្រូវចោទប្រកាន់ជាជនក្បត់ឬឈ្លបយកការណ៍ជានិច្ច ។

បទពិសោធន៍ប្អូនប្រុសរបស់ ដាង គឺគ្មានភាពប្លែកទេ ។ ដំបូងគាត់គឺជាទាហានខ្មែរក្រហមម្នាក់នៅក្នុងកងពលធំលេខ៧០៣ ។ យោងតាមប្រវត្តិរូបដែលបានរកឃើញនៅទួលស្លែង ដំបូង លោក ញ៉ុក ពុយ ជាពេទ្យទាហាននៅក្នុងគុកមួយ មុនពេលដែលគាត់ត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថាជាអ្នកយកការណ៍ប្រឆាំងនឹងបដិវត្តន៍ ។ ទោះបីជាមិនមានភ័ស្តុតាងបញ្ជាក់ពីទីកន្លែងដែលគាត់ត្រូវបានបញ្ជូនបន្ទាប់ពីការឃុំខ្លួននៅទួលស្លែងក៏ដោយ ក៏ឯកសារនៅឯមន្ទីរស-២១ ហើយនិងការសិក្សាស្រាវជ្រាវថ្មីៗបានបង្ហាញថាគ្មាននរណាម្នាក់មានសំណាងត្រូវបានដោះលែងបន្ទាប់ពីការចាប់ខ្លួននោះទេ ។

ក្នុងបទសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ដាង បានរំឭករឿងរបស់ប្អូនប្រុសគាត់ដោយនិយាយថា «ពេលមួយនៅចុងឆ្នាំ១៩៧២ នៅពេលប្អូនប្រុសរបស់គាត់មានអាយុ១៣ឆ្នាំ ប្អូនប្រុសរបស់គាត់បានចាកចេញពីផ្ទះ ។ ក្រុមគ្រួសាររបស់យើងបានទទួលដំណឹងពីប្អូនប្រុសម្នាក់នេះរយៈពេល៣ខែបន្ទាប់ពីគាត់បានប្រាប់ថា គាត់បានចូលរួមបដិវត្តន៍ ហើយបានបម្រើការនៅក្នុងកងពលធំលេខ៧០៣របស់តា ណាត» ។ បន្ទាប់ពី ពុយ ចាកចេញហើយចូលរួមជាមួយនឹងបដិវត្តន៍ ដាង មានការលំបាកក្នុងការស្វែងរកប្អូនប្រុសរបស់គាត់ ហើយបន្ទាប់ពីនោះមក ដាង និងក្រុមគ្រួសាររបស់គាត់បានជួប ពុយ តែប៉ុន្មានដងប៉ុណ្ណោះ ។ លើកទីពីរ អ្នកជិតខាងរបស់ ដាង បានផ្តល់ដំណឹងដល់ក្រុមគ្រួសាររបស់គាត់អំពីទីកន្លែងរបស់ ពុយ ហើយព្យាយាមបញ្ចុះបញ្ចូល ពុយ ឲ្យត្រឡប់មកផ្ទះវិញ ។ ពុយ បានបដិសេធដោយបន្តស្ថិតក្នុងជួរកងទ័ពរបស់ខ្មែរក្រហមតទៅទៀត ទោះបីជាមានការអង្វរពីគ្រួសាររបស់គាត់ក៏ដោយ ។ លើកទីបី និងជាលើកចុងក្រោយ គ្រួសាររបស់ ដាង បានឃើញ ពុយ បន្ទាប់ពីគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងភូមិជិតមួយ ។ បន្ទាប់មកម្តាយរបស់ ដាង បានឃើញ ពុយ នៅមន្ទីរពេទ្យដែលជាកន្លែងសម្រាកព្យាបាលដៃរលាករបស់គាត់មកពីការផ្ទុះគ្រាប់បែក ។ ចាប់តាំងពីពេលនោះមក ដាង និងគ្រួសារលែងបានជួប ពុយ រហូត ។

ចាប់តាំងពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៩ ក្រុមគ្រួសាររបស់គាត់តែងតែមានសង្ឃឹមថា ពុយ នៅរស់ ។ បន្ទាប់ពីឆ្នាំ១៩៧៩ សេចក្តីសង្ឃឹមទាំងនេះបានចាប់ផ្តើមសាបរលាបបន្តិចម្តងៗ ខណៈពេលអ្នកជិតខាងរបស់គាត់ដែលបានចូលរួមជាមួយកងទ័ពខ្មែរក្រហមបានត្រឡប់មកផ្ទះរៀងៗខ្លួនវិញ ។ ភាពតក់ស្លុតបានកើតមានឡើងក្នុងក្រុមគ្រួសាររបស់ ដាង បន្ទាប់ពីបានទទួលដំណឹងរបស់ ពុយ តាមរយៈអតីតទាហានខ្មែរក្រហមចំនួន៣នាក់ ។ ទាហានទាំងនោះបានប្រាប់ក្រុមគ្រួសារ ដាង ថា ពុយ ធ្លាប់ធ្វើជាអ្នកបើកឡានដឹកភ្ញៀវរបស់ខ្មែរក្រហម ហើយរស់នៅម្តុំវត្តក្តុលជិតព្រៃស ។ ម្នាក់ក្នុងចំណោមទាហានខ្មែរក្រហមទាំងបីនាក់នោះ (ត្រូវជាបងប្អូនជីដូនមួយរបស់ ដាង និង ពុយ) បានប្រាប់ក្រុមគ្រួសាររបស់ ដាង ថា ពុយ ត្រូវបានចាប់ដាក់គុកនៅព្រៃស ។ ព័ត៌មាននេះបានធ្វើឲ្យ ដាង និងក្រុមគ្រួសាររបស់គាត់ប្រាកដក្នុងចិត្តថា ពុយ ពិតជាស្លាប់ ទោះបីក្រុមគ្រួសាររបស់ ដាង មិនបានដឹងថាតើ ពុយ បានស្លាប់នៅក្នុងសង្គ្រាម ឬក៏នៅក្នុងមន្ទីរឃុំឃាំងក៏ដោយ ។

បន្ទាប់ពីបានដឹងអំពីគុកព្រៃសតាមរយៈសវនាការរបស់

ឌុច ដាង ក៏បានមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីរកប្រវត្តិរូបរបស់ ពុយ ។ ពុយ ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ១៩៧៨ ហើយ ដាង បានរកឃើញឯកសារមួយចំនួនទៀតទាក់ទងនឹងប្អូនប្រុសរបស់គាត់រយៈពេល៣១ឆ្នាំក្រោយគឺថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ។ ភាពចៃដន្យនេះបានជំរុញទឹកចិត្តរបស់គាត់ឲ្យព្យាយាមបន្តស្វែងរកព័ត៌មានបន្ថែមទៀតអំពីប្អូនប្រុសរបស់គាត់និងដាក់ពាក្យបណ្តឹងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់ពីបានទៅទស្សនានៅឯសារមន្ទីរទួលស្លែង និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដាង ប្រាកដក្នុងចិត្តថា រូបថតមួយក្នុងចំណោមរូបថតដទៃទៀតគឺជារូបថតប្អូនប្រុសរបស់គាត់ ។ រូបថតនេះត្រូវបានផ្តិតមួយទៀត ហើយត្រូវយកទៅរក្សាទុកនៅឯផ្ទះក្នុងភូមិរបស់គាត់សម្រាប់យកមកធ្វើបុណ្យតាមប្រពៃណី ។ បន្ទាប់ពីពិធីបុណ្យសពរួច ដាង បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា នេះគឺជាលើកទីមួយហើយបន្ទាប់ពីរយៈពេល៣០ឆ្នាំដែលគាត់បានដឹងច្បាស់ពីទីកន្លែងស្លាប់និងការស្លាប់របស់ប្អូនប្រុសគាត់ដោយរបៀបណា ។ សម្រាប់ក្រុមគ្រួសាររបស់គាត់វិញ ពិធីបុណ្យសពនេះគឺជាលើកទីមួយហើយដែលបានឲ្យសមាជិកក្រុមគ្រួសារគ្រប់រូបបាននិយាយរៀបរាប់ពីជីវិតរបស់ ពុយ ។ ដាង និយាយទាំងអារម្មណ៍ក្តុកក្តួលថា «ខ្ញុំមិនអាចជឿបានទេថាហេតុអ្វីខ្មែរក្រហមបែរជាសម្លាប់អ្នកបដិវត្តន៍ដ៏ស្មោះត្រង់ម្នាក់ ។ ប្អូនប្រុសរបស់ខ្ញុំបានបម្រើខ្មែរក្រហមដោយគ្មានមិនគិតពីការនឿយហត់និងស្មោះត្រង់បំផុត ក៏ប៉ុន្តែចុងបញ្ចប់ប្អូនប្រុសរបស់ខ្ញុំត្រូវបានសម្លាប់នៅក្នុងគុកមួយដ៏គួឲ្យភ័យខ្លាចទៅវិញ» ។ គាត់បានបន្ថែមទៀតថា «នៅពេលដែលខ្ញុំបានដឹងថា ប្អូនប្រុសរបស់ខ្ញុំស្លាប់នៅគុកទួលស្លែង ខ្ញុំពិតជាមានអារម្មណ៍តក់ស្លុតនិងខឹង ។ សុបិនអាក្រក់នៅតែតាមលងខ្ញុំជារៀងរាល់យប់» ។ ពិធីបុណ្យសពតាមបែបព្រះពុទ្ធសាសនាដែលត្រូវបានរៀបចំដោយ ដាង ហើយនិងក្រុមគ្រួសាររបស់គាត់បានឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ ពុយ ឲ្យទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាត ។

ការឈឺចាប់នេះមិនមែនមានតែ ដាង និងក្រុមគ្រួសាររបស់គាត់ទេ ។ ក្រុមគ្រួសារប្រជាជនកម្ពុជាដទៃទៀតក៏មានការឈឺចាប់ស្រដៀងគ្នាដែរ ។ មនុស្សមួយចំនួនរកឃើញសមាជិកគ្រួសាររបស់ខ្លួនត្រូវបានសម្លាប់នៅមន្ទីរស-២១ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹង ឌុច ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជនរងគ្រោះមួយចំនួនបានចូលរួមយ៉ាងសកម្មក្នុងសវនាការ ខណៈដែលជនរងគ្រោះដទៃទៀតកំពុងរង់ចាំយុត្តិធម៌ពិតប្រាកដមួយ ។ សម្រាប់ ដាង ទោះបីគាត់មិនបានដាក់ពាក្យបណ្តឹងជាផ្លូវការមួយប្រឆាំង ឌុច ក៏ដោយ ក៏គាត់បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតដែលកំពុងស្ថិតក្នុងការឃុំខ្លួនដែរ ។ ទោះបីជាមានភាពទុក្ខសោកនិងតក់ស្លុតបន្ទាប់ពីការរកឃើញរូបថតរបស់ ពុយ ហើយបានដឹងពីការស្លាប់របស់គាត់ក៏ដោយ ក៏ ដាង បានរៀបរាប់ពីការដឹងរឿងរ៉ាវដែលទាក់ទងនឹងប្អូនប្រុសរបស់គាត់ថាជាការបន្ធូរភាពតានតឹងអារម្មណ៍មួយដែរ ។

**ស៊ីវ សាទីណា**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ *http://www.voanews.com/ khmer/democratic-kampuchea.cfm* របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការរកឃើញសន្តិភាពនៅមណ្ឌលក្មេងកំព្រា វត្តអូរពោត

ក្នុងឆ្នាំ២០០៧ ខ្ញុំបានមកកាន់ប្រទេសកម្ពុជាដើម្បីទស្សនាមណ្ឌលក្មេងកំព្រាកើតជំងឺអេដស៍ នៅខេត្តតាកែវ ដែលមានឈ្មោះថា វត្តអូរពោត ។ មិត្តរបស់ខ្ញុំដែលជាអ្នកធ្វើការងារស្ម័គ្រចិត្តនៅមណ្ឌលក្មេងកំព្រានេះបានពិពណ៌នាពីសហគមន៍ក្មេងៗនៅវត្តអូរពោតនេះថាជាកន្លែងដែលសប្បាយបំផុតមួយនៅក្នុងពិភពលោក ។ ខ្ញុំមានការលំបាកក្នុងការយល់ពីអត្ថន័យហើយ ខ្ញុំបានរៀបចំសតិអារម្មណ៍របស់ខ្ញុំសម្រាប់អ្វីដែលខ្ញុំសន្មតថាជារឿងរ៉ាវដ៏ក្រៀមក្រំមួយសម្រាប់រយៈពេលពីរបីសប្ដាហ៍នេះ ។ ប៉ុន្តែខ្ញុំត្រូវបានគេធ្វើឲ្យយល់ខុស ព្រោះក្នុងអំឡុងពេលទស្សនកិច្ចរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាភ្ញាក់ផ្អើលដោយសារការសម្ដែងឲ្យឃើញនូវភាពកក់ក្ដៅ ការទទួលស្វាគមន៍ និងកម្លាំងចិត្តដ៏ច្រើនលើសលប់របស់ក្មេងៗទាំងនោះ ។

ខ្មែរក្រហមគឺជារឿងរ៉ាវដ៏វែងឆ្ងាយមួយបើប្រៀបធៀបនឹងការតស៊ូដែលក្មេងៗធ្លាប់បានឆ្លងកាត់ ហើយក្មេងៗនឹងបន្តប្រឈមមុខនៅពេលខាងមុខទៀត ។ កាលពីមុនមណ្ឌលក្មេងកំព្រាវត្តអូរពោត គឺជាមន្ទីរព្យាបាលជំងឺអេដស៍ដែលចាប់ផ្ដើមឡើងដោយ


អាឡីន សៅ

អតីតពេទ្យទាហានជើងទឹកអាមេរិកម្នាក់គឺ លោក វេយ ម៉ាធីស ។ វត្តអូរពោតគឺជាកន្លែងដ៏សំខាន់មួយសម្រាប់អ្នកដែលស្វែងរកទីកន្លែងដ៏ស្ងប់ស្ងាត់ដើម្បីស្លាប់ ។ មានមនុស្សជាច្រើនបានមកកាន់ទីកន្លែងនេះជាមួយនឹងកូនរបស់គេ ដែលក្មេងៗទាំងនោះមួយចំនួនក៏មានផ្ទុកមេរោគអេដស៍ដែរ ។ រហូតមកដល់ឆ្នាំ២០០៦ នៅពេលដែលថ្នាំពន្យារជីវិតប្រឆាំងមេរោគបាននាំចូលមកដល់ប្រទេសកម្ពុជា ការពិសោធន៍អ្នកជំងឺអេដស៍អាចចាត់ទុកស្មើនឹងការកាត់ទោសប្រហារជីវិត ។ សព្វថ្ងៃនេះ ដោយសារតែវត្តមានរបស់ថ្នាំពន្យារជីវិតប្រឆាំងមេរោគ ពេលនេះក្មេងៗនៅវត្តអូរពោតមានសង្ឃឹមសម្រាប់កសាងជីវិតដ៏ជោគជ័យ និងយូរអង្វែងមួយ ។

នៅពេលក្រឡេកមើលលើកដំបូង វាស្ទើរតែមិនគួរឲ្យជឿពីសោកនាដកម្មដែលក្មេងៗទាំងនេះធ្លាប់បានឆ្លងកាត់ ។ មណ្ឌលក្មេងកំព្រាគឺពោរពេញទៅដោយការឱបរឹត ការគូររូប ការលេងល្បែងកម្សាន្ត និងស្នាមញញឹមៗដែលគួរឲ្យអស់សំណើច ។ ក្មេងៗបានមើលថែរក្សាគ្នាទៅវិញទៅមកជាសហគមន៍បងប្អូនប្រុសស្រីដ៏ធំមួយ ។ បន្ថែមលើនេះ ក្មេងៗទាំងនេះក៏បានស្វាគមន៍សមាជិកដទៃទៀតដើម្បីធ្វើជាសមាជិកគ្រួសាររបស់គេដែរ ដោយមិនរើសអើងពីស្ថានភាពសុខភាព អាយុ ពូជសាសន៍ ឬវណ្ណៈអ្វីឡើយ ។ ខណៈពេលដែលខ្ញុំបានទៅដល់ទីនោះ ខ្ញុំត្រូវបានទទួលស្វាគមន៍ភ្លាមៗដោយក្មេងទើបនឹងចេះដើរដែលត្រៀមខ្លួនរួចជាស្រេចដើម្បីដឹកដៃខ្ញុំនិងនាំខ្ញុំដើរជុំវិញមណ្ឌលកំព្រានេះ ។

ទោះបីជាក្មេងៗមិនមែនជាជនរងគ្រោះ ឬជនរស់រានមានជីវិតដោយផ្ទាល់ពីរបបខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏ការបំផ្លិចបំផ្លាញភាពក្រីក្រនៅក្នុងសង្គមជាតិក្រោយពីសង្គ្រាមបានក្លាយទៅជាផ្នែកមួយក្នុងជីវិតប្រចាំថ្ងៃរបស់គេ ជាពិសេសគឺផ្នែកចំណេះដឹងនិងសុខុមាលភាពរបស់ពួកគេដែរ ។

អ្នកចេះដឹងដែលខ្មែរក្រហមបានចោទប្រកាន់ គឺឋិតនៅក្នុងចំណោម «ខ្មាំង» ដែលត្រូវបានជ្រើសរើសដើម្បីបង្ខំឲ្យផ្លាស់ប្តូរលំនៅ

និងយកទៅសម្លាប់ ។ ទោះបីជាក្មេងៗជាច្រើនជាសិស្សឆ្លាតក៏ដោយ ក៏ភាពទន់ខ្សោយនៃប្រព័ន្ធអប់រំបានបណ្ដាលឲ្យគ្រូបង្រៀនមិនយកចិត្តទុកដាក់ ហើយការសូកប៉ាន់ក៏ត្រូវតម្រូវឲ្យមានដើម្បីឡើងថ្នាក់ ។ វេយ បានចែករំលែកយោបល់ប្រាប់ខ្ញុំថា សិស្សដែលពូកែជាងគេអាចនឹងទទួលបាននូវឱកាសដើម្បីស្វែងរកអាហារូបករណ៍ទៅសិក្សានៅបរទេស ។ ប៉ុន្តែសិស្សដែលមានផ្ទុកមេរោគអេដស៍នឹងមិនអាចឈោងចាប់យកនូវឱកាសនេះបានទេ ពីព្រោះថាសិស្សដែលមានផ្ទុកមេរោគអេដស៍មិនត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរចេញក្រៅពីប្រទេសកម្ពុជាឡើយ ។

លើសពីនេះទៀត ឥទ្ធិពលសង្គ្រាម និងការសម្លាប់អ្នកមានចំណេះដឹងក៏បណ្ដាលឲ្យមានផលប៉ះពាល់ផងដែរដល់ប្រព័ន្ធសុខាភិបាល ដែលកំពុងតែធ្វើដំណើរឆ្ពោះទៅកាន់ដំណាក់កាលធូរស្បើយឡើងវិញក្នុងស្ថានភាពសេដ្ឋកិច្ចដ៏ពុះពារតស៊ូមួយ ។ ជាឧទាហរណ៍បច្ចុប្បន្ន វត្តអូរពោតទទួលបាននូវសេវាកម្មព្យាបាលដោយថ្នាំពន្យារជីវិតប្រឆាំងនឹងមេរោគចំនួនពីរដំណាក់កាល ។ ក្មេងៗទាំងអស់ចាប់ផ្ដើមទទួលសេវាកម្មព្យាបាលដំណាក់កាលទីមួយ ប៉ុន្តែប្រសិនបើក្មេងៗទាំងនេះខកខានជាមួយនឹងការព្យាបាលរបស់គេក្នុងរយៈពេលពីរបីថ្ងៃ ឬក្នុងករណីដែលថ្នាំលែងមានប្រសិទ្ធភាព នោះក្មេងៗត្រូវបញ្ជូនទៅទទួលការព្យាបាលដំណាក់កាលទីពីរទៀត ។ ទោះបីជាសេវាកម្មព្យាបាលដោយថ្នាំពន្យារជីវិតប្រឆាំងនឹងមេរោគអេដស៍អាចរកបានក្នុងប្រទេសជាច្រើនទូទាំងពិភពលោកក៏ដោយ ក៏នៅវត្តអូរពោតទទួលបាននូវសេវាកម្មព្យាបាលដោយថ្នាំពន្យារជីវិតប្រឆាំងនឹងមេរោគចំនួនពីរប្រភេទតែប៉ុណ្ណោះ ហើយក្មេងមួយចំនួនធំបានឈានដល់ដំណាក់កាលទីពីរនេះរួចទៅហើយ ។ នេះគ្រាន់តែជាឧទាហរណ៍នៃឥទ្ធិពលដ៏ហិនហោចរបស់ខ្មែរក្រហមដែលត្រូវបានឃើញយ៉ាងច្បាស់នៅក្នុងភាពក្រីក្រដែលរីកសុសសាយទូទាំងប្រទេសកម្ពុជា ជាពិសេសទៅលើក្មេងៗដែលស្ថិតនៅក្នុងស្ថានភាពត្រូវរងគ្រោះថ្នាក់ជាងគេ ។

មិនគួរឲ្យនឹកស្មានដល់ សង្គ្រាមស៊ីវិលដែលបន្តរហូតមកដល់ឆ្នាំ១៩៩៧ បានបញ្ចប់ ការចូលមកនូវមេរោគអេដស៍ក៏បានកើតឡើង ។ វាបានកើតឡើងខណៈពេលដែលការប្រយុទ្ធគ្នាបានបញ្ចប់នៅឆ្នាំ១៩៩៨ ដែលជាពេលដែលជនជាតិបរទេសអាចធ្វើដំណើរចូលមកក្នុងប្រទេស ហើយនាំមកជាមួយនូវមេរោគអេដស៍ដ៏កាចសាហាវ ។ យ៉ាងណាមិញ ក្រុមជនជាតិបរទេសមួយចំនួនធំបានបង្កើតជាអង្គការក្រៅរដ្ឋាភិបាល ដែលអ្នកទាំងនោះអាចធ្វើការអប់រំប្រជាជនក្មាមៗពីជំងឺអេដស៍ និងវិធីសាស្ត្រការពារផង ។ ជាលទ្ធផលប្រទេសកម្ពុជាក៏បានកាត់បន្ថយអត្រាអ្នកផ្ទុកមេរោគអេដស៍ ហើយអាយុជីវិតប្រជាជនជាច្រើនត្រូវបានជួយសង្គ្រោះ ។

ក្នុងរដូវក្ដៅនេះ ខ្ញុំមានឱកាសវិលត្រឡប់ទៅកាន់មណ្ឌលក្មេងកំព្រានេះម្ដងទៀត និងបានចែកចាយនូវសៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផង ។ ក្មេងៗនៅក្នុងមណ្ឌលក្មេងកំព្រានេះមិនត្រូវបានបង្រៀនមេរៀនស្ដីពីខ្មែរក្រហមឡើយ ហើយក្មេងៗភាគច្រើនមិនត្រូវបានសមាជិកគ្រួសារនិយាយប្រាប់ពីរឿងរ៉ាវអតីតកាលទេ ។ ភ្ញៀវអន្តរជាតិអាចបង្រៀនក្មេងៗបានដោយសារតែក្មេងអាចមើលឃើញរូបថតរបស់ ប៉ុល ពត និង អៀង សារី នៅក្នុងសៀវភៅ ។ លើសពីនេះ ក្មេងវ័យជំទង់ខ្លះបានទទួលការចាប់អារម្មណ៍លើការតាមដានដំណើរការតុលាការខ្មែរក្រហមតាមទូរទស្សន៍ទៀតផង ។

ខណៈពេលដែលខ្ញុំកំពុងតែចែកចាយសៀវភៅទៅឲ្យសិស្សជំទង់ ខ្ញុំបានជួបជាមួយនឹងស្ត្រីម្នាក់ឈ្មោះ អ.រ ដែលរស់នៅក្បែរវត្តអូរពោត ហើយបានចំណាយពេលវេលារបស់គាត់នៅទីនេះ ។ អ.រ គឺជាជនរងគ្រោះក្នុងរបបខ្មែរក្រហមដែលមានដើមកំណើតនៅខេត្តតាកែវ ហើយឪពុកម្ដាយនិងបងប្អូនរបស់គាត់ត្រូវបានខ្មែរក្រហមសម្លាប់ ពេលដែលគាត់នៅក្មេងនៅឡើយ ។ អ.រ បានរត់រួច ប៉ុន្តែក្រោយមក អ.រ ត្រូវបានចាប់ខ្លួនម្ដងទៀត និងបញ្ជូនចូលគុកអស់រយៈពេលបីខែ ។ នៅពេលដែល អ.រ ត្រូវបានដោះលែងមកវិញ នាងត្រូវបានបង្ខំឲ្យរៀបការ ។ អ.រ បានរស់នៅជាមួយស្វាមីដែលរៀបការដោយបង្ខំនោះអស់មួយរយៈ មុនពេល អ.រ បានរត់គេចខ្លួនម្ដងទៀត ។ អ.រ បានរត់ឡើងឡានកាកបាទក្រហមមួយដែលនាំនាងមកកាន់ជំរំជនភៀសខ្លួនជាប់ព្រំដែនប្រទេសថៃ ។ នៅជំរំ អ.រ បានជួបជាមួយនឹងអនាគតស្វាមីរបស់គាត់ឡើងវិញ ដែលបាននាំគាត់មកកាន់ប្រទេសអាមេរិក ។

ខណៈពេលដែលត្រូវបានសួរថាតើ អ.រ គិតយ៉ាងដូចម្ដេចចំពោះតុលាការខ្មែរក្រហម? អ.រ បាននិយាយថាប្រសិនបើខ្ញុំ

បានសួរគាត់កាលពីប្រាំមួយឆ្នាំមុន នោះ អ.រ ចង់ «កាច់ក ប៉ុល ពត ចោល» តែម្តង ។ ភាពតានតឹងវិបត្តិផ្លូវចិត្តក្រោយរបបខ្មែរក្រហម មានស្ថានភាពធ្ងន់ធ្ងរណាស់ក្នុងចំណោមប្រជាជនដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ពេលរស់នៅប្រទេសអាមេរិក អ.រ បានជួបពិភាក្សាពីរបៀបដែលគាត់ត្រូវបានផ្តល់ឲ្យនូវការណែនាំស្តីពីការទប់ស្កាត់ភាពតានតឹងផ្លូវចិត្ត ដែលមិនមានប្រសិទ្ធភាពដើម្បីព្យាបាលភាពឈឺចាប់របស់គាត់ឡើយ ។ យ៉ាងណាមិញ ថ្ងៃនេះ តាមរយៈការព្យាបាល និងការផ្តួចផ្តើមដោយខ្លួនឯងអស់រយៈពេលច្រើនឆ្នាំមក អ.រ អាចឈានដល់ការផ្សះផ្សាជាមួយនឹងអតីតកាលរបស់គាត់ ហើយអាចត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។ កាលពីប៉ុន្មានឆ្នាំមុន អ.រ បានមកលេងប្រទេសកម្ពុជា និងបានឃើញវត្តអូរពោតនៅក្នុងភូមិកំណើតរបស់គាត់ ។ ក្នុងអំឡុងពេលនោះ វត្តអូរពោត នៅតែជាមន្ទីរព្យាបាលអ្នកជំងឺមហារីក ជាកន្លែងដែលការស្លាប់បាត់បង់ជីវិតបានកើតឡើងជាញឹកញាប់ ។ វត្តអូរពោតនេះហើយដែលធ្វើឲ្យ អ.រ ដឹងថាគាត់អាចត្រឡប់មកកាន់ទីនេះម្តងទៀត និងផ្តល់ជំនួយក្នុងសហគមន៍ដែលជាផ្ទះរបស់គាត់រហូតមក ។

តាមការឆ្លុះបញ្ចាំងពីពេលវេលារបស់ខ្ញុំនៅប្រទេសកម្ពុជា ខ្ញុំត្រូវបានជំរុញលើកទឹកចិត្តដោយកម្លាំងចិត្តរបស់ប្រជាជនខ្មែរ ។ ក្មេងៗនៅវត្តអូរពោត បានឆ្លងកាត់ការស្លាប់បាត់បង់ជីវិត អំពើហិង្សា និងការបោះបង់ចោល ។ យ៉ាងណាមិញ ទោះបីជាមានផលវិបាកដែលក្មេងៗនឹងបន្តប្រឈមមុខក៏ដោយ ក៏ក្មេងៗនៅតែមានកម្លាំងគ្រប់គ្រាន់ដើម្បីលោតផ្លោះ និងទទួលបាននូវការឱបរឹតយ៉ាងច្រើនគ្មានព្រំដែនកំណត់ឡើយ ។ នៅក្នុងតុលាការ សាក្សីបានរៀបរាប់ពីពេលវេលាដ៏អាក្រក់បំផុតនៅក្នុងជីវិតរបស់គេ ហើយបានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីដោយឆន្ទៈមោះមុត ។ ទោះបីជាមានប្រវត្តិសាស្ត្រនៃភាពភ័យខ្លាច និងភាពស្អប់ខ្ពើមក៏ដោយ ក៏ទិដ្ឋភាពទាំងនេះបានឆ្លុះបង្ហាញពីការវិលត្រឡប់ទៅរកធាតុដើមវិញរបស់ប្រជាជនកម្ពុជា និងឆន្ទៈរបស់គេសម្រាប់ការផ្សះផ្សាជាតិ និងអនាគតដ៏ល្អប្រសើរមួយដែរ ។

**អាឡឺន សៅ**



ក្មេងៗកំពុងមើលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលភាសាអង់គ្លេសឲ្យឈ្មោះថា Cambodia Tribunal Monitor website គឺមាន «ប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ទាំងមូល ។ រយៈពេលជាង២ឆ្នាំកន្លងមកនេះ សមិទ្ធផលជាច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណៈជនទាំងអស់ក្នុងការស្វែងយល់អំពីដំណើរការទាំងមូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*សំណុំរឿងព្រហ្មទណ្ឌលេខ ០០១ ទាក់ទិននឹងការវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនិងនៅក្រោមបទបញ្ជារបស់អតីតប្រធានមន្ទីរស-២១ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានឈានដល់ដំណាក់កាលបញ្ចប់សវនាការសួរដេញដោលជាសាធារណៈកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ បើទោះបីជាមានការរិះគន់ពីសំណាក់ការិយាល័យកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដោយ ក៏ការខកខានមិនបានតាមដានដំណើរការនេះនៅមានចំនួនច្រើនលើសលប់នៅឡើយ ។*

*លើសពីនេះទៅទៀត សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ដែលទាក់ទិននឹងជនជាប់ចោទបួននាក់ទៀត គឺ ខៀវ សំផន (គណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ) នួន ជា (អនុលេខាបក្សនិងជាប្រធាន រដ្ឋសភានៃកម្ពុជាប្រជាធិបតេយ្យ) អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ) និង អៀង ធីរិទ្ធ (រដ្ឋមន្ត្រីសង្គមកិច្ចនិងសុខាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ) នឹងចាប់ផ្តើមបើកសវនាការជាបន្តបន្ទាប់ ដែលតាមការរំពឹងទុកគឺអាចនៅដើមឆ្នាំ២០១១ ។*

*ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានបែបនេះឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឲ្យមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ (BLOG) វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះលើសវនាការ (MULTIMEDIA) សារព័ត៌មានផ្សេងៗជុំវិញតុលាការ (NEWS) របាយការណ៍របស់អ.វ.ត.ក និងអង្គការក្រៅរដ្ឋាភិបាល (ECCC & NGO REPORTS) ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ (TRIAL PROCEEDINGS) ប្រវត្តិសាស្ត្រ (HISTORY) ប្រវត្តិរបស់តុលាការនេះ (TRIBUNAL BACKGROUND) និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ (COMMENTARY) ។*

*គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញ គឺទ្រឹស្តី «សហកម្មឧក្រិដ្ឋកម្មរួម» ដែលភាសាអង់គ្លេស ហៅថា «Join Criminal Enterprise» ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួល*



ខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើង ទៅតាម «ផែនការឧក្រិដ្ឋរួម» ដែលភាសាអង់គ្លេសហៅថា «Common Criminal Plan»។ ដូច្នេះយើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ (TRIAL PROCEEDINGS) ឬបទអត្ថាធិប្បាយរបស់អ្នកជំនាញ (COMMENTARY) ដើម្បីស្វែងយល់ថា តើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអ.វ.ត.ក? តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ឧទាហរណ៍មួយទៀត ប្រសិនបើយើងមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ យើងអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ (BLOG)។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង។ របាយការណ៍បែបនេះមានជាភាសាខ្មែរទៀតផង។

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org មានការត្រួតពិនិត្យដោយលោកសាស្ត្រាចារ្យច្បាប់ David Scheffer ដែលលោកធ្លាប់ធ្វើជាឯកអគ្គរដ្ឋទូតគោចរណ៍សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមក្នុងរដ្ឋការរបស់ប្រធានាធិបតី បៀល គ្លីនតុន និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការជាមួយ Illinois Holocaust Museum and Education Center ជំនួយឧបត្ថម្ភពីសំណាក់ B.J. and M.K. Pritzker Family Foundation tamry³ Northwestern University School of Law's Center for International Human Rights។

**ខ៉ាន់ថាន់ ពៅដារ៉ា**




# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org;*
*www.cambodiatribunal.org*

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ។ **ស៊ិន សុធីតា**

# ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិ នៅកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍

## សេចក្តីផ្តើម

រយៈពេល៣០ឆ្នាំកន្លងផុតទៅ ទើបសហគមន៍អន្តរជាតិអាចចាប់ផ្តើមកាត់ទោសជនដែលដៃដល់នៃអំពើប្រល័យពូជសាសន៍ដែលទទួលខុសត្រូវចំពោះការបាត់បង់ជីវិតមនុស្សអស់ប្រមាណមួយលានប្រាំពីរសែននាក់ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលទទួលការឧបត្ថម្ភពីអង្គការសហប្រជាជាតិ ទើបតែបានចាប់ផ្តើមបើកសវនាការនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ហើយមកទល់នឹងពេលនេះ អង្គជំនុំជម្រះបានកាត់ទោសបុគ្គលបីរូបពីបទឧក្រិដ្ឋកម្មសង្គ្រាម ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះ គឺថានៅពេលដែលពិភពលោកកំពុងមានការកត់សម្គាល់ពីការផ្សព្វផ្សាយព័ត៌មាននៅគ្រប់ទីកន្លែងដែលពុំធ្លាប់មានពីមុនមកនោះ កម្ពុជាមានតែសៀវភៅដែលពុំសូវយកចិត្តទុកដាក់ចំពោះប្រវត្តិសាស្ត្រខ្មែរក្រហម ដែលជារបបនយោបាយដឹកនាំមួយដែលបានបង្កការកាប់សម្លាប់មានលក្ខណៈជាខ្សែសង្វាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លក្ខខណ្ឌនេះបានទប់ស្កាត់យុវជនកម្ពុជាក្នុងការសិក្សាអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសរបស់ខ្លួននៅអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ទើបតែនៅឆ្នាំនេះ ដែលកម្ពុជាមានការផ្លាស់ប្តូរ ។ វាពិតជាចម្លែក ជាពិសេសចំពោះប្រទេសមួយដែលមានប្រជាជនរហូតដល់ទៅ៦៨ភាគរយ មានអាយុត្រឹមតែ២៩ឆ្នាំ ឬតិចជាងនេះទៅទៀត ។ លក្ខណៈនេះអាចឲ្យយើងយល់ថា ប្រជាជនកម្ពុជាមួយភាគធំបានដឹងតិចតួចអំពីឧក្រិដ្ឋកម្មដែលបង្កឡើងដោយខ្មែរក្រហមនោះ ពីអ្នកដែលធ្លាប់បានឆ្លងកាត់ផ្ទាល់តែប៉ុណ្ណោះ ការអត់អាហារ ការធ្វើពលកម្មគ្មានពេលសម្រាក និងភាពភ័យខ្លាចនៃការស្លាប់មិនចេះចប់ រហូតដល់ស្ថានភាពទាំងនេះបានបង្ខំឲ្យជនរងគ្រោះទទួលស្គាល់ថាជាការពិតមួយនៅក្នុងរបបនោះ ។

របបគ្រប់គ្រងដែលទទួលខុសត្រូវចំពោះភាពឃោរឃៅទាំងនេះត្រូវបានស្គាល់ថាជារបបខ្មែរក្រហមឬបក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រើប្រាស់វិធីសាស្ត្រដ៏គួរឲ្យភ័យខ្លាចជាច្រើននៃការឃោសនា ផ្នែកនយោបាយ រក្សាការសម្ងាត់ និងបង្កភាពតក់ស្លុតផ្សេងទៀតដើម្បីគ្រប់គ្រងអំណាចរបស់ខ្លួន ប៉ុន្តែក្រោយមកបែរជាគេចវេះមិនព្រមទទួលខុសត្រូវចំពោះការកាប់សម្លាប់របស់ខ្លួនទៅវិញ ដោយទម្លាក់កំហុសទៅលើវៀតណាម និងសហគមន៍អន្តរជាតិ ។ នៅពេលនោះ ខ្មែរក្រហមបានរៀបចំឡើងវិញនូវរដ្ឋបាលឃុំស្រុកទៅជាតំបន់ ហើយបញ្ជូនប្រជាជនកម្ពុជាទាំងអស់ឲ្យទៅរស់នៅតាមសហករណ៍និងត្រូវធ្វើការងារជាច្រើនទៀត មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមបានបំបែកប្តីចេញពីប្រពន្ធ កូន


ប្រជាជនត្រឡប់មកលំនៅឋាន ឆ្នាំ១៩៧៩

ចេញពីឪពុកម្ដាយ និងព្រះសង្ឃចេញពីទីវត្តអារាម ។ ខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត ជាបុគ្គលឆ្កួតលេលា និងមិនគួរឲ្យទុកចិត្តនោះបានផ្លាស់ប្ដូរនិងបង្កការខូចខាតដល់វិស័យវប្បធម៌ សង្គម នយោបាយ សេដ្ឋកិច្ច និងសាសនានៅលើទឹកដីកម្ពុជា ដែលមិនអាចបំភ្លេចបាន ។ នៅក្នុងការបំផ្លិចបំផ្លាញវិស័យសាសនា និងវប្បធម៌ ខ្មែរក្រហមបានលុបបំបាត់លុយ ទីផ្សារ ទ្រព្យសម្បត្តិឯកជន ការរៀនសូត្រ និងការគោរពសាសនា និងដកហូតនូវសិទ្ធិមូលដ្ឋានពីប្រជាជនគ្រប់រូប ដោយរួមទាំងសិទ្ធិក្នុងការជ្រើសរើសគូស្រករទៀតផង ។ គ្មាននរណាម្នាក់មានសុវត្ថិភាពទេនៅក្នុងរបបនោះ ដោយសារខ្មែរក្រហមរើសអើងជនជាតិខ្មែរដែលកាត់ជាមួយជាតិសាសន៍ផ្សេង ក៏ដូចជាជនជាតិខ្មែរសុទ្ធសាធ ដោយលើកយកមូលហេតុជាច្រើន ។ ប្រជាជនត្រូវរស់នៅក្នុងភាពភិតភ័តព្រោះខ្លាច «អង្គការ» យកទៅសម្លាប់ ដោយសង្ស័យថាក្បត់ជាតិ ។ ភាពភ័យខ្លាចនេះគឺសមហេតុផលនៅពេលដែលស្ទើរតែអ្វីៗគ្រប់យ៉ាងសុទ្ធសឹងតែខុសច្បាប់នោះ លើកលែងតែគោរពតាមបញ្ជាតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលរបស់ខ្មែរក្រហមចាត់ទុកប្រជាជនរបស់ខ្លួនថាគ្មានប្រយោជន៍ ដូចដែលមានបញ្ជាក់នៅក្នុងពាក្យស្លោកថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។

បើពិនិត្យទៅលើការសម្លាប់មនុស្សដ៏ឃោរឃៅគួរឲ្យរន្ធត់នៅក្នុងរបបខ្មែរក្រហម ការពន្យារពេលក្នុងការបង្កើតតុលាការកាត់ទោសអំពើប្រល័យពូជសាសន៍ដែលពេលមានពាក់ព័ន្ធនឹងអំពើពុករលួយ ទស្សនៈរបស់ជនរងគ្រោះចំពោះការទទួលបានយុត្តិធម៌ និងការសិក្សាស្រាវជ្រាវដោយផ្ទាល់អត្ថបទស្រាវជ្រាវនេះនឹងចោទសួរថា ៖ តើវិធីណាឬយុត្តិធម៌អន្តរកាលបែបណា (យុត្តិធម៌តាមផ្លូវច្បាប់ឬយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ) អាចជាវិធីសមស្រប និងល្អបំផុតដើម្បីផ្ដល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម និងជួយសម្រួលដល់ការផ្សះផ្សាមួយជាលក្ខណៈបុគ្គល សហគមន៍



និងជាតិទាំងមូលនៅក្នុងប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍នេះ និងថាតើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលគាំទ្រដោយអង្គការសហប្រជាជាតិអាចនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះកម្ពុជានិងពាំនាំនូវការផ្សះផ្សាជាតិនិងសហគមន៍បានកម្រិតណា ។ ដើម្បីធ្វើការវិភាគអំពីការនាំមកនូវយុត្តិធម៌ដល់សង្គមបាក់បែកបែបនេះ អត្ថបទនេះនឹងពិនិត្យលើកេរដំណែលនៃរបបខ្មែរក្រហមដែលរៀបរាប់អំពីការឡើងកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា ការរៀបចំគោលការណ៍សង្គមសេដ្ឋកិច្ច និងផលប៉ះពាល់នៃគោលការណ៍នេះចំពោះប្រជាជននៅក្នុងរបបនោះក៏ដូចជាផលប៉ះពាល់ដែលបន្តមានដល់ពេលបច្ចុប្បន្នដែលបានបន្តការលំបាកក្នុងការនាំមកនូវយុត្តិធម៌ជូនជនរងគ្រោះនៃរបបនេះ ។ នៅផ្នែកដំបូងនៃអត្ថបទនេះនិយាយអំពីប្រវត្តិរបស់ខ្មែរក្រហមដោយសង្កត់ធ្ងន់ទៅលើការកកើតនិងការឡើងកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា ផែនការបួនឆ្នាំរបស់ ប៉ុល ពត សម្រាប់កម្ពុជានិងផលប៉ះពាល់របស់របបនោះចំពោះវប្បធម៌ នយោបាយនិងរចនាសម្ព័ន្ធសាសនានៅកម្ពុជាទៀតផង ។ ផ្នែកទីពីរគឺផ្តោតលើការយល់ឃើញនៃយុត្តិធម៌ ទំនាក់ទំនងយុត្តិធម៌ជាមួយនឹងការអត់ឱនទោស និងភាពខុសប្លែកគ្នារវាងយុត្តិធម៌តាមផ្លូវច្បាប់និងយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ និងការផ្សះផ្សាជាលក្ខណៈបុគ្គលសហគមន៍ និងជាតិទាំងមូល និងការយល់ឃើញនៃយុត្តិធម៌អន្តរកាល និងថាតើត្រូវប្រើប្រាស់យុត្តិធម៌បែបណាចំពោះអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ផ្នែកទីបី ពិនិត្យលើការតស៊ូដើម្បីនាំមកនូវយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា វិធីសាស្ត្រផ្សេងៗក្នុងការនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះ ដែលរួមមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងចុងក្រោយគឺការវិភាគលើប្រសិទ្ធភាពនិងការឆ្លើយតបពីសំណាក់ប្រជាជនក្នុងស្រុកចំពោះវិធីសាស្ត្របែបនេះ ។ អត្ថបទនេះសរុបសេចក្តីដោយការផ្តល់គោលការណ៍មួយចំនួនដើម្បីជាជំនួយដល់ការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ក៏ដូចជាជួយសម្រួលនិងលើកស្ទួយដល់ការផ្សះផ្សាមួយសម្រាប់ប្រជាជនកម្ពុជាតាមកម្រិតជាច្រើន ។ ដោយសារលក្ខខណ្ឌនិងផលវិបាកជាច្រើននៃអំពើប្រល័យពូជសាសន៍កម្ពុជាដូចដែលបានរៀបរាប់ខាងលើ បានធ្វើឲ្យការនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះមានការលំបាក ។

## ប្រវត្តិសាស្ត្រនៃខ្មែរក្រហម

ខ្មែរក្រហមកើតឡើងចេញពីការវិវឌ្ឍនៃបក្សកុម្មុយនីស្តកម្ពុជា ដោយចាប់ផ្តើមពីបក្សប្រជាជនបដិវត្តន៍កម្ពុជានៅឆ្នាំ១៩៥១ ។ ដោយមានជំនួយពីពួកកុម្មុយនីស្តវៀតណាម សាឡុតស (ដែលស្គាល់ថាជា ប៉ុល ពត) បានបង្កើតជាបក្សស្របច្បាប់មួយហៅថា បក្សប្រជាជនដែលកើតចេញពីបក្សប្រជាជនបដិវត្តន៍កម្ពុជា ហើយក៏បានជួយបង្កើតអង្គការបក្សនិងកម្មវិធីនយោបាយជាច្រើនទៀត ។ បន្ទាប់ពីឈ្នះបានកៅអីចំនួនបីនៅក្នុងសភាជាតិនៅឆ្នាំ១៩៥៥ បក្សប្រជាជនបដិវត្តន៍កម្ពុជាមានការរីកចម្រើនតែបន្តិចបន្តួចប៉ុណ្ណោះ ហើយរហូតមកដល់ដើមឆ្នាំ១៩៦០ គឺមានតែសាខាបក្សនៅទីជនបទចំនួនពីរដែលនៅបន្តដំណើរការ ។ នៅចុងខែកញ្ញា ឆ្នាំ១៩៦០ មានការធ្វើសន្និបាតសម្ងាត់របស់បក្សប្រជាជនបដិវត្តន៍កម្ពុជាមួយ ដោយប្តូរឈ្មោះបក្សនេះទៅជាបក្សពលករកម្ពុជាវិញ ហើយក៏បានផ្លាស់ប្តូរមាគ៌ានយោបាយដែរ ។ នៅពេលដែលលេខាធិការបក្សបានបាត់ខ្លួននៅក្នុងឆ្នាំ១៩៦២នោះ មានការបើកសន្និបាតជាបន្ទាន់មួយ ដោយ ប៉ុល ពត ត្រូវបានជ្រើសតាំងជាលេខាធិការបក្សថ្មី ខណៈពេលដែល នួន ជា សមាជិកក្នុងគណៈកម្មការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបខ្មែរក្រហមនោះនៅតែជាអនុលេខាធិការបក្សដដែល ។

នៅឆ្នាំ១៩៦៦ ប៉ុល ពត បានប្តូរឈ្មោះបក្សពលករកម្ពុជាទៅជាបក្សកុម្មុយនីស្តកម្ពុជាក្នុងគោលបំណងបន្ថយឥទ្ធិពលវៀតណាមពីចលនាកុម្មុយនីស្តកម្ពុជា និងបង្កើនទំនាក់ទំនងកម្ពុជាជាមួយចិនជំនួសវិញ ។ តាមលោក ក្រេក អិចឆែស្សិន បក្សកុម្មុយនីស្តកម្ពុជាបានវិវឌ្ឍន៍ការរៀបចំធ្វើបដិវត្តន៍របស់ខ្លួននៅក្នុងព្រៃដើម្បីប្រុងប្រៀបធ្វើសង្គ្រាមទ្រង់ទ្រាយធំមួយក្នុងការបណ្តេញសម្តេច សីហនុ និងរបបរាជាណាចក្រកម្ពុជារបស់ព្រះអង្គ ។ ក្រោយមកសេនាប្រមុខ លន់ នល់ និងសហការីដែលមានទំនោរទៅប្រទេសអាមេរិកបានធ្វើរដ្ឋប្រហារបណ្តេញសម្តេច សីហនុ ពីប្រមុខរដ្ឋនៅក្នុងខែមីនា ឆ្នាំ១៩៧០ ហើយខ្មែរក្រហម (ដែលជាឈ្មោះសម្តេច សីហនុ បានដាក់ឲ្យនៅក្នុងទសវត្សន៍៦០) បានគ្រប់គ្រងភាគច្រើននៃប្រទេសកម្ពុជា ។ ខ្មែរក្រហមទទួលបានការគាំទ្រពី

សំណាក់ប្រជាជនរាប់ពាន់នាក់ដែលស្អប់ខ្ពើមរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់ ដែលគាំទ្រដោយអាមេរិកាំង និងមនុស្សដែលចូលបក្សកុម្មុយនីស្តកម្ពុជាក្នុងគោលបំណងជួយឲ្យសម្តេច សីហនុ ចូលមកកាន់កាប់តំណែងវិញ ។ បន្ទាប់ពីបាននិរទេសទៅប្រទេសចិន សម្តេច សីហនុ បានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលក្រៅស្រុកមួយដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលនៅក្នុងនោះក៏មានសមាជិកមកពីបក្សកុម្មុយនីស្តកម្ពុជាជាសមាជិកដែរ ។

ដោយមានជំនួយនិងការហ្វឹកហ្វឺនពីវៀតណាម ខ្មែរក្រហមចាប់ផ្តើមវាយប្រហារមកលើកម្លាំងរបស់សាធារណរដ្ឋខ្មែរ ។ ការគាំទ្រខ្មែរក្រហមកាន់តែកើនឡើង នៅពេលដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរដែលឧបត្ថម្ភដោយសហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកមកលើមូលដ្ឋាន និងបណ្តាខ្សែរយៈផ្គត់ផ្គង់របស់ក្រុមកុម្មុយនីស្ត ដែលបណ្តាលឲ្យមនុស្សប្រមាណបីសែននាក់បានស្លាប់ ដោយគិតចាប់តែពី ខែមីនា ដល់ខែសីហា ឆ្នាំ១៩៧៣ ប៉ុណ្ណោះ ។ ដោយមូលហេតុនេះហើយបានជាប្រជាជនជាច្រើនសម្រេចចូលបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា ។ នៅដើមឆ្នាំ១៩៧៣ ខ្មែរក្រហមបានគ្រប់គ្រង៨៥ភាគរយនៃទឹកដីកម្ពុជាទាំងមូល ។ ប៉ុន្តែដោយសារជំនួយពីសហរដ្ឋអាមេរិកនៅតែបន្តនោះ សង្គ្រាមស៊ីវិលរវាងសាធារណរដ្ឋខ្មែរនៃរដ្ឋាភិបាល លន់ នល់ និងបក្សកុម្មុយនីស្តកម្ពុជារបស់ ប៉ុល ពត អាចបន្តបានរយៈពេលពីរឆ្នាំទៀត ។ បរិមាណគ្រាប់បែកដែលបានទម្លាក់មកលើកម្ពុជារវាងឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧៣ គឺច្រើនជាងបីដងនៃបរិមាណគ្រាប់បែកដែលបានទម្លាក់មកលើប្រទេសជប៉ុននៅសម័យសង្គ្រាមលោកលើកទីពីរ ពោលគឺជិតពាក់កណ្តាលនៃចំនួននោះត្រូវបានទម្លាក់នៅក្នុងឆ្នាំ១៩៧៣ ។

ដូចដែលសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន បានរៀបរាប់នៅក្នុងសៀវភៅមានចំណងជើងថា «Why Did They Kill?» ដោយសារតែសង្គ្រាមវៀតណាមកាន់តែមានសភាពធ្ងន់ធ្ងរ និងការប៉ុនប៉ងផ្តួលរំលំ សម្តេច សីហនុ ដែលធ្វើឲ្យខ្មែរក្រហមអាចឡើងកាន់អំណាចបានដោយសារមានការជ្រោមជ្រែង និងការទទួលស្គាល់ស្របច្បាប់ ។ លក្ខខណ្ឌសំខាន់នៃការទទួលស្គាល់ខ្មែរក្រហមនោះ គឺការជ្រោមជ្រែងពីសម្តេច សីហនុ បន្ទាប់ពីការផ្តួលរំលំការគ្រប់គ្រងរបស់ព្រះអង្គនៅឆ្នាំ១៩៧០ និងដោយសារតែបក្សកុម្មុយនីស្តកម្ពុជាធ្លាប់ជាគណបក្សប្រឆាំងនៅក្នុងការបោះឆ្នោតនៅឆ្នាំ១៩៥៥ ។ សុន្ទរកថារបស់សម្តេច សីហនុ កាន់តែជំរុញឲ្យប្រជាជននៅទីជនបទជាច្រើនធ្វើតាមព្រះអង្គ ដោយសារព្រះអង្គជាព្រះរាជបិតាជាទីស្រឡាញ់ និងមានប្រជាប្រិយភាព ។ ដើម្បីបង្ហាញអំពីភាពស្មោះស្ម័គ្រចំពោះព្រះអង្គ គឺការចូលរួមក្នុងចលនាខ្មែរក្រហម ។ ដូចដែលសាស្ត្រាចារ្យ អាឡិច ហ៊ីនតុន បាននិយាយថា ខ្មែរក្រហមអាចចូលមកកាន់កាន់អំណាចបានដោយសារមានការផ្លាស់ប្តូរស្ថានភាពសង្គមសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរមួយ ។ ដោយការបែកបាក់គ្រួសារ អ្នកស្រុករាប់ពាន់នាក់ដែលភាគច្រើនជាអ្នកក្រខ្សត់ និងនៅវ័យក្មេងចូលបដិវត្តន៍ខ្មែរក្រហមដើម្បីនាំព្រះមហាក្សត្ររបស់ខ្លួនឲ្យមកចូលកាន់អំណាចវិញ ក៏ដូចជាការសងសឹកចំពោះការជិះជាន់នៃពួកឈ្មួញពានដែលទទួលខុសត្រូវចំពោះការបំផ្លិចបំផ្លាញ និងការទម្លាក់គ្រាប់បែកបំផ្លាញផ្ទះសម្បែងរបស់អ្នកស្រុកទាំងនោះដែរ ។ បន្ទាប់ពីរយៈពេល៥ឆ្នាំនៃអស្ថិរភាពផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម ប្រជាជនកម្ពុជាមានសុទិដ្ឋិនិយមចំពោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្លាំងណាស់ ដែលនៅពេលនោះខ្មែរក្រហមបានចូលមកដល់រាជធានីភ្នំពេញ ប្រជាជននៅទីក្រុងបានប្រមូលផ្តុំគ្នានៅតាមដងវិថីដើម្បីអបអរសាទរ ដោយការគ្រឹក្រណាត់សផង ។

ប៉ុន្តែកាលបរិច្ឆេទនេះបញ្ជាក់ពីការចាប់ផ្តើមភាពរន្ធត់តក់ស្លុតរបស់ប្រជាជនកម្ពុជា ដោយខ្មែរក្រហមទៅវិញទេ ។ ថ្ងៃនោះហើយដែលបង្ហាញពីអំពើអមនុស្សធម៌ដ៏សាហាវឃោរឃៅ ដូចជាការភ័យខ្លាចមិនចេះចប់ ខ្លាចបាត់បង់ជីវិត និងការកាប់សម្លាប់ប្រជាជនខ្មែរជាច្រើនដោយខ្មែរគ្នាឯង ។ សេចក្តីសង្ឃឹមនូវជីវភាពដូចពេលមុនមានសង្គ្រាមស្ទើរតែរលាយសូន្យក្នុងពេលមួយភ្លែតនៅពេលដែលខ្មែរក្រហមប្រកាសភ្លាមៗតាមវិទ្យុថា ពួកគេមិនមែនមកពិភាក្សាជាមួយនរណាម្នាក់ទេ ហើយការដឹកនាំនយោបាយនិងយោធានៃសាធារណរដ្ឋខ្មែររបស់ លន់ នល់ ត្រូវបានផ្តួលរំលំហើយ ។ ភ្លាមៗនោះ ខ្មែរក្រហមបញ្ជាឲ្យប្រជាជននៅទីក្រុងជម្លៀសចេញទៅទីជនបទរយៈពេល «ពីរ-បីថ្ងៃ» ដោយ

បន្ទុំប្រជាជនទាំងនោះឲ្យចាកចេញពីទីក្រុងទៅរស់នៅតាមទីជនបទដើម្បីធ្វើការងារស្រែចម្ការ ។ នៅក្នុងការជម្លៀសនោះមានប្រជាជនចំនួនពីរលាននាក់ ដែលចំនួននេះកើនឡើងដោយសារមានប្រជាជនចំនួនប្រមាណប្រាំមួយសែននាក់ ដែលបានបាត់បង់ផ្ទះសម្បែងដោយសារការទម្លាក់គ្រាប់បែក បានចូលមកទីក្រុងដើម្បីជ្រកកោន តាំងពីមុនពេលមានសង្គ្រាម ។ មិនមានការលើកលែងណាមួយឡើយ គឺត្រូវជម្លៀសចេញទាំងអស់ សូម្បីតែនៅតាមមន្ទីរពេទ្យ និងទីវត្តអារ៉ាម ហើយបើមានការជំទាស់ នឹងត្រូវសម្លាប់ចោល ។ ប្រជាជនរាប់ពាន់នាក់បានស្លាប់នៅពេលជម្លៀសដោយសារជំងឺ ដូចជាស្ត្រីមានផ្ទៃពោះត្រូវបានស្លាប់នៅពេលបង្កើតកូនដោយគ្មានការជួយសង្គ្រោះ ឈឺស្លាប់ដោយសារគ្មានថ្នាំព្យាបាល និងក្មេងតូចៗនិងចាស់ជរាស្លាប់ដោយសារការធ្វើដំណើរឆ្ងាយតែម្នាក់ឯង ។

កុង សួរ គឺជាព្រះសង្ឃមួយអង្គនៅទីក្រុងភ្នំពេញ មុនពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ។ ហាំង ង៉ោ គឺជាគ្រូពេទ្យធ្វើការពាក់កណ្ដាលថ្ងៃនៅក្នុងរបប លន់ នល់ ។ អ្នកទាំងពីរសុទ្ធតែនៅភ្នំពេញពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងនៅថ្ងៃទី១៧ ខែមេសា ។ កុង សួរ បានរំឭកឡើងវិញថា ព្រះសង្ឃជាច្រើនអង្គទៀត ព្រមទាំងរូបគាត់ពុំបានគិតថាការជម្លៀសគឺសំដៅដល់ព្រះសង្ឃដែរទេ ប៉ុន្តែបន្ទាប់ពីចេញបញ្ជាពីរដងក្នុងរយៈពេលពីរបីម៉ោងនោះ ខ្មែរក្រហមនិយាយថា ព្រះសង្ឃទាំងអស់ត្រូវជម្លៀសចេញពីវត្ត បើមិនដូច្នោះព្រះសង្ឃអាចនៅទីណាក៏បាន ប៉ុន្តែនឹងត្រូវសម្លាប់ ។ នៅក្នុងសៀវភៅ អ្នករស់ជីវិតពីវាលពិឃាដ **(Survival in the Killing Fields)** វេជ្ជបណ្ឌិត ហាំង ង៉ោ បាននិយាយអំពីការជម្លៀសរបស់គាត់ នៅពេលកំពុងធ្វើការវះកាត់ ហើយរៀបរាប់អំពីឥរិយាបថរបស់កម្មាភិបាលខ្មែរក្រហម ពេលជម្លៀសមនុស្សចេញពីបន្ទប់វះកាត់នោះថា «មានអ្វីម្យ៉ាងបង្កប់នៅក្នុងកំហឹងរបស់កងកម្មាភិបាលទាំងនោះ ។ ដូចជាមានអ្វីបានកើតឡើងចំពោះគេ បន្ទាប់ពីរស់នៅក្នុងព្រៃរយៈពេលប៉ុន្មានឆ្នាំនេះ ។ មនុស្សទាំងនេះត្រូវបានកែប្រែអស់ទៅហើយ ។ គេមិនមែនខ្មែរដែលខ្ញុំធ្លាប់ស្គាល់នោះទេ គឺខ្មែរដែលមានអត្តចរិតអៀនប្រៀន ខ្ជិលបន្តិច ប៉ុន្តែសុភាពរាបសារ» ។

ការជម្លៀសមនុស្សចេញពីភ្នំពេញ និងទីប្រជុំជននានានៅកម្ពុជាគឺជាសកម្មភាពដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីសម្រេចបាននូវនយោបាយ «មហាលោតផ្លោះ» ក្នុងការធ្វើឲ្យកម្ពុជាក្លាយទៅជាប្រទេសសង្គមនិយមដែលមិនធ្លាប់មានពីមុនមក ហើយដូចដែលបានប្រកាសតាមវិទ្យុនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ថានឹងបង្កើតនូវសង្គមដ៏ស្អាតស្អំ យុត្តិធម៌បំផុតមួយដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ការ «លោតផ្លោះ» នេះ គឺជាគោលបំណងនៃផែនការបួនឆ្នាំរបស់ ប៉ុល ពត ដែលបានសរសេរឡើងភ្លាមៗនៅក្នុងឆ្នាំ១៩៧៦ ដើម្បីទុកសម្រាប់អនុវត្តន៍រវាងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៨០ ។ ផែនការនេះក៏បង្ហាញអំពីការប្ដេជ្ញាកែប្រែកម្ពុជាឲ្យទៅជាជាតិមួយដែលប្រកបទៅដោយកសិករ និងពលករ និងលុបបំបាត់ចោលដល់ឫសគល់នូវអំពើពុករលួយ សក្ដិភូមិ និងមូលធននិយម ។ ផែនការបួនឆ្នាំនេះមានបំណងចង់បង្កើតនូវសមូហភាវនិយមនូវរាល់ទ្រព្យសម្បត្តិឯកជនទាំងអស់និងប្រើប្រាស់ថវិកាដែលបានមកពីការនាំចេញនូវផលិតផលកសិកម្មដែលសំខាន់ ទីមួយគឺស្រូវនិងកសិផលសំខាន់ទីពីរជាច្រើនទៀត ដូចជាកប្បាស ដើម្បីទិញនូវគ្រឿងម៉ាស៊ីនដែលអាចឲ្យបក្សកុម្មុយនីស្តកម្ពុជាអាចបង្កើតឧស្សាហកម្មធុនស្រាល បន្ទាប់មកទៀត ឧស្សាហកម្មធុនល្មម និងចុងក្រោយគឺឧស្សាហកម្មធុនធ្ងន់ ។ «មួយហិកតាបីតោន» បានក្លាយជាពាក្យស្លោកជាតិមួយដោយតម្រូវឲ្យទទួលបានលទ្ធផលជាមធ្យមនូវស្រូវមិនទាន់កិនចំនួន៣តោនក្នុងទំហំដីមួយហិកតានៅទូទាំងប្រទេស ។ ផែនការនេះគឺមិនអាចធ្វើទៅបានឡើយ ដោយសារបរិមាណស្រូវនេះមិនធ្លាប់ធ្វើបានពីមុនមកទេ ម្យ៉ាងទៀតកម្ពុជាក្នុងពេលនោះកំពុងទទួលរងនូវការបំផ្លិចបំផ្លាញជាច្រើនដោយសារសង្គ្រាម កង្វះសម្ភារៈ សត្វពាហណៈ និងកម្លាំងពលកម្មគ្រប់គ្រាន់ ។

ផែនការបួនឆ្នាំនេះត្រូវបានខូចខាត ដោយសារលក្ខណៈមិនពិតនិងការមិនគិតឲ្យបានគ្រប់ជ្រុងជ្រោយនូវរាល់ផែនការភាគច្រើនរបស់ខ្មែរក្រហមដែលរំពឹងចង់ឲ្យផលស្រូវកើនឡើងភ្លាមៗ ដើម្បីបង្ហាញអំពីឆន្ទៈនៃបដិវត្តន៍សមូហភាវកម្មនិងកែប្រែពីភាពក្លៀវក្លាផ្នែកយោធាមកជាការយកចិត្តទុកដាក់ផ្នែកសេដ្ឋកិច្ច

វិញជាជាងអភិវឌ្ឍន៍ខាងផ្នែកវិទ្យាសាស្ត្រឬការជំរុញឲ្យប្រើប្រាស់គ្រឿងចក្រនោះទេ ។ ផែនការនេះមិនបានពន្យល់អំពីថាតើ ខស្សរាហកម្មធុនស្រាលនោះធ្វើឡើងដោយរបៀបណាឡើយ ដោយគិតតែពីជំរុញឲ្យបានផលស្រូវតែប៉ុណ្ណោះ ។ ឧទាហរណ៍ថា រោងចក្រត្រូវផលិតម៉ាស៊ីនប្រើប្រាស់សម្រាប់ប្រព័ន្ធទឹក ប៉ុន្តែ «តើសារធាតុដើមសម្រាប់ធ្វើម៉ាស៊ីននេះបានមកពីណា ឬតាមរបៀបណា ហើយក៏មិនបានបញ្ជាក់អំពីថវិកា និងកម្លាំងត្រូវការដែរ» ។ ខ្មែរក្រហមអាចគ្រប់គ្រងអំណាចបានភាគច្រើនមកពីការលាក់បាំងនូវអត្តសញ្ញាណបក្សកុម្មុយនីស្តរបស់ខ្លួន ដែលដឹកនាំផ្តាច់ការក្នុងគោលបំណងលើកតម្កើងសេដ្ឋកិច្ចតាមរយៈអគ្គការដ៏អាថ៌កំបាំង ។ ដោយសារតែភាពអាថ៌កំបាំងនិងជំនឿដែលគ្មានហេតុផលនេះហើយដែលនាំឲ្យបក្សកម្មុយនីស្តកម្ពុជាបានឈានមកដល់ទីបញ្ចប់បាន ព្រោះតែខ្មែរក្រហមខ្វះការអំណត់ក្នុងការទទួលបាននូវការគាំទ្រនិងសេចក្តីទុកចិត្ត ដែលធ្វើឲ្យក្រុមគេក្លាយជាមនុស្សផ្តាច់ការដែលគ្រប់គ្រងប្រទេសដោយភាពសាហាវព្រៃផ្សៃ ។

ការពិតទៅ ផែនការបួនឆ្នាំនេះមិនបានយកមកអនុវត្តន៍ទេ ទោះបីជាអាថ៌កំបាំងនៃបក្សកម្មុយនីស្តកម្ពុជានៅតែបន្តរហូតដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៧ វិទ្យុភ្នំពេញបានចាក់ផ្សាយនូវសុន្ទរកថារបស់ប៉ុល ពត ដែលមានរយៈពេល៥ម៉ោង ។ ការចេញប្រកាសអំពីបក្សនេះប្រហែលមកពីការគាបសង្កត់ពីចិនប៉ុណ្ណោះ ដែលចិនជាសម្ព័ន្ធមិត្តនិងអ្នកឧបត្ថម្ភផ្នែកថវិកាមួយក្នុងចំណោមសម្ព័ន្ធមិត្តមួយចំនួនតូចទៀតរបស់បក្សកម្មុយនីស្តកម្ពុជា ។ ការគ្រប់គ្រងថ្មីរបស់ចិនមានការមិនពេញចិត្តចំពោះភាពលាក់បាំងរបស់បក្សអំពីកម្មុយនីស្តនិយមនៅកម្ពុជានិងការទាមទារឯករាជ្យពីចលនាកម្មុយនីស្តអន្តរជាតិ ។ ឥទ្ធិពលពីប្រទេសផ្សេងៗកាន់តែធ្វើឲ្យឥទ្ធិពលនៃសង្គ្រាមត្រជាក់មានសភាពធ្ងន់ធ្ងរចំពោះការផ្លាស់ប្តូរផ្នែកនយោបាយនៅកម្ពុជា ។ សហរដ្ឋអាមេរិកបានគាំទ្ររបបលន់ នល់ ចិនគាំទ្របក្សកម្មុយនីស្តកម្ពុជា ហើយសូវៀតឧបត្ថម្ភវៀតណាមដែលជាដៃគូប្រជែងកម្ពុជា ។ មូលហេតុនេះហើយទំនាក់ទំនងរវាងកម្ពុជានិងវៀតណាមបានក្លាយទៅជាអ្នកធ្វើសង្គ្រាមតំណាង បន្ទាប់ពីមានការបែងចែករវាងសូវៀតនិងចិនថ្មីៗដោយពុំគិតអំពីឥទ្ធិពលវៀតណាមក្នុងការបង្កើតចលនាកម្មុយនីស្តនៅកម្ពុជាឡើយ ។

បក្សកម្មុយនីស្តកម្ពុជាចង់ធ្វើឲ្យរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យទទួលបានឯករាជ្យទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ច ហើយចាត់ទុកវៀតណាមជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យ ដូច្នេះត្រូវរួបរួមប្រជាជនខ្មែរដើម្បីប្រឆាំង ។ ដូចដែលលោកសាស្ត្រា ដេវីដ ឆេនល័រ បានរៀបរាប់នៅក្នុងសៀវភៅ «បងធំទីមួយ» នៅពេលដែលខ្មែរក្រហមបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យនោះ គេបានប្រកាសភាពឯករាជ្យពីវៀតណាមដោយបំបាត់វៀតណាមចោលពីប្រវត្តិរបស់បក្ស ហើយមានការលួចវាយឆ្មក់ដ៏យង់ឃ្នងនៅតាមព្រំដែនទៀតផង ។ ភ័ស្តុតាងនេះអាចបញ្ជាក់បានថា អ្នកដឹកនាំនៅកម្ពុជាមិនពេញចិត្តចំពោះការគ្រប់គ្រងរបស់វៀតណាមទេ ។ បន្ទាប់ពីទទួលបានជោគជ័យ ក្រុមគេចាត់ទុកខ្លួនឯងថារ៉ឹងប៉ឹង ដោយសារតែភាពស្អាតស្អំនៃបដិវត្តន៍ និងការគាំទ្រពីចិននិងកូរ៉េ ។ នៅពេលដែលខ្មែរក្រហមចូលកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានបណ្តេញប្រជាជនវៀតណាមទាំងអស់ឲ្យចេញពីកម្ពុជា ហើយបានសម្លាប់មួយចំនួនតូចទៀតដែលនៅសេសសល់នៅកម្ពុជា ។ ជាថ្មីម្តងទៀត វាជាតំណាងអំពីការវិវឌ្ឍទៅមុខនៃសង្គ្រាមត្រជាក់ដែលសត្រូវរបស់បក្សកម្មុយ-នីស្តកម្ពុជាត្រូវបានចាត់ថ្នាក់ថាជា សេ.អ៊ី.អា, កា.ហ្សេ.បេ ឬវៀតណាម ។

លក្ខណៈពិសេសរបស់ខ្មែរក្រហមគឺការលាក់បាំងអំពីអត្តសញ្ញាណរបស់គណៈកម្មការមជ្ឈិមបក្សកម្មុយនីស្តកម្ពុជា និងរាល់ផ្នែកទាំងអស់នៃរបបនេះពីប្រជាជនខ្មែរ ។ ដូចដែលលោកហាំង ឆៅ បានរំឭកឡើងវិញអំពីហេតុការណ៍ដែលកើតឡើងប៉ុន្មានឆ្នាំមុនពេលបក្សកម្មុយនីស្តចូលកាន់តំណែងថា «មិនមានព័ត៌មានអ្វីច្រើនទេក្រៅតែអំពីការឃោសនា ។ ខ្មែរក្រហមមានស្ថានីយវិទ្យុសម្ងាត់មួយ ប៉ុន្តែគេមិនដែលប្រាប់យើងអំពីពួកទ័ពព្រៃនោះយ៉ាងម៉េចនិងអ្វីដែលពួកគេចង់បានពិតប្រាកដនោះទេ» ។ នួន ជា ដែលជាប្រធានសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិប-តេយ្យ ក្រៅពីតំណែងមួយទៀតជាអនុលេខាធិការបក្សកម្មុយនីស្តកម្ពុជា ហើយក៏ត្រូវបានស្គាល់ថាជាបងធំទីពីររបស់ ប៉ុល ពត

ដែលមានរហ័សនាមថាបងធំទីមួយ នោះក៏បាននិយាយអំពីគោលបំណងនៃការលាក់ការណ៍នេះគឺដោយសារមានគណៈប្រតិភូមកពីប្រទេសដាណឺម៉ាក់មកធ្វើទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ដេវីដ ឆេនដល័រ ក៏បាននិយាយដែរថា «នួន ជា ឲ្យយោបល់ថា ការរក្សាសម្ងាត់គឺមានអត្ថប្រយោជន៍ខ្លាំងណាស់ ។ ហើយបានបន្ថែមថា ប្រព័ន្ធនៃការគ្រប់គ្រងរបស់អ្នកដឹកនាំត្រូវតែការពារ ទោះក្នុងកាលៈទេសៈណាក៏ដោយ ។ ដរាបណានៅមានអ្នកដឹកនាំបក្សនឹងមិនរលាយជាដាច់ខាត» ។ កិច្ចការសម្ងាត់ទាំងនោះ រួមទាំងការវើដ្ឋះសម្បែងដោយមិនបានគិតទុកជាមុននូវការប្រើនិរសារ រស់នៅដោយមានការចាំយាម ភ្ញក់អាហារក្រែងមានជាតិពុល ។ល ។ ក្នុងការលើកឡើងអំពីសារសំខាន់នៃការលាក់ឈ្មោះទាំងនេះ នួន ជា ប្រហែលជាមិនបានរំឭកដល់ឈ្មោះ ប៉ុល ពត ឡើយ» ។

ការលាក់បាំងទាំងនេះជាសញ្ញានៃជំនឿគ្មានហេតុផលជ្រុលហួសហេតុរបស់ ប៉ុល ពត ក៏ដូចបក្សកុម្មុយនីស្តកម្ពុជា ។ នៅពេលដែល ប៉ុល ពត ទៅទស្សនកិច្ចនៅប្រទេសចិននៅក្នុងខែតុលា ឆ្នាំ១៩៧៧ បានលើកពីមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយសារមូលហេតុចាំបាច់នៃការបំផ្លាញខ្សែរយៈស៊ើបការណ៍ខ្មាំង ។ របៀបសួរចម្លើយអ្នកទោសនៅគុកទួលស្លែងអាចបញ្ជាក់អំពីសភាពគ្មានហេតុផលមានលក្ខណៈជាប្រព័ន្ធនិងដ៏ច្រើនលើសលប់នៃបក្សកុម្មុយនីស្តកម្ពុជា ។ ទួលស្លែងក៏ត្រូវបានស្គាល់ថាជាមន្ទីរ «ស-២១» ធ្លាប់ជាវិទ្យាល័យមួយដែលខ្មែរក្រហមបានប្រែទៅជាគុកដែលកម្មករធ្វើការនៅរោងចក្រនៅក្បែរៗនោះបាននិយាយថា «ជាកន្លែងដែលមនុស្សចូលទៅហើយមិនអាចចេញមកវិញឡើយ» ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ព្យាយាមយកព័ត៌មានចេញពីចម្លើយសារភាពរាប់ពាន់ដើម្បីចោទប្រកាន់ពីការប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ដោយការធ្វើទារុណកម្ម ។ ក្នុងនោះលោក ដេវីដ ឆេនដល័រ បានពន្យល់ថា «សារសំខាន់បំផុតនៃឯកសារទាំងនេះសរុបមកគឺដើម្បីជាភស្តុតាងមួយដែលបង្ហាញអំពីការភ័យព្រួយដោយគ្មានហេតុផលរបស់អ្នកដឹកនាំបក្ស ។ និយាយរួម ចម្លើយសារភាពទាំងនេះមិនមែនជាព័ត៌មានត្រឹមត្រូវពិតប្រាកដទេ ដោយសារតែខ្មែរក្រហមបានដោកជាំដោយភាពឃោរឃៅនិងការមិនទុកចិត្ត ។

ខ្មែរក្រហមក៏ចាត់ទុកថា ផលលំបាកក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធដែលមានសារសំខាន់ក្នុងការបញ្ចុះបញ្ចូលប្រជាជនជាបញ្ហារបស់កម្មាភិបាលដែលបានបញ្ជាក់ឡើងវិញជាញឹកញាប់នៅក្នុងកិច្ចប្រជុំនយោបាយ ដោយកម្មាភិបាលទាំងនោះលើកបង្ហាញឡើងវិញនូវពាក្យស្លោកបក្សកុម្មុយនីស្តជាច្រើន ដែលជារឿយៗក្នុងលក្ខណៈមិនទាក់ទាញដោយមូលហេតុថាកម្មាភិបាលខ្មែរក្រហមភាគច្រើនជាមនុស្សមិនបានរៀនសូត្រ ដែលអាចយល់អំពីគោលការណ៍របស់ខ្មែរក្រហមឲ្យបានច្បាស់លាស់ទេ ។ ដូចដែលលោក អាឡិច ហ៊ិនតុន បានពន្យល់ដែរថា «ដោយសារមិនអាចបញ្ចុះបញ្ចូលប្រជាជនបាន កម្មាភិបាលទាំងនេះប្រើការបំភិតបំភ័យនិងកម្លាំងយោធាដើម្បីបង្ខំឲ្យប្រជាជនគោរពតាមវិន័យរបស់ខ្លួន» ។ ការប្រជុំទាំងនេះធ្វើឡើងនៅតាមសហករណ៍នានាដែលបង្កើតឡើងសម្រាប់ជាផ្នែកមួយនៃការប៉ុនប៉ងរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការលុបបំបាត់ចោលនូវការកាន់កាប់ឯកជនមូលធននិយម និងដើម្បីពង្រឹងនូវឋានៈជាពលករនិងកសិករ ។ លោក អាឡិច ហ៊ិនតុន ក៏បានបន្តទៀតថា «ការអនុវត្តតាមសមូហភាវនិយមបានប៉ះពាល់ធ្ងន់ធ្ងរដល់លក្ខខណ្ឌសំខាន់បីយ៉ាងនៃទំនៀមទម្លាប់រស់នៅរបស់ប្រជាជនកសិករ ៖ ចំពោះគ្រួសារដែលមានសមាជិកជាច្រើននាក់ចូលរួមនៅក្នុងស្ថានភាពសេដ្ឋកិច្ចនិងការចំណាយផ្សេងៗ ចំពោះភូមិដែលប្រកបដោយមិត្តភក្តិនិងសាច់ញាតិច្រើនដែលមានអត្តសញ្ញាណតែមួយដូចគ្នានិងជួនកាលជួយទុក្ខធុរៈគ្នាទៅវិញទៅមក និងព្រះពុទ្ធសាសនាដែលផ្ដល់នូវការអប់រំផ្នែកសង្គម និងសីលធម៌ ក៏ដូចជាការរៀនសូត្រពីជីវិតប្រចាំថ្ងៃ» ។ ការអនុវត្តតាមសមូហភាវនិយមជ្រុលរបស់ខ្មែរក្រហម ដោយការដាក់ឲ្យរស់នៅជាសហករណ៍នេះ ជាពិសេសការបរិភោគអាហាររួម ការដាក់កំហិតយ៉ាងធ្ងន់ធ្ងរចំពោះជីវភាពគ្រួសារ ត្រូវមើលឃើញថា មិនសមហេតុផលនិងឃោរឃៅពេកដោយសារក្រុមគ្រួសារកម្ពុជាបានហូបចុករួមរាប់ពាន់ឆ្នាំមកហើយ ។ ***(នៅមានត)***

**ម៉ារីឌីត ឌីន និង ណាតាហ្សា បាច**

# ឌុច មិនអាចបំផ្លាញមនុស្សជាតិបាននោះទេ

ការបិទបញ្ចប់នៃជំនុំជម្រះក្នុងសំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលចំណាយពេលអស់មួយសប្តាហ៍បានប្រកាសជាលទ្ធផលនៅថ្ងៃនេះដែលប្រកបទៅដោយសេចក្តីថ្លែងការណ៍ដ៏វែងរបស់មេធាវីជាតិនិងអន្តរជាតិតំណាងឲ្យភាគីទាំងបួនក្រុមនៃភាគីរដ្ឋប្បវេណីសរុបទាំងអស់មានជនរងគ្រោះចំនួន៩០នាក់ ។ ក្នុងបន្ទប់សវនាការកកកុញទៅដោយអ្នកស្រុក អ្នកភូមិមកពីតំបន់នានាក្នុងប្រទេស និងជនរងគ្រោះតំណាងឲ្យភាគីរដ្ឋប្បវេណីខ្លះនិងជនបរទេសមួយចំនួនតូច ។ ក្រុមតំណាងឲ្យសង្គមស៊ីវិលនិងសារព័ត៌មានអន្តរជាតិក៏មានវត្តមានក្នុងឱកាសនោះដែរ ។ លោកស្រី ខារ៉ូល រ៉ដនី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា និងឧបការីបេសកកម្មរបស់លោកស្រីលោក ថេដ អាឡេហ្គ្រោ ក៏បានចូលរួមក្នុងសវនាការបញ្ចប់នៃជំនុំជម្រះនេះផងដែរទោះជាមិនបានចូលរួមពេញលេញក្តី ។ ដំណាក់កាលចុងក្រោយនៃអង្គសវនាការជាប្រវត្តិសាស្ត្រនេះចាប់ផ្តើមដោយការបង្ហាញនូវហេតុការណ៍គួរឲ្យចាប់អារម្មណ៍សម្រាប់ផលប្រយោជន៍ជាតិនិងអន្តរជាតិ ។

ឌុច បានចូលមកដល់ក្នុងបន្ទប់សវនាការក្នុងសម្លៀកបំពាក់អាវ-កអណ្តើកពណ៌លឿងនិងខោជើងវែងពណ៌ស ។ នៅក្នុងសវនាការពេលរសៀល ឌុច ពាក់អាវពណ៌ស ។ ឌុច ត្រូវបានដាក់ឲ្យអង្គុយនៅចំកណ្តាលនៃបន្ទប់កាត់ក្តី ដោយបែរមុខទៅរកចៅក្រម ហើយភាគីការពារក្តីនៅខាងស្តាំដៃរបស់គាត់ ចំណែកឯសហព្រះរាជអាជ្ញានិងភាគីរដ្ឋប្បវេណីនៅខាងឆ្វេង ។ ឌុច នៅរក្សាភាពនឹងនរនិងស្ងប់ស្ងាត់ពេញមួយថ្ងៃ ហើយគាត់បានចំណាយពេលរបស់គាត់ស្ទើរតែទាំងស្រុងកត់ត្រាចូលក្នុងសៀវភៅរបស់គាត់ សម្លឹងទៅរកកញ្ចក់ទូរទស្សន៍នៅពីមុខគាត់និងយូរៗម្តងងាកទៅខាងឆ្វេងដៃរបស់គាត់ដើម្បីមើលមុខអ្នកចោទប្រកាន់មកលើរូបគាត់ ។ ប៉ុន្តែនៅពេលលោក ហ្វ៊ីលីព ខាណុន មេធាវី ជនជាតិបារាំងដែលតំណាងឲ្យភាគីរដ្ឋប្បវេណីក្រុមបីនិងសហមេធាវីរបស់គាត់ឈ្មោះ ម៉ាទីន ហ្សាក់គិន ដែលជាជនជាតិបារាំងដូចគ្នាធ្វើសេចក្តីថ្លែងការណ៍ដែលប្រហែលជាពាក្យពេចន៍ដ៏មានអត្ថន័យជ្រាលជ្រៅនិងសំខាន់ជាងគេសម្រាប់ថ្ងៃបិទវគ្គនេះ ឌុច បានបញ្ឈរភ្នែកទ្រឹងពេលដែលមេធាវីទាំងពីររូបនេះបានធ្វើការតវ៉ាដែលធ្វើឲ្យខ្ញុំមានការងឿងឆ្ងល់ថាតើខ្ញុំកំពុងតែមើលឃើញដោយផ្ទាល់ភ្នែកនូវការថ្លែងវិប្បដិសារីឬក៏មិនមែនពេលដែលទ្រនិចនាទីនាឡិកាវិលហួសទៅ ។

ឌុច បានដើរសំដៅទៅកញ្ចក់ ហើយបានយកក្រដាសតូចមួយទៅបង្ហាញតាមកញ្ចក់នោះដែលមានពាក្យពេចន៍របស់គាត់សរសេរនៅលើក្រដាសនោះ ។ គាត់បានធ្វើបែបនេះចំនួនពីរដងក្នុងអំឡុងសវនាការ ។ ជនជាតិខ្មែរជាច្រើននាក់ដែលប្រហែល ឌុច ធ្លាប់ស្គាល់បានរង់ចាំគាត់ ហើយបន្ទាប់មកញញឹមមករកគាត់នៅពេលដែលអ្នកទាំងនោះអានអក្សរដែលគាត់សរសេរនៅលើក្រដាសនោះ ។ ឌុច បានដកក្រដាសចេញពីកញ្ចក់ ញញឹមងាកមុខចេញ ហើយសើច ។ ជនបរទេសម្នាក់បានដាក់ឯកសាររបស់គាត់នៅលើជញ្ជាំងកញ្ចក់ដើម្បីឲ្យ ឌុច អាន ។ ជនបរទេសហើយនិង ឌុច បានញញឹមរកគ្នា ។ ឌុច បានគោរពជនបរទេសនោះ ហើយបានត្រឡប់ទៅកាន់កៅអីអង្គុយរបស់គាត់វិញ ។ ហេតុការណ៍ចម្លែកបានកើតមានឡើងនៅក្នុងអង្គសវនាការ ប៉ុន្តែនេះគឺស្ថិតក្នុងចំណោមហេតុការណ៍ដែលគួរឲ្យរំខាន ជាពិសេសបានផ្តល់នូវការរំជួលចិត្តនិងការបន្ទោសរបស់ភាគីរដ្ឋប្បវេណីសម្រាប់ថ្ងៃនេះ ។

ការតវ៉ារបស់ភាគីរដ្ឋប្បវេណីមានការប្រែប្រួលយ៉ាងខ្លាំងទាំងគំនិតយោបល់និងសេចក្តីថ្លែងការណ៍ ។ វិធាន២៣នៃវិធានផ្ទៃក្នុងបានចែងថា ភាគីរដ្ឋប្បវេណីអាចចូលរួមក្នុងគោលបំណងគាំទ្រព្រះរាជអាជ្ញានិងដើម្បីអនុញ្ញាតឲ្យជនរងគ្រោះអាចស្វែងរកការជួលជុលរបួសក្នុងលក្ខណៈសីលធម៌និងលក្ខណៈសមូហភាព ។ ករណីនេះពិតជាមិនអាចយកមកប្រើប្រាស់ទេសម្រាប់ថ្ងៃនេះ ។ លោកប្រធានចៅក្រម និល ណុន បានបើកសវនាការនៅពេលរសៀលបន្ទាប់ពីក្រុមមួយនិងក្រុមពីរបានតវ៉ារួចដោយធ្វើការ

រំឭកដល់មេធាវីភាគីរដ្ឋប្បវេណីថាត្រូវតែធ្វើសេចក្តីថ្លែងការណ៍ដោយអនុលោមទៅតាមវិធានទី២៣ ។ លោក និល ណុន បានអះអាងថា សវនាការនៅពេលព្រឹកបានចាកឆ្ងាយចេញពីវិធានដែលបានចែង ។ ចំណែកឯការតវ៉ានៅពេលរសៀលមើលទៅដូចជាធ្វើទៅតាមការណែនាំរបស់ លោក និល ណុន ។ ពេលវេលាដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីរៀបចំការផ្តោតទៅលើកិច្ចការថ្ងៃនេះទៅលើផលប្រយោជន៍កូនក្តីរបស់ខ្លួន ហើយតម្រូវឲ្យមានការដោះស្រាយបញ្ហាក្នុងភាពសមស្រប ខ្ញុំយល់ឃើញថាជារឿងមួយគួរឲ្យភ្ញាក់ផ្អើលដែលមេធាវីខ្លះមិនបានរៀបចំនិងធ្វើសេចក្តីថ្លែងការណ៍ឲ្យមានប្រសិទ្ធភាពជាងនេះ ។

## ក្រុម១


លោក ការីម ខាន់

ព្រះរាជអាជ្ញាម្នាក់ លោក ការីម ខាន់ ដែលចេះភាសាអង់គ្លេសយ៉ាងជ្រៅជ្រះបានធ្វើសេចក្តីថ្លែងការណ៍បើកវគ្គសម្រាប់ភាគីរដ្ឋប្បវេណីក្រុមមួយដែលមានសមាជិក៣៥ រូប ។ លោក ការីម ខាន់ មិនបានធ្វើការបង្ហាញសវនាការ ឌុច ទាំងស្រុងទេ ហើយគាត់បានទទួលស្គាល់កិច្ចការរបស់សហមេធាវីរបស់គាត់ដោយមានលោក អាឡាំង វេណើ មកពីប្រទេសស៊ុីស (អវត្តមានថ្ងៃនេះ) លោកមេធាវី ប្រែអ៊ិន ម៉េកហ្គូនីគល មកពីសហរដ្ឋអាមេរិក និង ទី ស្រ៊ីណា ជាមេធាវីខ្មែរដែលឡើងនិយាយបន្ទាប់ពីលោក ការីម ខាន់ ។ លោកបាននិយាយដោយក្តីគោរពទៅកាន់ចៅក្រមទាំងប្រាំរូប ហើយបាននិយាយដោយពាក្យពេចន៍មានខ្លឹមសារ ។ លោកទទួលស្គាល់ថា មានការចាប់ផ្តើមជាលើកដំបូងជាច្រើននៅក្នុងអង្គសវនាការនេះរួមមានតុលាការអន្តរជាតិជាលើកដំបូងដែលភាគីរដ្ឋប្បវេណីមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការសវនាការ ។ លោកក៏បានធ្វើការពន្យល់ផងដែរថា ទោះបីជាមានបញ្ហាមិនប្រក្រតីនិងល្អកើតចេញពីតំណាងភាគីរដ្ឋប្បវេណីនៅក្នុងដំណើរការសវនាការក៏ដោយ ក៏កិច្ចការរបស់ពួកគេទាំងនោះត្រូវបានបំពេញក្នុងបុព្វហេតុយ៉ាងល្អក្នុងគោលបំណងច្បាស់លាស់ដើម្បីធ្វើឲ្យដំណើរការនេះប្រព្រឹត្តទៅដោយល្អប្រសើរដោយភាគីកម្ពុជានិងអង្គការសហប្រជាជាតិ ។

លោក ការីម ខាន់ ក៏បានសង្កត់ធ្ងន់អំពីតម្រូវការក្នុងការចែកឲ្យដាច់រវាងភាពមន្ទិលសង្ស័យនិងការពិត ។ គាត់បានកត់សម្គាល់ថា ការចោទប្រកាន់ដែលភាគីរដ្ឋប្បវេណីចង់បានគឺការសងសឹកត្រូវបានបំពេញ ឬសងឈាមនៅអំឡុងពេលសវនាការ ។ ភាគីការពារក្តីបានបញ្ជាក់អះអាងដោយនិយាយថា «យើងនៅក្នុងតុលាការដែលមានច្បាប់ មិនមែននៅក្នុងផ្សារលក់អីវ៉ាន់ដែលម្នាក់ៗគប់ដុំថ្មសំដៅជនជាប់ចោទទេ» ។ ប៉ុន្តែ លោក ការីម ខាន់ បាននិយាយបកស្រាយថា ភាគីរដ្ឋប្បវេណីទាំងអស់មិនធ្វើតាមគោលការណ៍ស្វែងរកការសងសឹកទេ ។ ប៉ុន្តែ អ្នកទាំងអស់នោះគោរពនូវដំណើរការតុលាការ ដូច្នេះពួកគេអាចទទួលបានលទ្ធផលនិងការពិតនូវអ្វីដែលបានកើតមានឡើងនៅទួលស្លែង ។

លោក ការីម ខាន់ បាននិយាយថា ក្រោយមកក្រុមប្រឹក្សាការពារក្តីបានធ្វើសំណើថា «យើងមិនបានធ្វើអ្វីលើសពីការកាត់ទោសទេ» ។ លោក ការីម ខាន់ បានសង្កត់ធ្ងន់ថា វិធានទី២៣ បានកំណត់អំពីវិសាលភាពនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ លោក ការីម ខាន់ ក៏បានអះអាងថា «យើងមិនបានធ្វើតាមព្រះរាជអាជ្ញាទេ» ។ ជាការពិត លោក ការីម ខាន់ បានបម្រុងទុកលើករណីទ្រឹស្តីនៃបទឧក្រិដ្ឋរួមរបស់ព្រះរាជអាជ្ញានៅក្នុងករណីដែលគេរាល់គ្នាដឹងពុ ។ ក្រុមទីមួយមិនបានដាក់ឯកសារ ដើម្បីគាំទ្រទ្រឹស្តីដែលបានលើកឡើងនោះទេ ។

លោក ការីម ខាន់ បានអះអាងថា ចំណុចសំខាន់របស់តុលាការគឺមិនមែនដើម្បីតែរកខុសឬត្រូវនៃករណី ឌុច ប៉ុណ្ណោះទេ ។ មួយក្នុងចំណោមចំណុចសំខាន់ទាំងឡាយអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ក្រៅអំពីការទាមទារសំណង) គឺថាការអនុញ្ញាតឲ្យជនរងគ្រោះមកចូលរួមនៅចំពោះមុខចៅក្រមដើម្បីផ្តល់ឱកាសដល់ពួកគាត់ក្នុងការបញ្ចេញគំនិតអំពីផលប៉ះពាល់នៃបទឧក្រិដ្ឋមកលើជីវិតរស់នៅរបស់គាត់ ។ នេះគឺជាចំណុចដ៏សំខាន់ដែលមានតែជនរងគ្រោះប៉ុណ្ណោះដែលអាចផ្តល់ជូនបាន ។

មេធាវីការពារក្តីបានតវ៉ាថា ដើមបណ្តឹងរដ្ឋប្បវេណីបានបង្កើតនូវភាពមិនស្មើភាពគ្នានៅក្នុងបន្ទប់សវនាការដែលការតវ៉ា

នេះបានធ្វើឲ្យលោក ការីម ខាន់ ធ្វើការបដិសេធ ។ លោក ការីម ខាន់ បានបដិសេធថា ឌុច បានប្រឈមមុខជាមួយព្រះរាជអាជ្ញាចំនួន៥នាក់ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏មិនមែនជាព្រះរាជអាជ្ញាដែរ ។ ពួកគេមិនបានទទួលប្រាក់ឧបត្ថម្ភពីតុលាការទេ ។ នេះគឺជាករណីមួយទោះបីជាវិធានជាមូលដ្ឋាននៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលក្នុងនោះសិទ្ធិគួរតែអនុញ្ញាតឲ្យមានទាំងក្នុងការអនុវត្តនិងទាំងការធ្វើឲ្យមានប្រសិទ្ធភាពដោយមិនមានភាពផ្គាំផ្គង ។ លោក ការីម ខាន់ បានបញ្ជាក់ទៀតថា ភាគីរដ្ឋប្បវេណីមានការខ្វះខាតនូវធនធានដូចជាព្រះរាជអាជ្ញានិងមេធាវីការពារ ដោយបញ្ជាក់ថា ភាពមិនស្មើភាពគ្នាគឺជាបញ្ហាមួយដែលមិនមានការចាត់ទុកឲ្យបានល្អប្រសើរសម្រាប់ភាគីរដ្ឋប្បវេណីជាជាងការបង្កើតនូវលទ្ធភាពដោយផ្តល់រថយន្តសម្រាប់ភាគីការពារក្តី ។

លោក ការីម ខាន់ បានធ្វើការសន្និដ្ឋានអំពីសេចក្តីថ្លែងការណ៍ជាលើកដំបូងរបស់គាត់ដោយធ្វើការរំឭកដល់ចៅក្រមថា ការទទួលយកនូវការចោទប្រកាន់របស់ ឌុច មិនតម្រូវឲ្យថា ការចោទប្រកាន់ទាំងអស់នោះត្រូវបានបង្ហាញនៅចំពោះមុខជនជាប់ចោទនោះទេ ។ លោក ការីម ខាន់ បានបន្ថែមទៀតថា ចៅក្រមត្រូវតែធ្វើការពិនិត្យភ័ស្តុតាងឡើងវិញថាតើអ្វីដែល ឌុច បានសារភាពជាការពិតដែរឬទេ ។ លោក ការីម ខាន់ បានបន្ថែមថា នៅពេលដែលភ័ស្តុតាងទាំងអស់ត្រូវបានពិនិត្យឡើងវិញ នោះនឹងបង្ហាញនូវការសន្និដ្ឋានតែមួយគត់គឺ ៖ ក្នុងករណីសំខាន់និងពិសេស ឌុច បានស្វែងរកនូវការមិនទទួលខុសត្រូវនិងបន្ថយនូវតួនាទីរបស់គាត់ ។

ក្រោយមក មេធាវីខ្មែរប្រចាំក្រុមមួយ កញ្ញា ទី ស្រ៊ីណា បានឡើងមានមតិ ។ នៅពេលដែល ទី ស្រ៊ីណា ចាប់ផ្តើមនិយាយ ព្រះសង្ឃចំនួនបីអង្គក្នុងស្បង់ពណ៌ទឹកក្រូចបានចូលក្នុងបន្ទប់សវនាការ ដែលធ្វើឲ្យសេចក្តីថ្លែងនោះកាន់តែមានចំណាប់អារម្មណ៍ជាងមុន ។ ទី ស្រ៊ីណា បានរៀបរាប់អំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការគាស់កកាយរកការពិតនៃបទឧក្រិដ្ឋ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានទទួលរងនូវការឈឺចាប់ដ៏ធំធេងពេញមួយជីវិត ។ ទី ស្រ៊ីណា បានបន្ថែមទៀតថា បើសិនជាជនរងគ្រោះទាំងនោះមិនបានចូលរួមក្នុងដំណើរការកាត់ទោសនេះទេនោះ អង្គសវនាការនឹងមានការលំបាកក្នុងការវាស់ស្ទង់មើលទំហំនៃបទឧក្រិដ្ឋនិងទុក្ខវេទនានៅមន្ទីរស-២១ ។ គោលបំណងរបស់ជនរងគ្រោះទាំងអស់នេះគឺដើម្បីស្វែងរកយុត្តិធម៌សម្រាប់ពួកគេនិងសម្រាប់មនុស្សជាទីស្រឡាញ់ដែលបានបាត់បង់ទៅ ។ អាណត្តិរបស់តុលាការគឺដើម្បីជួយភាគីរដ្ឋប្បវេណីទាំងអស់នេះបន្ធូរបន្ថយនូវភាពឈឺចាប់ និងទុក្ខសោកវេទនា ។

ដោយសារតែជនរងគ្រោះនៅមន្ទីរស-២១មិនត្រូវបានប្រាប់អំពីកំហុសរបស់ខ្លួននៅពេលដែលពួកគាត់ត្រូវបានចាប់ខ្លួនដោយខ្មែរក្រហម តុលាការនេះបានផ្តល់ឱកាសក្នុងការស្វែងរកការពិតនិងធានាថាយុត្តិធម៌នឹងត្រូវបានផ្តល់ជូន ។ ហេតុអ្វីបានជាជនរងគ្រោះទាំងនោះត្រូវបានចាប់ខ្លួន? តុលាការនេះក៏មានតួនាទីក្នុងការបង្រួបបង្រួមជាតិផងដែរ ។


កញ្ញា ទី ស្រ៊ីណា

ក្រោយមក ទី ស្រ៊ីណា បានបន្តរៀបរាប់អំពីចំនួនដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់នៅក្នុងក្រុមមួយ និងជនរងគ្រោះជាច្រើនទៀតនៅទួលស្លែងដែលបានធ្វើជាអ្នកតំណាង ។ ការរៀបរាប់របស់ ទី ស្រ៊ីណា ត្រូវបានបង្ហាញរួចហើយនៅអំឡុងពេលនៃការធ្វើសក្ខីកម្មលើកដំបូង ។ ប៉ុន្តែ ទី ស្រ៊ីណា បានធ្វើការរៀបរាប់យ៉ាងវែងដែលធ្វើឲ្យស៊ីពេលជាច្រើនសម្រាប់ក្រុម១ ដែលជាហេតុធ្វើឲ្យ ទី ស្រ៊ីណា ត្រូវតែអានឈ្មោះជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងញាប់ដោយមិនបានរៀបរាប់ឲ្យបានលម្អិតអំពីព័ត៌មានដែលទាក់ទងទៅនឹងជនរងគ្រោះទាំងនោះផងទេ ។

សេចក្តីថ្លែងការណ៍របស់ ទី ស្រ៊ីណា និង លោក ការីម ខាន់ បង្ហាញថា អ្នកទាំងពីរមិនបានត្រៀមពាក្យពេចន៍និយាយ និងពេលវេលាក្នុងឱកាសបិទបណ្តឹងតវ៉ានេះឲ្យបានល្អគ្រប់ជ្រុងជ្រោយទេ សម្រាប់ក្រុម១ ។ ភាពខ្វះសណ្តាប់ធ្នាប់បានកើតមានឡើង ។ ទី ស្រ៊ីណា បានបញ្ចប់សេចក្តីថ្លែងការណ៍យ៉ាងប្រញាប់ដោយបញ្ជាក់នូវចំណុចសំខាន់ថា ឯកសារជាច្រើនដែលបង្ហាញអំពីទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះជាច្រើនត្រូវបាន

បំផ្លាញនៅក្នុងរបបខ្មែរក្រហម ហើយនិងនៅពេលក្រោយទៀត ។ ទី ស្រ៊ីណា បានពន្យល់ថា ខ្លួនក៏មានផលលំបាកក្នុងការឆ្លើយតបទៅនឹងការតវ៉ានិងការសួរដេញដោលរបស់មេធាវីការពារក្តីដែរ ។

ក្រោយមក លោក ការីម ខាន់ បានក្រោកឡើងនិយាយសម្រាប់ក្រុមមួយជារបៀបថ្លែងការណ៍ដោយស៊ីពេលអស់ជិតមួយនាទី ។ សម្តីរបស់លោក ការីម ខាន់ នេះហើយដែលធ្វើឲ្យលោកប្រធាន និល ណុន នឹកឃើញឡើងវិញដែលបន្តិចក្រោយមកបានព្រមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យរក្សានូវបរិបទរបស់ខ្លួនឲ្យស្របតាមវិធាន២៣ ។ លោក ការីម ខាន់ បានបង្ហាញនូវជំនាញជាក់ច្បាស់របស់ខ្លួនដូចខ្លួនគាត់ជាព្រះជាអាជ្ញាដែលប្រឆាំងនឹង ឌុច អ៊ីចឹងដែរ ។ ខណៈពេលដែលការគាំទ្រសម្រាប់ព្រះរាជអាជ្ញាគឺជាផ្នែកមួយនៃវិធាន២៣ ចៅក្រមហាក់បីដូចជាមានការស្ទាក់ស្ទើរក្នុងការចាត់ទុកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាការលូកដៃជ្រៅចូលទៅក្នុងបញ្ហាបទឧក្រិដ្ឋរបស់ជនជាប់ចោទ ។

លោក ការីម ខាន់ បានលើកយកបញ្ហាអំពីការតវ៉ារបស់ ឌុច ដែលថាគាត់មិនមានសិទ្ធិស្វ័យសម្រេចទេនៅមន្ទីរស-២១ គឺថាគាត់គ្រាន់តែជាឧបករណ៍មួយប៉ុណ្ណោះ ។ វាគឺជាជំរំដែលនាំមនុស្សទៅរកសេចក្តីស្លាប់ដឹកនាំដោយ ឌុច ។ ឌុច មិនបានប្រើសិទ្ធិស្វ័យសម្រេចរបស់ខ្លួនដើម្បីកាត់បន្ថយភាពឈឺចាប់របស់អ្នកទោសទាំងនោះឡើយ ។ លោក ការីម ខាន់បានអះអាងយ៉ាងច្បាស់ថា «មិនមានការជួយសង្គ្រោះបានទេនៅចំពោះមុខ ឌុច» ។ ឌុច គឺជាមនុស្សម្នាក់ដែលមានការប្តេជ្ញាចិត្តមោះមុតចំពោះការងារ ។ លោក ការីម ខាន់ បន្ថែមថា ប៉ុន្តែអ្វីដែលគាត់អាចសម្រេចបានគឺមិនមែនតែចំពោះមន្ទីរស-២១តែមួយនោះទេ ។ យុទ្ធនាការនៃការបំភិតបំភ័យនិងទារុណកម្មដែល ឌុច បានដឹកនាំនៅមន្ទីរស-២១ បានជះឥទ្ធិពលដល់ការកើតឡើងនូវជំងឺផ្លូវចិត្តនិងការមិនទុកចិត្តគ្នាទូទាំងប្រទេសនៅក្នុងជួរដឹកនាំបក្ស ហើយបានបង្កើតនូវវដ្តចក្រដែលនាំឲ្យមានការចាប់ខ្លួនកាន់តែច្រើនឡើងៗ ហើយមនុស្សជាច្រើនរូបត្រូវបានធ្វើទារុណកម្មដើម្បីទទួលយកចម្លើយសារភាពដែលខុសពីការពិត ហើយចម្លើយសារភាពនោះបានដាក់បន្ទុកទៅលើអ្នកផ្សេងទៀតរហូតដល់មានការចាប់ខ្លួនជាបន្តបន្ទាប់ទៀត ។ ឌុច បានធ្វើកិច្ចការទាំងអស់នេះដោយសារតែគាត់មានមនោគមន៍វិជ្ជាដូចគ្នាទៅនឹងភាពជាអ្នកដឹកនាំដែរ ។ នេះមិនមែនដោយសារតែគាត់ចង់ក្លាយខ្លួនជាផ្នែកមួយរបស់ក្រុមដ៏មានអំណាចមួយនោះទេ តែគាត់ការធ្វើបែបនេះគឺដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ ។

លោក ការីម ខាន់ បន្តថា ភ័ស្តុតាងបានបញ្ជាក់ច្បាស់ដោយខ្លួនឯងហើយ ។ អំឡុងពេលនៃភាពរីកវរពេលដែលកងទ័ពវៀតណាមលុកលុយចូលមក គាត់អាចមានជម្រើសដោយឲ្យអ្នកទោសរត់គេចបាន តែ ឌុច បែរជាសម្លាប់អ្នកទោសទាំងនោះទៅវិញ ។ ឌុច បានបញ្ជាក់នូវភាពឆ្លាតវៃក្នុងការដោះស្រាយបញ្ហាកាលពីគាត់នៅក្មេងវ័យក្នុងកម្រិតវិទ្យាល័យ ហើយគាត់បានធ្វើកិច្ចការនៅឯមន្ទីរស-២១ដោយបំណងចង់ធ្វើ ។ ឌុច អាចមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការរាយការណ៍ទៅថ្នាក់លើដែលជាអ្នកដឹងអំពីអ្វីដែលគាត់បានស្នើជូន ។ នៅពេលដែលមេធាវីការពារក្តីស្វះស្វែងរកការបន្ថយតួនាទីរបស់ ឌុច មេធាវីការពារក្តីមិនបាននិយាយពីជម្រើសដែលអាចនាំឲ្យមានការបន្ថយតួនាទីរបស់ឌុចទេ ។ គ្មានឯកសារណាមួយបញ្ជាក់ពី ឌុច ទទួលយកសណ្ឋាននៃការធ្វើទារុណកម្មពីស្ថាប័នណាមួយឡើយ តែគាត់បានរៀបចំតាក់តែងប្រព័ន្ធដ៏មានលក្ខណៈសាហាវនិងព្រៃផ្សៃដែលបានអនុវត្តនៅមន្ទីរម-១៣ ហើយក្រោយមកប្រើប្រាស់នៅមន្ទីរស-២១ ។ ឌុច បានអះអាងបញ្ជាក់ថា គាត់បានដាក់អ្នកទោសចូលក្នុងរណ្តៅនៅមន្ទីរម-១៣ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក តែតាមការពិតយុទ្ធនាការទម្លាក់គ្រាប់បែកបានបញ្ចប់រួចទៅហើយ ។ លោក ការីម ខាន់ បាននិយាយបន្តទៀតថា ភាពមិនយល់ស្របបានកើតមានឡើងនៅពេលដែល ឌុច ព្យាយាមកែប្រែនិងបន្ថយតួនាទីរបស់ខ្លួននៅក្នុងលក្ខណៈមិនអាចទទួលយកបាន ។ ឌុច មិនបានដាក់ពិន័យដល់សន្តិសុខដែលបញ្ជាឲ្យអ្នកទោសស៊ីលាមកខ្លួនឯងទេ ។ លោក ការីម ខាន់ បានអះអាងយ៉ាងច្បាស់បន្ថែមថា វាជារឿងដ៏លេលាដែល ឌុច បានប្រាប់ក្រុមសួរចម្លើយបញ្ជាទៅលើអ្នកទោសឲ្យគូររូបសត្វឆ្កែ ហើយឲ្យអ្នកទោសគោរពរូបភាពនោះក្នុងគោលបំណងចាត់ទុកអ្នកទោសស្ថិតក្នុងសភាពអន់ជាងសត្វនោះទៅទៀត ។

លោក ការីម ខាន់ បានបញ្ជាក់បន្ថែមថា ទោះជា ឌុច បាន

បង្ហាញនូវវិប្បដិសារីក្នុងចំណុចតូចណាមួយក៏ដោយ នៅពេលដែលនរណាម្នាក់ធ្វើការប្រៀបធៀបនូវអ្វីដែលគាត់បានសារភាពនៅក្នុងអង្គសវនាការអំពីការពិតនិងគំរូនៃការបង្រួបបង្រួម ការលើកលែងទោសក្រោមយន្តការបែបនេះត្រូវបានផ្តល់ជូនបាន លុះត្រាតែសាក្សីបានសារភាពនូវការពិតនិងវិប្បដិសារីពិតប្រាកដប៉ុណ្ណោះ ។ លោក ការីម ខាន់ បានអង្វរដល់ចៅក្រមឲ្យ «ប្រតិកម្ម» ចំពោះការពិតដែល ឌុច មិនបានធ្វើដូចបទដ្ឋានខាងលើនោះ ។ លោក ការីម ខាន់ បានបន្ថែមថា យុទ្ធសាស្ត្ររបស់ ឌុច គឺដើម្បីបំភាន់តុលាការ ។ លោក ការីម ខាន់ បានបញ្ចប់សេចក្តីថ្លែងការណ៍ដោយស្នើទៅចៅក្រមដើម្បីឲ្យធ្វើការពិចារណាទៅលើភ័ស្តុតាងដោយយកចិត្តទុកដាក់បញ្ជាក់ថា ការពិតមិនចាំបាច់តម្រូវឲ្យយកមួយសេនមកដូសដុលនូវការឈឺចាប់ទេ ។ ប៉ុន្តែការពិតគឺមានតម្លៃឥតឧបមាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ លោក ការីម ខាន់ បានស្នើចៅក្រមឲ្យមើលឃើញពីកំហុសរបស់ ឌុច ចំពោះបទដែលបានចោទប្រកាន់ ។

## ក្រុម ២


លោកស្រី ស៊ីលកេ ស៊ុដហ្ស៊ីនស្គី

បន្ទាប់ពីរង់ចាំមួយសន្ទុះ មេធាវីក្រុម២ លោកស្រី ស៊ីលកេ ស៊ុដ ហ្ស៊ីនស្គី មកពីប្រទេសអាល្លឺម៉ង់បានរៀបរាប់ពីជីវិតផ្ទាល់ខ្លួនរបស់គាត់ក្នុងនាមជាពលរដ្ឋម្នាក់ដែលធ្លាប់ឆ្លងកាត់រឿងរ៉ាវអតីតកាលរបស់ប្រទេសអាល្លឺម៉ង់ ។ ទោះជាមានតុលាការនូរ៉េមប៊ើកក៏ដោយ ក៏អំពើព្រៃផ្សៃនៅតែកើតមានដដែលចាប់តាំងពីសង្គ្រាមលោកលើកទី២មក ។ លោកស្រីមានជំនឿថា សវនាការ ឌុច នឹងបញ្ឈប់នូវចន្លោះប្រហោងនៃនិទ្ទណ្ឌភាពដែលកើតមានឡើងក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ ជាពិសេសចំពោះហេតុការណ៍ដែលកើតឡើងក្នុងជំនាន់ ប៉ុល ពត ។ លោកស្រីនិងក្រុមរបស់គាត់តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំនួន១៧នាក់នៅក្នុងក្រុម២ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែដោះស្រាយជាមួយអ្វីដែលបានកើតឡើងជារៀងរាល់ថ្ងៃ ។ ហេតុអ្វីបានជាជនរងគ្រោះត្រូវបានចាប់ដាក់គុកនិងទទួលទារុណកម្ម នៅពេលដែលជនរងគ្រោះទាំងនោះគ្មានកំហុសអ្វីសោះ? តើជនរងគ្រោះទាំងនោះត្រូវបានសួរចម្លើយដោយវិធីណា ហើយដោយនរណា? តើជនរងគ្រោះទាំងនោះត្រូវបានសម្លាប់ដោយវិធីណា? ដោយនរណា? តុលាការមិនអាចឆ្លើយសំណួរទាំងអស់នោះបានទេ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងនូវការរំខានខាងផ្លូវអារម្មណ៍ពេញមួយជីវិតនោះទាមទារឲ្យបកស្រាយនូវការពិតទាំងអស់នោះ ។ តុលាការគឺជាវិធីសាស្ត្រតែមួយគត់ក្នុងការស្តាបនាកិត្យានុភាពរបស់ជនរងគ្រោះឡើងវិញ ។ លោកស្រីបានរៀបរាប់រឿងរ៉ាវអតីតកាលរបស់ភាគីរដ្ឋប្បវេណីចំនួន៩នាក់ដែលលោកស្រីធ្វើជាអ្នកតំណាងដែលជនរងគ្រោះទាំង៩នាក់នោះមិនបានចូលមកក្នុងតុលាការទេ ។

បន្ទាប់មក លោកស្រី ស៊ុដហ្ស៊ីនស្គី បានធ្វើការរិះគន់យ៉ាងខ្លាំងដល់ចៅក្រម ហើយនិយាយពីអ្វីដែលចៅក្រមមិនបានដោះស្រាយឲ្យបានល្អប្រសើរចំពោះភាគីរដ្ឋប្បវេណី ។ លោកស្រីបានចោទចៅក្រមថាមិនមានសមានចិត្តចំពោះទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ លោកស្រីនិយាយថា «អរគុណ» គឺជាពាក្យពីរម៉ាត់តែមានន័យច្រើនណាស់ តែចៅក្រមមិនដែលនិយាយពាក្យនេះចេញមកទាល់តែសោះចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។ គ្មានការយកចិត្តទុកដាក់គ្រប់គ្រាន់ថាតើដើមបណ្តឹងរដ្ឋប្បវេណីទទួលនូវអារម្មណ៍ប៉ះទង្គិចផ្លូវចិត្តប៉ុនណា ហើយតើជនរងគ្រោះមិនបានសម្រាន្តលក់យ៉ាងណាមុននឹងមកផ្តល់សក្ខីកម្មនោះ ។ ជនរងគ្រោះទាំងនោះមានការឈឺចាប់ណាស់ដែលជាហេតុនាំឲ្យពួកគាត់មានការភ្លេចភ្លាំងនិងនិយាយមិនបានល្អ ។ លោកស្រីបន្ថែមថា គ្មានអ្នកជំនាញណាម្នាក់មិនត្រូវបានយកចិត្តទុកដាក់មិនបានល្អប្រសើរនោះទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានប្រាប់ឲ្យចេះគ្រប់គ្រងអារម្មណ៍រំជួលចិត្តខ្លួនឯង ដូចច្នេះគាត់បានព្យាយាមទប់ទឹកភ្នែកកុំឲ្យស្រក់ និងទប់អារម្មណ៍មិនឲ្យទុក្ខសោក ។ ប៉ុន្តែ ការបញ្ចេញអារម្មណ៍ឈឺចាប់និងការប៉ះទង្គិចផ្លូវអារម្មណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញនូវឧក្រិដ្ឋកម្មរបស់ ឌុច ហើយចៅក្រមគួរតែមើលឃើញនូវសកម្មភាពនេះ ។ នៅពេលដែលជនរងគ្រោះម្នាក់ត្រូវបានប្រាប់ឲ្យបង្ហាញមុខរបួស

របស់ខ្លួនជាសាធារណៈនៅក្នុងបន្ទប់សវនាការ មេធាវីបានធ្វើអន្តរាគមន៍ ហើយសំណាងហើយដែលយើងបានធ្វើដំណើរពីសំណើរបស់ចៅក្រម ។ លោកស្រីបានអះអាងបញ្ជាក់ថា មេធាវីរដ្ឋប្បវេណីតែងតែត្រូវបានកាត់សន្ទាក់សម្តីដោយលោកប្រធានតុលាការ ហើយលោកប្រធានបានបង្ហាញអារម្មណ៍ថា ចៅក្រមមិនមានចំណាប់អារម្មណ៍មកលើដើមបណ្តឹងរដ្ឋប្បវេណីទេ ។

លោកស្រីបានរិះគន់មេធាវីការពារក្តីជនជាតិខ្មែរលោក ការ សាវុត្ថ ពីអ្វីដែលគាត់បានតិះដៀលកេរ្តិ៍ខ្មាស់ដល់មេធាវីអន្តរជាតិម្នាក់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ លោកស្រីបានសួរថាតើហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានចាត់ទុកឲ្យស្មើភាពគ្នាដោយក្តីគោរព ។ លោកស្រីបានឆ្ងល់ថា «តើភាពឈឺចាប់មានការលំបាកក្នុងការទ្រាំដែរឬទេ?» លោកស្រីបន្ថែមថា លោកប្រធានតុលាការគួរតែការពារផលប្រយោជន៍របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ទោះបីជាមិនសូវមានភាពល្អប្រសើរក៏ដោយ ក៏ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានការពេញចិត្តនឹងរៀបរាប់ពីរឿងរ៉ាវរបស់គាត់នៅចំពោះមុខតុលាការដែរ ។

ក្រោយពីរៀបរាប់នូវរឿងរ៉ាវនិងទុក្ខសោកវេទនារបស់ជនរងគ្រោះចុងក្រោយ លោកស្រីបានបញ្ចប់ដោយរៀបរាប់ពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលជាជនរងគ្រោះពីការចាប់រំលោភ ។ ជនរងគ្រោះម្នាក់នោះនៅតែរក្សាការសម្ងាត់ក្នុងខ្លួនអស់រយៈពេលជាច្រើនឆ្នាំពីព្រោះការប្រាប់ឲ្យអ្នកដទៃដឹងពីរឿងដែលត្រូវបានរំលោភនៅក្នុងប្រទេសកម្ពុជាចាត់ទុកថាជា «រឿងអាម៉ាស់» សម្រាប់ប្រជាជនកម្ពុជា ។ ប៉ុន្តែនៅពេលដែលជនរងគ្រោះនោះបានឃើញ ឌុច នៅក្នុងបន្ទប់សវនាការ គាត់មិនបានទប់ភាពស្ងៀមស្ងាត់តទៅទៀតបានឡើយ ។ វានឹងគ្មានយុត្តិធម៌សម្រាប់ជនរងគ្រោះដោយការចាប់រំលោភទេ បើសិនជាអ្វីដែលគាត់បានទាមទារត្រូវបានបដិសេធ ។


លោក គង់ ពិសី

មេធាវីខ្មែរ គង់ ពិសី បាននិយាយដោយផ្តោតទៅលើឧក្រិដ្ឋកម្មរំលោភផ្លូវភេទ ហើយគាត់បានរិះគន់ ឌុច ដែលធ្វើមិនដឹងអំពីក្រមព្រហ្មទណ្ឌស្តីពីឧក្រិដ្ឋកម្ម ។ ទង្វើរបស់ ឌុច គឺជាការទះកំផ្លៀងដល់ជនរងគ្រោះ ។ មេធាវី គង់ ពិសី បានអះអាងទៀតថា ឌុច បានព្យាយាមគេចពីការទទួលខុសត្រូវនៅពេលដែលមានការចោទប្រកាន់មកលើគាត់ ។ ស្ត្រីជាច្រើនមានអារម្មណ៍ថាខ្លួនជាចំណីតណ្ហាផ្លូវការក្រោមការបញ្ជារបស់ ឌុច ។ លោកមេធាវីបានផ្តល់ឧទាហរណ៍មួយចំនួនដូចជាអ្នកយាមគុកបុរសជាអ្នកមើលការខុសត្រូវអ្នកទោសស្ត្រី ។ ដោយសារតែអ្នកទោសស្រីទាំងអស់នោះរង់ចាំតែថ្ងៃស្លាប់ ស្ត្រីជានោះអាចក្លាយជាចំណីតណ្ហារបស់អ្នកយាមគុកបានយ៉ាងស្រួល ។ ប៉ុន្តែ ឌុច មិនបានហាមឃាត់ការរំលោភបំពានឬដាក់ទណ្ឌកម្មដល់ជនល្មើលដែលប្រព្រឹត្តអំពីបៀតបៀនផ្លូវភេទទេ ។ គាត់ថែមទាំងអនុញ្ញាតឲ្យអ្នកយាមធ្វើឲ្យអ្នកទោសប្រុសមានភាពអាម៉ាសដោយជេប្រទេចអ្នកទោសទាំងនោះនៅពេលដែលអ្នកទោសទាំងនោះស្រាតខោអាវចេញទាំងអស់នៅអំឡុងពេលបាញ់ទឹក ។ នេះគឺជាការបំពារបំពានផ្លូវភេទដែលរំលោភបំពានក្រឹត្យក្រមមនុស្សជាតិប្រឆាំងនឹងអ្នកទោស ។

លោកមេធាវីបានសង្កត់ធ្ងន់ថា ឌុច មិនមែនជាអ្នកទទួលខុសត្រូវទាំងស្រុងទេ ។ គាត់គឺជាមនុស្សម្នាក់ដែលមានសមានចិត្តនិងឆន្ទៈ និងសមត្ថភាពគ្រប់គ្រងយ៉ាងល្អចំពោះលក្ខខណ្ឌរស់នៅក្នុងគុក ។ លោកមេធាវីបានបញ្ជាក់ទៀតថា ឌុច មិនត្រឹមតែមានមោទនភាពចំពោះកិច្ចការរបស់ខ្លួនប៉ុណ្ណោះទេ គាត់ក៏ជាមនុស្សដែលរីករាយនឹងអំណាចក្នុងនាមជាមនុស្សឃ្លានអំណាចម្នាក់ដែរ ។ គោលបំណងរបស់ ឌុច គឺត្រូវរក្សាអំណាចរបស់ខ្លួនឲ្យបាន ។ ក្រោយមក គាត់បានប្តូរទៅកាន់សាសនាគ្រិស្តវិញដើម្បីទទួលអំណាចសាសនាគ្រិស្តជាជាងរស់នៅក្រោមពុទ្ធសាសនាដែលគាត់ត្រូវធ្លាក់នរក១៨ជាន់ហើយគ្មានឱកាសនិងចាប់ជាតិវិញបានទេ ។ នៅក្នុងបន្ទប់តុលាការ មេធាវី គង់ ពិសី បានអះអាងថា ឌុច មិនមានភាពស្មោះត្រង់និងនិយាយការពិតទេ ហើយការសារភាពរបស់គាត់មានភាពត្រឹមត្រូវតែពាក់កណ្តាលប៉ុណ្ណោះ ។ មានសំណួរជាច្រើនដែលបានចោទសួរ ហើយគាត់មិនបានឆ្លើយដើម្បីគេចពីការទទួលខុសត្រូវ ។ លោកមេធាវីបន្តថា ឌុច មិនបានរក្សាពាក្យសន្យាថាត្រូវឆ្លើយការពិតទាំងអស់ដល់ដើមបណ្តឹង

រដ្ឋប្បវេណីនិងឆ្លើយគ្រប់សំណួរទាំងអស់ទេ ។ វិប្បដិសារីនិងការសុំទោសជាច្រើនលើកច្រើនសាររបស់ ឌុច មិនត្រូវបានយល់ស្របដោយមេធាវីការពារក្ដីទេ ។ នៅម៉ោង៤រសៀលនេះ ឌុច បានយំក្នុងសភាពមួយដែលមិនមែនជាអារម្មណ៍ពិត ។ នេះជាវិប្បដិសារីក្លែងក្លាយ ។

លោកមេធាវីបានបញ្ចេញយោបល់ដ៏មានសារសំខាន់មួយចំនួនអំពីការជួសជុលការឈឺចាប់សម្រាប់ជនរងគ្រោះ ។ ឌុច បានសរសេរសៀវភៅអំពីប្រវត្តិផ្ទាល់ខ្លួនរបសគាត់និងប្រើប្រាស់លុយពីការលក់សៀវភៅនោះដើម្បីទូទាត់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។ គាត់អាចធ្វើការពេលដែលគាត់នៅក្នុងគុក ហើយប្រើប្រាស់ថវិកាដែលគាត់រកបានមកផ្គត់ផ្គង់កិច្ចការទាំងអស់ខាងលើនេះ ។ លោកមេធាវីក៏បានស្នើផងដែរថា ឌុច គួរសរសេរសំបុត្រពីរទៅរដ្ឋាភិបាល ។ សំបុត្រទីមួយគួរតែសរសេរសុំទោសរដ្ឋាភិបាល ហើយសំបុត្រទីពីរគួរតែស្នើថា ថវិកាមួយភាគបីដែលបានមកពីការចូលទស្សនាទួលស្លែងគួរតែយកមកជួយជួសជុសរបួសផ្លូវចិត្តរបស់ជនរងគ្រោះ ។ ចុងបញ្ចប់ លោកមេធាវីខ្មែររូបនេះបាននិយាយថា ឌុច មិនគួរអនុញ្ញាតឲ្យទៅធ្វើការក្នុងជួររដ្ឋាភិបាលវិញជាដាច់ខាត ។ ក្រោយពីបញ្ចប់ការបកស្រាយរបស់ក្រុម២ តុលាការក៏ដល់ពេលសម្រាកសម្រាប់អាហារថ្ងៃត្រង់ ។

## ក្រុម៣


លោក ហ្វីលីព ខាណុន

លោក ហ្វីលីព ខាណុន បានធ្វើសេចក្ដីថ្លែងការណ៍ក្នុងការបិទការតវ៉ាជាលើកដំបូងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបីដែលមានសមាជិក២៨នាក់ ។ លោកបានពិពណ៌នាអំពីផលលំបាកដែលគាត់និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានជួបប្រទះ ។ លោកនិងមេធាវីបានធ្វើការដោយមិនគិតពីការនឿយហត់ដើម្បីនាំជនរងគ្រោះឲ្យមកនិយាយនៅក្នុងអង្គសវនាការនេះ ។ វត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិគឺទើបតែមានទេនៅពេលនេះ ។ មេធាវីទាំងពីររូបនេះបានសុះស្វែងរកជំនួយពីតុលាការដើម្បីធានានូវភាពយុត្តិធម៌នៅក្នុងតុលាការនេះ ។

ប្រតិកម្មជាលើកដំបូងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាអ្វីដែលត្រូវតែកើតមាន វាជាសភាវគតិ ។ ឌុច ត្រូវទទួលនូវការឈឺចាប់ដូចយើងដែរ ។ លោក ខាណុន បានឲ្យដំបូន្មានថា មេធាវីបានឆ្លើយតបទៅនឹងប្រតិកម្មរបស់ជនរងគ្រោះដែរ ប៉ុន្តែមេធាវីទាំងនោះត្រូវតែធ្វើឲ្យបានច្រើនជាងនេះ ។ ធ្វើដូច្នេះទើបទទួលបានយុត្តិធម៌ ហើយយុត្តិធម៌នោះមិនមានភាពលម្អៀង ។ លោក ខាណុន បានដកស្រង់សម្ដីដ៏វែងរបស់ ឌុច នៅអំឡុងពេលសវនាការដែលទទួលរងការចោទប្រកាន់នូវបទឧក្រិដ្ឋ ។ ប្រសាសន៍របស់លោក ខាណុន បានបង្កើតឲ្យមានចម្ងល់ថាតើអ្វីដែលបានរៀបរាប់ដោយ ឌុច និង វិប្បដិសារីរបស់គាត់នៅក្នុងអង្គសវនាការជាការពិតឬទេ ។ ទោះបីការយំខ្សឹកខ្សួលគឺជាការចាប់ផ្ដើមនូវវិប្បដិសារីនោះក៏ដោយ ក៏ ឌុច បានសុំឲ្យមានការដោះលែង ។ លោក ខាណុន បានបន្តទៀតថា «ចូរ!ក្រឡេកមើលជនរងគ្រោះទាំងអស់នោះ ។ ឌុច ចូរ! មើលទៅពួកគេដែលចង់ឲ្យ ឌុច ទទួលនូវទណ្ឌកម្ម ។ អ្នកអាចបំផ្លាញសត្វល្អិតនិងសត្វពាហនៈបាន ។ អ្នកមិនអាចបំផ្លាញមនុស្សលោកបានទេ ព្រោះថ្ងៃណាមួយអ្នកទាំងនោះអាចងើបឈរឡើងព្រោះកូនចៅជនរងគ្រោះទាំងនោះនឹងទាមទារនូវយុត្តិធម៌ ។ អ្នកទាំងអស់នោះសម្លឹងមើលទៅអ្នកដែលស្លាប់កាលពីអតីតកាលគឺជាអ្វីដែលបានកាត់ក្ដី ។ ប្រហែលជាជនរងគ្រោះអាចអត់ឱនទៅដល់អ្នកបានបន្ទាប់ពីសវនាការចប់ ។ ស្រមើស្រមៃមើលថាតើជនរងគ្រោះទាំងអស់នេះខិតខំសុះស្វែងរកនិងព្យាយាមស្វែងយល់ថាតើហេតុអ្វីបានជាបុរសម្នាក់នេះមានសភាពសាហាវព្រៃផ្សៃយ៉ាងនេះ ។ តើហេតុអ្វីបានជាមនុស្សជាតិមានការគោរពកោតខ្លាចបុរសម្នាក់នេះខ្លាំងម្ល៉េះ? ។

លោក ខាណុន បានរំឭក ឌុច ថា ដើមបណ្ដឹងរដ្ឋប្បវេណីខ្លះមានលក្ខណៈសាមញ្ញ សុភាព ឬក្រីក្រ ខ្លះទទួលបានចំណេះដឹងនិងខ្លះអត់ ហើយអ្នកទាំងអស់នោះសុទ្ធតែចង់បានយុត្តិធម៌ដូចគ្នាខិតខំប្រយុទ្ធតាមផ្លូវច្បាប់ដើម្បីរក្សាភាពជាមនុស្សលោកដើម្បីកុំឲ្យលិចលង់ដូចសត្វធាតុ ។ គោលបំណងរបស់ជនរងគ្រោះគឺមិនមែនបំផ្លិចបំផ្លាញមនុស្សជាតិក្នុងភាពជាឧត្តមគតិរបស់ខ្លួនទេ ។

ការដែលមិនសម្តែងនូវការគោរពចំពោះដើមបណ្តឹងរដ្ឋប្បវេណីគឺជាសណ្ឋានថ្មីនៃការបាត់បង់នូវភាពជាមនុស្សដែលមានគុណធម៌ ។

លោក ខាណុន បានសារភាពដោយក្តីចាប់អារម្មណ៍ថា ដំណើរការរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនសូវមានភាពរលូនប៉ុន្មានទេនៅអំឡុងពេលនៃសវនាការនេះ ។ ប៉ុន្តែពួកគេស្វាគមន៍នូវប្រព័ន្ធតុលាការថ្មីនៃសវនាការ ឌុច នេះ ។ ប្រសិនបើតុលាការបំបាត់សំឡេងដើមបណ្តឹងរដ្ឋប្បវេណីនៅអំឡុងពេលតុលាការនេះ ជនរងគ្រោះនឹងក្លាយជាវត្ថុមួយគ្មានសំឡេង ហើយរឿងរ៉ាវរបស់គេនឹងត្រូវកប់ចោល ។ បើសិនជាជនរងគ្រោះទាំងអស់នោះមិនមែនជាជនគ្រោះនៃអតីតកាល ប្រហែលជាពួកគេយល់បាន ។ លោក ខាណុន បានធ្វើការទស្សន៍ទាយថា ប្រវត្តិសាស្ត្រអាចត្រូវបានបង្កើត បើសិនជាមានវត្តមានរបស់ជងរងគ្រោះ ។ សំណងដែលមានតម្លៃជាទីបំផុតគឺវត្តមានរបស់ជនរងគ្រោះនៅក្នុងតុលាការ ហើយនិងការអនុវត្តសិទ្ធិរបស់គាត់ ។

លោក ខាណុន បាននិយាយទៀតថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់ជាឧទាហរណ៍មួយដល់តុលាការអន្តរជាតិនានាដែលមានការចូលរួមពីសំណាក់ជនរងគ្រោះ ។ លោក ខាណុន បានបិទសេចក្តីថ្លែងការណ៍ ដោយរិះគន់ទៅលើ ឌុច ដែលបានប្រើកំណាព្យបារាំងមួយមានចំណងជើងថា «កាសម្លាប់របស់ឆ្កែចចក» ព្រោះតែគាត់បានសម្លឹងមើលតែចំណុចមិនល្អនៅក្នុងកំណាព្យនោះប៉ុណ្ណោះ ។ ឌុច មិនបានផ្តល់ឱកាសដល់មនុស្សជាតិទេ ។ ដោយសារតែបញ្ហានេះហើយទើបលោក ខាណុន មិនបានជឿជាក់ទៅលើអ្វីដែល ឌុច បានសម្តែងនូវវិប្បដិសារី ។ លោក ខាណុន បានចោទសួរដោយចម្ងល់ថាតើ ឌុច កំពុងតែធ្វើឲ្យយើងដេកលក់ឬ? កន្លែងណាទៅដែលបញ្ជាក់ថា គាត់មានមនោសញ្ចេតនាចំពោះជនរងគ្រោះជាង១៦០០០នាក់នៅទួលស្លែង? ចុងបញ្ចប់លោក ខាណុន បានបញ្ចប់ ដោយនិយាយថា «យើងចាត់ទុកថា អ្នកក្លាយជាឆ្កែចចកនៃមនុស្សលោក» ។

អ្នកស្រី មាទីន ហ្សាកឃ្មីន បាននិយាយក្រោយលោក ខាណុន ដោយធ្វើសេចក្តីថ្លែងការណ៍គួរឲ្យចាប់អារម្មណ៍លើកទីពីរ ។ អ្នកស្រីបានរៀបរាប់ថាហេតុដូចម្តេចបានជាជនរងគ្រោះរង់ចាំយូរម្ល៉េះក្នុងការនិយាយចេញមកនេះ? អ្នកស្រីបានថ្លែងថា «តុលាការកំពុងតែផ្តល់សំឡេងដើម្បីឲ្យមានការចងចាំ» ។ តុលាការបានធ្វើឲ្យកុលបុត្រកុលធីតារបស់អ្នកដែលស្លាប់ទៅបានដឹងឮពីអ្វីដែលបានកើតឡើង ។ ក្រោយមក អ្នកស្រីបានបង្ហាញរូបថតជនរងគ្រោះនិងអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនសន្លឹក ។ ក្រោយមកអ្នកស្រីបាននិយាយថា ជនដែលដល់នៃបទឧក្រិដ្ឋកម្មនេះមិនបានប្រព្រឹត្តបទឧក្រិដ្ឋដោយសារតែខ្លួនមានជំងឺផ្លូវចិត្តនោះទេ ។ តែពួកគេបានធ្វើដោយរីករាយដើម្បីធ្វើឲ្យមនុស្សម្នាក់មានភាពច្របូកច្របល់ ។ នេះគឺជាភាពពិតដែលគួរឲ្យខ្លាចជាទីបំផុត ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញសក្ខីភាពដូច្នេះមនុស្សជាតិទាំងឡាយអាចនាំទៅរកយុត្តិធម៌បាន ។ នៅក្នុងទស្សនៈរបស់លោកស្រី ហ្សាក់ឃ្មីន ដើមបណ្តឹងរដ្ឋប្បវេណីនឹងអត់ទោសដល់អ្នកណាដែលដឹងពីកំហុសរបស់ខ្លួនដែលបានធ្វើឡើងក្នុងអតីតកាលប៉ុណ្ណោះ ហើយមានឆន្ទៈនឹងទទួលស្គាល់កំហុសពីសតិសម្បជញ្ញៈរបស់ខ្លួន ។ អ្នកស្រីនិយាយថា គ្មានអ្វីអាចបញ្ជាក់អំពីមនុស្សម្នាក់ដែលត្រូវបានជិះជាន់ដោយមនុស្សផ្សេងទៀតទេ ។

មេធាវីជនជាតិខ្មែរម្នាក់ទៀតឈ្មោះ ម៉ុច សុវណ្ណារី បានសម្តែងនូវអំណរគុណដល់រដ្ឋាភិបាលកម្ពុជា ហើយនិងអង្គការសហប្រជាជាតិក្នុងការបង្កើតតុលាការនេះឡើង ។ សុវណ្ណារី បាននិយាយដោយផ្តោតទៅលើការជួសជុលរបួសផ្លូវចិត្ត ហើយបានបញ្ជាក់នូវតម្រូវការថែទាំផ្នែកវេជ្ជសាស្ត្រសម្រាប់ជនរងគ្រោះដែលរស់រានមានជីវិត ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវការយុត្តិធម៌ ហើយយុត្តិធម៌ត្រូវតែផ្តល់ជូន ហើយត្រូវតែមានសំណងសម្រាប់ជួលជុលនូវអ្វីដែលបានបាត់បង់ ។ សុវណ្ណារី បានស្នើបំណងមួយចំនួនសម្រាប់ជាសំណងជួសជុល ។ ១) បង្កើតមូលនិធិស្មគ្រចិត្ត ២) ថែទាំនិងថែរក្សាទីតាំងឧក្រិដ្ឋកម្មដែលជនរងគ្រោះត្រូវបានសម្លាប់ និងឯកសារដែលពាក់ព័ន្ធទាំងអស់ ដូច្នេះកូនចៅជំនាន់ក្រោយអាចបញ្ជប់នូវ «កង់ប្រវត្តិសាស្ត្រនេះបាន» ៣) ថែរក្សារូបថតទាំងអស់ដែលដាក់បង្ហាញនៅគុកទួលស្លែង ៤) បង្កើតបូជនីយដ្ឋានមួយដែលចារឈ្មោះជនរងគ្រោះទាំងអស់និងការបង្ហាញធ្វើការនានា ៥) ថែរក្សាផ្នូរនិងរណ្តៅនៅជើងឯក ៥) បង្ហាញនូវទ្រព្យសម្បត្តិទាំងប៉ុន្មានដែល ឌុច មាន និង ៦) កំណត់ឲ្យច្បាស់ថាតើនរណាជាអ្នកសងសំណងជួសជុលនេះដល់ជនរងគ្រោះ ។

## ក្រុម៤



លោក ហុន គឹមសួន

មេធាវីខ្មែរម្នាក់ឈ្មោះ ហុន គឹមសួន បានឡើងនិយាយតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ ។ លោក គឹមសួន បានថ្លែងមួងម្នាក់ៗអំពីអ្វីដែលសមាជិកដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០នាក់នៅក្នុងក្រុមរបស់គាត់បានជួបប្រទះ ។ ក្នុងនោះមានម្នាក់បានឆ្ងល់ថាតើខ្លួនបានធ្វើអ្វីខ្លះដែលបានចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ ចំណែកអ្នកខ្លះទៀតមានការពេញចិត្តចំពោះការទទួលស្គាល់មកលើខ្លួនក្នុងការមានវត្តមាននៅក្នុងអង្គសវនាការនេះ ។ អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយមិនមានឥទ្ធិពលដែលនាំឲ្យផ្លាស់ប្តូរការគិតនិងអត្តចរិតរបស់ចៅក្រមទេ ។ ឌុច មើលទៅដូចជាមិនមានចំណាប់អារម្មណ៍ចំពោះអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយទាល់តែសោះ ។ ប៉ុន្តែលោក គឹមសួន បានសន្និដ្ឋានចុងក្រោយថា ការដែលប្រើប្រាស់ថវិកាបានមកពីថ្លៃចូលមើលសារមន្ទីរទួលស្លែងគួរតែប្រើសម្រាប់ការជួលជុលរបួសផ្លូវចិត្តរបស់ជនរងគ្រោះ ។ លោកព្យែ អូលីវីយេ ស៊ូ មកពីប្រទេសបារាំងបានឡើងនិយាយចុងក្រោយគេបង្អស់ ។ លោកបានកំណត់សម្គាល់ថា ឌុច បានមកកាន់តុលាការដោយគ្មានភាពលំបាកអ្វីបន្តិចឡើយខណៈពេលដែលជនរងគ្រោះមានការលំបាកឥតឧបមាក្នុងការធានាបាននូវការទទួលស្គាល់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គសវនាការ ។ លោកបានថ្លែងថា ចំនួនដើមបណ្តឹងរដ្ឋប្បវេណីសរុបទាំងចំនួនអស់៩៤នាក់បានកាត់បន្ថយនូវស្ថានភាពទៅដល់កម្រិតនៃទ្រឹស្តី ។ លោកក៏បានតវ៉ាផងដែរថា ឌុច កំពុងតែចូលពាក់ព័ន្ធជាមួយតុលាការទៅលើសិទ្ធិរបស់ជនរងគ្រោះ ។ ខណៈពេលដែលជនរងគ្រោះធ្វើទៅតាមទ្រឹស្តីពុទ្ធសាសនាតាមរយៈផលកម្ម ការចាប់ជាតិ និងទស្សនៈ «រឿងអតីតកាលឲ្យផុតទៅ» ប្រទេសរបស់ពួកគេកំពុងតែដឹកនាំដោយអតីតទាហានខ្មែរក្រហមម្នាក់ធ្វើឲ្យជនរងគ្រោះមានការលំបាកធ្វើដំណើរទៅរកអនាគត ហើយអតីតកាលនៅតែរស់រវើកនៅឡើយ ។ ទើបតែពីរ-បីខែចុងក្រោយនេះទេទើបសៀវភៅសិក្សារបស់សាលាត្រូវបានផ្សព្វផ្សាយដែលមានព័ត៌មានអំពីមន្ទីរស-២១ផង ។

លោកបានអះអាងថា ការស្រក់ទឹកភ្នែករបស់ ឌុច នៅចំពោះមុខសាធារណជនគឺមានលក្ខណៈចម្លែកនៅក្នុងវប្បធម៌ពុទ្ធសាសនាដែលបានបញ្ជាក់ពីអារម្មណ៍សោកសៅ ។ តាមរយៈការផ្លាស់ប្តូរទៅជាគ្រិស្តសាសនិកវិញ ឌុច បានធ្វើតាមតក្កវិទ្យានៃភាពសោកសៅ ។ ឌុច បានស្វះស្វែងរកការចូលរួមជាមួយតុលាការ និងតាំងខ្លួនជាមនុស្សសំខាន់នៅក្នុងដំណើរការនេះ ។ សម្រាប់ជនរងគ្រោះវិញ មានភាពមិនស្រណុកសុខស្រួលយ៉ាងខ្លាំង ។

លោកបានតវ៉ាថា សម្រាប់ជនរងគ្រោះ ការអត់ឱនទោសអាចធ្វើទៅបានលុះត្រាតែជនដៃដល់សារភាពពីការពិតច្បាស់លាស់និងស្មោះត្រង់ ។ ឌុច មិនបានធ្វើបែបនេះនៅឡើយទេ ។ តែគាត់បានគេចពីការទទួលខុសត្រូវ ។ ឌុច នៅតែបន្តតវ៉ាថា ខ្លួនទទួលបញ្ជាពីអ្នកផ្សេងទៀតនៅក្នុងក្បាលម៉ាស៊ីនរបស់ខ្មែរក្រហម ។ គាត់បានដឹកនាំយ៉ាងល្អនៅមន្ទីរម-១៣ ដូច្នេះគាត់មានសមត្ថភាពល្អជាងអ្នកផ្សេង ហើយគាត់អាចត្រូវបានដំឡើងតំណែងជាប្រធានមន្ទីរស-២១សម្រាប់សមត្ថភាពរបស់គាត់ ។ គាត់មានអំណាចនឹងជួយសង្គ្រោះប្រជាជនបាន ប៉ុន្តែគាត់បានសង្គ្រោះតែអ្នកថតរូបម្នាក់ (ដែលបានថតរូប ឌុច ជាច្រើនសម្រាប់ជីវិតផ្ទាល់ខ្លួនរបស់ឌុច) ពេទ្យធ្មេញម្នាក់ និងជាងគំនូរម្នាក់ប៉ុណ្ណោះ ។ អ្នកដែលគាត់អាចសង្គ្រោះបាន តែគាត់បែរជាសម្លាប់ទៅវិញដូចជាគ្រូរបស់គាត់ម្នាក់ ។ ឌុច មិនមែនជាកូនអុករបស់គេទេ ។ គាត់ត្រូវបានវិនិច្ឆ័យជាឧក្រិដ្ឋជនម្នាក់ប្រឆាំងមនុស្សជាតិ ។

លោកបានរៀបរាប់រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ។ បន្ទាប់មក គាត់បានស្នើឲ្យមានការទទួលខុសត្រូវចំពោះភាពយុត្តិធម៌អន្តរជាតិថា «បេសកម្មថ្លៃថ្នូរក្នុងការនិយាយនិងកាត់ក្តីថាមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាច្រើនដែលមិនទាន់បានវិនិច្ឆ័យ» ។

លោកប្រធាន និល ណុន បានប្រកាសថា ថ្ងៃអង្គារ ទី២៥ វិច្ឆិកា និងជាថ្ងៃដែលបិទការតវ៉ាវទូទៅរបស់សហព្រះរាជអាជ្ញា ។

**ដេវីដ សេហ្វ័រ**

# កំហុសរបស់មេធាវីការពារក្តី

**(តចប់)**

***ការចោទជាសំណួរទៅលើភាពស្របច្បាប់របស់តុលាការ***

ទោះបីជាឥរិយាបថរបស់មេធាវីដែលប្រើប្រាស់នីតិវិធីរបស់តុលាការដើម្បីបង្អាក់និងរំខានដល់តុលាការអាចត្រូវប្រឈមមុខនឹងសកម្មភាពរបស់តុលាការ ក៏យុត្តិសាស្ត្រអន្តរជាតិបានបង្ហាញថា យ៉ាងហោចណាស់ក៏មានយុត្តិសាស្ត្រមួយដែលមិនទទួលឥទ្ធិពលពីការចោទប្រកាន់ពីការរំខាននិងរំលោភទៅលើដំណើរការនីតិវិធីដែរ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីករណី តាឌីក មេធាវីបាននិយាយវាយប្រហារទៅលើការបង្កើតតុលាការនិងបានចោទជាសំណួរអំពីភាពស្របច្បាប់នៃការបង្កើតតុលាការនោះ ។ ដោយមិនពិចារណាភ្លាមៗទៅលើបញ្ហាដែលរំលោភទៅលើដំណើរការនិងលើកលែងឬមិនអើពើនឹងការចោទប្រកាន់ សាលាឧទ្ធរណ៍បាននិយាយនិងឆ្លើយតបអំពីការព្រួយបារម្ភអំពីភាពស្របច្បាប់របស់តុលាការ ។ ទោះបីជាសាលាឧទ្ធរណ៍មិនយល់ស្របនឹងការលើកឡើងថា តុលាការគឺជាតុលាការមិនស្របច្បាប់ការពិតដែលថាសវនាការមិនបានដាក់ទណ្ឌកម្មភ្លាមៗទៅលើមេធាវីដែលបានចោទជាសំណួរអំពីមូលដ្ឋាននៃអំណាចរបស់តុលាការគឺដោយសារតែមេធាវីការពារក្តីអាចសួរអំពីមូលដ្ឋានគ្រឹះនៃតុលាការអន្តរជាតិ ។ ទោះបីជាសេចក្តីសម្រេចនេះបង្ហាញថាវាគឺជាយុត្តិសាស្ត្រត្រឹមត្រូវមួយនៅពេលដែលតុលាការសម្រេចអំពីភាពស្របច្បាប់របស់ខ្លួន ប្រសិនបើមេធាវីនៅតែបន្តលើកឡើងអំពីបញ្ហានេះនៅក្នុងសវនាការ វានឹងត្រូវបានចាត់ទុកថាជាការរំខានហើយត្រូវចាត់ទុកថាជាការរំលោភទៅលើដំណើរការដូចដែលបានពិភាក្សានៅខាងលើ ។

***ង) ការអនុវត្តផ្ទុយពីវិធានលក្ខន្តិកៈ និងបទដ្ឋានជាក់លាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឥរិយាបថដែលរំលោភទៅលើបទដ្ឋានរបស់តុលាការឬវិជ្ជាជីវៈច្បាប់អាចបង្កើតជាកំហុស ។ មាត្រា២១(៣) បានរៀបរាប់ពីព័ត៌មាននិងទម្លាប់ដែលបង្ហាញពីបទដ្ឋានទាំងនោះដែលអាចជួយឲ្យអង្គជំនុំជម្រះធ្វើការកំណត់នៅពេលមានការប្រព្រឹត្តបែបនោះកើតមាននៅពេលអនាគត ។ មាត្រា២១(៣) តម្រូវឲ្យមេធាវីអនុវត្តទៅតាមបទដ្ឋានជាក់លាក់មួយចំនួនដែលរួមមានអ្វីដែលបានរៀបរាប់នៅចំណុច ១) កិច្ចព្រមព្រៀងឆ្នាំ២០០៣រវាងអង្គការសហប្រជាជាតិនិងកម្ពុជា ២) ច្បាប់កម្ពុជាស្តីអំពីលក្ខន្តិកៈគណៈមេធាវីនិង ៣) «បទដ្ឋានដែលត្រូវបានគេទទួលស្គាល់និងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់» ។ ជាងនេះទៅទៀត អង្គជំនុំជម្រះអាចនឹងរកឃើញការប្រព្រឹត្តដែលរំលោភវិធានផ្ទៃក្នុងណាមួយដែលបង្កើតជាកំហុស ។

**១) កិច្ចព្រមព្រៀងឆ្នាំ២០០៣**

កិច្ចព្រមព្រៀងឆ្នាំ២០០៣មិនបានរៀបរាប់ពីស្ថានភាពជាក់លាក់ពេលណាទើបឥរិយាបថរបស់មេធាវីគឺជាកំហុស ។ កិច្ចព្រមព្រៀងរួមមានមាត្រាមួយចំនួនដែលអាចបង្កើតជាបទដ្ឋាននៃឥរិយាបថ ។ មាត្រា១៣ បានរៀបរាប់ពីសិទ្ធិទទួលបានការកាត់ក្តីដ៏យុត្តិធម៌របស់ជនត្រូវចោទ ហើយយើងអាចសន្និដ្ឋានថាប្រសិនបើឥរិយាបថណាមួយរបស់មេធាវីរំលោភទៅលើសិទ្ធិទទួលបានការកាត់ក្តីដ៏យុត្តិធម៌របស់ចុងចោទ ឥរិយាបថនោះអាចត្រូវបានចាត់ទុកថាកំហុស ។ បន្ថែមពីលើនេះទៀត មាត្រា២៣បានធានានូវការការពាររបស់តុលាការទៅលើជនរងគ្រោះនិងសាក្សី ។ ឥរិយាបថណាមួយរបស់មេធាវីដែលរំខានដល់ដល់ការការពារនេះអាចបង្កើតជាកំហុសដោយរំលោភទៅលើកិច្ចព្រមព្រៀងឆ្នាំ២០០៣ ។

**២) ច្បាប់កម្ពុជាស្តីអំពីលក្ខន្តិកៈគណៈមេធាវី**

ច្បាប់កម្ពុជាស្តីអំពីលក្ខន្តិកៈគណៈមេធាវីគឺជាលក្ខន្តិកៈគ្រប់គ្រងទៅលើគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់នេះបានរាយពីបទល្មើសដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចយកមកប្រើដើម្បីអះអាងប្រឆាំងមេធាវីការពារក្តី ។ ជាឧទាហរណ៍ ច្បាប់កម្ពុជាស្តីអំពីលក្ខន្តិកៈគណៈមេធាវីតម្រូវថាមេធាវីដែលសិក្សាវិជ្ជាជីវៈច្បាប់ខណៈពេលដែលខ្លួនជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវតែរក្សាឲ្យបាននូវការ

សម្ងាត់ ។ ច្បាប់កម្ពុជាស្ដីអំពីលក្ខន្តិកៈគណៈមេធាវីសន្និដ្ឋានថា «ការប្រឹក្សា ការផ្ដល់យោបល់និងឯកសារមិនផ្លូវការដែលរៀបចំដោយមេធាវីសម្រាប់កូនក្ដីរបស់ខ្លួននិងការឆ្លើយឆ្លងរវាងមេធាវីនិងកូនក្ដីរបស់ខ្លួន» ត្រូវទុកជាការសម្ងាត់ ។ តាមមាត្រា១៩ច្បាប់កម្ពុជាស្ដីអំពីលក្ខន្តិកៈគណៈមេធាវីក៏បានតម្រូវឲ្យគណៈមេធាវីបង្កើតនិងប្រតិបត្តិតាម «ក្រមសីលធម៌មេធាវី» ។ ក្រមសីលធម៌មេធាវីតម្រូវថា មេធាវីត្រូវតែគោរពតាមភារកិច្ចដែលខ្លួនបានធ្វើសច្ចាប្រណិធាន និង «គោលការណ៍នៃសតិសម្បជញ្ញៈនិងការប្រយ័ត្នប្រយែងក្នុងការប្រើពាក្យសម្ដី» ស្លៀកពាក់ឯកសណ្ឋានមេធាវី «គោរពតាមចៅក្រមដោយឯករាជ្យនិងថ្លៃថ្នូរ ការគោរពនេះគឺស្របទៅតាមមុខតំណែងរបស់ខ្លួន» ត្រួតពិនិត្យទៅលើវិធាននីតិវិធីនិងការប្រតិបត្តិនៃយុត្តាធិការនិងមិនប្រព្រឹត្តអំពើមិនស្មោះត្រង់និងអំពើដែលអាចបង្អាក់ដល់ដំណើរការ ។ អាស្រ័យហេតុនេះ រាល់ឥរិយាបថដែលប្រព្រឹត្តឡើងមិនស្របទៅតាមបទដ្ឋានទាំងនេះត្រូវបានចាត់ទុកថាជាការអនុវត្តមិនត្រឹមត្រូវ ។

**៣) បទដ្ឋានដែលត្រូវបានទទួលស្គាល់និងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់ ៖ ភាពអសមត្ថភាព ឬកំហុសដែលប្រព្រឹត្តឡើងដោយមេធាវីមិនអាចអះអាងពីសកម្មភាពរបស់តុលាការបាន**

ទោះបីជាពាក្យ «បទដ្ឋានដែលត្រូវបានគេទទួលស្គាល់និងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់» មានលក្ខណៈទូលំទូលាយ មេធាវីការពារក្ដីរបស់ អៀង សារី ត្រូវបានចាត់ទុកថារំលោភទៅលើ «បទដ្ឋាននិងក្រមសីលធម៌» ទាំងនេះនៅពេលដែលមេធាវីការពារក្ដីបានផ្សព្វផ្សាយឯកសារសំណុំរឿងជាសាធារណៈបន្ទាប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រាប់មេធាវីការពារក្ដីថាឯកសារនោះមិនអាចផ្សព្វផ្សាយជាសាធារណៈបានឡើយ ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះបានអះអាងថាមេធាវីការពារក្ដីបានរំលោភទៅលើមាត្រា២(១៣) ដោយខកខាន «មិនបានប្រព្រឹត្តតាមបទដ្ឋាននិងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់» ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការបានរកឃើញថាមេធាវីការពារក្ដីក្នុងសំណុំរឿងតាឌិកបានរំលោភទៅលើបទដ្ឋានដែលមានការទទួលស្គាល់និងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់និងរំលោភទៅលើក្រមសីលធម៌វិជ្ជាជីវៈមេធាវីការពារក្ដីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដោយបញ្ចុះបញ្ចូលសាក្សី និង «ប្ដឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍...សំណុំរឿងដែលភាគីដឹងថាមានលក្ខណៈមិនត្រឹមត្រូវប្រៀបទៅទម្ងន់ដែលបានផ្ដល់ឲ្យនៅក្នុងរបាយការណ៍និងការទទួលខុសរបស់បុគ្គលក្នុងការសម្លាប់ប៉ូលិសមូស្លីមពីរនាក់» ។ សាលាឧទ្ធរណ៍បានសម្រេចថា «មិនមានហេតុផលដែលថាការប្រព្រឹត្តនេះបង្កឲ្យមានការមិនគោរពតុលាការ ហើយមេធាវីត្រូវជាប់ទោសពីបទអនុវត្តវិជ្ជាជីវៈមិនត្រឹមត្រូវទេ ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏វាគួរឲ្យកត់សម្គាល់ថាតុលាការអន្តរជាតិផ្ដល់ពេលវេលាឲ្យមេធាវីការពារក្ដីជាច្រើនជាមួយនឹង «បទដ្ឋានដែលបានទទួលស្គាល់និងក្រមសីលធម៌» ដើម្បីឲ្យមេធាវីការពារក្ដីបង្កើតយុត្តិសាស្ត្ររបស់ខ្លួន ។ តុលាការទាំងនេះប្រហែលរកឃើញថាការអះអាងតាមផ្លូវច្បាប់មិនគ្រប់គ្រាន់ មេធាវីការពារក្ដីមិនស្របទៅតាម «បទដ្ឋានដែលមានការទទួលស្គាល់» ផ្លូវច្បាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលកូនក្ដីយល់ស្រប តុលាការមិនបានរកឃើញយុត្តិសាស្ត្រមិនគ្រប់គ្រាន់របស់មេធាវីដើម្បីយកមកអះអាងឡើយ ។ ក្នុងករណី តាឌិក នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សាលាឧទ្ធរណ៍បានបដិសេធមិនកែតម្រូវការចោទប្រកាន់ភាពអសមត្ថភាពរបស់មេធាវីក្នុងការខកខានមិនលើកឡើងពីភស្តុតាងដែលពាក់ព័ន្ធទេ ។ តុលាការបានអះអាងថា «ការសហការគ្នារវាងកូនក្ដីនិងមេធាវីមានសារសំខាន់សម្រាប់ការងាររបស់តុលាការអន្តរជាតិ» ។ ទោះបីជាតុលាការមិនយល់ស្របនឹងយោបល់ដែលមេធាវីផ្ដល់ឲ្យចុងចោទក៏ដោយ ក៏តុលាការមិនអាចធ្វើអ្វីបានទេ ដរាបណាមានការបង្ហាញជាក់លាក់អំពីភាពអសមត្ថភាពនោះ» ។

ជាងនេះទៅទៀត ករណី អាកាយីស៊ុ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដាក្នុងបណ្ដឹងឧទ្ធរណ៍ ចុងចោទអះអាងថាខ្លួនត្រូវបានបិទបាំងសិទ្ធិមិនឲ្យទទួលបានការការពារក្ដីដ៏ពេញលេញមួយនិងសិទ្ធិមិនឲ្យមានមេធាវីដែលមានសមត្ថភាព ។ ដូចដែលសិទ្ធិដ៏តិចតួចនៅតុលាការត្រូវបានរំលោភ ចុងចោទបានលើកឡើងពីការខ្វះខាតការរៀបចំរបស់មេធាវី ការខកខានបង្ហាញខ្លួននៅតុលាការនិងការខកខានមិនបានដាក់យុត្តិសាស្ត្រច្បាប់ពិតប្រាកដ ។ តុលាការ

ដែលកាត់ទោសករណី អាកាយេស៊ុ បានយល់ស្របនឹងទស្សនៈរបស់សាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនៅក្នុងសេចក្តីសម្រេចទាក់ទងនឹងករណី តាឌីក ហើយបានអះអាងថា ភាពអសមត្ថភាពរបស់មេធាវីក្លាយទៅជាបទល្មើសមួយនៅពេលមេធាវីបានប្រព្រឹត្តអ្វី «ប្រឆាំងនឹងគោលបំណងរបស់អ្នកប្តឹងឧទ្ធរណ៍និងមិនមានការប្រឆាំងដោយចុងចោទនៅពេលនោះ» ។ តុលាការបានរកឃើញថា ចាប់តាំងពីការចាប់ផ្តើមសវនាការ គឺមិនមានភស្តុតាងបង្ហាញពីការតវ៉ាប្រឆាំងរបស់ចុងចោទទៅនឹងយុត្តិសាស្ត្ររបស់មេធាវីឡើយ ។ ចុងចោទនិងមេធាវីបាន «បង្ហាញពីការសហការគ្នា» ហើយមិនមានភស្តុតាងបង្ហាញថាយុត្តិសាស្ត្ររបស់មេធាវីមិនមានការយល់ស្របពីចុងចោទទេ ។ អាស្រ័យហេតុនេះ ការចោទប្រកាន់អំពីការអនុវត្តមិនត្រឹមត្រូវមិនមែនជាហេតុផលសម្រាប់កែប្រែសេចក្តីសម្រេចទៅលើចុងចោទទេ ។

ដូច្នេះ ទោះបីជាជម្រើសរបស់មេធាវីការពារក្តីមិនបានផ្តល់ផលប្រយោជន៍ច្រើនបំផុតដល់កូនក្តីរបស់ខ្លួនក៏ដោយ ក៏តុលាការអន្តរជាតិតែងតែមិនធ្វើការកំណត់ពីសមត្ថភាពឬយុត្តិសាស្ត្រដ៏ទន់ខ្សោយដែលបានរំលោភទៅលើបទដ្ឋាននិងក្រមសីលធម៌វិជ្ជាជីវៈច្បាប់ដែរ ដរាបណាមានការបង្ហាញថាចុងចោទនិងមេធាវីមិនបានធ្វើការជាមួយគ្នា ។

### ៤) ការរំលោភបំពានទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ

ការរំលោភបំពានមួយទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះដោយមេធាវីប្រហែលជាអាចចាត់ទុកជាការអនុវត្តមិនត្រឹមត្រូវ ។ ឧទាហរណ៍ វិធាន៣៥បានចែងថា ការដឹកនាំក្លាយជាកំហុសដូចដែលបានចែងនៅក្នុងវិធាន៣៨នៅពេលដែលបទល្មើសដូចខាងក្រោមត្រូវបានប្រព្រឹត្តឡើង ។ បទល្មើសនោះកើតមានប្រសិនបើមេធាវី ៖

ក) ផ្សាយចេញនូវព័ត៌មានសម្ងាត់ដោយរំលោភទៅលើដីការបស់ចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ។

ខ) មិនគោរពតាមដីកាឲ្យចូលរួម ឬមិនផ្តល់ឯកសារ ឬភស្តុតាងផ្សេងទៀតទៅឲ្យចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដោយមិនមានមូលហេតុសមស្រប ។

គ) បំផ្លាញឬក្លែងបន្លំឯកសារវត្ថុតាងឬភស្តុតាងផ្សេងៗដោយមធ្យោបាយនានាដែលស្ថិតនៅក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះ ។

ឃ) គំរាមកំហែងបំភិតបំភ័យ ផ្តល់សំណូកឬស្វែងរកវិធីគាបសង្កត់សាក្សីដែលបានផ្តល់ ឬនឹងផ្តល់ភស្តុតាងនៅក្នុងដំណើរការនីតិវិធីទៅឲ្យសហចៅក្រមស៊ើបអង្កេតឬអង្គជំនុំជម្រះ ។

ង) គំរាមកំហែងបំភិតបំភ័យ ឬសូកសំណូក ឬស្វែងរកវិធីគាបសង្កត់លើជនដទៃទៀតក្នុងគោលបំណងទប់ស្កាត់បុគ្គលនោះមិនឲ្យបុគ្គលនោះអនុវត្តតាមដីកាសហចៅក្រមស៊ើបអង្កេតឬអង្គជំនុំជម្រះ ។

ច) ជួយដោយចេតនាដើម្បីឲ្យជនត្រូវចោទ ឬជនជាប់ចោទរត់គេចពីអំណាចយុត្តាធិការរបស់អង្គជំនុំជម្រះឬ

ឆ) ញុះញង់ ឬប៉ុនប៉ងប្រព្រឹត្តអំពើណាមួយដែលមានចែងខាងលើ ។

ទោះបីជាទាំងនេះគឺជាកំហុសជាក់លាក់ហើយការបកស្រាយពន្យល់ដ៏តឹងរឹងអាចកំណត់នូវការប្រព្រឹត្តមិនត្រឹមត្រូវក៏ដោយ ក៏អង្គជំនុំជម្រះនឹងប្រហែលជាពិនិត្យទៅលើការរំលោភទៅលើវិធាន៣៥តាមមូលដ្ឋាននៃករណីនីមួយៗដែរ ។ ជាមួយនឹងឧទាហរណ៍នៃការប្រព្រឹត្តមិនត្រឹមត្រូវនីមួយៗ វានៅតែមានអាចមានការបកស្រាយផ្សេងទៀត ។ ជាឧទាហរណ៍ យោងតាមវិធាន២៥(១)ក) និយមន័យនៃពាក្យ «ការសម្ងាត់» ឬ «ដីកា» អាចមានលក្ខណៈមិនច្បាស់លាស់ ។ ដូចគ្នានឹងករណី អៀង សារី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេធាវីការពារក្តីផ្សព្វផ្សាយព័ត៌មានជាសាធារណៈដែលខ្លួនគិតថាព័ត៌មាននោះមិនមែនជាការសម្ងាត់ ប៉ុន្តែការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាន់បានធ្វើសេចក្តីណែនាំថាអ្វីជាការសម្ងាត់ទេ ដោយគ្រាន់តែនិយាយថាអ្វីដែលមិនទាន់បានបោះពុម្ពផ្សាយសុទ្ធតែជាការសម្ងាត់ ។ ជាងនេះទៅទៀត វាមានភាពច្របូកច្របល់ចំពោះធាតុផ្សំដែលបង្កើតជា «ដីកា» ។ នៅក្នុងសេចក្តីសម្រេចបឋមការិយាល័យសហចៅក្រមស៊ើបអង្កេតរកឃើញថាខ្លួនបានដាក់កំហិតមិនឲ្យមានការផ្សព្វផ្សាយឯកសារនៅក្នុងលិខិតផ្ញើទៅមេធាវីការពារក្តី ដូច្នេះលិខិតនេះតំណាងឲ្យដីកាដែលត្រូវបានរំលោភដោយមេធាវីការពារក្តីដែលបង្កឲ្យមានការរំលោភ

ទៅលើវិធាន៣៥(១)ក) ។ អង្គបុរេជំនុំជម្រះបានជំទាស់ ហើយរកឃើញថាលិខិតនោះមិនបានតំណាងឲ្យ «ដីកា»ទេ ហេតុដូច្នេះការអនុវត្តរបស់មេធាវីការពារក្តីមិនអាចចាត់ទុកជាការរំលោភទៅលើវិធាន៣៥(១)ក) បានទេ ។ ដូច្នេះការរំលោភទៅលើវិធាន៣៥(១)ដែលត្រូវបានចោទប្រកាន់ត្រូវតែយកមកពិនិត្យទៅតាមមូលដ្ឋាននៃករណីនីមួយៗដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើមានការរំលោភបំពានមែនឬអត់ ។ ការរំលោភទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះអាចត្រូវបានអង្គជំនុំជម្រះចាត់ទុកថាជាកំហុស ហើយទទួលបានវិធានការផ្សេងៗពីតុលាការ ។ នៅក្នុងករណី អៀង សារី ការិយាល័យសហចៅក្រមស៊ើបអង្កេតរកឃើញថានៅពេលដែលមេធាវីការពារក្តីផ្សព្វផ្សាយឯកសារសម្ងាត់ដោយ «មិនមានការយល់ស្របដោយអាជ្ញាធរដែលពាក់ព័ន្ធ» មេធាវីនោះគឺបានរំលោភទៅលើវិធាន៥៦ដែលមានឈ្មោះថា «ការផ្តល់ព័ត៌មានដល់សាធារណជនដោយការិយាល័យសហចៅក្រមស៊ើបអង្កេត» ។ ការរំលោភបំពាននេះគឺយោងទៅតាមវិធាន៣៨» ។

ឧទាហរណ៍មួយទៀត មានរួមបញ្ចូលទាំងវិធានផ្ទៃក្នុង១១ ដែលមានឈ្មោះថា «អង្គភាពគាំពារការការពារក្តី» ។ វិធាននេះបានផ្តល់អំណាចដល់អង្គភាពគាំពារការការពារក្តីក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យនិងនីតិវិធីដែលមេធាវីត្រូវតែគោរពតាមដើម្បីចូលរួមក្នុងអង្គជំនុំជម្រះ ។ សម្រាប់មេធាវីកម្ពុជា អ្នកទាំងនេះត្រូវតែជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាហើយត្រូវ «មានសមត្ថភាពខាងផ្នែកនីតិវិធីនិងច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ» ។ មេធាវីអន្តរជាតិត្រូវតែជាសមាជិកបច្ចុប្បន្នដែលមានកេរ្តិ៍ឈ្មោះល្អនៅក្នុងគណៈមេធាវីដែលត្រូវបានទទួលស្គាល់ដោយរដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិមានសញ្ញាប័ត្រផ្នែកច្បាប់ ឬគុណសម្បត្តិផ្នែកច្បាប់ ឬវិជ្ជាជីវៈដែលមានតម្លៃស្មើ មានបទពិសោធន៍ការងារដែលជាប់ពាក់ព័ន្ធយ៉ាងតិច១០ឆ្នាំ មានសមត្ថភាពផ្នែកនីតិវិធី និងច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ ចេះភាសាខ្មែរ បារាំង ឬអង់គ្លេសយ៉ាងស្ទាត់ជំនាញ និងទទួលបានការអនុញ្ញាតដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីអនុវត្តមុនពេលចូលរួមនឹងអង្គជំនុំជម្រះ ។ ជាការសន្មត ប្រសិនបើនៅអំឡុងពេលដំណើរការនីតិវិធីមេធាវីការពារក្តីបានល្មើសនឹងលក្ខណៈវិនិច្ឆ័យទាំងនេះ អង្គជំនុំជម្រះអាចសម្រេចថាមេធាវីបានប្រព្រឹត្តកំហុស ។

## ៤) តើពេលណាទើបការប្រព្រឹត្តមិនត្រឹមត្រូវកើតឡើងសម្រាប់យកមកអះអាង?

អង្គជំនុំជម្រះបានបំបែកការប្រព្រឹត្តមិនត្រឹមត្រូវជាពីរដំណាក់កាល ១) ការប្រព្រឹត្តមិនត្រឹមត្រូវរបស់មេធាវីដែលកើតឡើងនៅក្នុងដំណាក់កាលណាមួយនៃដំណើរការនីតិវិធីរបស់ចុងចោទ ។ ២) ការប្រព្រឹត្តខុសដែលកើតឡើងនៅក្នុងតុលាការពីមុនចំពោះចុងចោទផ្សេង ។ អង្គជំនុំជម្រះបានពឹងផ្អែកយ៉ាងខ្លាំងទៅលើការប្រព្រឹត្តដែលកើតឡើងនៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធីរបស់ចុងចោទ ហើយមិនធ្លាប់បានប្រើប្រាស់ភស្តុតាងប្រព្រឹត្តខុសរបស់មេធាវីដែលយកមកពីតុលាការអន្តរជាតិពីមុនទេ ។ នៅក្នុងករណី អៀង សារី អំពើដែលបង្កឲ្យមានការប្រព្រឹត្តខុសបានកើតមានឡើងនៅក្នុងអង្គបុរេ ។ នៅក្នុងករណី ខៀវ សំផន ទោះបីជាសហព្រះរាជអាជ្ញាបានអះអាងថាទាំងការប្រព្រឹត្តមិនត្រឹមត្រូវរបស់មេធាវីនៅតុលាការអន្តរជាតិពីមុន និងនៅអង្គជំនុំជម្រះគួរតែយកមកពិចារណា ក៏អង្គបុរេជំនុំជម្រះពឹងផ្អែកជាសំខាន់ទៅលើការប្រព្រឹត្តរបស់មេធាវីនៅដំណាក់កាលអង្គបុរេនៃអង្គជំនុំជម្រះដែរ ។

តុលាការអន្តរជាតិបានប្រើប្រាស់ការប្រព្រឹត្តខុសដែលកើតឡើងនៅក្នុងដំណើរការនីតិវិធីដដែលដើម្បីអះអាងពីដំណើរការនៅក្នុងតុលាការ ។ នៅក្នុងករណីហ្សុីហេ្សលនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មេធាវីស្តីទីបានអះអាងថាការប្រើប្រាស់ការប្រព្រឹត្តមិនត្រឹមត្រូវរបស់តុលាការពីមុនអាចមានលក្ខណៈមិនត្រឹមត្រូវ ។ សាលាឧទ្ធរណ៍បានអះអាងថា អង្គជំនុំជម្រះមិនមានកំហុសទេពីព្រោះនៅពេលដែលធ្វើការពិនិត្យទៅលើកំហុស អង្គជំនុំជម្រះពឹងផ្អែកយ៉ាងខ្លាំងទៅលើការប្រព្រឹត្តដែលកើតឡើងនៅក្នុងដំណើរការនីតិវិធីដូចគ្នា គឺមិនមែនយោងទៅតាមការប្រព្រឹត្តខុសនៅក្នុងតុលាការពីមុនទេ ។ អាស្រ័យហេតុនេះ ខណៈពេលដែលការប្រព្រឹត្តខុសដែលកើតមាននៅក្នុងតុលាការផ្សេងអាចត្រូវបានយកអះអាង តុលាការគួរតែពឹងផ្អែកយ៉ាងខ្លាំងទៅលើការប្រព្រឹត្តខុសដែលធ្លាប់កើតមាននៅក្នុងដំណើរការនីតិវិធីដូចគ្នា ។

ទោះបីជាយ៉ាងណាក៏ដោយ ករណី គុណារ៉ាក់ នៅក្នុង

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការបានអនុញ្ញាតឲ្យការប្រព្រឹត្តរបស់មេធាវីដែលកើតមាននៅក្នុងសវនាការពីមុនត្រូវបានយកមកពិចារណាថាជាភ័ស្តុតាងនៃការរំខាន ។ ចុងចោទ គុណារ៉ាក់ បានស្នើសុំមេធាវីដែលត្រូវបានរកឃើញថាធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីក្នុងករណីតាឌីក ។ ទោះបីជាមេធាវីនេះមិនទាន់បានចូលរួមនៅក្នុងតុលាការកាត់ទោស ហើយមិនអាចសម្រេចថាមេធាវីនេះបានរំខានដល់ដំណើរការនីតិវិធីករណី គុណារ៉ាក់ ក៏ដោយ ក៏តុលាការបានបដិសេធមិនឲ្យមេធាវីរូបនេះចូលរួមនៅក្នុងសវនាការឡើយ ។ ដោយសារតែ «តុលាការមានអំណាចគ្រប់គ្រងដំណើរការនីតិវិធីដើម្បីធានាឲ្យមានយុត្តិធម៌និងដោះស្រាយនូវការប្រព្រឹត្តដែលរំខានដល់ការគ្រប់គ្រងយុត្តិធម៌របស់តុលាការ» ហើយមេធាវីបានបង្ហាញពីការមិនគោរពវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ខណៈនោះមេធាវីការពារឲ្យកូនក្តីពីមុនតុលាការមិនអនុញ្ញាតឲ្យចុងចោទ គុណារ៉ាក់ ជ្រើសរើសមេធាវីនេះទេ ។

ដោយសារតែអង្គជំនុំជម្រះទើបតែបង្កើតឡើងថ្មី ទើបមិនទាន់មានមេធាវីណាប្រព្រឹត្តខុសនៅក្នុងករណីពីមុនដើម្បីឲ្យអង្គជំនុំជម្រះយកមកធ្វើជាឧទាហរណ៍ ។ ទោះបីជាយ៉ាងណាក៏ដោយ គុណារ៉ាក់ បានស្នើថាតុលាការអាចពិចារណាទៅលើការប្រព្រឹត្តមិនត្រឹមត្រូវដែលកើតឡើងនៅក្នុងតុលាការជាមួយនឹងវិធាននិងគូនាទីច្បាប់ស្រដៀងគ្នាប៉ុន្តែមិនមែនដូចគ្នាទេ ។ ប្រសិនបើអង្គជំនុំជម្រះអាចអះអាងថា នៅក្រោមវិធានស្រដៀងគ្នាមេធាវីបានបង្ហាញពីការមិនគោរពវិធាន នោះអង្គជំនុំជម្រះអាចអះអាងពីការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទដោយផ្អែកទៅលើការប្រព្រឹត្តមិនមានពីមុនរបស់មេធាវី ។

## ៥) នៅពេលដែលមានការប្រព្រឹត្តប្រឆាំងនឹងដីកា តើតុលាការនឹងធ្វើអ្វីនៅជំហានបន្ទាប់?

### ក) ការព្រមាន

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះតម្រូវថា គួរតែមានការព្រមានមុនពេលដាក់ទណ្ឌកម្ម ឬបដិសេធការចូលរួមរបស់មេធាវី ។ នៅក្នុងករណី ខៀវ សំផន សហមេធាវីអន្តរជាតិបានទទួលការព្រមានពីរដងចំពោះការប្រព្រឹត្តខុសគ្នាពីរប្រភេទ ។ ទីមួយ) ប្រាប់ដំណឹងដល់មេធាវីថាបានបំពានទៅលើដំណើររបស់អង្គបុរេជំនុំជម្រះ ។ ទីពីរ) ប្រាប់ដល់មេធាវីថាប្រសិនបើការប្រព្រឹត្តរបស់មេធាវីនោះមានលក្ខណៈ «ប្រឆាំងឬក៏រំលោភ ឬរំខានដល់ដំណើរការនីតិវិធី ឬប្រព្រឹត្តដែលអាចបង្កើនការរំលោភដល់ដំណើរការអង្គជំនុំជម្រះអាចដាក់ទណ្ឌកម្មបាន» ។ នៅក្នុងករណី អៀង សារី អង្គបុរេជំនុំជម្រះបានអះអាងថា មេធាវីការពារក្តីធ្លាប់ទទួលបានការព្រមាននៅក្នុងដីការក្សាការសម្ងាត់អនុលោមទៅតាមវិធាន ៣៨ ។ នៅក្នុងដីកាបានអះអាងថា ប្រសិនបើមេធាវីមិនបានអនុវត្តទៅតាមរបៀបដែលគេរៀបចំឲ្យទេ មេធាវី «នឹងរំលោភទៅលើដីកា ហើយត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់» ។

ការសិក្សាទៅលើច្បាប់អន្តរជាតិបានស្នើលក្ខណៈវិនិច្ឆ័យពីរដើម្បីយកមកពិចារណាក្នុងការកំណត់ថាតើដីកាមានលក្ខណៈគ្រប់គ្រាន់ហើយឬនៅ ។ ទីមួយ លក្ខណៈជាក់លាក់នៃការព្រមាន ។ ទីពីរ ថាតើតុលាការបានផ្តល់ឱកាសពិតប្រាកដមួយចំពោះការប្រព្រឹត្តមិនត្រឹមត្រូវឲ្យធ្វើការកែប្រែមុនពេលធ្វើការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទដែរឬទេ ។

### ភាពជាក់លាក់នៃការព្រមាន

នៅក្នុងករណី ហ្សុីហេរុល សាលាឧទ្ធរណ៍តម្រូវការព្រមានរបស់តុលាការមានលក្ខណៈជាក់លាក់និងច្បាស់លាស់សម្រាប់ពន្យល់ពីផលវិបាកប្រសិនបើការប្រព្រឹត្តខុសនៅតែបន្តទៀត ។ តុលាការបានព្រមានចុងចោទជាច្រើនលើកច្រើនសា ប៉ុន្តែមិនបានអះអាងជាសាធារណៈថា ប្រសិនបើការប្រព្រឹត្តរំខាននៅតែបន្ត វានឹងបង្កឲ្យមានការដាក់កំហិតទៅលើសិទ្ធិរបស់ចុងចោទក្នុងការតំណាងឲ្យខ្លួនឯង ។ សាលាឧទ្ធរណ៍បានអះអាងថា វិធាន៨០(ខ) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ការព្រមានត្រូវតែ «បង្ហាញថាប្រសិនបើការប្រព្រឹត្តការរំខាននៅតែកើតមាន វាអាចបង្កឲ្យមានការដាក់កំហិតជាក់លាក់មួយ» ។ តុលាការបានសម្រេចថារាល់សកម្មភាពរបស់តុលាការអាចប៉ះទង្គិចដល់សិទ្ធិមូលដ្ឋាន ។

ដូច្នេះ ដីកាត្រូវតែបញ្ជាក់យ៉ាងច្បាស់ថាការប្រព្រឹត្តមិនត្រឹមត្រូវជាងនេះអាចដាក់កំហិតដល់សិទ្ធិមូលដ្ឋាននេះ ។ តុលាការ

បានផ្ដល់សេចក្ដីណែនាំបន្ថែមដែលអះអាងថាការព្រមាន «ត្រូវតែធ្វើឡើងជាសាធារណៈ ក្នុងទម្រង់ជាសារណាផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរទៅកាន់ជនត្រូវចោទដោយពន្យល់ថា ប្រសិនបើការប្រព្រឹត្តការរំខាននៅតែបន្តមាន នោះនឹងមានការដាក់កំហិតទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការតំណាងឲ្យខ្លួនឯង» ។

ទោះបីជាវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានរៀបរាប់លម្អិតដូចវិធាន៨៨ (១) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹងលក្ខណៈជាក់លាក់នៃដីកាក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចធ្វើតាមការសម្រេចរបស់តុលាការក្នុងករណី ហ្សុីហ្សេល ដែរ ។ ការព្រមានទូទៅដល់មេធាវីការពារក្ដីមិនបានផ្ដល់សេចក្ដីណែនាំពិតប្រាកដថាតុលាការនៅពេលអនាគតគួរតែចៀសវាងសកម្មភាពនោះដោយរបៀបណាទេ ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអង្គបុរេជំនុំជម្រះនិងការិយាល័យសហចៅក្រមស៊ើបអង្កេតហាក់ដូចជាទទួលស្គាល់ផលប្រយោជន៍នៃភាពជាក់លាក់ដូចជាការព្រមានទៅលើករណី ខៀវ សំផន និង អៀង សារី មានលក្ខណៈជាក់លាក់ ហើយបានអះអាងថាការប្រព្រឹត្តបែបណាអាចត្រូវបានចាត់ទុកថាជាការប្រព្រឹត្តខុស ។ ទោះបីជាយ៉ាងណាក៏ដោយ ការព្រមានទាំងពីរមិនបានផ្ដល់ការពន្យល់ច្បាស់លាស់ពីប្រភេទនៃវិន័យដែលមេធាវីនឹងប្រឈមមុខ ប្រសិនបើការប្រព្រឹត្តមិនត្រឹមត្រូវនៅតែបន្ត ។

### រយៈពេលនៃការព្រមាន

ការសិក្សាទៅលើតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានស្នើថា គួរតែមានគម្លាតពេលវេលារវាងពេលដែលដីកាត្រូវបានចេញនិងរាល់សកម្មភាពរបស់តុលាការក្នុងការដាក់ទណ្ឌកម្មលើការប្រព្រឹត្តខុស ។ ជាឧទាហរណ៍ នៅក្នុងករណី ហ្សុីហ្សេល តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មេធាវីស្ដីទីសម្រាប់ចុងចោទបានអះអាងថាវិធានភស្តុតាងនិងនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីតម្រូវថា រាល់ការព្រមានត្រូវតែ «ធ្វើឡើងមុនពេលការដាក់កំហិតទៅលើសិទ្ធិតំណាងខ្លួនឯង» ។ ទោះបីជាសាលាឧទ្ធរណ៍បានផ្លាស់ប្ដូរតំណែងរបស់មេធាវីដោយហេតុផលផ្សេងទៀតក៏ដោយ ក៏សាលាឧទ្ធរណ៍បានបដិសេធជាសាធារណៈនូវការអះអាងរបស់មេធាវីស្ដីទីដោយអះអាងថាភាសានៃវិធានធ្វើឲ្យមាន «គម្លាត» រវាងការព្រមាននិងសកម្មភាពរបស់តុលាការ ។

«គម្លាត» នេះត្រូវបានអះអាងនៅក្នុងបណ្ដឹងឧទ្ធរណ៍ក្រោយៗទៀត ។ បន្ទាប់ពីសេចក្ដីសម្រេចលើកដំបូងរបស់សាលាឧទ្ធរណ៍សិទ្ធិរបស់ចុងចោទក្នុងការតំណាងឲ្យខ្លួនឯងត្រូវបានផ្ដល់ឲ្យសាជាថ្មី ។ នៅពេលដែលដំណើរការនីតិវិធីចាប់ផ្ដើមម្ដងទៀតនៅក្នុងសវនាការមេធាវីស្ដីទីត្រូវបានតែងតាំងសាជាថ្មីដែលបង្កឲ្យចុងចោទកាន់តែបង្ហាញឥរិយាបថរំខានថែមទៀត ហើយតុលាការបានដាក់បន្ទុកទៅលើមេធាវីម្ដងទៀត ។ សាលាឧទ្ធរណ៍បានបង្ហាញថា អង្គសវនាការមិនបានផ្ដល់ឱកាសដ៏ពិតប្រាកដមួយដល់ចុងចោទដើម្បីបង្ហាញថា «ថ្វីបើអ្វីដែលចុងចោទធ្លាប់បានប្រព្រឹត្តមិនសមរម្យនៅសវនាការមុនៗបានបណ្ដាលឲ្យមានការដាក់បន្ទុកទៅលើមេធាវីប៉ុន្តែឥឡូវនេះចុងចោទយល់ច្បាស់ថា ដើម្បីទទួលការអនុញ្ញាតឲ្យការពារក្ដីដោយខ្លួនឯង ចុងចោទត្រូវតែគោរពតាមវិធាន ហើយចុងចោទក៏មានសុឆន្ទៈនឹងកែតម្រូវដែរ» ។ ដូច្នេះ បន្ទាប់ពីមានការព្រមាន ចុងចោទត្រូវតែទទួលបានឱកាសដើម្បីបង្ហាញពីឥរិយាបថថ្មីមុនពេលតុលាការចេញវិធានការ ។

យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាហាក់ដូចជាគាំទ្រនឹងចំណុចនេះដែលថា ចុងចោទគួរតែទទួលបាន «ឱកាសពិត» ដើម្បីកែប្រែឥរិយាបថរបស់គេមុនពេលតុលាការចាត់វិធានការទៅលើការប្រព្រឹត្តខុស ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បន្ទាប់ពីចេញការព្រមានដល់ អៀង សារី និង ខៀវ សំផន តុលាការមិនបានចេញវិធានការបន្ថែមទេ ប៉ុន្តែហាក់ដូចជាបានផ្ដល់ «ឱកាសពិត» ដល់មេធាវីសម្រាប់កែប្រែឥរិយាបថរបស់ខ្លួនដើម្បីអាចចាត់ទុកថាជាកំហុស ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ករណី ម្វូសេម៉ា មេធាវីបានទទួលការព្រមានបន្ទាប់ពីមេធាវីនោះអវត្តមានម្ដងហើយម្ដងទៀតនៅតុលាការ បន្ទាប់មកមេធាវីនោះបានទទួលឱកាសដើម្បីបង្ហាញខ្លួននៅតុលាការនិងតំណាងឲ្យកូនក្ដីរបស់ខ្លួន ។ តុលាការបានចេញវិធានការនិងតែងតាំងមេធាវីថ្មីនៅពេលដែលមេធាវីនោះបាន

អវត្តមាននៅក្នុងតុលាការនៅពេលក្រោយទៀត ។

### ១) ដំណោះស្រាយចំពោះកំហុសរបស់មេធាវី

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំណត់ថា មេធាវីបានប្រព្រឹត្តកំហុស នៅពេលនោះមានដំណោះស្រាយបីនៅក្រោមវិធាន៣៨ ។ តុលាការប្រហែល ១)ដាក់ទណ្ឌកម្មដល់មេធាវី ២)បដិសេធមិនឲ្យមានការចូលរួមរបស់មេធាវី និង ៣)ប្រាប់កំហុសនោះទៅកាន់អង្គភាពវិជ្ជាជីវៈដែលសមស្រប ។ នៅក្នុងយុត្តិសាស្រ្តអន្តរជាតិ នៅពេលដែលតុលាការប្រើប្រាស់មធ្យោបាយសម្រេចបានយុត្តិធម៌ តុលាការត្រូវតែយោងទៅតាមគោលការណ៍សមតុល្យដើម្បីកំណត់ថាដំណោះស្រាយមួយដែលនឹងត្រូវយកមកប្រើ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីករណី មីឡូសេវិក សាលាឧទ្ធរណ៍បានលើកឡើងថា ការដាក់កំហិតលើសិទ្ធិចុងចោទគួរតែយោងទៅតាម «គោលការណ៍មូលដ្ឋានសមតុល្យ ៖ រាល់ការដាក់កំហិតទៅលើសិទ្ធិមូលដ្ឋានត្រូវតែស្របទៅតាមគោលការណ៍សំខាន់ដែលមានប្រសិទ្ធភាព ហើយត្រូវតែលុបបំបាត់គោលការណ៍មិនគិតអ្វីទាំងអស់ដើម្បីសម្រេចគោលដៅ» ។ សាលាឧទ្ធរណ៍បានកែប្រែសេចក្តីសម្រេចរបស់តុលាការក្នុងការដាក់កំហិតទៅលើការចូលរួមរបស់ចុងចោទក្នុងការការពារក្តី ។ សាលាឧទ្ធរណ៍ទទួលស្គាល់ថាដោយសារតែសុខភាពរបស់ចុងចោទអាចមានភាពធូរស្រាល សិទ្ធិរបស់ចុងចោទក្នុងការចូលរួមនៅក្នុងតុលាការនៅពេលខាងមុខមិនគួរបំបិទទេ ។ ករណីនេះត្រូវបានបញ្ជូនទៅតុលាការដើម្បីបង្កើតជាទម្រង់មួយដែលអាចបន្ថយផលប៉ះពាល់នៃការតែងតាំងមេធាវីជាផ្លូវការ លើកលែងតែក្នុងករណីពាក់ព័ន្ធនឹងផលប្រយោជន៍យុត្តិធម៌» ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងត្រូវពិនិត្យទៅលើករណីពីមុនដែលតុលាការធ្លាប់ប្រើគោលការណ៍នោះដើម្បីជាការណែនាំនៅពេលសម្រេចថាពេលណាត្រូវប្រើវិធាន៣៨ និងប្រើដោយរបៀបណា ។

### ការដាក់ទណ្ឌកម្មមេធាវី

ដោយពឹងផ្អែកទៅលើមេធាវី តុលាការប្រហែលជាមិនជំរុញឲ្យមានការប្រព្រឹត្តខុសទៀតទេ ដោយធ្វើការដាក់ទណ្ឌកម្មមេធាវីដែលប្រព្រឹត្តខុស ។ ទាំងក្នុងករណី អៀង សារី និង ខៀវ សំផន តុលាការមិនបានប្រើឬធ្វើការគំរាមកំហែងដាក់ទណ្ឌកម្មដាក់លាក់ណាមួយដល់មេធាវីឡើយ ។ តុលាការអន្តរជាតិបានប្រើប្រាស់ទណ្ឌកម្មផ្សេងៗគ្នាជាច្រើនដែលរួមមាន ការព្រមាន ការផាកពិន័យ និងការដាក់ពន្ធនាគារ ។ នៅក្នុងការកំណត់ថាទណ្ឌកម្មណាប្រើសម្រាប់បទល្មើសណាដូចដែលបានពិភាក្សានៅខាងលើ តុលាការអន្តរជាតិហាក់ដូចជាបានប្រើគោលការណ៍សមតុល្យ ។ ជាឧទាហរណ៍ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីករណី បាឡាហ្គូជីវីក តុលាការយល់ឃើញថា បន្ទាប់ពីទទួលការព្រមានពីតុលាការ មេធាវីការពារក្តីបានដាក់របាយការណ៍មិនសមរម្យដែលបានចោទប្រកាន់យ៉ាងធ្ងន់ធ្ងរពី «កំហុសក្រមសីលធម៌ និងកំហុសវិជ្ជាជីវៈ» ។ សម្រាប់កំហុសនេះ តុលាការបានសម្រេចថាការព្រមានគឺជាការដាក់ទណ្ឌកម្មដ៏សមស្របមួយ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិករណី អាលីសូស៊ី តុលាការបានដាក់ទណ្ឌកម្មដល់មេធាវី បន្ទាប់ពីមេធាវីបានប្រព្រឹត្តឥរិយាបថមិនសមស្របដោយផ្សព្វផ្សាយនូវអត្តសញ្ញាណរបស់សាក្សីដែលត្រូវទទួលការការពារ ។ នៅពេលសម្រេចថាធ្វើការផាកពិន័យជំនួសការដាក់ពន្ធនាគារ តុលាការត្រូវរកឲ្យឃើញកត្តាដែលបង្ហាញថាកំហុសនោះគឺជាការប្រព្រឹត្តមិនត្រឹមត្រូវលើកដំបូង ហើយជននោះត្រូវសន្យាថានឹងមិនធ្វើខុសម្តងទៀតទេ ។

### ការបដិសេធមិនឲ្យមានការចូលរួមរបស់មេធាវី

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់ថាឥរិយាបថរបស់មេធាវីបានបង្កើតជាកំហុស ជម្រើសមួយទៀតដែលអាចប្រើដោយយោងទៅតាមវិធាន៣៨(១) គឺបដិសេធមិនឲ្យមានការចូលរួមរបស់មេធាវី ។ នៅពេលដែលតុលាការបដិសេធមិនឲ្យមានការចូលរួម ប្រសិនបើចុងចោទមានលទ្ធភាព ចុងចោទត្រូវតែជ្រើសរើសមេធាវីថ្មីដែលបានចុះឈ្មោះនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រសិនបើចុងចោទមិនមានលទ្ធភាព ចុងចោទអាចជ្រើសរើសមេធាវីក្នុងចំណោមមេធាវីជាតិនិងអន្តរជាតិដែលមានឈ្មោះនៅក្នុងបញ្ជីដែលបង្កើតឡើងដោយអង្គភាពគាំពារការការពារក្តី ។ នីតិវិធីនេះស្រដៀងទៅនឹងនីតិវិធីដែលមាននៅក្នុងតុលាការអន្តរជាតិដែរ ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី

ករណី គុណាវ៉ាក់ តុលាការបានបដិសេធមិនឲ្យមានការចូលរួមរបស់សហមេធាវីម្នាក់របស់ចុងចោទដោយសារតែមេធាវីនោះត្រូវបានរកឃើញថាមិនបានគោរពតុលាការពីមុន ។ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រសិនបើចុងចោទបដិសេធមិនជ្រើសរើសមេធាវីថ្មីវិធាន៨១(៤) អនុញ្ញាតឲ្យសវនាការអាចឲ្យមេធាវីដែលតែងតាំងដោយអង្គភាពគាំពារការការពារក្តីតំណាងឲ្យចុងចោទ ។

យុត្តិសាស្ត្រអន្តរជាតិបានច្របល់គ្នារវាងថាតើតុលាការគួរតែតែងតាំងមេធាវីឲ្យចុងចោទដែលមិនត្រូវការមេធាវីដែរឬទេ ។ ករណី ហេរូលហ្ស៊ី ទោះបីជាបានរកឃើញថាឥរិយាបថរបស់ចុងចោទបង្កើតជាកំហុស តុលាការមិនដែលបានតែងតាំងមេធាវីណាម្នាក់ឡើយ ។ ចុងចោទបានបញ្ជាក់យ៉ាងច្បាស់ថាខ្លួនមិនចង់បានមេធាវីដែលតុលាការតែងតាំងឲ្យទេ ។ នៅរាល់ពេលដែលតុលាការព្យាយាមតែងតាំងមេធាវីឲ្យចុងចោទ សាលាឧទ្ធរណ៍បានលើកឡើងពីមូលហេតុផ្សេងដើម្បីផ្លាស់ប្តូរការតែងតាំងនោះ ។ ករណី មីឡូសេវិក ក៏ស្រដៀងគ្នានេះដែរ ។ ករណី គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិចោទប្រកាន់ប្រទេសអេស្ប៉ាញ តុលាការអេស្ប៉ាញបានតែងតាំងមេធាវីឲ្យចុងចោទដែលព្យាយាមអះអាងពីសិទ្ធិតំណាងឲ្យខ្លួនឯង ប៉ុន្តែ គណៈកម្មាការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានផ្លាស់ប្តូរការតែងតាំងដោយយល់ឃើញថាសិទ្ធិតំណាងឲ្យខ្លួនឯងមិនត្រូវបានគេគោរពទេ ។ នេះគឺជាករណីពិសេស ដោយសារតែមេធាវីដែលបានតែងតាំងហើយត្រូវបានចាត់ទុកថាមិនមានសមត្ថភាព ហើយអង្គហេតុបង្ហាញថាគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិមានការព្រួយបារម្ភអំពីយុត្តិធម៌របស់តុលាការ ។ វាហាក់ដូចជាថាតុលាការជាច្រើនមានភាពយឺតយ៉ាវក្នុងការតែងតាំងមេធាវីឲ្យចុងចោទដែលមិនចង់បានមេធាវី ។

តុលាការខ្លះបានតែងតាំងមេធាវីទៅឲ្យចុងចោទដែលមិនចង់បានមេធាវី ។ នៅក្នុងករណី ស៊ីសេ និង បារ៉ាយ៉ាកវីហ្សា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានបង្ខំចាត់តាំងមេធាវីឲ្យចុងចោទ ទោះបីជាចុងចោទបានអះអាងជាសាធារណៈថាខ្លួនមិនត្រូវការមេធាវីដើម្បីតំណាងក៏ដោយ ។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ករណីស៊ីសេ នៅពេលចាត់តាំងមេធាវីតុលាការបានអះអាងថា "ច្បាប់មិនបានទទួលស្គាល់សិទ្ធិរបស់ចុងចោទដែលបដិសេធមិនប្រើប្រាស់ជម្រើសដែលខ្លួនមាន គឺមិនត្រូវការមេធាវីដែលតុលាការតែងតាំងឲ្យនោះទេ" ។ ទោះបីជាយុត្តិ-សាស្ត្រមិនបានបង្ហាញពីទម្រង់ច្បាស់លាស់ថាតើនៅពេលត្រូវតែងតាំងមេធាវីឲ្យចុងចោទដែលបដិសេធមិនចង់បានមេធាវីក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែមានការប្រុងប្រយ័ត្ននៅពេលចាត់តាំងមេធាវីឲ្យចុងចោទដែលប្តេជ្ញាចិត្តបដិសេធមិនចង់បានមេធាវី ។ ប្រសិនការបដិសេធមិនចង់បានមេធាវីរបស់ចុងចោទអាច ក) បណ្តាលឲ្យចុងចោទមិនបានចូលរួមក្នុងការកាត់សេចក្តី ហើយតុលាការត្រូវដំណើរការដោយមិនមានចុងចោទ ខ) បង្កើតជាស្ថានភាពដែលថាចុងចោទមិនទទួលខុសត្រូវក្នុងការការពារក្តីដោយខ្លួនឯង និងមិនទទួលបានការកាត់សេចក្តីដ៏យុត្តិធម៌ កេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងទទួលបានការរិះគន់ ហើយសាលក្រមរបស់តុលាការអាចនឹងមិនទទួលបានការយល់ស្រប ។

## ការបញ្ជូនកំណត់សម្គាល់ឲ្យគណៈមេធាវី

យោងតាមវិធាន៣៨ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងបញ្ជូនកំហុសរបស់មេធាវីទៅឲ្យអង្គភាពវិជ្ជាជីវៈណាមួយ ។ អង្គជំនុំជម្រះធ្លាប់បានបញ្ជូនកំហុសទៅឲ្យអង្គភាពវិជ្ជាជីវៈមេធាវី ។ ករណី ខៀវ សំផន អង្គបុរេបានព្រមានសហមេធាវីការពារក្តីថា ប្រសិនបើឥរិយាបថរំខានរបស់មេធាវីរូបនោះនៅតែបន្ត តុលាការអាចនឹងដាក់ទណ្ឌកម្មមួយចំនួនដល់មេធាវី ។ អង្គបុរេជំនុំជម្រះបានបញ្ជូនច្បាប់ចម្លងនៃការព្រមានទៅឲ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីនៅប៉ារីស និងអង្គភាពគាំពារការការពារក្តី ។ ករណី អៀង សារី ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ជូនកំហុសរបស់មេធាវីទៅឲ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីនៃរដ្ឋអាឡាស្កា និងអង្គភាពគាំពារការការពារក្តី ។

យោងទៅតាមវិធាន៦០ នៃលក្ខន្តិកៈគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើគណៈមេធាវីនៃព្រះរាជាណាចក្រ

កម្ពុជាទទួលបានពាក្យបណ្ដឹង ដូចជាការបញ្ជូនកំហុសពីអង្គជំនុំជម្រះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាប្រហែលជានឹងធ្វើការស៊ើបអង្កេតដោយចំហ ។ ប្រសិនបើគណៈមេធាវីមិនបានឆ្លើយតបនឹងពាក្យបណ្ដឹងនោះទេ នេះមានន័យថាគណៈមេធាវីបដិសេធនឹងពាក្យបណ្ដឹងនោះហើយ ប៉ុន្តែប្រសិនបើគណៈមេធាវីស៊ើបអង្កេតទៅលើពាក្យបណ្ដឹងនោះ យោងតាមវិធាន៦៣ ទណ្ឌកម្មដែលត្រូវផ្ដល់ឲ្យមេធាវីនោះគឺ «ការព្រមាន ការស្ដីបន្ទោស ការហាមប្រាមមិនឲ្យប្រើប្រាស់វិជ្ជារបស់ខ្លួនរយៈពេលមិនលើសពី ២ឆ្នាំ ឬក៏លុបឈ្មោះចេញ ពីបញ្ជីមេធាវី» ។

ប្រសិនបើពាក្យបណ្ដឹងកំហុសត្រូវបានបញ្ជូនទៅឲ្យគណៈមេធាវីបរទេស ពាក្យបណ្ដឹងនោះអាចបង្កឲ្យមានការចាត់វិធានការមួយចំនួន ។ ឧទាហរណ៍ ប្រសិនបើគណៈមេធាវីអាឡាស្កាទទួលបានពាក្យបណ្ដឹង គណៈមេធាវីនឹងពិនិត្យទៅលើពាក្យបណ្ដឹងនោះដើម្បីកំណត់ថាតើឯកសារណារួមមានការចោទប្រកាន់ជាក់ស្ដែងគ្រប់គ្រាន់ដែលពិតជាអាចបង្កើតទៅជាកំហុសក្រមសីលធម៌ ។ ប្រសិនបើពាក្យបណ្ដឹងនោះពិតជាបង្ហាញពីកំហុស ច្បាប់ចម្លងនោះនឹងត្រូវបញ្ជូនទៅកាន់មេធាវីដើម្បីជាការឆ្លើយតប ។ ជាងនេះទៅទៀត ប្រសិនបើការចោទប្រកាន់ជាក់ស្ដែងមានប្រសិទ្ធភាព គណៈមេធាវីនឹងចាប់ផ្ដើមការស៊ើបអង្កេតពេញលេញមួយទៅលើកំហុសដែលបានចោទប្រកាន់ ហើយនិង ក) ច្រានចោលពាក្យបណ្ដឹង ខ) ចេញសេចក្ដីព្រមានជាបុគ្គលដែលនឹងបញ្ចូលទៅក្នុងកំណត់ហេតុរបស់មេធាវី គ) ដាក់ពាក្យស្នើសុំឲ្យមានការជំនុំជម្រះនៅក្នុងសវនាការជាផ្លូវការ ឬបញ្ចូលលក្ខខណ្ឌវិន័យនោះទៅក្រុមប្រឹក្សាវិន័យ ឬតុលាការកំពូលនៅអាឡាស្កា ។ ករណី អៀង សារី កំហុសរបស់មេធាវីការពារក្ដីត្រូវបានបញ្ជូនទៅគណៈមេធាវីអាឡាស្កា ប៉ុន្តែនៅពេលថ្មីនេះ គណៈមេធាវីសម្រេចមិនចាត់វិធានការអ្វីទាំងអស់ទៅលើ ម៉ៃខល ខារណាវ៉ាស ដែលជាសហមេធាវីអន្តរជាតិរូបនោះទេ ។ គណៈមេធាវីយល់ឃើញថា «ការរំលោភទៅលើការសម្ងាត់» មិនអាចបណ្ដាលឲ្យមានការស៊ើបអង្កេតជាផ្លូវការទេ ។ ទោះបីជាមិនមានការចាត់វិធានការអ្វីក៏ដោយ ក៏ខារណាវ៉ាស ហាក់ដូចជាទទួលទណ្ឌកម្មដែរពីព្រោះប្រសិនមានការបញ្ជូនរបាយរការណ៍កំហុសបន្ថែមទៀតទៅគណៈមេធាវីនោះគណៈមេធាវីនឹងចាប់អារម្មណ៍ទៅលើសកម្មភាពរបស់គាត់ ។

## ៦) សេចក្ដីសន្និដ្ឋាន

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុងចោទមានសិទ្ធិជ្រើសរើសមេធាវីការពារក្ដីដើម្បីធានាថាជននោះអាចជ្រើសរើសយុត្តិសាស្ត្រការពារក្ដីដោយខ្លួនឯង ។ ទោះបីជាវិធាន៣៨អនុញ្ញាតឲ្យអង្គជំនុំជម្រះដាក់កំហិតទៅលើសិទ្ធិចុងចោទក្នុងការជ្រើសរើសយុត្តិសាស្ត្រការពារក្ដីក៏ដោយ ក៏តុលាការគួរតែយកចិត្តទុកដាក់ទៅលើចំណុចនេះ ។ ការពិនិត្យទៅលើយុត្តិសាស្ត្រអន្តរជាតិបង្ហាញថា មានការផ្ដល់ជម្រើសជាច្រើនដល់មេធាវីមុនពេលតុលាការចាត់ទុកឥរិយាបថនោះថាជាកំហុស ។ ជាងនេះទៅទៀត នៅពេលដែលតុលាការកំណត់ថាឥរិយាបថនោះគឺជាកំហុស រាល់សេចក្ដីសម្រេចទៅលើដំណោះស្រាយគួរតែយោងទៅតាមគោលការណ៍សមតុល្យ ។ ដោយធ្វើសមតុល្យទៅលើសិទ្ធិចុងចោទក្នុងជ្រើសរើសមេធាវីនិងតម្រូវការរបស់តុលាការដើម្បីដំណើរការដោយមិនមានការពន្យារពេលឬការរំខាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចធានាថា រាល់សាលក្រមដែលនឹងចេញនៅពេលអនាគតនឹងប្រកបដោយយុត្តិធម៌និងភាពមិនលម្អៀង ។

**អាដាម ខូឌី**

## ស្ដាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្ដល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ជីវិតឪពុកម្ដាយខ្ញុំក្នុងរបប ប៉ុល ពត

ប្រទេសកម្ពុជាគឺជាប្រទេសចំណាស់មួយដែលប្រវត្តិសាស្ត្ររបស់ប្រទេសនេះបានកត់ត្រាទុកតាំងពីសតវត្សរ៍ទីមួយមកម្ល៉េះ ។ ជាការពិត ប្រទេសកម្ពុជាបានឆ្លងកាត់អន្តរកាលជាច្រើនទាំងផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ ព្រមទាំងបានឆ្លងកាត់នូវយុគសម័យផ្សេងៗដូចជា សម័យហ្វូណន សម័យអង្គរ រហូតដល់សម័យខ្មែរក្រហមដែលបានសម្លាប់មនុស្សអស់ជិតពីរលាននាក់ ដោយសារការយកទៅសម្លាប់ ការធ្វើទារុណកម្ម ការបង្ខំឲ្យធ្វើការជាទម្ងន់ ការធ្លាក់ខ្លួនឈឺគ្មានថ្នាំព្យាបាល និងការអត់បាយហូបជាដើម ។

សម័យខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា របបកម្ពុជាប្រជាធិបតេយ្យ គឺពោរពេញទៅដោយភាពចលាចល ។ បើយោងតាម «សៀវភៅប្រវត្តិសាស្ត្រកម្ពុជា» របស់លោក ដេវីដ ឆេនដល័រ របបនេះបានគ្រប់គ្រងអំណាចនៅក្នុងប្រទេសកម្ពុជាចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតមកដល់ ខែមករា ឆ្នាំ១៩៧៩ ។ នៅអំឡុងពេលនោះ របបនេះបានលុបបំបាត់រូបិយវត្ថុ ទីផ្សារ ការអប់រំ ការគោរពសាសនា កម្មសិទ្ធិឯកជន ម៉ូតសម្លៀកបំពាក់ផ្សេងៗ ហើយថែមទាំងផ្លាស់ប្តូរពីរបបសាធារណរដ្ឋខ្មែរដែលគាំទ្រដោយសហរដ្ឋអាមេរិកមកជារបបកុម្មុយនីស្ត ឬរបបប៉ុល ពត ដែលទទួលឥទ្ធិពលពីមេដឹកនាំបក្សកុម្មុយនីស្តចិន ម៉ៅ សេទុង ។

ជាក់ស្តែង ឪពុកម្តាយរបស់ខ្ញុំដែលជាជនរងគ្រោះម្នាក់នៅក្នុងរបបនេះបានរៀបរាប់ឲ្យដឹងថា ដំបូងឡើយឪពុកម្តាយ


ការដ្ឋានលើកទំនប់ ប្រឡាយ នៅក្នុងរបបខ្មែរក្រហម

របស់ខ្ញុំមិនទាន់រៀបការនៅឡើយទេ ។ ឪពុករបស់ខ្ញុំរស់នៅជាមួយជីតាខ្ញុំនៅក្នុងភូមិរលួស ខេត្តព្រៃវែង ក្បែរព្រំដែនវៀតណាម ។ ជីតានិងឪពុករបស់ខ្ញុំគឺជាកសិករធ្វើស្រែចម្ការនៅលើដីមួយដែលជាកម្មសិទ្ធិរបស់ពួកគាត់ ។ គាត់បានបន្តថា ទោះបីជាក្នុងអំឡុងពេលនោះជីតារបស់ខ្ញុំជាកសិករក៏ដោយ ក៏ពួកគាត់មានអង្ករសម្រាប់ហូបគ្រប់គ្រាន់ ហើយថែមទាំងមានលទ្ធភាពចិញ្ចឹមឪពុកខ្ញុំនិងបងប្អូនរបស់គាត់ចំនួន១៣នាក់ឲ្យរស់នៅបានស្រួលដែរ ។ ឪពុកខ្ញុំរួមទាំងបងប្អូនរបស់គាត់បាននាំគ្នាចុះធ្វើស្រែនិងជួយធ្វើកិច្ចការផ្ទះ ។ ចំណែកឯម្តាយខ្ញុំវិញ គាត់រស់នៅភូមិព្រៃវែង ខេត្តព្រៃវែងជិតព្រំដែនវៀតណាមជាមួយឪពុកម្តាយគាត់ និងបងប្អូនរបស់គាត់ប្រាំនាក់ទៀត ។ ម្តាយរបស់ខ្ញុំនិងជីដូនរួមទាំងបងប្អូនរបស់គាត់នាំគ្នាធ្វើស្រែ ចំណែកជីតាខ្ញុំមានរបរជាជាងប៉ះកង់ ។ ជីដូនជីតាខាងម្តាយខ្ញុំបានប្រាប់ខ្ញុំថា ពួកគាត់មានអាហារហូបគ្រប់គ្រាន់ មានដី និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ជាពិសេសកូនៗរបស់គាត់អាចចូលរៀនគ្រប់ៗគ្នាទៀតផង ។

នៅពេលដែលខ្មែរក្រហមចូលមកគ្រប់គ្រងនៅឆ្នាំ១៩៧៥ សមាជិកគ្រួសារឪពុករបស់ខ្ញុំភាគច្រើនត្រូវបានជម្លៀសឲ្យទៅរស់នៅខេត្តស្វាយរៀង ។ នៅទីនោះ គាត់ត្រូវតែធ្វើការតាំងពីព្រលឹមរហូតដល់ព្រលប់ជាមួយនឹងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីដទៃទៀត ។ ក្នុងមួយថ្ងៃ ប្រជាជនទាំងអស់មានពេលសម្រាកតែមួយម៉ោងប៉ុណ្ណោះ គឺចាប់ពីម៉ោង១១ ដល់ម៉ោង១២ថ្ងៃត្រង់ ។ ចំណែកអាហារវិញ ប្រជាជនទាំងអស់ទទួលបានរបបអាហារតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។

នៅរដូវវស្សា ឪពុកខ្ញុំត្រូវភ្ជួររាស់ ស្ទូង និង ប្រូតស្រូវ ចំណែកនៅរដូវប្រាំងវិញត្រូវជីកប្រឡាយ និង លើកទំនប់ជាដើម ។ ដើម្បីរស់ ឪពុករបស់ខ្ញុំត្រូវតែខំប្រឹងធ្វើការងារធ្ងន់ៗទាំងនេះរហូតដល់គាត់ធ្លាក់ខ្លួនស្គម ។ លើសពីនេះទៅទៀត គាត់មិនត្រូវបានអនុញ្ញាតឲ្យមកសួរសុខទុក្ខឪពុកម្តាយរបស់គាត់ឡើយព្រោះថាសេរីភាពនៅក្នុងការដើរហើរត្រូវបិទទាំងស្រុង ។

ចំណែកផ្លែឈើដែលដាំនៅក្នុងផ្ទះ ក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យបេះហូបដែរ ព្រោះជារបស់អង្គការ ។ «ប្រសិនបើអង្គការចាប់បានថាលួចបេះបន្លែ ឬផ្លែឈើរបស់អង្គការ អ្នកនោះនឹងត្រូវយកទៅសម្លាប់ភ្លាម ។ ឪពុកខ្ញុំនៅតែចងចាំជានិច្ចនូវទិដ្ឋភាពដែលគាត់បានឃើញមនុស្សមួយក្រុមដែលនៅភូមិផ្សេងត្រូវបានខ្មែរក្រហមយកមកសម្លាប់នៅក្បែរភូមិដែលគាត់រស់នៅ ។

ចំណែកបទពិសោធន៍របស់ម្តាយខ្ញុំវិញក៏មានភាពប្រហាក់ប្រហែលនឹងឪពុករបស់ខ្ញុំដែរ ។ ជារៀងរាល់ថ្ងៃ ម្តាយខ្ញុំត្រូវតែទៅធ្វើការតាំងពីព្រលឹម មានពេលខ្លះគាត់ចាប់ផ្តើមធ្វើការតាំងពីម៉ោងមួយឬពីរយប់ដើម្បីធ្វើឲ្យហើយតាមផែនការរបស់អង្គការ ។ ចំណែករបបអាហារគឺទទួលបានតែបបររាវពីរពេលប៉ុណ្ណោះ ។ គាត់បានរៀបរាប់ថា ប្រជាជនគ្រប់គ្នារស់នៅដោយភាពភ័យខ្លាចពីព្រោះមិនដឹងថាថ្ងៃណាខ្មែរក្រហមនឹងយកគាត់ទៅសម្លាប់ដូចជាប្រជាជនដទៃទៀតដែលគ្មានកំហុសទេ ។ ម្តាយខ្ញុំបានរំឭកអំពីការស្លាប់របស់សាច់ញាតិគាត់ម្នាក់ដោយសារខ្មែរក្រហមសង្ស័យគាត់ជានារីជនជាតិវៀតណាមថា គាត់គឺជាមនុស្សរួសរាយនិងជាមនុស្សចិត្តល្អម្នាក់នៅក្នុងភូមិ ប៉ុន្តែគាត់បែរជាត្រូវខ្មែរក្រហមយកទៅសម្លាប់ទៅវិញ ។

ក្រោយពីរបបខ្មែរក្រហមបានដួលរំលំទៅ ជីវភាពគ្រួសាររបស់ឪពុកម្តាយខ្ញុំទាំងពីរមានលក្ខណៈល្អប្រសើរជាងមុន ។ ឪពុកខ្ញុំនិងបងប្អូនរបស់គាត់ទាំងអស់បានត្រឡប់មករស់នៅជួបជុំគ្នាក្នុងផ្ទះរបស់ពួកគាត់វិញ ។ ឪពុកខ្ញុំមានអារម្មណ៍ហាក់បីដូចជាត្រូវបានគេដោះលែងពីគុក ក្រោយពេលរបបខ្មែរក្រហមត្រូវបានបញ្ចប់ ។ គ្រួសាររបស់ឪពុកខ្ញុំចាប់ផ្តើមមានរបស់ជាវត្ថុកម្មសិទ្ធិផ្ទាល់ខ្លួនម្តងទៀតដូចជាមានដីសម្រាប់ធ្វើស្រែចម្ការ មានសម្លៀកបំពាក់ល្អៗ មានម្ហូបអាហារបរិភោគគ្រប់គ្រាន់ លើសពីនេះទៅទៀត ពួកគាត់មិនចាំបាច់ធ្វើការងារធ្ងន់ដូចមុនឡើយ ជាពិសេសពួកគាត់អាចធ្វើដំណើរទៅកន្លែងណាមួយក៏បាន អាចសួរសុខទុក្ខសាច់ញាតិដែលនៅឆ្ងាយៗនិងមិនមានភាពភ័យខ្លាចនឹងការយកទៅសម្លាប់ឡើយ ។ ចំណែកម្តាយរបស់ខ្ញុំក៏អឺចឹងដែរ គាត់ត្រេកអរជាខ្លាំងដែលរបបនេះត្រូវបានរំដោះ ។ សព្វថ្ងៃនេះ ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅ៣០ឆ្នាំហើយក៏ដោយ ក៏បទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅតែស្ថិតនៅក្នុងចិត្តរបស់ពួកគាត់គ្មានថ្ងៃបំភ្លេចបានឡើយ ។ ចុងក្រោយគាត់សង្ឃឹមថា របបនេះនឹងមិនកើតឡើងសាជាថ្មីទៀតនោះទេ ។ **ជួង ចំរើន**

# សេចក្តីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហោង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្តាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៨ឬ១៩ឆ្នាំប៉ុណ្ណោះ បានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។ ប្រសិនបើប្អូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ**

# ដំណឹងស្វែងរកប្អូនស្រី

នាងខ្ញុំឈ្មោះ ឌៀង ស៊ីដានី សព្វថ្ងៃនេះរស់នៅផ្ទះលេខ២០អា ផ្លូវលេខ៣៣៦ ក្រុមទី៥២ ភូមិទី៧ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុករបស់ខ្ញុំឈ្មោះ ឌៀង សាម និងម្តាយខ្ញុំឈ្មោះ ម៉ាយ កាន និងមានបងប្អូនចំនួន៧នាក់ ១) ខ្ញុំ, ២) ប្អូនប្រុស ឌៀង សុផាត, ៣) ប្អូនប្រុស ឌៀង សាមចន្ទ្រាវុធ, ៤) ប្អូនប្រុស ឌៀង តារ៉ា, ៥) ប្អូនប្រុស ឌៀង សំសុផន, ៦) ប្អូនស្រី ឌៀង សុផល ហៅ ម៉ៅ និង ៧) ប្អូនស្រីពៅ ឌៀង វណ្ណារី ។ នាងខ្ញុំសូមប្រកាសស្វែងរកប្អូនស្រីឈ្មោះ ឌៀង សុផល ហៅ ម៉ៅ ដែលបានបែកគ្នានៅឆ្នាំ១៩៧៨ នៅខេត្តបាត់ដំបង ។ មុនពេលបែកគ្នា សុផល ហៅ ម៉ៅ បានមកលេងផ្ទះដែលខ្ញុំស្នាក់នៅសហករណ៍ខេត្តបាត់ដំបង «ភូមិតាគង់ ស្រុកភ្នំស្រុក» បានរយៈពេលមួយយប់ទើបត្រឡប់ទៅកងចល័តបន្ទាយរំចេក «កងចល័តកុមារឈានមុខ» វិញ ។ ចាត់តាំងពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីប្អូនស្រីឈ្មោះ សុផល ហៅ ម៉ៅ ឡើយ ។

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ឌៀង សុផល ហៅ ម៉ៅ ខាងលើនេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១១ ២៧៨ ០៦៦ ឬ០១១ ៩១៤ ៥៥២ ឬក៏ទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។**សូមអរគុណ**



គ្រួសាររបស់ ស៊ីដានី រូបថតឆ្នាំ១៩៧២




ការតាំងលក់ទស្សនាវដ្ដីស្វែងការពិតឆ្នាំ២០០០




ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដែន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 121, January 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.